# របាយការណ៍

# ប្រចាំឆ្នាំស្តីពីសេដ្ឋកិច្ចកម្ពុជា

កង ច័ន្ទតារ័ត្ន និង ច័ន្ទ សុផល

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ខែធ្នូ ឆ្នាំ២០០៣

**Cambodia’s Annual Economic Review**

December 2003

*Dr. Kang Chantararot and Mr. Chan Sophal*

**© រក្សាសិទ្ធិ២០០៣ វិទ្យាស្ថានបណ្ដុះបណ្ដាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)**

រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃឯកសារនេះ ចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និង មធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្ដកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាត ជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

# របាយការណ៍ប្រចាំឆ្នាំស្ដីពីសេដ្ឋកិច្ចកម្ពុជា ខែធ្នូ ឆ្នាំ២០០៣

*កង ច័ន្ទតារារ័ត្ន និង ច័ន្ទ សុផល*

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*

វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ផ្ទះ៥៦ ផ្លូវ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទៈ (៨៥៥-២៣) ៨៨១-៩១៦ ទូរស័ព្ទ/ទូរសារៈ (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែលៈ cdri@camnet.com.kh website: http://www.cdri.org.kh

បកប្រែដោយៈ អែម សូវ៉ានី
កែសម្រួល និងរចនាដោយៈ យូ សិទ្ធីរិទ្ធ និងអ៊ុំ ចាន់ថា
បោះពុម្ពនៅកម្ពុជា ដោយរោងពុម្ព JSRC ភ្នំពេញ

# មាតិកា

បញ្ជីក្រាហ្វិក និងតារាង....................i
បញ្ជីអក្សរកាត់....................iii
បុព្វកថា....................v
សេចក្តីថ្លែងអំណរគុណ....................vii

**ជំពូកទី ១. សេចក្តីផ្តើម....................១**

**ជំពូកទី ២. លទ្ធផលសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០០២....................៥**

២.១. លទ្ធផលទូទៅ....................៥
២.២. ផលិតផលក្នុងស្រុកសរុប-តាមវិស័យ....................៧
២.៣. ផលិតផលក្នុងស្រុកសរុបគិតតាមប្រភេទតំរូវការ....................២០
២.៤. ហិរញ្ញវត្ថុសាធារណៈ....................២៥
២.៥. រូបិយវត្ថុ និងកំរិតថ្លៃ....................២៩
២.៦. ជញ្ជីងទូទាត់....................៣៦
២.៧. ស្ថានភាពនៃភាពក្រីក្រ....................៣៩
២.៨. សេចក្តីសន្និដ្ឋាន និងការប្រមើលឃើញពីអនាគត....................៤១
**ឯកសារយោង**....................៤៥

**ជំពូកទី ៣. ដំណាំលក់យកប្រាក់ ........................................................ ៤៧**

៣.១. សេចក្តីផ្តើម ........................................................................................ ៤៧

៣.២. ផលិតកម្មដំណាំលក់យកប្រាក់នៅកម្ពុជា .................................................. ៤៩

៣.៣. ម៉ាឃីទីង និងការនាំចេញ...................................................................... ៧២

៣.៤. ការកែច្នៃកសិផល............................................................................... ១០១

៣.៥. សន្និដ្ឋាន............................................................................................ ១១៣

**ឯកសារយោង**.......................................................................................... ១១៥

**តារាងស្ថិតិបន្ថែម**..................................................................................... ១១៧

# បញ្ជីក្រាហ្វិក និងតារាង

## បញ្ជីក្រាហ្វិក


ក្រាហ្វិក ១. ការរួមចំណែកតាមវិស័យដល់ ផសស នៅកម្ពុជា.................................. ៩

ក្រាហ្វិក ២. គំរោងកែច្នៃស្បៀងនិងកសិផលអនុម័តដោយ CDC ......................... ១៥

ក្រាហ្វិក ៣. ការនាំចូលស៊ីម៉ង់ត៍ និងដែក (ពាន់តោន)........................................... ១៦

ក្រាហ្វិក ៤. ការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា............................ ១៧

ក្រាហ្វិក ៥. ការវិនិយោគឯកជន និងសាធារណៈ ...................................................២១

ក្រាហ្វិក ៦. FDI និងការវិនិយោគកម្ពុជា (លានដុល្លារគិតថ្លៃបច្ចុប្បន្ន).................២២

ក្រាហ្វិក ៧. ការនាំចូលម៉ូតូ និងរថយន្ត មកកម្ពុជា ១៩៩៥-២00២ (គ្រឿង) ..... ២៥

ក្រាហ្វិក ៨. ការនាំចូលសាំង និងម៉ាស៊ូតរបស់កម្ពុជា នៅឆ្នាំ១៩៩៥-២00២ ........ ២៥

ក្រាហ្វិក ៩. ការអនុវត្តន៏ចំណូលចរន្ត (ភាគរយនៃផែនការ) .................................២៦

ក្រាហ្វិក ១0. ការអនុវត្តន៏ចំណាយចរន្ត (ភាគរយនៃផែនការ) ............................. ២៩

ក្រាហ្វិក ១១. អត្រាការប្រាក់ចារិកលើកំចីនៅកម្ពុជា ថៃ និងវៀតណាម.............. ៣១

ក្រាហ្វិក ១២. អត្រាការប្រាក់ ..............................................................................៣៣

ក្រាហ្វិក ១៣. ថ្លៃលក់ដុំសណ្តែកសៀងនៅខេត្តកំពង់ចាមឆ្នាំ១៩៩៨-២00៣....... ៧៤

## បញ្ជីតារាង

តារាង ១. ផលិតកម្ម និងផលិតភាពនៃដំណាំចំបង១នៅកម្ពុជា ក្នុងឆ្នាំ២០០២...... ៥៣
តារាង ២. តំបន់ប្រមូលផល ទិន្នផល និងផលិតកម្មសណ្តែកសៀង ......................... ៥៥
តារាង ៣. ចរិកាផលិតកម្មសណ្តែកសៀងនៅខេត្តកំពង់ចាម និងព្រះវិហារ............ ៥៨
តារាង ៤. តំបន់ប្រមូលផល ទិន្នផល និងផលិតកម្មពោត ....................................... ៦០
តារាង ៥. ផ្ទៃដីផលិតកម្មពោតក្រហមក្នុងស្រុកនានានៅខេត្តបាត់ដំបង................ ៦២
តារាង ៦. ចរិកាផលិតកម្មពោតនៅ ៣ស្រុកក្នុងខេត្តបាត់ដំបងនាឆ្នាំ២០០២......... ៦៣
តារាង ៧. ផ្ទៃដីប្រមូលផល ទិន្នផល និងផលិតកម្មដំឡូងឈើ................................ ៦៦
តារាង ៨. ចរិកាផលិតកម្មដំឡូងឈើនៅខេត្តកំពង់ចាមក្នុងឆ្នាំ២០០២................... ៦៨
តារាង ៩. តំបន់ដាំស្វាយចន្ទីនៅកម្ពុជាពីឆ្នាំ២០០០ ដល់ ២០០២........................... ៧០
តារាង ១០. ថ្លៃសណ្តែកសៀងនៅក្នុងខ្សែរយៈទីផ្សារ............................................. ៧៥
តារាង ១១. ផលចំណេញនៅតាមខ្សែរយៈទីផ្សារពោតនៅឆ្នាំ២០០៣................... ៨៥
តារាង ១២. ការនាំចេញគ្រាប់ស្វាយចន្ទីជាប់សំបក ប៉ាន់ស្មានដោយអ្នកលក់ដុំ........ ៨៩
តារាង ១៣. ផលិតកម្មគ្រាប់ស្វាយចន្ទីជាប់សំបកក្នុងពិភពលោក........................... ៩០
តារាង ១៤. ការនាំចេញផលិតផលក្នុងវិស័យកសិកម្មដែលផ្អែកលើទិន្នន័យផ្លូវ ....... ៩១
តារាង ១៥. តំលៃនាំចេញនៃផលិតផលកសិកម្មសំខាន់១ ....................................... ៩២

# បញ្ជីអក្សរកាត់

| | |
|---|---|
| ACLEDA | សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា (Association of Cambodian Local Economic Development Agencies) |
| ASEAN | សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (Association of Southeast Asian Nations) |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (Council for the Development of Cambodia) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| FDI | វិនិយោគផ្ទាល់ពីបរទេស (Foreign Direct Investment) |
| GDP/ផសស | ផលិតផលក្នុងស្រុកសរុប (Gross Domestic Product) |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) |
| LOI | ច្បាប់ស្តីពីវិនិយោគទុន (Law on Investment) |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Ministry of Economy and Finance) |
| NBC | ធនាគារជាតិនៃកម្ពុជា (National Bank of Cambodia) |
| NIS | វិជ្ជាស្ថានជាតិស្ថិតិ (National Institute of Statistics) |
| UNWFP | កម្មវិធីស្បៀងអាហាររបស់អង្គការសហប្រជាជាតិ (United Nations World Food Programme) |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក (World Trade Organisation) |

# បុព្វកថា

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា មានក្តីសោមនស្សរីករាយ ដោយបានបោះពុម្ពរបាយការណ៍សេដ្ឋកិច្ចលើកទីបីរបស់ខ្លួន ។ ដូចកាលពីលើកមុនដែរ ការសិក្សានេះមានបំណងពិនិត្យមើលឡើងវិញយ៉ាងលំអិតនូវសេដ្ឋកិច្ចកម្ពុជា និងធ្វើវិភាគលើលទ្ធផលឆ្នាំ២០០២ ដោយផ្អែកលើទិន្នន័យថ្មីៗបំផុត ។ លើសពីនេះទៀតក្នុងឆ្នាំនីមួយៗ របាយការណ៍បានបង្ហាញពីលទ្ធផលស្រាវជ្រាវរបស់ វបសអ លើផ្នែកសំខាន់ណាមួយ ។ កាលពីឆ្នាំ២០០២ ផ្នែកសំខាន់ដែលបានលើកយកមកបង្ហាញ គឺការអភិវឌ្ឍន៍វិស័យឯកជន ។ សំរាប់ឆ្នាំ២០០៣ យើងពិនិត្យពីភាពប្រកួតប្រជែងខាងកសិកម្ម ពិសេសវិស័យដាំដុះមិនមែនស្រូវ ។ ដំណាំបួនមុខបានយកមកធ្វើជាករណីសិក្សាមាន សណ្តែកសៀង ពោត ដំឡូង និងស្វាយចន្ទី ។

វិស័យកសិកម្មកម្ពុជា មានការរីកចំរើនខ្លាំងណាស់ ដោយទិន្នផលស្រូវកើនយ៉ាងខ្ពស់ពី ១,៣ត/ហត ដល់ ២,១ត/ហត ពីឆ្នាំ១៩៩៤-២០០១ ។ ដំណាំមិនមែនស្រូវមួយចំនួន ពិសេសដំណាំបន្លែ ក៏មានកំណើនគួរឱ្យកត់សំគាល់ដែរ ។ ទោះយ៉ាងនេះក្តី ការសិក្សាជាច្រើនបានបង្ហាញពីដំណើរការមិនល្អនៃកសិកម្មកម្ពុជា ជាពិសេសបើធៀបនឹងប្រទេសជិតខាងក្នុងតំបន់ ដោយសារមានឧបសគ្គនៃទិន្នផលទាប អត្រាទាបនៃការប្រើប្រាស់បច្ចេកវិទ្យាទំនើប ហេដ្ឋារចនាសម្ព័ន្ធអន់ និងការពឹងផ្អែកយ៉ាងធ្ងន់ធ្ងរលើការដាំស្រូវ ។

ការសិក្សានេះ ប្រឹងប្រែងស្វែងយល់ពីឧបសគ្គរារាំងផលិតកម្មដំណាំមិនមែនស្រូវនៅកម្ពុជា ដោយផ្តោតជាពិសេសលើពាណិជ្ជកម្ម ចំណាយម៉ាឃីទីង និងការប្រែប្រួលខុសលំនាំដើមនានា ដែលធ្វើឱ្យធ្លាក់ចុះទាបដល់ថ្លៃលក់នៅកសិដ្ឋាន និងគ្រឿងលើកទឹកចិត្តចំពោះផលិតករ ។ ការសិក្សានេះពឹងផ្អែកយ៉ាងសំខាន់លើទិន្នន័យមានស្រាប់ និងការសំភាសន៍ជាមួយនឹងភ្នាក់ងារ

ពាណិជ្ជកម្ម និងទីផ្សារសំខាន់ៗ ។ នៅក្នុងទស្សនៈរបស់យើង គំហើញជាដំបូងៗទាំងនេះ មានលក្ខណៈគួរឱ្យចាប់អារម្មណ៍ និងគួរបោះពុម្ពផ្សាយចេញជារបាយការណ៍នេះឡើង ។ បច្ចុប្បន្ន វិបសអ កំពុងស្រាវជ្រាវក្នុងដំណាក់កាលទីពីរលើប្រធានបទនេះ ដោយប្រើវិធីសាស្ត្រសិក្សាក្នុងតំបន់ និងពហុប្រទេស ដែលធ្វើឱ្យយើងអាចប្រៀបធៀបដោយផ្ទាល់នូវភាពប្រកួតប្រជែងនៃកសិកម្មកម្ពុជា តាមមុខដំណាំជាក់លាក់មួយចំនួន ជាមួយនឹងប្រទេសឯទៀតនៅក្នុងតំបន់ ដូចជា វៀតណាម ថៃ និងឡាវ ។

យើងរំពឹងថា ការវិភាគ និងគំហើញនៅក្នុងរបាយការណ៍សេដ្ឋកិច្ចប្រចាំឆ្នាំនេះ នឹងមានប្រយោជន៍ដល់អ្នកចែងគោលនយោបាយ អ្នកអនុវត្តន៍ជាក់ស្តែង និងអ្នកវិភាគនៅក្នុងសហគមន៍ធំទូលាយនៃអ្នកធ្វើអភិវឌ្ឍន៍ ។ យើងសូមបញ្ជាក់ឡើងវិញផងដែរពីការប្តេជ្ញាចិត្តរបស់យើង ដើម្បីធ្វើការស្រាវជ្រាវដែលទាក់ទងដល់ការចែងគោលនយោបាយឱ្យមានគុណភាពខ្ពស់ ហើយយើងទទួលស្វាគមន៍ចំពោះការជួយមតិ និងការចូលរួមផ្សេងៗនៅក្នុងដំណើរការស្វែងរកគុណភាពឱ្យកាន់តែប្រណិតឡើង ។

*ភ្នំពេញ, ខែកញ្ញា ឆ្នាំ២០០៣*

*អេវ៉ា មីស្លីវិក*

*នាយិកា វិបសអ*

# សេចក្តីថ្លែងអំណរគុណ

ក្រុមអ្នកនិពន្ធសូមអរគុណចំពោះអ្នកឆ្លើយសំភាសន៍ទាំងអស់ ដែលបានចំណាយពេលដ៏មានតំលៃដើម្បីឆ្លើយសំនួរ ជាពិសេសចំពោះមន្ត្រីរដ្ឋាភិបាល និងពាណិជ្ជករ ទាំងនៅថ្នាក់ជាតិ និងមូលដ្ឋានដែលបានឆ្លើយសំភាសន៍ ព្រមទាំងផ្តល់ពតិមានសំខាន់ៗដល់ក្រុមស្រាវជ្រាវ ។ ក្រុមអ្នកនិពន្ធ ទទួលបានអត្ថប្រយោជន៍យ៉ាងច្រើនពីសហប្រតិបត្តិការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិ វិជ្ជាស្ថានជាតិស្ថិតិ និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

ក្រុមអ្នកនិពន្ធសូមអរគុណដល់បណ្ឌិត K.A.S Murshid, អ្នកស្រី អេវ៉ា មីស្លីវិក និងបណ្ឌិត Jayant Menon ដែលបានពិនិត្យ និងផ្តល់យោបល់ដ៏មានប្រយោជន៍ជួយកែលំអឯកសារនេះ ។ ក្រុមអ្នកនិពន្ធក៏សូមអរគុណដល់សហការីទាំងអស់ ពិសេសលោក តុង-គឹមស៊ុន អ្នកស្រី ប៉ុន ដូរីណា និងលោក Bruce McKenney ដែលបានរួមចំណែកផ្ទាល់ដល់ការកសាងរបាយការណ៍នេះ ។ ក្រុមអ្នកនិពន្ធសូមអរគុណជាពិសេសផងដែរដល់លោក Ray Hossinger និងបុគ្គលិករដ្ឋបាលនិងហិរញ្ញវត្ថុ ដែលបានផ្តល់ការគាំទ្រយ៉ាងសក្តិសិទ្ធខាងសំភារៈ និងភស្តុភារ ។

អ្នកនិពន្ធ រួមទាំង វិបសអ សូមថ្លែងអំណគុណចំពោះអង្គការ Danida, មូលនិធិ Rockefeller និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត, ចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុ ។

*កង ច័ន្ទតារារ័ត្ន និង ច័ន្ទ សុផល*

*ខែកញ្ញា ឆ្នាំ២០០៣ ភ្នំពេញ, កម្ពុជា*

# ជំពូកទី ១
# សេចក្ដីផ្ដើម

នៅឆ្នាំ២០០២ ប្រទេសកម្ពុជាបានជួបព្រឹត្តិការណ៍សំខាន់ៗជាច្រើន ។ នៅខែកុម្ភៈ ឆ្នាំ២០០២ កម្ពុជាបានធ្វើការបោះឆ្នោតនៅក៏រិតឃុំជាលើកទី១ ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ហើយបន្ទាប់មក បានចាប់ផ្ដើមអនុវត្តកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការមួយ ។ ទាក់ទិននឹងគោលនយោបាយថវិកាសាធារណៈ រាជរដ្ឋាភិបាលកម្ពុជា បានផ្ដល់អាទិភាពដល់កម្មវិធីនានាដើម្បីកសាងសមត្ថភាពខាងហិរញ្ញវត្ថុនៅក៏រិតឃុំ-សង្កាត់ និងបានអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យមមួយ ។

វិធានការកំណែទំរង់នានាដើម្បីពង្រឹងការគ្រប់គ្រងចំណូល ជាពិសេសពន្ធដារ និងគយ និងសំរាប់កែលំអប្រសិទ្ធភាពចំណាយសាធារណៈក៏បានធ្វើបន្តដែរ ។ ដើម្បីកែលំអលទ្ធផលខាងចំណូល រាជរដ្ឋាភិបាលកម្ពុជាបានដាក់អាករលើតំលៃបន្ថែមប្រេងម៉ាស៊ូត និងបង្កើនពន្ធចំនួន ០,០២ដុល្លារ និង ០,០៤ដុល្លារ លើប្រេងសាំង និងម៉ាស៊ូត ។ ដើម្បីកែលំអការតម្រឹមចំណាយថវិកាសាធារណៈក្រសួងទាំងបួនគឺ អប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍន៍ជនបទ បានទទួលអាទិភាពនៃការបើកផ្ដល់ថវិកាឱ្យយ៉ាងពេញលេញ ។

នៅពាក់កណ្ដាលឆ្នាំ២០០២ បណ្ដាប្រទេសអ្នកផ្ដល់ជំនួយ បានសន្យាផ្ដល់ជំនួយច្រើនថែមទៀត និងបានធ្វើការប្ដេជ្ញាផ្ដល់ទុនថ្មីៗមួយចំនួនដល់រាជរដ្ឋាភិបាលកម្ពុជា ។ កំណែទំរង់ខាងតុលាការ និងច្បាប់ បានបន្តទៅមុខ ថ្វីបើមានការខកចិត្តជាទូទៅពីល្បឿនយឺតនៃកំណែ

ទំរង់ ។ ប៉ុន្តែការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីសុំចូលអង្គការពាណិជ្ជកម្មពិភពលោក គឺជាកំលាំងជំរុញមួយដើម្បីពន្លឿនការកសាងច្បាប់ដ៏ចាំបាច់នានា ។

កំណែទំរង់ក្នុងរដ្ឋបាលសាធារណៈ បានអនុវត្តឡើងក្នុងគោលដៅផ្តល់សេវាដ៏សមស្របនានាដល់វិស័យឯកជន ហើយវិធានការដ៏សំខាន់បំផុតគឺ កំណើន ៤៤% នៃកំរិតប្រាក់បៀវត្សរ៍សំរាប់រដ្ឋបាលស៊ីវិលនៅឆ្នាំ២០០២ ។ម្យ៉ាងទៀត មានការផ្តល់ប្រាក់ឧបត្ថម្ភ ពិសេសសំរាប់រដ្ឋបាលស៊ីវិលនៅក្នុងវិស័យជាអាទិភាពមួយចំនួន ។ ប្រព័ន្ធបើកបៀវត្សរ៍ ត្រូវបានដាក់បញ្ចូលទៅក្នុងកុំព្យូទ័រដល់គ្រប់ក្រសួងជំនាញនៅតាមខេត្ត-ក្រុងនិមួយៗ ដើម្បីអាចចេញតារាងបៀវត្សរ៍បានដោយគ្មានការយឺតយ៉ាវ និងជួយសំរួលដល់ការបើកបៀវត្សរ៍ ។

នៅចំពោះមុខបញ្ហាប្រឈមថ្មីៗ ទាំងពីខាងក្នុង និងខាងក្រៅប្រទេស រាជរដ្ឋាភិបាលកម្ពុជា បានធ្វើវិសោធនកម្មលើច្បាប់វិនិយោគ និងច្បាប់ស្តីពីសារពើពន្ធនៅឆ្នាំ២០០២ ។ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្មក្រុមហ៊ុន ត្រូវបានអនុម័តប្រើដើម្បីកែលំអតម្លាភាព ។

ការរីកលូតលាស់ក្នុងវិស័យសាធារណៈ បានរួមចំណែកជួយពង្រឹងបន្ថែមដល់សេដ្ឋកិច្ច ប៉ុន្តែការប្រែប្រួលក្នុងបរិស្ថានធម្មជាតិ បានប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ចនៅឆ្នាំ២០០២ ។ គ្រោះរាំងស្ងួត និងទឹកជំនន់ដ៏ធ្ងន់ធ្ងរ បានកាត់បន្ថយផលិតកម្មកសិកម្ម និងបានធ្វើឱ្យជីវភាពប្រជាជនកម្ពុជាជាច្រើនប្រឈមនឹងគ្រោះថ្នាក់ ។ ក្នុងពេលជាមួយគ្នា ដៃគូពាណិជ្ជកម្មចំបងៗរបស់កម្ពុជា គឺមានទាំងសហរដ្ឋអាមេរិក ប្រទេសមួយចំនួននៅអាស៊ី និងអាស៊ីអគ្នេយ៍ផង បានរើបឡើងវិញយឺតៗពីការធ្លាក់ចុះសេដ្ឋកិច្ច ។

ប្រទេសកម្ពុជា ត្រូវប្រឈមនឹងបញ្ហាមួយចំនួនទៀតដែលផុសចេញពីការកសាងតំបន់ពាណិជ្ជកម្មសេរីក្នុងអាស៊ាន ការត្រៀមរៀបចំផ្សេងៗដើម្បីចូលជាសមាជិក WTO, និងការត្រៀមរៀបចំនានា សំរាប់កិច្ចព្រមព្រៀងលើគ្រឿងអំបោះគ្រប់មុខ (Multi-Fibre Arrangement: MFA) ដែលទាក់ទិននឹងពាណិជ្ជកម្មអន្តរជាតិលើផលិតផលវាយនភ័ណ្ឌ ត្រូវផុតកំណត់នៅឆ្នាំ២០០៤ ។

ដោយសារមានកំលាំងជាច្រើនធ្វើសកម្មភាពយ៉ាងស្មុគស្មាញ ដូច្នេះជារឿងសំខាន់មួយដែលត្រូវពិនិត្យបូកសរុបពីលទ្ធផលនៃសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០០២ ។

ទីមួយ លទ្ធផលនៃវិស័យសេដ្ឋកិច្ចចំបងៗ នឹងត្រូវពិភាក្សាដោយផ្អែកលើលទ្ធផល និងកំហិតផ្សេងៗ ។ ទីពីរ ការពិនិត្យបូកសរុបនេះ នឹងរាយការណ៍ពីលទ្ធផលសេដ្ឋកិច្ចដោយផ្តោតលើអថេរសំខាន់ៗ ដូចជា ការប្រើប្រាស់ វិនិយោគ និងអាហារ័ណ-នីហារ័ណ ។ បន្ទាប់មកមានការសង្ខេបត្រួសៗពីហិរញ្ញវត្ថុសាធារណៈ, ការផ្គត់ផ្គង់សាច់ប្រាក់និងក៏រិតថ្លៃ, ជញ្ជីងទូទាត់ព្រមទាំងរចនាសម្ព័ន្ធ និងសារៈសំខាន់នៃជំនួយបរទេស ។

របាយការណ៍នឹងពិនិត្យត្រួសៗពីស្ថានភាពនៃភាពក្រីក្រនៅកម្ពុជាផងដែរ ដោយផ្អែកលើលទ្ធផលនៃអង្កេតពលករងាយរងគ្រោះធ្វើដោយ វបសអ ។ ជាការសន្និដ្ឋាន របាយការណ៍រំលេចពីទស្សនវិស័យ/ប្រមើលមើលពីអនាគតនៃសេដ្ឋកិច្ចកម្ពុជា ។

# ជំពូកទី ២
# លទ្ធផលសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០០២

## ២.១. លទ្ធផលទូទៅ

នៅឆ្នាំ២០០២ ផលិតផលក្នុងស្រុកសរុបនៅកម្ពុជា មានកំណើនយឺតត្រឹម ៤,២% គឺធ្លាក់ចុះពីកំរិត ៦,៧% នៅឆ្នាំ២០០១ ។ បញ្ហាចំបង គឺការធ្លាក់ចុះផលិតកម្មកសិកម្ម ជាពិសេសស្រូវក្នុងឆ្នាំ២០០១-២០០២ ដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួត ។

ក្នុងកំឡុងពេលដដែល វិស័យឧស្សាហកម្មមានអត្រាកំណើននៅនឹងស្ថិតត្រឹម ១១% នៅឆ្នាំ២០០២ គឺស្មើរតែស្មើគ្នានឹងឆ្នាំ២០០១ ។ ប៉ុន្តែអត្រាកំណើនបានបិទបាំងនូវការផ្លាស់ប្តូរយ៉ាងខ្លាំងនៃលទ្ធផលតាមអនុវិស័យ ។ ឧទាហរណ៍ ខណៈដែលឧស្សាហកម្មកាត់ដេរបានកើនឡើងយ៉ាងលឿនពី ១៧% នៅឆ្នាំ២០០១ ដល់ ២០% នៅឆ្នាំ២០០២, អត្រាកំណើនក្នុងវិស័យសំណង់បានចុះពី ១០% មកត្រឹម ៧% ។

វិស័យសេវាកម្មកើនយឺតៗត្រឹម ៧% ធៀបនឹងកំរិត ២០% នៅឆ្នាំ២០០១ ។ ផ្នែកនានាដែលមានចំណែកធំក្នុងកំណើន ដូចជា ពាណិជ្ជកម្ម និងទេសចរណ៍ជាដើម និងដែលទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងកំណើនចំណូលអំពី "សណ្ឋាគារ និងភោជនីយដ្ឋាន" បានជួបការរអាក់រអួល ។ ការថយចុះចំណាយជាមធ្យមនៅកម្ពុជារបស់ភ្ញៀវទេសចរណ៍ បានរួមចំណែកធ្វើឱ្យប្រាក់ចំណូលបានពីសណ្ឋាគារ និងភោជនីយដ្ឋាន មានកំណើនយឺត ទោះបីចំនួនភ្ញៀវទេសចរណ៍កើនឡើង ៣០% បើធៀបនឹងឆ្នាំ២០០១ ក្តី ។

ខាងផ្នែកចំណាយ រូបភាពជារួម ហាក់ដូចជាបញ្ជាក់ពីការលូតលាស់ក្នុងផលិតកម្មតាមវិស័យនីមួយៗ ។ ចំណាយលើទំនិញប្រើប្រាស់ស្ទុះឡើងយ៉ាងលឿនពីអត្រាកំណើន ៣% នៅឆ្នាំ២០០១ ដល់ ៥% នៅឆ្នាំ២០០២ ។ កត្តាសំខាន់គឺការស្ទុះឡើងនៃអត្រាកំណើនក្នុងចំណាយប្រើប្រាស់ឯកជនដែលជាលទ្ធផលនៃកំណើនចំណាយលើការលំហែកំសាន្ត និងយានយន្ត ។ ក្នុងពេលជាមួយគ្នានេះ ចំណាយប្រើប្រាស់សាធារណៈធ្លាក់ចុះសំខាន់ គឺដោយសារគំលាតរវាងការអនុវត្តន៍ថវិកា និងគោលដៅ បានកំណត់ក្នុងច្បាប់ថវិកា ដែលបានរាំងខ្ទប់កំណើនចំណាយប្រើប្រាស់ក្នុងវិស័យនេះ ។

វិនិយោគសរុបបានកើន ៥% នៅឆ្នាំ២០០២ គឺទាបជាងកំណើន ១៨% នៅឆ្នាំ២០០១ យ៉ាងខ្លាំង ដោយមូលហេតុនៃការថយចុះកំណើនទាំងខាងវិនិយោគសាធារណៈ (ដោយសារតែភាពខុសគ្នារវាងការអនុវត្តន៍ថវិកា និងផែនការក្នុងថវិកាឆ្នាំ២០០១ និង២០០២) និងការថយចុះខាងវិនិយោគឯកជន (ដោយសារការធ្លាក់ចុះវិនិយោគផ្ទាល់ពីបរទេសជាសំខាន់) ។ វិស័យនាំចេញដែលមានតួនាទីសំខាន់ក្នុងការជំរុញសេដ្ឋកិច្ច បានថយកំណើនដែរ ជាពិសេសការនាំចេញផលិតផលវាយនភ័ណ្ឌ ។ ក្នុងរយៈពេលជាមួយគ្នានេះ ការនាំចូលមកកម្ពុជាក៏បានកើនឡើងដែរ ជាពិសេសការនាំចូលផលិតផលប្រេងឥន្ធនៈ សំភារៈសំណង់ និងយានយន្ត ។

តុល្យភាពថវិកាសាធារណៈមានការកែលំអ ។ ឱនភាពថវិកាសាធារណៈសរុបធ្លាក់ចុះដល់ ២២៥លានដុល្លារនៅឆ្នាំ២០០២ ធៀបនឹង ២៣៨លានដុល្លារនៅឆ្នាំ២០០១ ។ បើគិតជាភាគរយនៃ ផសស ឱនភាពថវិកាសាធារណៈថយចុះមកត្រឹម ៦,៧% នៅឆ្នាំ២០០២ គឺចុះពី ៧% នៅឆ្នាំ២០០១ ។

ការផ្គត់ផ្គង់រូបិយវត្ថុកើន ៣១% ជាអត្រាលឿនបំផុតក្នុង ៦ឆ្នាំចុងក្រោយ ។ ថ្លៃទំនិញប្រើប្រាស់កើន ៣,៣% ធៀបនឹងក៏រិត ០,២% នៅឆ្នាំ២០០១ ។ ទោះយ៉ាងនេះក្តី ប្រាក់រៀលឡើងថ្លៃបានបន្តិចដែរគឺ ០,១៥% ទល់នឹងប្រាក់ដុល្លារពីឆ្នាំ២០០១-២០០២ ។ ជញ្ជីងពាណិជ្ជកម្ម កើនឱនភាពដល់ ២៨២លានដុល្លារនៅឆ្នាំ២០០២ ធៀបនឹងឱនភាព ២២៦លានដុល្លារនៅឆ្នាំ២០០១ ។ ហេតុផលចំបង គឺការនាំចូល កើនដល់ ១.៧៣៦លានដុល្លារនៅឆ្នាំ២០០២

ធៀបនឹង ១.៦០០លានដុល្លារនៅឆ្នាំ២០០១ ដោយសារកំណើនការនាំចូលយានយន្ត និងសំភារៈសំណង់ ។ ប៉ុន្តែដោយសារកំចី និងការផ្ទេរជាផ្លូវការ បានកើនឡើង ដូច្នេះជញ្ជីងទូទាត់របស់កម្ពុជាមានអតិរេក ដែលបានកើនពី ៧៣លានដុល្លារនៅឆ្នាំ២០០១ ដល់ ១៧២លានដុល្លារនៅឆ្នាំ២០០២ ធ្វើឱ្យទ្រព្យសកម្មបរទេសសុទ្ធនៅធនាគារជាតិនៃកម្ពុជា កើនបាន ១៧៧លានដុល្លារពីឆ្នាំ២០០១ ដល់ ២០០២ ។

## ២.២. ផលិតផលក្នុងស្រុកសរុប តាមវិស័យ

### *២.២.១. កសិកម្ម*

នៅឆ្នាំ២០០២ វិស័យកសិកម្មមានការធ្លាក់ចុះ ដោយសារគ្រោះធម្មជាតិ ដូចជាទឹកជំនន់ និងការរាំងស្ងួត ។ ផលិតកម្មស្រូវធ្លាក់ដល់ ៣,៧លានតោនពី ៤,១លានតោនក្នុងឆ្នាំ២០០១ ។ មូលហេតុចំបង គឺការធ្លាក់ចុះផលិតកម្មស្រូវក្នុងរដូវវស្សាពី ៣,៣លានតោននៅឆ្នាំ២០០១ ដល់ ២,៩លានតោននៅឆ្នាំ២០០២ ។ ថ្វីបើ ផ្ទៃដីបានប្រមូលផលដែលមាន ១,៧លានហ.ត[១] គឺប្រែប្រួលតែបន្តិចបន្តួច ប៉ុន្តែ ទិន្នផលស្រូវវស្សាធ្លាក់ដល់ ១,៧ត/ហត នៅឆ្នាំ២០០២ ធៀបនឹង ១,៩ត/ហ.តនៅឆ្នាំ២០០១ ។ ការធ្លាក់ចុះនេះ បណ្តាលមកពីមានភ្លៀងយឺតយ៉ាវ ។ ខេត្តកណ្តាល ព្រៃវែង ស្វាយរៀង តាកែវ កំពង់ស្ពឺ និងកំពង់ចាម ដែលតំណាងឱ្យ ៤២% នៃផលិតកម្មស្រូវវស្សា មានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារគ្រោះរាំងស្ងួត ។

គិតចូលទាំងមុខដំណាំផ្សេងៗទៀតផង កម្ពុជាបង្កើតតំលៃបន្ថែមអំពីផលិតកម្មដំណាំបាន ៤៥១លានដុល្លារនៅឆ្នាំ២០០២ (គិតតាមកំរិតថ្លៃឆ្នាំ១៩៩៣) ឬ ៧% ទាបជាងឆ្នាំ២០០១ ។ ផ្ទុយពីផលិតកម្មដំណាំ ផលិតកម្មសត្វចិញ្ចឹម និងបក្សី បានរួមចំណែកជាវិជ្ជមានដល់ផសស ។ នៅឆ្នាំ២០០២ ចំណូលពិតពីការចិញ្ចឹមសត្វ និងបក្សី កើន ៨% គឺផ្ទុយពីឆ្នាំ២០០១ ដែលមានការធ្លាក់ចុះ ៨% ។ ផលិតកម្មសត្វចិញ្ចឹម និងបក្សី មានចំណែក ៦% ក្នុង ផសស ពិតឆ្នាំ២០០២ ធៀបនឹង ៥% ក្នុងឆ្នាំ២០០១ ។ នេសាទដែលជាវិស័យផ្តល់ចំណូលសំខាន់លំដាប់

[១] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទៈ ស្ថិតិកសិកម្ម ២០០១- ២០០២ និងរបាយការណ៍ផ្លូវការស្តីពីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០០២ -២០០៣ ។

ទីពីរបន្ទាប់ពីស្រូវបានបន្តធ្លាក់ចុះ ។ យោងតាមទិន្នន័យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សកម្មភាពនេសាទផ្តល់ចំណូលពិត ២៣៨លានដុល្លារ ឬ ១៣% ទាបជាងឆ្នាំ២០០១ ។ ហេតុផលសំខាន់គឺ ការធ្លាក់ចុះផលនេសាទពី ១៧៧.០០០តោននៅឆ្នាំ២០០១ ដល់ ១៥៦.១៥០តោននៅឆ្នាំ២០០២ ព្រមទាំងការបន្តធ្លាក់ចុះនៃសមាមាត្រត្រីមានតំលៃខ្ពស់នៅក្នុងផលនេសាទសរុប[២] ។ ប៉ុន្តែផលនេសាទទឹកប្រៃបាន ៤៥.៨៥០តោន ឬ ៣.៨៥០តោន ច្រើនជាងឆ្នាំ២០០១ ដូច្នេះការធ្លាក់ចុះក្នុងផលនេសាទសរុប គឺបណ្តាលមកពីការធ្លាក់ចុះផលនេសាទទឹកសាបពី ១៣៥.០០០តោននៅឆ្នាំ២០០១ មកត្រឹម ១១០.៣០០តោននៅឆ្នាំ២០០២ ។ ទោះយ៉ាងនេះក្តី ផលនេសាទទឹកសាប ១១០.៣០០តោនក្នុងឆ្នាំ២០០២ វានៅតែមានកំរិត ០,២៧% ខ្ពស់ជាងផែនការជាផ្លូវការដែរ ។

ប្រភពចំណូលពីកសិកម្មផ្សេងៗទៀតដូចជា ព្រៃឈើ និងកៅស៊ូ បានធ្លាក់ចុះជាបណ្តើរៗ ។ ការកាប់ឈើខុសច្បាប់ និងការធ្វើអាជីវកម្មច្រើនហួសហេតុ បានបំផ្លាញធនធានព្រៃឈើ និងឈើមានតំលៃខ្ពស់[៣] ។ ទន្ទឹមគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តគោលនយោបាយមួយចំនួនទាក់ទងនឹងកិច្ចការពារធនធានព្រៃឈើ ។ ប៉ុន្តែ ចំណូលពិតពីព្រៃឈើឆ្នាំ២០០២ ធ្លាក់ចុះ ៩% បានប្រហែលតែ ៩៣លានដុល្លារ ។

---

[២] McKenney B. & Prom T. (2002) ធនធានធម្មជាតិ និងការចិញ្ចឹមជីវិតនៅកម្ពុជា, ឯកសារពិភាក្សាលេខ២៣ របស់ វិបសអ ។

[៣] អាចមានការពិតច្រើនដែលថា ធនធានព្រៃឈើ និងឈើមានតំលៃខ្ពស់ ត្រូវបានបំផ្លិចបំផ្លាញ ។ ប៉ុន្តែមានការច្របូកច្របល់ច្រើនពីស្ថានភាពបច្ចុប្បន្ននៃធនធានព្រៃឈើនៅកម្ពុជា ។ ដូច្នេះហើយ ជាការមួយគួរត្រេកអរណាស់ដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងបន្តធ្វើបច្ចុប្បន្នភាព ផែនទីធនធានព្រៃឈើជាតិ ។ ទង្វើនេះ នឹងផ្តល់ពត៌មានច្បាស់ស្តីពីស្ថានភាពធនធានព្រៃឈើនៅកម្ពុជា ។ ផែនទីធនធានព្រៃឈើកម្ពុជា ត្រូវបានរៀបចំឡើងចុងក្រោយបំផុតនៅឆ្នាំ១៩៩៦-១៩៩៧ ដោយប្រើរូបភាពផ្កាយរណប ថតនៅឆ្នាំ១៩៩៥-១៩៩៦ ។

ក្រាហ្វិក ១. ការរួមចំណែកតាមវិស័យដល់ ផសស នៅកម្ពុជា




*ប្រភព: វិបសអ*

ការធ្លាក់ចុះជាទូទៅក្នុងផលិតកម្មផលកសិកម្មចំបង១ ធ្វើឱ្យតំលៃបន្ថែមបានពីវិស័យកសិកម្មថយចុះអស់ ៦% នៅឆ្នាំ២០០២ ធៀបនឹងឆ្នាំ២០០១ ហើយចំណែករបស់វាក្នុង ផសសសរុប ធ្លាក់ចុះដល់ ២៩% ធៀបនឹង ៣២% នៅឆ្នាំ២០០១ (ក្រាហ្វិក ១) ។

### *២.២.២. ឧស្សាហកម្ម និងសំណង់*

ផ្ទុយពីកសិកម្ម កំណើនប្រចាំឆ្នាំនៃវិស័យឧស្សាហកម្មមានស្ថិរភាពត្រឹមប្រហែល ១២% (១១% នៅឆ្នាំ២០០១) ។ កត្តាចំបងដែលរួមចំណែកដល់កំណើនឧស្សាហកម្ម គឺកំណើនកាន់តែលឿនក្នុងផ្នែកកម្មន្តសាល ប៉ុន្តែវិស័យសំណង់មានការធ្លាក់ចុះកំណើន ។

នៅឆ្នាំ២០០២ វិស័យកម្មន្តសាលកម្ពុជា ដែលមានជាអាទិ៍ ផលិតកម្មខាង "វាយនភ័ណ្ឌ សំលៀកបំពាក់ និងស្បែកជើង" និង "ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់" កើនបាន ១៤% ធៀបនឹង ១១% នៅឆ្នាំ២០០១ ។ ជាពិសេស ផលិតកម្ម "វាយនភ័ណ្ឌ សំលៀកបំពាក់ និងស្បែកជើង" រកចំណូលពិតបាន ៥២០លានដុល្លារ គិតតាមការិតថ្លៃឆ្នាំ១៩៩៣ ឬ ២០% ខ្ពស់ជាងឆ្នាំ២០០១ ដែលមានកំណើន ១៧% ។ អត្រាកំណើនកាន់តែលឿននៃផ្នែកសំលៀកបំពាក់ បង្ក

ជាសំខាន់ដោយសារកំណើនតំរូវការពីខាងក្រៅ ជាពិសេសពីសហរដ្ឋអាមេរិក ដែលជាទីផ្សារធំចំបងសំរាប់ឧស្សាហកម្មសំលៀកបំពាក់កម្ពុជា ។ តំរូវការអាមេរិក មានកំណើន ២២% នៅឆ្នាំ២០០២ ធៀបនឹងកំណើន ៦% នៅឆ្នាំ២០០១[៤] ។ អត្រាកំណើនកាន់តែលឿនឆ្លុះបញ្ចាំងពីលក្ខខណ្ឌផលិតកម្មកាន់តែប្រសើរ (ទន់ភ្លន់ងាយបត់បែនបាន) ដែលជាលទ្ធផលនៃការកែលំអច្បាប់ ការពង្រឹងការអនុវត្តន៍ច្បាប់ និងសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងវិស័យឯកជន ។ មានគោលនយោបាយបី បានជួយពង្រីកផលិតកម្ម ដើម្បីការឆ្លើយតបនឹងតំរូវការខាងក្រៅ:

១. ការធ្វើឱ្យសាមញ្ញជាបណ្តើរៗនូវនីតិវិធីនាំចេញ និងនាំចូល បានសំរាលការលំបាកមួយចំនួន និងបំព្រួញពេលវេលាក្នុងការងារធ្វើលិខិតស្នាម ។ ជាលទ្ធផល ផលិតករអាចឆ្លើយតបបានកាន់តែល្អទៅនឹងការបញ្ជាទិញពីខាងក្រៅ ។ ដោយឡែកពេលវេលាចំណាយលើបែបបទរដ្ឋបាល និងធ្វើលិខិតស្នាម បានបំព្រួញខ្លី បន្ទាប់ពីការចេញសេចក្តីប្រកាសលេខ ១៣០០ ចុះថ្ងៃទី២៤ សីហា ២០០១[៥] ។

២. ការរៀបចំវេទិការដ្ឋាភិបាល-វិស័យឯកជន ផ្តល់ឱកាសឱ្យរដ្ឋាភិបាលស្វែងយល់បានកាន់តែច្បាស់ពីបញ្ហានានាដែលវិស័យឯកជនត្រូវប្រឈមមុខ ព្រមទាំងផលប្រយោជន៍ និងតំរូវការផ្សេងៗរបស់ពួកគេ ។ ទន្ទឹមនេះដែរ វិស័យឯកជនទទួលពត៌មានបានច្បាស់ជាងមុន ពីការផ្លាស់ប្តូរដ៏ចាំបាច់ៗក្នុងគោលនយោបាយនៃរដ្ឋាភិបាល ដែលជាប់ទាក់ទិននឹងបញ្ហាព្រួយបារម្ភរបស់ពួកគេ ។ ជាទូទៅ ផលិតកម្មត្រូវឆ្លើយតបទៅនឹងទីផ្សារឱ្យបានបន្តជាប់រហូត និងយ៉ាងសក្តិសិទ្ធិ ។ តាមធម្មតា រឿងនេះពឹងផ្អែកលើបរិយាកាសផលិតកម្ម ដែលជារឿយៗតែងទទួលរងឥទ្ធិពលអំពីគោលនយោបាយរដ្ឋាភិបាល ។ ដូច្នេះ សហប្រតិបត្តិការរវាងរដ្ឋាភិបាល និងវិស័យឯកជន អាចជួយកែលំអបានច្រើនណាស់ដល់លទ្ធភាពឆ្លើយតបចំពោះតំរូវការទីផ្សារ ។

---

[៤] តាមទិន្នន័យពី ក្រសួងពាណិជ្ជកម្មកម្ពុជា ។

[៥] ចំពោះចំណុចចំបងៗនៃកំណែទំរង់សូមអាន Hing, T. (2003): Cambodia’s Investment Potential ។

៣. ដើម្បីជួយដោះស្រាយការប្រឈមគ្នារវាងសហជីពកម្មករ និងថ្នាក់គ្រប់គ្រងរោងចក្រ យន្តការមានលក្ខណៈជាស្ថាប័នមួយចំនួន ដើម្បីស្វែងយល់ពីផលប្រយោជន៍ទៅវិញទៅមកបានកកើតឡើង ហើយបានជួយកែលំអកិច្ចសហប្រតិបត្តិការ និងជួយធ្វើឱ្យល្អប្រសើរ នូវដំណើរការផលិតកម្ម ។ ជាលទ្ធផលនៃអន្តរាគមន៍របស់រាជរដ្ឋាភិបាលកម្ពុជា កម្មករបានយល់ដឹងកាន់តែប្រសើរឡើងពីសិទ្ធិរបស់ខ្លួន និងពីវិធី ប្រើសិទ្ធិនេះដោយសន្តិភាព អ្នកគ្រប់គ្រងរោងចក្រក៏កាន់តែមានការយល់ដឹងពីវិធីដោះស្រាយជាមួយកម្មករ ក្នុងស្ថានភាពដ៏លំបាកផ្សេងៗ ។ បរិយាកាសកាន់តែល្អ និងមានសន្តិភាពនៅក្នុងរោងចក្រ បានជួយឱ្យអ្នកគ្រប់គ្រងអាចឆ្លើយតបបានលឿនចំពោះកំណើនតំរូវការ ។

ដោយហេតុថា ឧស្សាហកម្មកាត់ដេរកម្ពុជា ពឹងផ្អែកលើកូតាសហរដ្ឋអាមេរិកផ្តល់ឱ្យ ដូច្នេះសក្តានុពលនៃការពង្រីកអាចមានកំរិត ។ នៅពេលកូតាផុតកំណត់នៅឆ្នាំ២០០៤ ការអភិវឌ្ឍន៍វិស័យកាត់ដេរ នឹងពឹងលើការពង្រឹងភាពប្រកួតប្រជែងជាអន្តរជាតិរបស់វា ។ ជាទូទៅ ភាពប្រកួតប្រជែងពឹងលើគុណភាពផលិតផល និង/ឬ ថ្លៃផលិតផល ដែលត្រូវមានកំរិតអប្បរមាមួយកំណត់ដោយបន្ទុកចំណាយផលិតកម្ម ។

ធៀបនឹងប្រទេសជិតខាង ដែលកំពុងព្យាយាមអភិវឌ្ឍន៍ឧស្សាហកម្មកាត់ដេររបស់ខ្លួនដែរ ប្រទេសកម្ពុជាមានបន្ទុកចំណាយខ្ពស់លើថាមពល[៦], ការដឹកជញ្ជូន, និងប្រាក់កំរៃក្រៅផ្លូវការ, ទោះបីរាជរដ្ឋាភិបាលកម្ពុជាបានដាក់អនុវត្តគោលនយោបាយមួយចំនួនដើម្បីដោះស្រាយបញ្ហាទាំងនេះក្តី ។ ឧទាហរណ៍ យោងតាមអង្កេតធ្វើដោយទីប្រឹក្សាអន្តរជាតិមួយក្រុម ដោយរួមសហការជាមួយក្រសួងពាណិជ្ជកម្មនៅឆ្នាំ២០០១ កំពង់ផែព្រះសីហនុ ទារប្រាក់កំរៃខ្ពស់ជាងគេនៅក្នុងតំបន់ និងថ្លៃ៤ដង ច្រើនជាងកំពង់ផែដែលមានទំហំប្រហែលគ្នា ដូចជា កំពង់ផែ Songkhla នៅថៃជាដើម ។

---

[៦] ថ្លៃប្រេងនៅក្រុងភ្នំពេញគឺ ០,៥៥ដុល្លារ/លីត្រ ជាមធ្យមនៅឆ្នាំ២០០២ ចំណែកថ្លៃប្រេងសាំងនៅប្រទេសថៃគឺ ០,៣៣ ដុល្លារ/លីត្រ ។

អង្កេតស្តីពី "*ភាពប្រកួតប្រជែងនៃឧស្សាហកម្មកម្ពុជា*" ដែលធ្វើឡើងរួមគ្នានៅដើមឆ្នាំ២០០៣ ដោយ វិបសអ និងវិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ជប៉ុន បានបង្ហាញថា អ្នកគ្រប់គ្រងរោងចក្រភាគច្រើនយល់ថា មានកត្តាពីរយ៉ាងជាឧបសគ្គចំបង ចំពោះភាពប្រកួតប្រជែងរបស់រោងចក្រកាត់ដេរកម្ពុជាៈ

១. *ការពិនិត្យចាត់ចែងលើសំណុំឯកសារប្រើរយៈពេលវែង និងស្មុគ្រស្មាញៈ* ដើម្បីបានអាជ្ញាប័ណ្ណនាំចេញ រោងចក្រកាត់ដេរត្រូវរងចាំយ៉ាងតិច ៥ថ្ងៃ ចំណែកឯផលិតករនៅហ្វីលីពីន គេត្រូវការតែ ២ថ្ងៃទេ ដើម្បីបង្ហើយសំណុំលិខិតដូចគ្នា ។ ជាលទ្ធផលរោងចក្រកាត់ដេរទាំងអស់នៅកម្ពុជា ត្រូវដំណើរការនៅក្រោមសំពាធពេលវេលាជាប្រចាំ ។ ហើយសំពាធទាំងនេះកើនឡើងថែមទៀត ដោយសារមានអធិការកិច្ចជាកាតព្វកិច្ចជាច្រើនលើរាល់ការបញ្ជូនទំនិញចេញ ។ រោងចក្រកាត់ដេរមានជួបសំពាធពេលវេលាមួយទៀត ដោយសារការដឹកទំនិញចេញមានតែមួយលើកទេក្នុងមួយសប្តាហ៍នៅរៀងរាល់ថ្ងៃសៅរ៍ ។ ប្រសិនបើខកមួយជើង ត្រូវរស់សោហ៊ុយបន្ថែមនៃការរង់ចាំមួយសប្តាហ៍ទៀត ។ កត្តាទាំងពីរនៃការដឹកចេញប្រចាំសប្តាហ៍ និងបែបបទធ្វើឯកសារយូរ ធ្វើឱ្យអ្នកគ្រប់គ្រងរោងចក្រកាត់ដេរស្ថិតក្នុងស្ថានភាពត្រូវចាញ់ប្រៀប ពួកមន្ត្រីរាជការដែលទទួលខុសត្រូវពិនិត្យការងារដឹកទំនិញចេញ ហើយនៅចុងបញ្ចប់ការបង់ប្រាក់កំរៃក្រៅផ្លូវការ ក៏កើតមានឡើង ។ យោងតាមបទសំភាសន៍ "លុយបង់ក្រោមតុ" នេះជួនកាលមានសមាមាត្រយ៉ាងធំនៅក្នុងចំណាយផលិតកម្មសរុប ។

២. កង្វះឧស្សាហកម្មគាំទ្រៈ ឧស្សាហកម្មនាំចេញកម្ពុជាភាគច្រើន ត្រូវនាំចូលធាតុចូលដូចជា វត្ថុធាតុដើម និងទំនិញអន្តរការីមកពីក្រៅ ។ រឿងនេះធ្វើឱ្យចុះខ្សោយដល់ភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងទីផ្សារនាំចេញ ដោយសារចំណាយខ្ពស់លើការទិញធាតុចូល ។ បញ្ហាចោទធំបំផុត គឺក្នុងករណីភាគច្រើន កម្ពុជាត្រូវនាំចូលធាតុចូលមកពី

ប្រទេសជាគូប្រកួតប្រជែងរបស់ខ្លួន ដូចជា ចិន វៀតណាម និងថៃ ។ ដូច្នេះ ភាពប្រកួតប្រជែងរបស់កម្ពុជា គ្មានមូលដ្ឋានគ្រឹះអ្វីរឹងមាំទេ ។

ដើម្បីដោះស្រាយបញ្ហាទាំងនេះ កម្ពុជា បានពិចារណាលើគោលនយោបាយសំខាន់ៗបី សំដៅលើកកំពស់ការអភិវឌ្ឍន៍ឧស្សាហកម្មនាំចេញ:

១. *កែតំរូវច្បាប់វិនិយោគតាមការផ្លាស់ប្តូរផ្សេងៗក្នុងសេដ្ឋកិច្ច:* យោងតាមវិសោធនកម្មចុងក្រោយនៃច្បាប់វិនិយោគដែលចូលជាធរមាននៅខែមីនា ២០០៣ ឧស្សាហកម្មគាំទ្រចំពោះឧស្សាហកម្មនាំចេញ ត្រូវបានគិតគូរ ។ ដូចមានបញ្ជាក់ក្នុងអនុក្រឹត្យ "ឧស្សាហកម្មគាំទ្រ - គំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" អាចនាំចូលសំភារៈផលិតកម្ម សំភារៈសំណង់ វត្ថុធាតុដើម ទំនិញអន្តរការី និងគ្រឿងបន្ទាប់បន្សំផ្សេងៗនៃធាតុចូលផលិតកម្ម ដោយគ្មានបង់ពន្ធគយ ។

២. *បង្កើត "តំបន់ឧស្សាហកម្ម":* ច្បាប់ស្តីពីតំបន់ឧស្សាហកម្ម និងច្បាប់ស្តីពីការគ្រប់គ្រងឧស្សាហកម្ម នឹងត្រូវរៀបចំ[៧] ។ គោលនយោបាយនេះផ្តោតជាមូលដ្ឋានលើ ក) ពីដំបូង ត្រូវលៃចែកធនធានសំរាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដ៏កំរ យកទៅប្រើនៅក្នុងតំបន់ ឧស្សាហកម្ម ដើម្បីឱ្យវាមានភាពប្រកួតប្រជែងដល់កំរិតអន្តរជាតិ និង ខ) បញ្ចុះបន្ទុកចំណាយរដ្ឋបាលនៃការលើកលែងទាំងស្រុងនូវពន្ធគយ និងពន្ធផ្សេងទៀតលើការនាំចូលនៅក្នុងតំបន់ឧស្សាហកម្មដែលបានកំណត់ ។ ត្រូវមានគោលនយោបាយមួយសំរាប់ "តំបន់ឧស្សាហកម្ម" ដែលអាចទាក់ទាញផលិតករនៃប្រទេសជិតខាងឱ្យផ្លាស់ប្តូរទីតាំងនៃប្រតិបត្តិការផលិតកម្មរបស់ពួកគេ មកដាក់ក្នុងតំបន់នានានៅកម្ពុជានៅតាមបណ្តោយព្រំដែន ។

៣. *ធ្វើសេរីភាវូបនីយកម្មគោលនយោបាយពាណិជ្ជកម្ម:* មានគោលដៅពីរដែលជាប់ទាក់ទងដល់គោលនយោបាយពាណិជ្ជកម្មគឺ ១) កាត់បន្ថយបន្ទុកចំនាយផលិតកម្ម និង ២)

[៧] Hing, T. (2003) Cambodia Investment Potential ។

ស្វែងរកទីផ្សារសំរាប់ឧស្សាហកម្មនាំចេញ ។ ក្នុងចំណុចនេះ កម្ពុជាបានកសាងគោលនយោបាយផ្សេងៗ ដើម្បីជួយសំរួលដល់ពាណិជ្ជកម្ម និងការធ្វើសមាហរណកម្មទៅក្នុងអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក[៨] ។

ថ្វីបើលទ្ធផលជាផ្លែផ្កានៃការខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីលើកកំពស់ឧស្សាហូបនីយកម្មដែលផ្អែកលើឧស្សាហកម្មនាំចេញ ក៏ជាប់ទាក់ទងនឹងការវិវត្តន៍នៅក្នុងបណ្តាប្រទេសគូប្រកួតប្រជែងនៅក្នុងទីផ្សារនាំចេញដែរ ។ ជាលទ្ធផលការរីកចំរើនឬកែលំអផ្សេងៗនៅក្នុងលក្ខខណ្ឌផលិតកម្ម មិនមែនសុទ្ធតែមានន័យថា ឧស្សាហកម្មនាំចេញរបស់កម្ពុជា នឹងអាចប្រកួតប្រជែងបាននោះទេ ។ ប្រទេសផ្សេង ក៏នឹងអនុម័តវិធានការផ្សេងៗ ដើម្បីកែលំអស្ថានភាពរបស់ពួកគេដែរ រួមទាំង កំណែទំរង់វិសោធនកម្មលើច្បាប់ និងគោលនយោបាយពាណិជ្ជកម្មនានាដើម្បីកាត់បន្ថយបន្ទុកចំណាយ ។ ការប្រកួតប្រជែងជាមួយតួអង្គនានាក្នុងតំបន់ដែលមានជំហររឹងមាំហើយ គឺជាបញ្ហាប្រឈមមួយដ៏ធំធេង ។

ដូច្នេះ យុទ្ធសាស្ត្រដែលនាំមុខដោយការនាំចេញ វាមានហានិភ័យ និងមិនអាចទាយទុកមុនបានទាំងចំពោះដៃគូក្នុងស្រុក និងអន្តរជាតិ ។ ក្នុងបរិបទនេះ ទីផ្សារក្នុងស្រុក គួរតែធ្វើអាជីវកម្មឱ្យបានពេញលេញ ហើយឧស្សាហកម្មផលិតអីវ៉ាន់សំរាប់ជំនួសទំនិញនាំចូល និងមានម្ចាស់ជាអ្នកក្នុងស្រុក ក៏មិនគួរមានការរាំងស្ទះអ្វីដែរ ។

គួរពិនិត្យមើលឡើងវិញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដើម្បីពិចារណាធ្វើការផ្លាស់ប្តូរពីការពឹងផ្អែកយ៉ាងធ្ងន់ធ្ងរលើវិនិយោគផ្ទាល់ពីបរទេស និងកំណើននាំមុខដោយការនាំចេញទៅផ្តោតលើតួនាទីដ៏ធំធេងនៃវិនិយោគឯកជនក្នុងស្រុក[៩] និងទីផ្សារក្នុងស្រុក ។

---

[៨] ពតិមានលំអិត សូមអានឯកសារក្រសួងពាណិជ្ជកម្ម (២០០២): ការសិក្សាពីសមាហរណកម្ម និងភាពប្រកួតប្រជែង ។

[៩] ការបង្កើតឱ្យមានបរិយាកាសវិជ្ជមានសំរាប់អ្នកវិនិយោគក្នុងស្រុក មិនមានន័យថា ចាត់វិធានការទប់ស្កាត់ពួកគេពីការប្រកួតប្រជែងនាំចូល "ថោក" នោះទេ ។ ផ្ទុយទៅវិញ វាជាការកែលំអប្រសិទ្ធភាពរបស់ពួកអ្នកវិនិយោគក្នុងស្រុកឱ្យមានសមត្ថភាពប្រកួតប្រជែងជាមួយការនាំចូល "ថោក" ។

ឧទាហរណ៍ វិនិយោគច្រើនៗថែមទៀតក្នុងការកែច្នៃស្បៀងនិងកសិផល សំណង់ និង ការតំលើងគ្រឿងយន្ត ដែលជាសកម្មភាពសេដ្ឋកិច្ចពឹងផ្អែកសំខាន់លើទីផ្សារក្នុងស្រុកគួរទទួល បានការលើកទឹកចិត្ត ។

យោងតាមបញ្ជីគំរោងអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គំរោងវិនិយោគលើ ការកែច្នៃស្បៀងនិងកសិផលកើនដល់ ៣៦,៧លានដុល្លារនៅឆ្នាំ២០០២ ធៀបនឹង ៥,៧លាន ដុល្លារនៅឆ្នាំ២០០១ ។ ក្នុង ៣៦,៧លានដុល្លារនេះ វិនិយោគបរទេសមាន ៣៥,៣លានដុល្លារ ដែលជាបរិមាណខ្ពស់បំផុតតាំងពីឆ្នាំ១៩៩៦មក ។ សល់ពីនេះ គឺជាវិនិយោគក្នុងស្រុក ហើយ វាជាតួលេខដ៏ទាបបំផុត (ក្រាហ្វិក ២) ។

ចាប់ពីឆ្នាំ១៩៩៧ ដល់ ២០០១ វិនិយោគលើការកែច្នៃស្បៀងនិងកសិផល មានកំរិត ទាបមិនលើសពី ២៥លានដុល្លារទេ ។ នៅឆ្នាំ២០០០-០១ វាមានប្រហែល ៦លានដុល្លារ ឬ ១% នៃវិនិយោគឯកជនសរុប ។ និន្នាការនេះបង្ហាញថា បណ្តាសហគ្រាសក្នុងឧស្សាហកម្ម កែច្នៃស្បៀងនិងកសិផល មិនបានទទួលការគាំពារផ្អែកនយោបាយគ្រប់គ្រាន់ទេ ។

**ក្រាហ្វិក ២. គំរោងកែច្នៃស្បៀងនិងកសិផលអនុម័តដោយ CDC (លានដុល្លារ)**




*ប្រភព: ទិន្នន័យពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)*

វិស័យសំណង់ដែលមានទាំងសកម្មភាពសំណង់សាធារណៈនិងឯកជន ជាប់ចំណាត់ថ្នាក់លេខពីរ (បន្ទាប់ពីកម្មន្តសាល) នៅក្នុងវិស័យឧស្សាហកម្ម ដោយមានទំហំជាមធ្យម ប្រហែល ២០% នៃចំនួលឧស្សាហកម្មសរុប ។ ដោយសារកង្វះបែបបទប្រមូលទិន្នន័យនៅតាមខេត្ត សកម្មភាពសំណង់ឯកជននៅក្រៅក្រុងភ្នំពេញ មិនអាចតាមដានបានទេ គឺបានន័យថា មានការប៉ាន់ស្មានបន្ទាបលើសកម្មភាពសំណង់ក្នុងឯកសារនេះ ។ ប៉ុន្តែទិន្នន័យនាំចូលសំភារៈសំណង់ ដូចជាស៊ីម៉ង់ និងដែក (ក្រាហ្វិក ៣) បញ្ជាក់ពីកំណើនបន្តជាប់រហូតក្នុងសកម្មភាពសាងសង់ ។

បន្ទាប់ពីការធ្លាក់ចុះនៅឆ្នាំ២០០១ វិស័យសំណង់ឯកជនកម្ពុជាបានរីកលូតលាស់គួរកត់សំគាល់នៅឆ្នាំ២០០២ ។ តំលៃនៃគំរោងអនុម័តដោយនាយកដ្ឋានសូរិយោដី និងភូមិសាស្ត្រនៃសាលាក្រុងភ្នំពេញឡើងដល់ ២២០លានដុល្លារ ឬ ១២% ច្រើនជាងឆ្នាំ២០០១ ។ ចំនួនគំរោងបានអនុម័តកើនពី ៦៦២ នៅឆ្នាំ២០០១ ដល់ ៧៧៤ នៅឆ្នាំ២០០២ ក្នុងនេះមាន ៥៣០គំរោងសំរាប់សំណង់ផ្ទះល្វែង, ១៦២គំរោងសំរាប់សំណង់ភូមិគ្រឹះ និង ៨២គំរោងសំរាប់ "សំណង់ផ្សេងៗ" ដូចជាអគារពាណិជ្ជកម្មជាដើម ។

**ក្រាហ្វិក ៣. ការនាំចូលស៊ីម៉ង់តិ៍ និងដែក (ពាន់តោន)**




*ប្រភព: ទិន្នន័យពីទីចាត់ការគយ និងរដ្ឋាករ*

កំណើនសកម្មភាពសំណង់ ទាក់ទងមួយចំណែកទៅនឹងចំណាប់អារម្មណ៍របស់ប្រជាជនពីបញ្ហាសន្តិសុខក្នុងប្រទេស ។ ទោះបីនៅមានការរំជើបរំជួលម្តងម្កាលក្តី ប៉ុន្តែ សព្វថ្ងៃប្រជាជនកម្ពុជារស់នៅក្នុងសន្តិភាព និងមានស្ថិរភាពមួយកំរិតធំ ។ ប្រជាជនលែងរស់នៅក្រោមការភ័យខ្លាចសង្គ្រាមស៊ីវិលដូចក្នុងទសវត្សរ៍១៩៧០ ១៩៨០ និង ១៩៩០ ទៀតហើយ ។ ក្នុងបរិបទនេះ វាគួរឱ្យជឿបានថា ប្រជាជនអាចទិញភូមិគ្រឹះ ផ្ទះល្វែង និងអគារផ្សេងទៀត បើសិនមានប្រាក់ចំណូលគ្រប់គ្រាន់ ។

កំណើនសកម្មភាពសំណង់ បានបង្កើតប្រាក់ចំណូល និងការងារច្រើនណាស់ ។ ថ្វីបើគ្មានទិន្នន័យដ៏ពិតប្រាកដ ប៉ុន្តែ គេទទួលស្គាល់ជាទូទៅថា ភាគច្រើននៃកម្មករសំណង់ គឺជាប្រជាជនក្នុងស្រុក ។ ប្រាក់ចំណូលរបស់អ្នកទាំងនេះ តាមធម្មតាចំណាយនៅក្នុងទីផ្សារជនបទ ពីព្រោះភាគច្រើនពួកគេមកពីតំបន់ជនបទទាំងនោះ ។ រឿងនេះអាចជំរុញឱ្យមានវិនិយោគថ្មីទៀតនៅតំបន់ជនបទ ដែលនឹងជួយពង្រីកមូលដ្ឋាននៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ ដូច្នេះ វិធានការសំដៅជំរុញសកម្មភាពសំណង់ អាចមានអត្ថប្រយោជន៍ធំធេង ។

## ក្រាហ្វិក ៤. ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា




*ប្រភព វបសអ ប្រមូលពី ទិន្នន័យរដ្ឋាភិបាល*

វិស័យសំណង់កើន ៧% នៅឆ្នាំ២០០២ គឺយឺតជាង ២០០១ ដែលកើនបាន ១០% ។ កំណើនយឺតនៃផ្នែកសំណង់ទាំងមូល ឆ្លុះបញ្ចាំងពីកំណើនយឺតក្នុងសកម្មភាពសំណង់សាធារណៈ ដែលកើនបានត្រឹម ៤% នៅឆ្នាំ២០០២ ធៀបទៅនឹង ២២% កាលពីឆ្នាំ២០០១ ។

យោងតាមនិន្នាការពីមុន ការរួមចំណែកនៃវិស័យសំណង់ចំពោះវិស័យឧស្សាហកម្ម ជាទូទៅ បានធ្លាក់ចុះដល់ ១៩% នៅឆ្នាំ១៩៩៨ ហើយក៏ចាប់ផ្តើមកើនយឺតៗរហូតដល់ ២២% នៅឆ្នាំ២០០២ (ក្រាហ្វិក៤) ។ កំនើនចំនាយសាធារណៈ សំរាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសនៅតំបន់ជនបទ ធ្វើឱ្យគេរំពឹងថា សកម្មភាពសំណង់នឹងបន្តរីកលូតលាស់ ។

ចំនូលមធ្យមប្រចាំថ្ងៃនៃអ្នកធ្វើការងារសំនង់ បានប្រែប្រួលតិចតួចណាស់ ។ យោងតាមអង្កេតរបស់ វិបសអ កម្មករសំណង់មានជំនាញ អាចកែលំអចំនូលប្រចាំថ្ងៃរបស់ខ្លួនបាន ១៧%[១០] ឡើងដល់ ១២.៨៥៦រៀលនៅឆ្នាំ២០០២ ធៀបនឹង ១០.៩៣៧រៀលនៅឆ្នាំ២០០១ ។ ទន្ទឹមគ្នានេះ កម្មករសំណង់គ្មានជំនាញ មានចំណូលប្រចាំថ្ងៃសឹងនៅនឹងដដែល[១១] គឺ ៦.៥៧៨ រៀលនៅឆ្នាំ២០០២ ធៀបនឹង ៦.៥៥៧រៀលនៅឆ្នាំ២០០១ ។ មូលហេតុសំខាន់គឺ លំហូរយ៉ាងខ្សោយទាត់នៃកម្មករគ្មានជំនាញចេញពីខេត្តមកក្រុងភ្នំពេញ ដើម្បីរកការងារធ្វើ[១២] ជាពិសេសក្នុងវិស័យសំណង់ ។ សក្តានុពលរកចំណូលរបស់កម្មករគ្មានជំនាញនៅតាមខេត្ត ហាក់ដូចមានកំរិតទាបជាងនៅភ្នំពេញ ។ យោងតាមអង្កេត វិសបអ នៅខែកុម្ភៈ ២០០៣ កម្មករគ្មានជំនាញនៅកំពង់ចាម រកចំណូលបានជាមធ្យម ៣.៦០០រៀល/ថ្ងៃ ឬ ២៦% ទាបជាងនៅភ្នំពេញ ។ យោងតាមអ្នកត្រូវបានសំភាសដោយ វិសបអ គំលាតរវាងកំរិតប្រាក់ចំណូលនេះ ហាក់ដូចធំគ្រប់គ្រាន់អាចជំរុញពួកគេឱ្យធ្វើចំណាកស្រុក ។

---

[១០] គិតតាមកំរិតតំលៃពិត (កាត់អតិផរណាចេញ) ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់មានជំនាញកើនបាន ១៣% ពីឆ្នាំ២០០១ ដល់ ២០០២ ។

[១១] គិតតាមកំរិតតំលៃពិត ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញធ្លាក់ចុះ ៣,៣% (ដែលជាអត្រាអតិផរណាពីឆ្នាំ២០០១ ដល់ ២០០២) ។

[១២] តាមសំភាសន៍ធ្វើដោយ វិបសអ នៅខែកុម្ភៈ ២០០៣ ។

### ២.២.៣. វិស័យសេវាកម្ម

វិស័យសេវាកម្មកម្ពុជា កើនយឺត។ នៅឆ្នាំ២០០២ ត្រឹម ៧% ធៀបនឹង ២០% កាលពី ២០០១ ។ ការធ្លាក់ចុះអត្រាកំណើននេះ បណ្តាលមកពីការថយកំណើនក្នុងវិស័យពាណិជ្ជកម្ម និង "សណ្ឋាគារ និងភោជនីយដ្ឋាន" ដែលជាប់ទាក់ទងនឹងវិស័យទេសចរណ៍ ។

វិស័យទេសចរណ៍កម្ពុជា ដែលដើរតួនាទីសំខាន់លំដាប់ទីពីរនៅក្នុងកំណើនសេដ្ឋកិច្ចកម្ពុជា បានបន្តរីកលូតលាស់បើគិតតាមចំនួនភ្ញៀវទេសចរណ៍បរទេស ។ យោងតាមក្រសួងទេសចរណ៍ កម្ពុជាទទួលភ្ញៀវបរទេសបាន ៧៨៦.៥២៤នាក់នៅឆ្នាំ២០០២ ឬ ៣០% ច្រើនជាង ២០០១ ។ ក្នុងនេះ ៦៨% ចូលមកតាមផ្លូវអាកាស និង ៣២% ទៀត ចូលមកតាមផ្លូវគោក និងផ្លូវទឹក ។ លទ្ធផលនេះមួយភាគធំបណ្តាលមកពីការបើកច្រកព្រំដែនថ្មី ជាពិសេសនៅព្រំប្រទល់កម្ពុជាថៃ ។ ចំនួនភ្ញៀវអន្តរជាតិមកដល់តាមយន្តហោះកើន ១៦% ។ អាកាសយានដ្ឋានពោធិចិនតុង (ឥឡូវនេះឈ្មោះថា អាកាសយានដ្ឋានភ្នំពេញ) ទទួលបានភ្ញៀវទេសចរណ៍ ៣៤៨.៣១៣នាក់ នៅ ២០០២ ឬ ៥% ច្រើនជាង ២០០១ រីឯអាកាសយានដ្ឋានសៀមរាប ទទួលបាន ១៨៨.៩១៣នាក់ ឬ ៤១% ច្រើនជាងឆ្នាំមុន ។

ប៉ុន្តែ ចំណាយរបស់ភ្ញៀវបរទេសឆ្នាំ២០០២ កើនក្នុងអត្រាយឺតជាង ២០០១ ។ ក្រសួងទេសចរណ៍ប៉ាន់ប្រមាណថា ចំណាយសរុបរបស់ភ្ញៀវបរទេសគឺ ៣៧៩លានដុល្លារនៅឆ្នាំ២០០២ ។ ដូច្នេះវាមានកំណើន ២៥% នៅឆ្នាំ២០០២ ធៀបនឹង ៣៣%នៅ២០០១ ។ មូលហេតុចំបងនៃ កំណើនយឺត គឺការធ្លាក់ចុះចំណាយមធ្យមប្រចាំថ្ងៃ គឺភ្ញៀវម្នាក់ចំនាយ ៩ដុល្លារនៅ២០០១ ប៉ុន្តែនៅ២០០២ ចំនាយតែ ៨ដុល្លារ[១៣] ។ ម្យ៉ាងទៀត រយៈពេលមធ្យមស្នាក់នៅកម្ពុជាកើនពី ៥,៥ថ្ងៃនៅ២០០១ ដល់ត្រឹម ៥,៨ថ្ងៃនៅ២០០២ ។ ដើម្បីជំរុញឱ្យជនបរទេសចំណាយពេល វែង និងប្រាក់ច្រើននៅកម្ពុជា រដ្ឋាភិបាលបានចាប់អនុវត្តគោលនយោបាយថ្មីដែលមានទាំងការ សំរួលបែបបទទិដ្ឋាការ ជាពិសេសភ្ញៀវមកពីប្រទេសអាស៊ាន ពង្រឹងសន្តិសុខសំរាប់ភ្ញៀវទេសចរណ៍

[១៣] ក្រសួងទេសចរណ៍ (២០០២) របាយការណ៍ស្ថិតិទេសចរណ៍ ឆ្នាំ២០០២

និងផ្តោតលើការឃោសនាផ្សព្វផ្សាយពីសេវាកម្ម និងកន្លែងកំសាន្តថ្មីៗ ដូចជាខាងអេកូទេសចរណ៍ជាដើម ។ ការកែលំអហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសន្តិសុខ ប្រហែលនឹងជួយជំរុញការលូតលាស់ខាងទេសចរណ៍ រួមទាំងទេសចរណ៍ក្នុងស្រុកផងដែរ ។

## ២.៣. ផលិតផលក្នុងស្រុកសរុបគិតតាមប្រភេទតំរូវការ

### *២.៣.១. ការប្រើប្រាស់*

ក្នុងផ្នែកចំណាយ (ដែលជាប់ទាក់ទងនឹងការបែងចែកចំណូលជាតិ) ចំណាយប្រើប្រាស់មានសមាមាត្រធំជាងគេគឺ ៨៣% នៃ ផសស នៅឆ្នាំ២០០២ ។ កំណើនចំណាយប្រើប្រាស់ដែលជាកត្តាដ៏សំខាន់មួយនៃតំរូវការផលិតកម្ម និងដែលបានជំរុញការលូតលាស់ វាកើនបាន ៥% (ធៀបនឹងកំណើន ៣% នៅឆ្នាំ២០០១) ។ កត្តាសំខាន់ គឺកំណើនកាន់តែលឿនក្នុងចំណាយប្រើប្រាស់ឯកជន ប៉ុន្តែចំណាយប្រើប្រាស់សាធារណៈថយចុះ ៦% នៅឆ្នាំ២០០២ ។

ប៉ុន្តែយោងតាមច្បាប់ថវិកាឆ្នាំ២០០២ ចំណាយសាធារណៈគួរកើន ១០,៥% ។ ការធ្លាក់ចុះ[១៤] ចំណាយសាធារណៈនៅឆ្នាំ២០០២ គឺជាលទ្ធផលនៃការអនុវត្តន៍ថវិកា និងកត្តាជាច្រើនទៀត ។ ចំណាយប្រើប្រាស់សាធារណៈ ត្រូវបានកែលំអដែលជាលទ្ធផលនៃគោលនយោបាយកំណែទំរង់សារពើពន្ធ ។ យោងតាមច្បាប់ថវិកាឆ្នាំ២០០២ ចំណាយបៀវត្សរ៍សំរាប់រដ្ឋបាលស៊ីវិលគួរកើន ១០% ខ្ពស់ជាង ២០០១ ចំណែកឯចំនាយបៀវត្សរ៍សំរាប់ការពារ និងសន្តិសុខជាតិ គួរថយចុះ ១៤% ។ តាមទិន្នន័យពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំណាយថវិកាពិត មានលំនាំប្រហាក់ប្រហែលនឹងច្បាប់ថវិកា គឺកំណើនចំនាយបៀវត្សរ៍ សំរាប់រដ្ឋបាលស៊ីវិល និងការថយចុះចំនាយបៀវត្សរ៍សំរាប់ខាងការពារនិងសន្តិសុខជាតិ ។

ប៉ុន្តែចំណាយថវិកាមិនមែនបៀវត្សរ៍ មិនបានស្របតាមច្បាប់ថវិកា២០០២ ទេគឺៈ

- ចំនាយសំរាប់ប្រតិបត្តិការរដ្ឋបាលស៊ីវិល បានត្រឹម ៧៦% នៃផែនការក្នុងច្បាប់ថវិកា និងមានកំរិត ១៦% ទាបជាងចំណាយនៅឆ្នាំ២០០១ ។

[១៤] ទាំងប្រាក់រៀល និងដុល្លារ ពីព្រោះប្រាក់រៀលឡើងថ្លៃ ០,១៣% ទល់នឹងដុល្លារ ។

- ចំនាយសំរាប់ប្រតិបត្តិការការពារនិងសន្តិសុខ គួរកើន ១១% យោងតាមច្បាប់ថវិកា ប៉ុន្តែវាបានធ្លាក់ ២១% យោងតាមទិន្នន័យអនុវត្តន៍ជាក់ស្តែង ។

ដូច្នេះ ការធ្លាក់ចុះនៃចំណាយប្រើប្រាស់សាធារណៈ មិនមែនជាលទ្ធផលនៃគោលនយោបាយសារពើពន្ធ ដែលកំណត់ដោយច្បាប់ថវិកាឆ្នាំ២០០២ នោះទេ ប៉ុន្តែគឺការអនុវត្តន៍ចំណាយប្រតិបត្តិការទាបជាងផែនការ នៅក្នុងរដ្ឋបាលស៊ីវិល និងការពារនិងសន្តិសុខ ។

### *២.៣.២. វិនិយោគ*

ចំណាយទៅលើវិនិយោគកើនឡើង ៥% នៅឆ្នាំ២០០២ ធៀបនឹងកំណើន ១៨% នៅឆ្នាំ២០០១ ។ មូលហេតុគឺកំណើនយឺតនៅក្នុងវិនិយោគឯកជន និងសាធារណៈ (ក្រាហ្វិក ៥) ។

**ក្រាហ្វិក ៥. ការវិនិយោគឯកជន និងសាធារណៈ (លានដុល្លារ នៃថ្លៃ ១៩៩៣)**




*ប្រភពទិន្នន័យពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

វិនិយោគសាធារណៈ កើនបាន ៥% នៅឆ្នាំ២០០២ គឺទាបជាងឆ្នាំ២០០១ ដែលមានកំណើន ២៤% ។ ការធ្លាក់ចុះកំនើនដ៏ធំនេះ មិនមែនមកពីគោលនយោបាយទេ ប៉ុន្តែមកពីការអនុវត្តន៍ច្បាប់ថវិកា ។ យោងតាមច្បាប់ថវិកា សំរាប់រយៈពេលបីឆ្នាំ (២០០០-២០០២) វិនិយោគសាធារណៈគួរកើនឡើង ០,៥% នៅឆ្នាំ២០០១ និង ០,៩% នៅឆ្នាំ២០០២ ។

អត្រាកំណើនខ្ពស់ (២៤%) នៃវិនិយោគសាធារណៈនៅឆ្នាំ២០០១ បណ្តាលមកពីចំណាយមូលធននៅឆ្នាំ២០០២ ដែលធ្វើហិរញ្ញប្បទានដោយជំនួយពីខាងក្រៅគឺបានតែ ៨៣% នៃផែនការ ចំណែកចំណាយមូលធននៅឆ្នាំ២០០១ បានដល់ ១១៧% នៃផែនការ ។

កំណើន ៥% នៃវិនិយោគសាធាណៈនៅឆ្នាំ២០០២ ដែលខ្ពស់ជាងផែនការ (០,៩%) គឺទទួលឥទ្ធិពលពីទំហំកាន់តែច្រើននៃចំណាយមូលធនធ្វើហិរញ្ញប្បទានដោយជំនួយពីក្រៅ ដែលឡើងដល់ ១២៣% នៃផែនការ ។

វិនិយោគឯកជនធ្វើដោយអ្នកវិនិយោគក្នុងស្រុក និងបរទេស បានថយអត្រាកំណើនគឺចុះពី ១៣% នៅឆ្នាំ២០០១ ដល់ ១០% នៅឆ្នាំ២០០២ ។ មូលហេតុសំខាន់គឺ ការធ្លាក់ចុះវិនិយោគផ្ទាល់ពីបរទេសដល់ ១៤៦លានដុល្លារនៅឆ្នាំ២០០២ ធៀបនឹង ១៥២លានដុល្លារនៅឆ្នាំ២០០១[១៥] (ក្រាហ្វិក ៦) ។

**ក្រាហ្វិក ៦. FDI និងការវិនិយោគកម្ពុជា (លានដុល្លារគិតថ្លៃបច្ចុប្បន្ន)**




*ប្រភព: ទិន្នន័យពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

[១៥] ទិន្នន័យសំដៅដល់តំលៃទ្រព្យសកម្មជាប់លាប់ ដែលអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

មានមូលហេតុធំៗពីរចំពោះការធ្លាក់ចុះ FDI នៅកម្ពុជាៈ

- ការរើបឡើងវិញយឺតនៃសេដ្ឋកិច្ចនៅអាស៊ីខាងកើត និងអាស៊ីអគ្នេយ៍ ដែលជាប្រភពអ្នកវិនិយោគក្រៅប្រទេសភាគច្រើនរបស់កម្ពុជា
- *ការកែលំអយ៉ាងលឿននៃបរិយាកាសវិនិយោគក្នុងប្រទេសប្រកួតប្រជែង ដូចជា វៀតណាម ហ្វីលីពីន ចិន និងថៃ* ។ កំណើននៅក្នុងការកែលំអហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបរិយាកាសស្ថាប័ននៅកម្ពុជា មិនបានលឿនដូចការកែលំអនៅក្នុងប្រទេសប្រកួតប្រជែងទេ ។ ឧទាហរណ៍ វៀតណាម បានកែលំអការដឹកជញ្ជូន អគ្គិសនី ការស្រោចស្រព និងប្រព័ន្ធស្ថាប័នផ្សេងៗទៀត ដល់កំរិតមួយដែលកម្ពុជា មិនអាចសំរេចបាននៅពេលបច្ចុប្បន្ន ។ ដរាបណា ប្រទេសកម្ពុជាស្ថិតនៅក្រោយប្រទេសប្រកួតប្រជែង ក្នុងការធ្វើឱ្យកាន់តែប្រសើរឡើងនូវបរិយាកាសវិនិយោគ, FDI ប្រហែលនឹងមិនកើនឡើងទេ ។ រឿងនេះតំរូវឱ្យរដ្ឋាភិបាលប្រឹងប្រែងខ្លាំងក្លា ដើម្បីអនុម័តធ្វើកំណែទំរង់តាមតំរូវការដ៏ធំ ជាពិសេសទាក់ទងទៅនឹងកំណែទំរង់រដ្ឋបាល និងការប្រយុទ្ធនឹងអំពើពុករលួយ ។

ដូច្នេះគឺមានតំរូវការគោលនយោបាយសេដ្ឋកិច្ចថ្មីមួយ ដែលសង្កត់ធ្ងន់លើយុទ្ធសាស្ត្រផ្តល់អាទិភាពដល់តួអង្គដ៏ជាក់លាក់មួយចំនួន ។ ផ្អែកលើយោបល់ខាងលើ អ្នកវិនិយោគឯកជនក្នុងស្រុកដែលផលិតសំរាប់ទីផ្សារក្នុងស្រុក និង/ឬទីផ្សារនាំចេញ គួរតែចាត់ទុកជាតួអង្គជាយុទ្ធសាស្ត្រដែលអាចជួយជំរុញកំណើនសេដ្ឋកិច្ចមានចីរភាព នៅក្នុងដំណាក់កាលសេដ្ឋកិច្ច "ចាប់ផ្តើមស្ទុះឡើង"[១៦] ។

[១៦] សំខាន់ត្រូវពិនិត្យមើលពីទំហំវិស័យវិនិយោគឯកជនក្នុងស្រុក (និងការវិនិយោគក្នុងស្រុក) ដែលអាចជំរុញបាន ។ ត្រូវមានការស្រាវជ្រាវដែលជាប់ទាក់ទិននឹងវិស័យនេះ ។

### *២.៣.៣. ការនាំចេញ និងការនាំចូល*

តំរូវការខាងក្រៅនូវផលិតផលកម្ពុជា បានផ្តល់កំលាំងជំរុញមួយចំនួនសំរាប់សេដ្ឋកិច្ចកម្ពុជា ។ ការនាំចេញកម្ពុជា កើន ៦% នៅឆ្នាំ២០០២ គឺចុះពី ៨% នៅឆ្នាំ២០០១ ។ ការនាំចេញសំខាន់គឺ ផលិតផលកាត់ដេរ ។ ការនាំចេញផលិតផលវាយនភ័ណ្ឌកើន ១៣% ឡើងដល់ ១.៣៣៣លានដុល្លារនៅឆ្នាំ២០០២ ធៀបនឹងកំណើន ២៥% នៅឆ្នាំ២០០១ ។ ទីផ្សារនាំចេញចំបងសំរាប់ផលិតផលវាយនភ័ណ្ឌកម្ពុជាគឺ សហរដ្ឋអាមេរិក និងបន្ទាប់មក សហគមអឺរ៉ុប ។ ចាប់តាំងពីធ្វើពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិកនៅឆ្នាំ១៩៩៥ តំលៃនៃការនាំចេញសំលៀកបំពាក់កម្ពុជាទៅអាមេរិក កើនឡើងយ៉ាងទ្បើងទាត់ ។ បើសិន កូតាផ្តល់ដោយអាមេរិក ត្រូវផុតកំណត់នៅឆ្នាំ២០០៤ ការអភិវឌ្ឍន៍ឧស្សាហកម្មកាត់ដេរកម្ពុជា នឹងត្រូវពឹងផ្អែកទាំងស្រុងលើភាពប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ ។

ផ្ទុយពីការនាំចេញ, ការនាំចូលរបស់កម្ពុជាកើន ៨% នៅឆ្នាំ២០០២ គឺលឿនជាងឆ្នាំ២០០១ បន្តិចដែលមានកំណើន ៧% ។ ផលិតផលចំបងៗដែលកម្ពុជានាំចូល គឺផលិតផលប្រេងឥន្ធនៈ សំភារៈសំណង់ និងយានយន្ត ។

តាមទិន្នន័យពីទីចាត់ការគយនិងរដ្ឋាករកម្ពុជា ការនាំចូលរថយន្តឡើងដល់ ៧២លានដុល្លារនៅឆ្នាំ២០០២ ឬ ៤២% ច្រើនជាងឆ្នាំ២០០១ ។ បន្ទាប់ពីការធ្លាក់ចុះអស់រយៈពេលបួនឆ្នាំរហូតដល់ចុងឆ្នាំ២០០១ (ក្រាហ្វិក ៧) កម្ពុជាបានបង្កើនការនាំចូលម៉ូតូឡើងវិញ រហូតដល់ ៧៤.៩២៥គ្រឿងនៅឆ្នាំ២០០២ ធៀប ៥៥.០១៨គ្រឿងនៅឆ្នាំ២០០១ ។

ពីឆ្នាំ១៩៩៥-២០០២ ការនាំចូលប្រេងសាំងធ្លាក់ពីកំរិតខ្ពស់បំផុតគឺ ១៤៩.៩៦៩តោននៅឆ្នាំ១៩៩៥ ដល់ ១១៥.១០៦តោននៅ១៩៩៩ និងដល់ ៨២.៨៦៣តោនដែលជាកំរិតទាបបំផុត នៅ២០០២ (ក្រាហ្វិក ៨)។ ប៉ុន្តែក្នុងរយៈពេលដូចគ្នា ការនាំចូលម៉ាស៊ូតកើនពីកំរិតទាបបំផុតគឺ ២១០.០៧០តោននៅ១៩៩៥ ដល់កំរិតខ្ពស់បំផុតគឺ ៤៥៩.៦៩២តោននៅ២០០១ រួចហើយធ្លាក់ចុះមកវិញ ដល់ ៣៣៤.៩៥៦តោននៅ២០០២ ។

ក្រាហ្វិក ៧. ការនាំចូលម៉ូតូ និងរថយន្ត មកកម្ពុជា ១៩៩៥-២០០២ (គ្រឿង)




*ប្រភព: ទិន្នន័យពីទីចាត់ការគយ និងរដ្ឋាករកម្ពុជា*

ក្រាហ្វិក ៨. ការនាំចូលសាំង និងម៉ាស៊ូតរបស់កម្ពុជា នៅឆ្នាំ១៩៩៥-២០០២ (តោន)




*ប្រភព ទិន្នន័យពីទីចាត់ការគយ និងរដ្ឋាករកម្ពុជា*

## ២.៤. ហិរញ្ញវត្ថុសាធារណៈ

នៅឆ្នាំ២០០២ ឱនភាពសរុបឡើងដល់ ៧៦២ពាន់លានរៀល គឺទាបជាងក៏រិត ៧៩៥ ពាន់លានរៀលកំណត់ដោយច្បាប់ថវិកាឆ្នាំ២០០២[១៧] ។ គិតជាសមាមាត្រនៃ ផសស ឱនភាពថវិកាធ្លាក់ចុះពី ៧% នៅឆ្នាំ២០០១ មកត្រឹម ៥% នៅឆ្នាំ២០០២ ។ ឱនភាពសរុបសំរាប់ការអនុវត្តន៍ថវិកា រួមទាំងការកែតំរូវចំណាយមានដល់ ៨៨១ពាន់លានរៀលនៅឆ្នាំ២០០២ (២២៥លានដុល្លារ) ឬ ១១% ច្រើនជាងផែនការ ហើយឱនភាពទាំងអស់នេះ ត្រូវធ្វើហិរញ្ញប្បទានដោយប្រភពបរទេស ។ ឱនភាពលើសផែនការនេះ បណ្តាលមកពីចំណូលទាបជាងផែនការ និងចំណាយលើសផែនការ ។

កម្ពុជាប្រមូលចំណូលសរុបបាន ១.៧២៩ពាន់លានរៀល (៤៤១លានដុល្លារ) ដែលចែកជាចំណូលចរន្ត ១.៧១៣ពាន់លានរៀល(៤៣៧លានដុល្លារ) និងចំនូលមូលធន ១៦ពាន់លានរៀល (៤លានដុល្លារ) ។ ធៀបនឹងផែនការកំណត់ដោយច្បាប់ថវិកាឆ្នាំ២០០២ ចំណូលចរន្តបាន ៩៦% នៃផែនការ ។ បរិមាណនេះរួមទាំង ចំណូលពន្ធដែលបាន ៩៧% នៃផែនការ និងចំណូលមិនមែនពន្ធដែលបាន ៩២% នៃផែនការ ។

ចំពោះចំណូលពន្ធវិញ ការប្រមូលអាករលើផលរបរបានទាបបំផុត គឺត្រឹមតែ ៧៨% នៃផែនការ ចំណែកការប្រមូលពន្ធគយបាន ៩៩% នៃផែនការ ។ អាករលើតំលៃបន្ថែមដែលមានចំណែកធំជាងគេ (៤០%) ក្នុងចំណូលពន្ធសរុប គឺបាន ៨៩% នៃផែនការ ។

ចំពោះចំណូលមិនមែនពន្ធ អាជីវកម្មព្រៃឈើឃ្លាតពីផែនការខ្លាំងជាងគេ គឺបានតែ ៣២% នៃផែនការប៉ុណ្ណោះ ចំណែកពន្ធទេសចរណ៍បានត្រឹម ៧១% នៃផែនការ ។ ការប្រមូលចំណូលពីកូតា និងអាជ្ញាបណ្ណ័នាំចេញ សំរេចបាន ២៧លានដុល្លារ ឬ ១៣៣% នៃផែនការពីការនាំចេញវាយនភ័ណ្ឌទំហំ ១.៣៣៣លានដុល្លារនៅឆ្នាំ២០០២ ។

**ក្រាហ្វិក ៩. ការអនុវត្តន៍ចំណូលចរន្ត (ភាគរយនៃផែនការ) តាមរយៈពេលគិតជាខែ**

---

[១៧] ផ្អែកតាមទិន្នន័យបានពីរបាយការណ៍ប្រចាំខែ ស្តីពី "ការអនុវត្តន៍ថវិកាជាតិ" ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុកម្ពុជា ។




*ប្រភព: ទិន្នន័យពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ប៉ុន្តែតាមទិន្នន័យពីឆ្នាំមុនៗ ផែនការចំណូលតែងតែកំនត់ខ្ពស់មិនប្រាកដនិយមទេដែលច្រើនធ្វើឱ្យការប្រៀបធៀបរវាងចំណូលពិត និងផែនការមិនមានន័យអ្វី ។ ចំណូលថវិកាពិតបានប្រមូល មិនដែលបានដល់ផែនការកំណត់ដោយច្បាប់ថវិកាសោះ គឺទទួលបានជាមធ្យមត្រឹម ៩៤% នៃផែនការ ។ តាមការប្រៀបធៀបចំណូលពិត និងចំណូលក្នុងផែនការ (ក្រាហ្វិក ៩) គេឃើញមានចំណុចគួរចាប់អារម្មណ៍ពីរ ក្នុងការអនុវត្តន៍ថវិកា:

១. គំលាតរវាងចំណូលពិត និងចំណូលក្នុងផែនការ កាន់តែរួមតូចនៅពេលចុងឆ្នាំសារពើពន្ធខិតមកជិត ។ ឧទាហរណ៍ នៅឆ្នាំ២០០២ ក្នុងរយៈមួយខែដល់ខែមករា ចំណូលពិតមាន ៦% នៃផែនការ ក្នុងរយៈពេលបីខែដល់ខែមីនា វាកើនដល់ ២៣% នៃផែនការ, សំរាប់ ៦ខែដល់ខែមិថុនា វាកើនដល់ ៤៣% សំរាប់ ៩ខែដល់ខែកញ្ញា វាកើនដល់ ៦៩% និងសំរាប់ដប់ពីរខែដល់ខែធ្នូ វាកើនដល់ ៩៦% ។

២. យោងតាមទិន្នន័យពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លំនាំនៃការអនុវត្តន៍ថវិកាប្រចាំឆ្នាំនីមួយៗ វាមានរចនាសម្ព័ន្ធដូចគ្នា (ក្រាហ្វិក ៩) ។ ឧទាហរណ៍ ក្នុងរយៈមួយខែដំបូងដល់ខែមករា ចំណូលប្រមូលបាន ៧% នៃផែនការ, ក្នុងរយៈ៥ខែដល់ខែឧសភា ចំណូលប្រមូលបាន ៤០% នៃផែនការ ។ល។

ចំពោះចំណាយចរន្តវិញ កម្ពុជាចំណាយសរុប ២.៦១០ពាន់លានរៀល (៦៦៦លានដុល្លារ) រួមទាំងការកែតំរូវចំណាយផង ។ ចំណាយចរន្តមានទំហំ ១.៣៨២ពាន់លានរៀល (៣៥២លានដុល្លារ) ឬ ៨៥% នៃផែនការ ។ ក្នុងនេះ ចំណាយរដ្ឋបាលទូទៅមាន ២៧៥ពាន់លានរៀល ការពារនិងសន្តិសុខជាតិចំណាយ ៣៦៨ពាន់លានរៀល រដ្ឋបាលសង្គមកិច្ចចំណាយ ៤៣៧ពាន់លានរៀល និងរដ្ឋបាលសេដ្ឋកិច្ច ១៤២ពាន់លានរៀល ។

ទោះបីច្បាប់ថវិកាឆ្នាំ២០០២ ឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីគោលបំណងរដ្ឋាភិបាល ដើម្បីបង្កើនចំណាយសាធារណៈសំរាប់ប្រព័ន្ធអប់រំរហូតដល់ ២៨% ក្តី ក៏ចំណាយពិតមានត្រឹមតែ ២២០ពាន់លានរៀល (៥៦លានដុល្លារ) ឬ ៧៧% នៃផែនការ ។ តួលេខនេះខ្ពស់ជាងឆ្នាំ ២០០១ តែ ៥% ប៉ុណ្ណោះ ។ ក្នុងរយៈពេលដូចគ្នានេះ ចំណាយសំរាប់រដ្ឋបាលមហាផ្ទៃ ដែលស្ថិតក្នុងរដ្ឋបាលទូទៅ មានកំណើនជាងពីរដង ឬ ១៨១% នៃផែនការ ។

ចំនាយសាធារណៈផ្សេងទៀត ដែលរួមចំណែកធ្វើឱ្យឱនភាពធំលើសផែនការគឺមានៈ

- ក្រុមប្រឹក្សារដ្ឋមន្ត្រី ១៨៤% នៃផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១៦៣% នៃផែនការ
- ក្រសួងផែនការ ១០៨% នៃផែនការ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ២៦៣% នៃផែនការ
- អាជ្ញាធរសវនកម្មជាតិ ១០២% នៃផែនការ និង
- ឧបត្ថម្ភធនដល់ខេត្ត និងក្រុង ១១១% នៃផែនការ

ចំណាយមូលធននៅឆ្នាំ២០០២ មាន ១.១៤៩ពាន់លានរៀល (២៩៣លានដុលារ) ត្រូវជា ១១១% នៃផែនការ ។ ចំណាយសំរាប់គំរោងធ្វើហិរញ្ញប្បទានដោយជំនួយពីក្រៅប្រទេសមានទំហំដល់ ៨៦១ពាន់លានរៀល (២២០លានដុល្លារ) គឺខ្ពស់ច្រើនជាងផែនការដែលបានកំណត់ត្រឹម ៧០០ពាន់លានរៀល (១៧៧លានដុល្លារ) ។

ការអនុវត្តន៍ចំនាយថវិកាចរន្ត ធៀបនឹងផែនការកំណត់ក្នុងច្បាប់ថវិកា បង្ហាញនូវរចនាសម្ព័ន្ធ និងលំនាំជាមូលដ្ឋាន (ក្រាហ្វិក ១០) ដូចគ្នានឹងការអនុវត្តន៍ចំនូលចរន្តដែរ ។

**ក្រាហ្វិក ១០. ការអនុវត្តន៍ចំណាយចរន្ត (ភាគរយនៃផែនការ) តាមរយៈពេលគិតជាខែ**




*ប្រភព: ទិន្នន័យពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ២.៥. រូបិយវត្ថុ និងអតិផរណា

### *២.៥.១. ការផ្គត់ផ្គង់រូបិយវត្ថុ*

បន្ទាប់ពីការអនុម័តគោលនយោបាយរឹតបន្តឹងនៅឆ្នាំ២០០១ ធនាគារជាតិនៃកម្ពុជាបានបន្ធូរសម្ពាធរូបិយវត្ថុនៅឆ្នាំ២០០២ ។ បរិមាណប្រាក់រៀលដែលមានទាំងប្រាក់រៀលក្រៅធនាគារ និងប្រាក់រៀលក្នុងគណនីបញ្ញើនៅធនាគារ កើន ៣៣.៥% ត្រូវជា ៨៨៨ពាន់លានរៀលនៅចុងឆ្នាំ២០០២ ធៀបនឹងកំណើន ១៤% នៅឆ្នាំ២០០១ ។ ក្នុងពេលជាមួយគ្នា ប្រាក់បញ្ញើជារូបិយវត្ថុបរទេស ដែលតំណាងឱ្យមួយភាគធំនៃការផ្គត់ផ្គង់រូបិយវត្ថុនៅក្នុងប្រទេសកើនដល់ ៥០៨លានដុល្លារនៅចុងឆ្នាំ២០០២ ឬ ៣០% ច្រើនជាងកាលពីមួយឆ្នាំមុន ។ រូបិយវត្ថុ

ទូទៅរបស់កម្ពុជា (M2) ដែលរួមមានប្រាក់បញ្ញើជារៀល និងជារូបិយវត្ថុបរទេស (គិតចេញជារៀលវិញ) កើនដល់ ២.៨៨៨ពាន់លានរៀល (៧៣៤លានដុល្លារ) នៅចុងឆ្នាំ២០០២ ឬ ៣១% ច្រើនជាងឆ្នាំ២០០១ ។

កំណើនទឹកប្រាក់រៀលនៅក្នុងរូបិយវត្ថុទូទៅ (M2) របស់កម្ពុជា គឺបណ្តាលជាចំបងពីការបោះពុម្ពសាច់ប្រាក់បន្ថែមដោយធនាគារកណ្តាល ។ ពីខែធ្នូ ឆ្នាំ២០០១ ដល់ខែធ្នូ ឆ្នាំ២០០២ ធនាគារកណ្តាលបោះពុម្ពប្រាក់រៀលបន្ថែមចំនួន ១៨៧ពាន់លានរៀល ធ្វើឱ្យស្តុកសរុបកើនដល់ ៨០៣ពាន់លានរៀលនៅចុងឆ្នាំ២០០២ ។ ធៀបនឹងចុងឆ្នាំ២០០១ ការបញ្ចេញសាច់ប្រាក់សរុបដោយធនាគារកណ្តាលកើន ៣០% គឺលឿនជាងក្នុងរយៈពេលពីឆ្នាំ២០០០ ដល់ឆ្នាំ ២០០១ ដែលមានកំណើន ១៦% ។ បរិមាណប្រាក់រៀលក្រៅធនាគារ ឬកំពុងធ្វើចរាចរកើនដល់ ៧៦៦ពាន់លានរៀលនៅចុងឆ្នាំ២០០២ ឬ ៣៣% ច្រើនជាងមួយឆ្នាំមុន ។

ដោយហេតុថាឥណទេយ្យរបស់ធនាគារកណ្តាលលើរដ្ឋាភិបាល និងលើប្រាក់បញ្ញើនៅធនាគារប្រាក់បានធ្លាក់ចុះពីឆ្នាំរវាងឆ្នាំ២០០១ ដល់ឆ្នាំ២០០២[១៨] ដូច្នេះការបញ្ចេញសាច់ប្រាក់ទៅក្នុងចរាចរទីផ្សារ គួរទាក់ទិនយ៉ាងជិតស្និទ្ធទៅនឹងកំណើនដ៏ខ្ពស់នៃទ្រព្យសកម្មបរទេសនៅធនាគារកណ្តាល និង/ឬកំណើនអចលនទ្រព្យនៃធនាគារកណ្តាល ។ យោងតាមធនាគារកណ្តាល ទ្រព្យសកម្មបរទេសនៅធនាគារកណ្តាលកើន ៣១% ពី ៦៩៦លានដុល្លារនៅឆ្នាំ ២០០១ ដល់ ៩១៤លានដុល្លារនៅឆ្នាំ២០០២ ។ ក្នុងរយៈពេលដដែលអចលនទ្រព្យនៅធនាគារកណ្តាលកើនពី ៧៣ពាន់លានរៀលនៅឆ្នាំ២០០១ ដល់ ១៤១ពាន់លានរៀលនៅឆ្នាំ ២០០២ ។ ការរីកធំនៃរូបិយវត្ថុទូទៅ (M2) ក៏ជាប់ទាក់ទងផងដែរជាមួយកំណើនលឿននៃបរិមាណប្រាក់បញ្ញើជារូបិយប័ណ្ណដែលមានសមាមាត្រធំជាងគេគឺ ៧០% នៃរូបិយវត្ថុទូទៅ (M2) ។ នៅចុងឆ្នាំ២០០២ រូបិយប័ណ្ណផ្ញើនៅធនាគារបញ្ញើប្រាក់កើន ៣០% ឡើងដល់ ៥០៩លានដុល្លារ ធៀបនឹងកំណើន ២១% នៅឆ្នាំ២០០១ ។ ដោយហេតុថាធនាគារកណ្តាលមិនបោះពុម្ព

---

[១៨] ទិន្នន័យពីធនាគារជាតិនៃកម្ពុជា: របាយការណ៍ប្រចាំខែ ។

រូបិយប័ណ្ណទេ ដូច្នេះកំណើនក្នុងប្រាក់បញ្ញើជារូបិយប័ណ្ណត្រូវជាប់ទាក់ទងនឹងកត្តាដូចខាងក្រោម ដែលតំណាងឱ្យប្រភពរូបិយប័ណ្ណផ្សេងៗគ្នា:

- ការលូតលាស់ក្នុងការនាំចេញទំនិញនិងសេវារបស់កម្ពុជា ជាពិសេស ផលិតផលកាត់ដេរ និងទេសចរណ៍
- ការលូតលាស់នៃវិនិយោគផ្ទាល់ពីបរទេស
- ជំនួយបរទេស
- ការផ្ទេរប្រាក់ឯកជន និង
- ការផ្ទេរសាច់ប្រាក់ជារូបិយប័ណ្ណដែលមានកាន់កាប់ទៅដាក់ក្នុងខ្ទង់បញ្ញើ ។ នៅដើមឆ្នាំ២០០១ បរិមាណប្រាក់ដុល្លារធ្វើចរាចរឡើងដល់ប្រហែល ៣ពាន់លានដុល្លារ[១៩] ។

### *២.៥.២. អត្រាការប្រាក់*

ចាប់ពីឆ្នាំ១៩៩៦ មក ធនាគារនៅកម្ពុជាបានកាត់បន្ថយអត្រាការប្រាក់ជាបន្តបន្ទាប់ចំពោះកំចីរូបិយប័ណ្ណ ជាពិសេសប្រាក់ដុល្លារពី ១៨.៨% នៅឆ្នាំ១៩៩៦ ដល់ ១៦.២% នៅឆ្នាំ២០០២ ។ ប៉ុន្តែធៀបនឹងថៃ និងវៀតណាម កម្ពុជានៅតែទារអត្រាការប្រាក់ខ្ពស់ជាងគេចំពោះកំចីជារូបិយប័ណ្ណ ។ ជាទូទៅ ធនាគារនៅថៃទារអត្រាការប្រាក់កំរៃទាបជាងគេ គឺ ៦.៨៨% នៅឆ្នាំ២០០២ ហើយបន្ទាប់មក វៀតណាមដែលទារអត្រាការប្រាក់ ៩.១% នៅឆ្នាំ២០០២ (ក្រាហ្វិក ១១) ។

### ក្រាហ្វិក ១១. អត្រាការប្រាក់ចារិកលើកំចីនៅកម្ពុជា ថៃ និងវៀតណាម

១៩ Zamaróczy, M. d. & Sa, S. (2002) ការកែតំរូវម៉ាក្រូសេដ្ឋកិច្ច ក្នុងសេដ្ឋកិច្ចដុល្លារូបនីយកម្មកំរិតខ្ពស់: ករណីកម្ពុជា, ឯកសារពិភាក្សា IMF (WP/02/92) ។




*ប្រភព: ធនាគារជាតិនៃកម្ពុជា និង IMF*

ពិនិត្យតាមគោលការណ៍ហិរញ្ញវត្ថុ អត្រាការប្រាក់ខ្ពស់ចំពោះកំចីនៅកម្ពុជា ដែលមាន ៩៥% នៃឥណទានសរុបបានបង់ជាប្រាក់ដុល្លារ វាធ្វើឱ្យការវិនិយោគទុននៅកម្ពុជាមិនសូវមានលក្ខណៈទាក់ទាញទេ បើធៀបនឹងថៃ ឬវៀតណាម ។ ជារឿយៗគេវែកញែកថា អត្រាការប្រាក់ខ្ពស់ធ្វើឱ្យវិនិយោគមានហានិភ័យខ្ពស់ ហើយធនាគារក៏មានចំណាយប្រតិបត្តិការខ្ពស់ ដោយសារចំណាយរដ្ឋបាលខ្ពស់ ហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ និងកត្តាផ្សេងៗទៀត[២០] ។ ឧទាហរណ៍ នៅខែមករា ឆ្នាំ២០០២ អេស៊ីលីដា ដែលជាធនាគារឯកទេសមួយនៅកម្ពុជា បានទារអត្រាការប្រាក់ខ្ពស់បំផុតដល់ ២៤% លើកំចីប្រាក់ដុល្លារ បើធៀបនឹងធនាគារផ្សេងទៀត ដូចជា ធនាគារពាណិជ្ជក្រៅប្រទេស និងធនាគារកាណាឌីយ៉ាដែលទារត្រឹមតែ ១៨% ។ មូលហេតុសំខាន់គឺ កំចីរបស់អេស៊ីលីដា ដែលមានទឹកប្រាក់តូចជាង គឺមានហានិភ័យខ្ពស់ជាង និង ចំណាយធ្វើប្រតិបត្តិការខ្ពស់ជាងកំចីដូចធម្មតា ។

[២០] ចំពោះបរិយាកាសពាណិជ្ជកម្ម វិស័យធនាគារនៅកម្ពុជា បានប្រឈមនឹងបញ្ហាដូចគ្នា ទាំងសហគ្រិន ផលិតកម្ម និងសេវាកម្ម ។ ពត៌មានលំអិតស្តីពីពាណិជ្ជកម្មនៅក្នុងវិស័យឯកជននៅកម្ពុជា សូមអាន Sok, H. & Acharya, S. (2002): *របាយការសេដ្ឋកិច្ចប្រចាំឆ្នាំ២០០២ របស់ វិបសអ* ។

អត្រាការប្រាក់ខ្ពស់បែបនេះ ជំរុញឱ្យអ្នកវិនិយោគកម្ពុជាស្វែងរកប្រភពមូលធនផ្សេងទៀត ដើម្បីធ្វើវិនិយោគ ។ នៅឆ្នាំ២០០២ ២៩% នៃវិនិយោគក្នុងវិស័យសំណង់ប្រើទុនបានពីឥណទានផ្តល់ដោយធនាគារកម្ពុជា គឺកើនពីកំរិត ១៤% នៅឆ្នាំ២០០១[២១] ។

**ក្រាហ្វិក ១២. អត្រាការប្រាក់ (%) ចំពោះប្រាក់បញ្ញើនៅកម្ពុជាវៀតណាម និងថៃ**




*ប្រភព: ធនាគារជាតិនៃកម្ពុជា និង IMF*

ដូចករណីអត្រាលើកំចីដែរ ធនាគារកម្ពុជាបានកាត់បន្ថយអត្រាការប្រាក់ជាបន្តបន្ទាប់លើប្រាក់បញ្ញើជារៀលពី ៨,៨% នៅឆ្នាំ១៩៩៦ ដល់ ២,៥% នៅឆ្នាំ២០០២ (ធៀបនឹង ៦,៥% ចំពោះប្រាក់បញ្ញើជាដុងនៅវៀតណាម និង ២% ចំពោះប្រាក់បញ្ញើជាបាតនៅថៃ (ក្រាហ្វិក ១២) ។

នៅពេលគិតចូលនូវអត្រាអតិផរណាលើរូបិយវត្ថុក្នុងស្រុក[២២] ធនាគារកម្ពុជាផ្តល់អត្រាការប្រាក់ពិតអវិជ្ជមាន -០,៨% នៅឆ្នាំ២០០២ ចំណែកថៃផ្តល់អត្រា ១,៤% និងវៀតណាមផ្តល់ ២,៧%[២៣] ។ ជាលទ្ធផល គឺមានការលើកទឹកចិត្តតិចតួចណាស់ដល់ការមានប្រាក់បញ្ញើជា

---

[២១] របាយការណ៍សេដ្ឋកិច្ចកម្ពុជាប្រចាំខែរបស់ វបសអ ខែឧសភា ឆ្នាំ២០០៣ ។

[២២] អត្រាអតិផរណានៅកម្ពុជានៅឆ្នាំ២០០២ (រូបិយវត្ថុក្នុងស្រុក) គិតជាមធ្យម ៣,៣% ចំណែកថៃកើន ០,៦% និងវៀតណាម មាន ៣,៨% ។ សូមអាន IMF ស្ថិតិហិរញ្ញវត្ថុអន្តជាតិឆ្នាំ២០០២ ។

[២៣] ជាការស្មានថា អត្រាអតិផរណានៅប្រទេសទាំងបីមិនប្រែប្រួលធំដុំរវាងឆ្នាំ២០០២ និង២០០៣ ។

រៀល ។ ប្រាក់បញ្ញើជាដុល្លារនឹងនៅតែមានសមាមាត្រធំជាងជាបន្តទៀត បើសិនជាគ្មានការអនុវត្តន៍គោលនយោបាយរូបិយវត្ថុអ្វីផ្សេងទេ ។

### *២.៥.៣. អត្រាការប្រាក់*

សំរាប់មួយឆ្នាំ២០០២ កម្ពុជាមានកំណើនថ្លៃ ៣,៣% ធៀបនឹងកំរិត ០,៣% នៅឆ្នាំ ២០០១ ។ កត្តាចំបងគឺកំណើនថ្លៃដ៏ធំនៅក្នុង "ការស្នាក់នៅ និងផ្គត់ផ្គង់សាធារណៈ" ដែលកើន ៧,២% នៅឆ្នាំ២០០២ ធៀបនឹង ០,៩៨% នៅឆ្នាំ២០០១ ។ ថ្លៃម្ហូបអាហារដែលមានចំណែកធំជាងគេនៅក្នុងកន្ត្រកចំនាយប្រើប្រាស់ បានធ្លាក់ចុះរហូតតាំងពីខែកញ្ញា ឆ្នាំ២០០២ ។ នៅខែមករា ឆ្នាំ២០០៣ ថ្លៃអាហារធ្លាក់ចុះ ០,៨% ប៉ុន្តែនៅមានកំរិត ២,៧% ខ្ពស់ជាងឆ្នាំមុន ។ ផ្ទុយទៅវិញ ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍បានកើនបន្តបន្ទាប់ដោយមានកំណើន ៣,៨% ពីខែមករា ឆ្នាំ២០០២ ដល់ខែមករា ឆ្នាំ២០០៣ ។ មូលហេតុសំខាន់គឺ កំណើន ៩% នៃថ្លៃម៉ាស៊ូតពីខែធ្នូ ឆ្នាំ២០០២ ដល់ខែមករា ឆ្នាំ២០០៣ ។ ការស្ទុះឡើងនេះឆ្លុះបញ្ចាំងពីកំណើនថ្លៃផលិតផលប្រេងនៅទីផ្សារអន្តរជាតិ ដែលជាប់ទាក់ទងនឹងភាពតានតឹងរវាង អាមេរិក និង អ៊ីរ៉ាក់ និង កូដកម្មរបស់ពលករនៅប្រទេសវេណេស៊ុយអេឡា ។

### *២.៥.៤. អត្រាប្តូរប្រាក់*

ប្រាក់រៀលឡើងថ្លៃបានខ្លះត្រឹម ០,២% ទល់នឹងដុល្លារសហរដ្ឋអាមេរិក ដោយប្តូរបាន ៣.៩១៨រៀល/ដុល្លារនៅឆ្នាំ២០០២ ធៀបនឹង ៣៩២៤រៀល/ដុល្លារនៅឆ្នាំ២០០១ ។ ប៉ុន្តែធៀបនឹងប្រាក់បាតថៃ វាធ្លាក់ថ្លៃ ៣,៧% គឺចុះពី ៨៨,៤រៀល/បាត ដល់ ៩១,៣៛/បាត ។

មានមូលហេតុពីរដែលប្រាក់រៀលឡើងថ្លៃទល់នឹងដុល្លារគឺ ទី១) តំរូវការប្រាក់រៀលច្រើននៅត្រីមាសទី១ ឆ្នាំ២០០២ និង ទី២) ការចុះខ្សោយជាទូទៅនៃប្រាក់ដុល្លារ ។ ការបោះឆ្នោតឃុំសង្កាត់នៅខែកុម្ភៈ ឆ្នាំ២០០២ បណ្តាលឱ្យមានតំរូវការប្រាក់រៀលច្រើន ។ ដោយហេតុថា សេដ្ឋកិច្ចកម្ពុជាធ្វើដុល្លារូបនីយកម្មកំរិតខ្ពស់ ដូច្នេះវាធ្វើឱ្យអត្រាប្តូរប្រាក់ពីដុល្លារទៅរៀលបានខ្ពស់ជាងពីប្រាក់បាតទៅរៀល ។

ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០២ តំលៃមធ្យមប្រចាំឆ្នាំនៃប្រាក់រៀលធៀបនឹងដុល្លារប្រែប្រួលតិចតួចណាស់ (សូមអានឧបសម្ព័ន្ធ: តារាង១) គឺឡើងថ្លៃ ឬចុះថ្លៃប្រហែល ១% ។ ជាទូទៅ ការប្រែប្រួលតិចតួចក្នុងអត្រាប្តូរប្រាក់ គេតែងបកស្រាយថា ប្រាក់រៀលមានលំនឹង ប៉ុន្តែទស្សនៈបែបនេះអាចយកមកវែកញែកជំទាស់បាននៅឡើយទេ ។ លំនឹងនៃរូបិយវត្ថុ ក៏មានជាប់ទាក់ទងនឹងកត្តាបីថែមទៀតយ៉ាងតិចៈ

- តួនាទីធនាគារកណ្តាលក្នុងការគ្រប់គ្រងបរិមាណសាច់ប្រាក់ ដែលតាមធម្មតាតែងអនុវត្តតាមរយៈទំហំធនបំរុង និងអត្រាការប្រាក់
- គណនីចរន្តដែលពឹងផ្អែកយ៉ាងខ្លាំងលើការនាំចេញ និងលំហូរចូលមូលធន
- ថវិកាសាធារណៈដែលតំណាងឱ្យលទ្ធភាពនៃរដ្ឋាភិបាល ដើម្បីធ្វើអន្តរាគមន៍ក្នុងសេដ្ឋកិច្ច

ក្នុងបរិបទបច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាមិនអាចគ្រប់គ្រងបរិមាណសាច់ប្រាក់ឱ្យបានសក្តិសិទ្ធិទេ ពីព្រោះមានបញ្ហាដុល្លារូបនីយកម្ម ហើយក៏មានលទ្ធផលដូចតទៅ:

- ធនាគារជាតិកម្ពុជាមិនអាចអនុវត្តបានច្រើនទេនូវគោលនយោបាយអត្រាការប្រាក់ ។ ធនាគារជាតិត្រូវពឹងលើធនបំរុងបរទេស (ដែលពឹងផ្អែកជាចំបងលើជំនួយបរទេស) ដើម្បីគ្រប់គ្រងប្រាក់រៀលដែលមានប្រហែល ៣០% នៃរូបិយវត្ថុទូទៅ (M2) ។ ជាលទ្ធផល ធនាគារកណ្តាលមានឧបករណ៍សំខាន់តែមួយគឺ "ការប្រើធនបំរុងបរទេស" សំរាប់ធ្វើឱ្យអត្រាប្តូរប្រាក់រៀល/ដុល្លារមានលំនឹង ។ ដោយហេតុថាប្រភពធនបំរុងបរទេសកន្លងមកគ្មានលំនឹងល្អ ដូច្នេះ ឧបករណ៍ខាងរូបិយវត្ថុនៃ "ការប្រើធនបំរុងបរទេស" ក៏មិនខ្លាំងប៉ុន្មានដែរ ។ ការទិញ និងលក់ប្រាក់ដុល្លារដោយធនាគារកណ្តាល អាចជួយទប់ស្កាត់ភាពរំជើបរំជួលក្នុងទីផ្សារប្តូរប្រាក់ ប៉ុន្តែមិនអាចដោះស្រាយការទន់ខ្សោយនៃប្រាក់រៀលនៅក្នុងទីផ្សារប្តូរប្រាក់បានទេ ។
- រូបិយប័ណ្ណបរទេសមានចំនែកធំជាងគេគឺ ៧០% នៃរូបិយវត្ថុទូទៅ ។ បើសិនគេគិតបញ្ចូលទាំងប្រាក់ដុល្លារនៅក្រៅធនាគារ រូបិយប័ណ្ណនឹងមានចំណែកធំជាងនេះ

ទៀត ។ គឺបានន័យថា ធនាគារកណ្តាលមានការគ្រប់គ្រងតិចតួចបំផុតលើរូបិយវត្ថុទូទៅ ។ រឿងនេះតួសរំលេចពីជំហរដ៏ខ្សោយនៃធនាគារកណ្តាលក្នុងការដឹកនាំអនុវត្តគោលនយោបាយរូបិយវត្ថុ ។

គណនីចរន្តរបស់កម្ពុជា ដោយមិនគិតពីការផ្ទេរជាផ្លូវការផ្សេងៗ មានសមតុល្យអវិជ្ជមានជានិច្ច (សូមអានឧបសម្ព័ន្ធ: តារាង ៨) ។ នៅកម្ពុជា គ្មានទីផ្សារហិរញ្ញវត្ថុអ្វីដែលអាចជំរុញលំហូរចូលមូលធនមកក្នុងប្រទេសទេ ។ ក្នុងបរិបទបច្ចុប្បន្ន ការនាំចេញរបស់កម្ពុជាជាទូទៅមិនសូវមានភាពប្រកួតប្រជែងទេ ហើយបន្តចុះខ្សោយទៀតផង ។ ជាវិបាក កម្ពុជាគ្មានប្រភពដុល្លារមានស្ថិរភាពល្អ សំរាប់ជួយធានាតំលៃប្រាក់រៀលទេ ។ ម្យ៉ាងទៀត ថវិកាសាធារណៈកម្ពុជា មានឱនភាពច្រើនឆ្នាំហើយ ។ ឱនភាពនេះត្រូវបានផ្តល់ហិរញ្ញប្បទានដោយជំនួយបរទេសសឹងតែទាំងស្រុង ។ ជាលទ្ធផល រដ្ឋាភិបាលមានលទ្ធភាពមានកំរិតដើម្បីធ្វើអន្តរាគមន៍ទៅក្នុងសេដ្ឋកិច្ចនៅពេលមានវិបត្តិផ្សេងៗ ។

## ២.៦. ជញ្ជីងទូទាត់

### *២.៦.១. គណនីចរន្ត*

គណនីចរន្តរបស់កម្ពុជា ដែលរួមមានជញ្ជីងពាណិជ្ជកម្ម តុល្យភាពសេវាកម្ម តុល្យភាពចំណូល និងការផ្ទេរចរន្ត, គឺមានសមតុល្យវិជ្ជមានតាំងពីឆ្នាំ២០០០មក នៅពេលគិតបញ្ចូលទាំងការផ្ទេរជាផ្លូវការផង ។ ប៉ុន្តែវាមិនវិជ្ជមានទេ នៅពេលការផ្ទេរជាផ្លូវការមិនត្រូវបានគិតបញ្ចូល (សូមមើលឧបសម្ព័ន្ធ: តារាង ៨) ។

កំណើនការនាំចូល វ៉ាលុបលើកំណើនការនាំចេញដែលនាំមុខដោយការនាំចេញផលិតផលវាយនភ័ណ្ឌ និងបង្កកំណើនឱនភាពជញ្ជីងពាណិជ្ជកម្ម ពី ២២៦លានដុល្លារនៅឆ្នាំ២០០១ ដល់ ២៨២លានដុល្លារនៅឆ្នាំ២០០២ ។ ការលូតលាស់ជាវិជ្ជមានក្នុងឧស្សាហកម្មទេសចរណ៍នៅឆ្នាំ២០០២ បានបង្កើនចំនូលនៃអ្នកផ្តល់សេវាក្នុងស្រុកដល់ ២៨៩លានដុល្លារ គឺកើនពី ២៥៣លានដុល្លារនៅឆ្នាំ២០០១ ។ នៅពេលជាមួយគ្នា ការប្រើប្រាស់សេវាបរទេសរបស់កម្ពុជាឡើងដល់ ៣០៥លានដុល្លារ គឺកើនពី ២៧៣លានដុល្លារនៅឆ្នាំ២០០១ ។ ជាវិបាក

តុល្យភាពសេវាកម្មរបស់កម្ពុជា បន្តមានឱនភាព ប៉ុន្តែវាថយចុះបន្តិចពី ២០លានដុល្លារនៅឆ្នាំ២០០១ មកត្រឹម ១៦លានដុល្លារនៅឆ្នាំ២០០២ ។

តុល្យភាពចំណូល ដែលតំណាងឱ្យការទទួលប្រាក់ពីជនកម្ពុជាធ្វើការនៅក្រៅប្រទេស និងការបង់ប្រាក់ឱ្យអ្នកធ្វើការបរទេសនៅក្នុងប្រទេសកម្ពុជា ព្រមទាំងការបង់ការប្រាក់ មានការរីកចំរើនបន្តិចបន្តួច ។ ឱនភាពធ្លាក់ចុះពី ៤១លានដុល្លារនៅឆ្នាំ២០០១ មកត្រឹម ៣៩លានដុល្លារនៅឆ្នាំ២០០២ ។

ផ្ទុយពីជញ្ជីងពាណិជ្ជកម្ម, តុល្យភាពសេវាកម្ម និងតុល្យភាពចំណូល តុល្យភាពនៃការផ្ទេរចរន្ត ដែលមានគិតទាំងការផ្ទេរផ្លូវការនិងការផ្ទេរឯកជន និងជំនួយបរទេសក្នុងទំរង់ជាជំនួយឥតសំណង មានអតិរេកចាប់តាំងពីឆ្នាំ១៩៩៣ ដោយសារការបន្តផ្តល់ជំនួយឥតសំណងពីខាងក្រៅ ។ ជំនួយឥតសំណងកើនដល់ ៣៥៣លានដុល្លារនៅឆ្នាំ២០០២ ឬ ២,៦% ច្រើនជាងឆ្នាំ២០០១ ។ ក្នុងនេះ ២៨០លានដុល្លារទទួលបានពីការផ្ទេរផ្លូវការសុទ្ធ ហើយបរិមាណនៅសល់ ៧៣លានដុល្លារ ទទួលបានពីការផ្ទេរឯកជនសុទ្ធ ។

អតិរេកនៅក្នុងតុល្យភាពនៃការផ្ទេរចរន្ត បានប៉ះប៉ូវលើសពីគ្រប់ដល់ឱនភាពនៅក្នុងតុល្យភាពលំអិតផ្សេងៗទៀត (sub-balance) នៃគណនីចរន្តដែលធ្វើឱ្យគណនីចរន្តទូទៅ (overall current account) បូកទាំងការផ្ទេរផ្លូវការផងមានអតិរេក ។ ប៉ុន្តែ អតិរេក ១៥លានដុល្លារនេះ វាមានកំរិត ៧៤% ទាបជាងអតិរេកនៅឆ្នាំ២០០១ ហើយមូលហេតុចំបងគឺ កំណើនលឿនជាងនៃឱនភាពជញ្ជីងពាណិជ្ជកម្ម ដោយសារកំណើនការនាំចូល និងកំណើនយឺតជាងនៃការនាំចេញ ។

### *២.៦.២. គណនីហិរញ្ញវត្ថុ*

ដោយសារការធ្លាក់ចុះក្នុងវិនិយោគផ្ទាល់ពីបរទេសនៅឆ្នាំ២០០២ នៅក្នុងគណនីហិរញ្ញវត្ថុកម្ពុជា លំហូចូលនៃកំចីផ្លូវការកាន់តែមានចំណែកចំបងឡើងៗ ជាពិសេសហិរញ្ញវត្ថុឧបត្ថម្ភគំរោង (ដោយមិនគិតកំចីពី IMF ផងទេ) ។ នៅឆ្នាំ២០០២ កម្ពុជាទទួលបានការបើកផ្តល់កំចី

ផ្លូវការ ១៥០លានដុល្លារ ឬ ៥៨% ច្រើនជាង ២០០១ ។ ក្នុងឆ្នាំដដែល កម្ពុជាបានសង កំចីវិញតែ ៩លានដុល្លារ ។ ជាលទ្ធផលលំហូចូលសុទ្ធនៃមូលធន ក្នុងទំរង់ជាកំចីផ្លូវការ មាន ១៤១លានដុល្លារ ឬ ៦២% ច្រើនជាងឆ្នាំ២០០១ ។

វិនិយោគសុទ្ធក្រៅផ្លូវការ ដែលជាលទ្ធផលនៃលំហូចូលនិងចេញក្រៅកម្ពុជា បានធ្វើឱ្យ ខូចខាតដល់មូលដ្ឋានហិរញ្ញវត្ថុសំរាប់ពាណិជ្ជកម្មអន្តរជាតិកម្ពុជានៅឆ្នាំ២០០២ ។ វិនិយោគផ្ទាល់ ពីបរទេសដែលជា "វិនិយោគក្រៅផ្លូវការ" ប្រភេទទី១ ចុះដល់ប្រហែល ៩៨លានដុល្លារធៀប នឹង ១១៣លានដុល្លារនៅឆ្នាំ២០០១ ។ វិនិយោគឯកជនផ្សេងទៀតដែល "វិនិយោគក្រៅផ្លូវការ" ក៏ធ្លាក់ចុះដែរ ផ្អែកតាមតួលេខប៉ាន់ស្មាននៃលំហូរចេញសុទ្ធ ១១៧លានដុល្លារនៅឆ្នាំ២០០២ ។

ទោះយ៉ាងនេះក្តី គណនីហិរញ្ញវត្ថុកម្ពុជា ដែលមានទាំងលំហូរចូល និងលំហូរចេញ ជា ផ្លូវការ និងក្រៅផ្លូវការ ឡើងដល់ ១២២លានដុល្លារនៅឆ្នាំ២០០២ ដែលកើនពី ៩៤លានដុល្លារ នៅឆ្នាំ២០០១ ។

សរុបមក ជាលទ្ធផលនៃការប្រតិបត្តិគណនីចរន្ត រួមទាំងការផ្ទេរជាផ្លូវការ និងការផ្ទេរ ក្នុងគណនីហិរញ្ញវត្ថុ លទ្ធផលសរុបនៃជញ្ជីងទូទាត់កម្ពុជា បង្ហាញនូវអតិរេកដែលស្ទុះឡើងដល់ ១៧២លានដុល្លារ ធៀបនឹង ៧៣លានដុល្លារនៅឆ្នាំ២០០១ ។ ដោយគិតទាំងការប្រើប្រាស់ ឥណទាន IMF ផង ធនបំរុងនៃធនាគារកណ្តាល កើនបាន ១៨៧លានដុល្លារពីឆ្នាំ២០០១ ដល់ ឆ្នាំ២០០២ ធៀបនឹងកំណើន ៩០លានដុល្លារ ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០១ ។

បើពិនិត្យពីទិន្នាការកន្លងមក ជញ្ជីងទូទាត់កម្ពុជាមានអតិរេកតាំងពីឆ្នាំ១៩៩៣ ។ ប៉ុន្តែ ក្នុងនេះភាគច្រើនគឺជាកំចី និងជំនួយឥតសំណងពីបរទេស ។

## ២.៧. ស្ថានភាពនៃភាពក្រីក្រ

យោងតាមក្រសួងផែនការកម្ពុជា និងអង្គការកម្មវិធីស្បៀងអាហារពិភពលោក អត្រាភាពក្រីក្រនៅកម្ពុជាមានកំរិត ៣៦,១%[២៤] នៅឆ្នាំ១៩៩៩ ។ ក្នុងពេលជាមួយគ្នា ចំណាយប្រើប្រាស់មធ្យមក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃគឺ ១.៦២៩រៀលនៅភ្នំពេញ, ១.២១៤រៀលនៅតំបន់ទីក្រុងផ្សេងទៀត និង ១.០៣៦រៀលនៅជនបទ ។ ធៀបនឹងឆ្នាំ១៩៩៧ គឺមានការធ្លាក់ចុះចំណាយប្រើប្រាស់ចារិករបស់ប្រជជននៅគ្រប់តំបន់ រួមទាំងនៅភ្នំពេញ តំបន់ទីក្រុងផ្សេងៗ និងតំបន់ជនបទ ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ១៩៩៩[២៥] ។

សំរាប់ឆ្នាំ២០០២ មិនអាចរកបានទិន្នន័យសំរាប់វាយតំលៃពីស្ថានភាពក្រីក្រនៅកម្ពុជាទេ ។ ប៉ុន្តែអង្កេតធ្វើជាទៀងទាត់ដោយ វបសអ បានផ្តល់រូបភាពខ្លះ ទោះបីមិនបានធំទូលាយក្តី អំពីស្ថានភាពក្រីក្រនៅក្នុងឆ្នាំប៉ុន្មានថ្មីៗ ដោយពិនិត្យពីចំណូលប្រចាំថ្ងៃរបស់កម្មករងាយរងគ្រោះ ។ យោងតាមអង្កេតទាំងនេះ ស្ថានភាពក្រីក្រដែលឆ្លុះបញ្ចាំងតាមរយៈចំណូលប្រចាំថ្ងៃរបស់កម្មករងាយរងគ្រោះ មានលក្ខណៈចំរុះនៅឆ្នាំ២០០២ ។

អង្កេតធ្វើដោយ វបសអ នៅភ្នំពេញ និងកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០០៣ បានបង្ហាញពីការលូតលាស់មិនស្មើគ្នា ក្នុងចំណូលប្រចាំថ្ងៃរបស់កម្មករងាយរងគ្រោះ ។ ធៀបនឹងខែវិច្ឆិកា ឆ្នាំ២០០២ ក្រុមពលករខ្លះមានកំណើនចំណូលប្រចាំថ្ងៃ ចំណែកក្រុមខ្លះទៀត គ្មានកំណើនទេ ។ ឧទាហរណ៍ អ្នកធាក់ស៊ីក្លូ អាចរកចំណូលប្រចាំថ្ងៃបាន ៩.២០០រៀល នៅខែកុម្ភៈ ឆ្នាំ២០០៣ គឺកើនបន្តិចពីកំរិត ៨.៨៧៨រៀលកាលពី៣ខែមុន ។ កំណើននេះ អាចមកពីកត្តារដូវកាល ដូចជា ចូលឆ្នាំចិនជាដើម ។ ប៉ុន្តែធៀបនឹងរយៈដូចគ្នាឆ្នាំ២០០២ ចំណូលប្រចាំថ្ងៃរបស់អ្នកធាក់ស៊ីក្លូធ្លាក់ចុះ ៤% បើគិតជាតួលេខពិត ។ មូលហេតុចំបងនៃការធ្លាក់ចុះនេះ គឺមានជនចំណាកស្រុកកាន់តែច្រើនចូលមកភ្នំពេញ ដោយសារគ្រោះរាំងស្ងួត និងទឹកជំនន់ធ្ងន់ធ្ងរនៅឆ្នាំ២០០២ ។ បន្ទាប់ពីមានកំណើននៅខែវិច្ឆិកា ឆ្នាំ២០០២ ចំណូលប្រចាំថ្ងៃអ្នករត់ម៉ូតូឌុប

[២៤] ក្រសួងផែនការ និង UNWFP (2002)៖ការប៉ាន់ស្មានអត្រាភាពក្រីក្រនៅកំរិតឃុំ នៅកម្ពុជា ។
[២៥] សូមអានតារាង២ ក្រសួងផែនការ និង UNWFP (2002)

ធ្លាក់ចុះវិញដល់ ១១.៤០០រៀលនៅខែកុម្ភៈ ឆ្នាំ២០០៣ គឺចុះពី ១២.០៧៥រៀលនៅខែវិច្ឆិកា ។ ធៀបនឹងខែកុម្ភៈ ឆ្នាំ២០០២ ចំណូលពិតរបស់ពួកគេធ្លាក់ចុះ កាន់តែច្រើនដល់ ២១% ដោយសារកំណើនថ្លៃប្រេងសាំង និងម៉ាស៊ូត ។

ធៀបនឹងលទ្ធផលអង្កេតខែវិច្ឆិកា ឆ្នាំ២០០២ ចំណូលប្រចាំថ្ងៃចារិករបស់អ្នកលីសែងកើនដល់ ៧.៦០០រៀលនៅខែកុម្ភៈ ឆ្នាំ២០០៣ ។ ប៉ុន្តែធៀបនឹងឆ្នាំមុន ចំណូលចារិករបស់ពួកគេធ្លាក់ចុះ ៧%[២៦] ។ ការធ្លាក់ចុះនេះបណ្តាលជាសំខាន់ដោយសារការជួសជុលផ្លូវ ឬការកសាងផ្លូវថ្មី បានជួយសំរួលដល់ការដឹកជញ្ជូនតាមបណ្តាខេត្ត ។ អ្នកលក់បន្លែតូចតាច ដែលភាគច្រើនមកពីខេត្ត មានចំនូលប្រចាំថ្ងៃពិតនៅខែកុម្ភៈ ឆ្នាំ២០០៣ កើន ១,១%ច្រើន ជាងខែវិច្ឆិកា ឆ្នាំ២០០២ និង ១៧% ច្រើនជាងកាលពីមួយឆ្នាំមុន ។ កំណើនការប្រើប្រាស់ បន្លែក្នុងពេលចូលឆ្នាំចិន និងចូលឆ្នាំខ្មែរ បានជួយបង្កើនចំណូលប្រចាំថ្ងៃរបស់ពួកគេ ។

អ្នកបំរើតាមហាងរកចំនូលប្រចាំថ្ងៃបាន ៤.៦០០រៀលនៅខែកុម្ភៈ ឆ្នាំ២០០៣ ធៀបនឹង ៤.០០០រៀលកាលពី៣ខែមុន ។ ក្នុងរយៈពេលដដែល ចំណូលប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែធ្លាក់ពី ៤.២១៩រៀលដល់ ៤.១៨០រៀល ។ ប៉ុន្តែធៀបនឹងខែកុម្ភៈ ឆ្នាំ២០០២ អ្នកស៊ីឈ្នួលធ្វើស្រែរកចំណូលប្រចាំថ្ងៃកើនបាន ៥% បើគិតជាតួលេខពិត ។ កំណើននេះបណ្តាលពីប្រជាជនក្មេងៗជាច្រើនបានធ្វើចំណាកស្រុកមកភ្នំពេញ ឬបណ្តាទីប្រជុំជនតាមខេត្ត ក្នុងខណៈតំរូវការអ្នកស៊ីឈ្នួលធ្វើស្រែបានកើនឡើង ។

អង្កេត វបសអ នៅខែកុម្ភៈ ឆ្នាំ២០០៣ បង្ហាញថា ចំណូលប្រចាំថ្ងៃរបស់កម្មករកាត់ដេរបន្តកើនឡើងដល់ ១០.១២៧រៀល/ថ្ងៃ ធៀបនឹង ១០.០៩៧រៀលនៅខែវិច្ឆិកា ឆ្នាំ២០០២ ។ ប្រាក់ខែមធ្យមរបស់កម្មករកាត់ដេរនៅខែកុម្ភៈ ឆ្នាំ២០០៣ ឡើងដល់ ៦៧,៥ដុល្លារ បូកទាំងប្រាក់បន្ថែមម៉ោងផង ។

[២៦] គិតជាតួលេខពិត ចំណូលប្រចាំថ្ងៃរបស់កម្មករលីសែងធ្លាក់ចុះ ៩% ។

## ២.៨. សេចក្តីសន្និដ្ឋាន និងការប្រមើលមើលឃើញពីអនាគត

ចំណែកកសិកម្មក្នុង ផសស សរុបបន្តធ្លាក់ចុះដល់ទាបជាង ៣០% នៅឆ្នាំ២០០២ ។ តាមមើលវិស័យកសិកម្មកម្ពុជា ហាក់ដូចកំពុងបាត់បង់ឋានៈចំបងគេដែលធ្លាប់មានជាប្រពៃណីក្នុងសេដ្ឋកិច្ច ។ នៅចំពោះមុខការថយចុះធនធានព្រៃឈើ និងនេសាទ ផលិតកម្មផលដំណាំកាន់តែមានតួនាទីសំខាន់ឡើង ។ ក្នុងបរិបទនេះ មានគោលនយោបាយពីរដែលត្រូវគូសរំលេចៈ ការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ និងជំរុះកម្មផលិតកម្មកសិកម្ម ។ ដោយមានជំនួយពីអង្គការអន្តរជាតិនានា រដ្ឋាភិបាលបានអនុវត្តវិធានការមួយចំនួនដ៏គួរឱ្យពេញចិត្តគឺមានទាំងការកែលំអហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជនបទ (ឧ. ផ្លូវ ប្រព័ន្ធស្រោចស្រព) និងការជំរុញផលិតកម្មដំណាំផ្សេងទៀត ដូចជា ដំឡូងមី និងស្វាយចន្ទី ។

ផ្ទុយពីការធ្លាក់ចុះចំណែកកសិកម្មនៅក្នុង ផសស សរុប, ចំណែកនៃឧស្សាហកម្ម និងសេវាកម្មបានកើនឡើង ។ រឿងនេះកើតឡើងជាសំខាន់ដោយសារការរីកធំធាត់យ៉ាងលឿនក្នុងវិស័យទេសចរណ៍ និងវាយនភ័ណ្ឌ ។ ឧស្សាហកម្មវាយនភ័ណ្ឌកម្ពុជាបានរីកលូតលាស់នៅលើមូលដ្ឋានកូតា និងកិច្ចព្រមព្រៀងដោយអនុគ្រោះផ្សេងៗ ជាពិសេសបានពីអាមេរិក និងអឺរ៉ុប ។ នៅក្រោយឆ្នាំ២០០៤ នៅពេលដែលកិច្ចព្រមព្រៀងសំរាប់គ្រឿងអំបោះគ្រប់មុខ (Multi-Fibre Arrangement: MFA) ដែលទាក់ទិននឹងពាណិជ្ជកម្មអន្តរជាតិលើផលិតផលវាយនភ័ណ្ឌត្រូវផុតកំណត់, ឧស្សាហកម្មវាយនភ័ណ្ឌកម្ពុជាដែលមានចំណែកធំជាងគេក្នុងការនាំចេញសរុបនឹងត្រូវប្រកួតប្រជែងជាមួយប្រទេសឯទៀតនៅលើមូលដ្ឋានស្មើភាពគ្នា ។ ផលប៉ះពាល់អវិជ្ជមាននៃការប្រកួតប្រជែងពេញកំលាំងបែបនេះចំពោះសេដ្ឋកិច្ចកម្ពុជា អាចសំរាលបានមួយកំរិតដោយការស្វែងរកមធ្យោបាយពង្រីកទីផ្សារនាំចេញ ។ ប៉ុន្តែនៅទីបំផុត កម្ពុជាត្រូវតែកែលំអភាពប្រកួតប្រជែងរបស់ខ្លួន ។ ទង្វើនេះទាមទារនូវការប្តេជ្ញាចិត្តគ្រប់បែបយ៉ាងអំពីរដ្ឋាភិបាលកម្ពុជា ដើម្បីពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងស្ថាប័ន សំដៅកែលំអបរិយាកាសវិនិយោគ និងពាណិជ្ជកម្ម ។

បន្ថែមលើយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចផ្តោតលើការនាំចេញ គេគួរផ្តល់អាទិភាពដល់បណ្តាតួអង្គ និងទីផ្សារក្នុងស្រុក ។ ជាការគួរពេញចិត្តណាស់ដែលរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមយកចិត្តទុកដាក់កាន់តែច្រើនដល់ការអភិឌ្ឍន៍ជនបទ តាមការកែលំអហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការជួយទ្រទ្រង់មីក្រូហិរញ្ញវត្ថុ និងការបង្កើតតំបន់ទេសចរណ៍ថ្មីៗ ដើម្បីបង្កើតបរិយាកាសមួយដែលអំណោយផលល្អដល់សហគ្រិនក្នុងស្រុក ។

ការចូលរួមគួរឱ្យកត់សំគាល់របស់វិស័យសាធារណៈក្នុងការអភិវឌ្ឍន៍ជនបទ ទាមទារឱ្យមានវិនិយោគសាធារណៈដ៏ច្រើនៗ ។ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនវិនិយោគតាំងពីឆ្នាំ១៩៩៨មក ទោះបីហាក់ដូចមានការធ្លាក់ចុះមួយនៅឆ្នាំ២០០២ ក្តី ។ ការប្រមូលចំណូលសាធារណៈគឺសំខាន់បំផុតដើម្បីផ្តល់ហិរញ្ញប្បទានដល់ចំណាយសាធារណៈ ។ ដូច្នេះហើយការអនុម័តកំណែទំរង់នានាខាងថវិកា គឺជាការសំខាន់ណាស់ ដូចជា អាករលើតំលៃបន្ថែមលើប្រេងម៉ាស៊ូត, ការប្រើក្រដាសស្អិតបញ្ជាក់ទិដ្ឋាការ (visa stickers), ការបង្កើតអង្គភាពបង់ពន្ធតូច និងមធ្យម, និងការអនុវត្តន៍បង់ប្រាក់ផ្ទាល់ទៅរតនាគារជាតិ ។

ប្រព័ន្ធរូបិយវត្ថុនៅតែទន់ខ្សោយ ។ ដុល្លារូបនីយកម្មនៃសេដ្ឋកិច្ចបន្តកាត់បន្ថយសមត្ថភាពធនាគារកណ្តាលក្នុងការអនុវត្តន៍គោលនយោបាយរូបិយវត្ថុ ។ ជាលទ្ធផល គោលនយោបាយខាងការប្រាក់ និងអត្រាប្តូរប្រាក់ មិនបានដើរតួនាទីគួរកត់សំគាល់ទេក្នុងការជំរុញកំណើនសេដ្ឋកិច្ច ។ កង្វះទំនុកចិត្តលើប្រាក់រៀល និងការប្រើប្រាស់ប្រាក់ដុល្លារជាទូទៅនៅក្នុងប្រតិបត្តិការសេដ្ឋកិច្ចសំខាន់ៗ វាមានន័យថា កម្ពុជាបន្តប្រឈមមុខនឹងភាពមិនប្រាកដប្រជា និងហានិភ័យ ក្នុងការផ្តល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ។

អនាគតសំរាប់សេដ្ឋកិច្ចកម្ពុជា ហាក់ដូចជាផុយស្រួយ ។ ដរាបណាគ្មានការប្តេជ្ញាចិត្តឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីលើកកំពស់ប្រភពនានានៃកំណើនក្នុងស្រុក សេដ្ឋកិច្ចនៅតែបន្តពឹងផ្អែកលើវិនិយោគផ្ទាល់ពីបរទេស និងការនាំចេញ ។ គេតែងគិតថា វិនិយោគផ្ទាល់ពីបរទេសនឹងផ្តល់ជាមូលធន និងបច្ចេកវិជ្ជាសំរាប់ការអភិវឌ្ឍន៍ រីឯការនាំចេញវាតំណាងឱ្យទីផ្សារសំរាប់ផលិតផលរបស់សាមីប្រទេស ។

ប៉ុន្តែ ការពឹងផ្អែកតែលើវិនិយោគផ្ទាល់ពីបរទេស និងការនាំចេញ អាចកាត់បន្ថយលទ្ធភាពទៅអនាគតក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ បញ្ហាស្នូលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចគឺមិនមែនវាយតំលៃថា តើវិនិយោគផ្ទាល់ពីបរទេស ឬការនាំចេញ វាអាចជួយជំរុញកំណើនសេដ្ឋកិច្ចបានមែនឬមិនបាននោះទេ ប៉ុន្តែត្រូវវាយតំលៃពីសមត្ថភាពធ្វើនិចលភាពរបស់ប្រទេសមួយដូចជាកម្ពុជា ដើម្បីទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និង/ឬធានាឱ្យមានទីផ្សារនាំចេញសំរាប់ជួយជំរុញកំណើនសេដ្ឋកិច្ច ។

ត្រូវមានទិសដៅគោលនយោបាយថ្មីមួយដែលផ្តល់អាទិភាពដល់សហគ្រិន និងទីផ្សារក្នុងស្រុក ទោះបីសក្តានុពលបច្ចុប្បន្នមានកំរិតក្តី ។ ជំហានដំបូងដ៏សំខាន់ គឺការកែលំអបរិយាកាសសំរាប់សហគ្រិនក្នុងស្រុក តាមការកសាងរៀបចំខាងស្ថាប័ន ហេដ្ឋារចនាសម្ព័ន្ធ និងអភិបាលកិច្ចល្អ ។ ការឈានទៅមុខយ៉ាងរឹងប៉ឹងក្នុងកំណែទំរង់វិស័យហិរញ្ញវត្ថុ ក៏សំខាន់ណាស់ដែរ ដើម្បីបង្កើតយន្តការនានាសំរាប់ការធ្វើអន្តរការីកម្មខាងហិរញ្ញវត្ថុដ៏សក្តិសិទ្ធិ ជួយដល់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឯកជនក្នុងស្រុក ។ វាមានលទ្ធភាពច្រើនដែរ ដែលកំណែទំរង់បែបនេះអាចជួយពន្លឿនដំណើរការបដិដុល្លារូបនីយកម្មនៃសេដ្ឋកិច្ច ។

# ឯកសារយោង


Cambodia Development Resource Institute (2003): Monthly Flash Report (May 2003).

Hing, T. (2003): Cambodia's Investment Potential.

International Monetary Fund (2002): International Financial Statistics 2002.

McKenney, B. & Prom, T. (2002): Natural Resources and Livelihoods in Cambodia. CDRI's Working Paper No. 23.

Ministry of Agriculture, Forestry and Fisheries (2002): Agricultural Statistics 2001-2002.

Ministry of Agriculture, Forestry and Fisheries (2003): Official Report on Agriculture, Forestry and Fisheries 2002-2003.

Ministry of Commerce (2002): Cambodia - Integration and Competitiveness Study.

Ministry of Economy and Finance: Monthly Report on “State Budget Implementation".

Ministry of Planning & UNWFP (2002): Estimation of Poverty Rates at Commune-Level in Cambodia.

Ministry of Tourism (2002): Tourism Statistical Report - Year Book 2002.

National Bank of Cambodia: Monthly Report.

Sok, H. & Acharya, S. (2002): Cambodia's Annual Economic Review - 2002, CDRI.

Zamaroczy, M. d. & Sa, S. (2002): Macroeconomic Adjustment in a Highly Dollarised Economy - the Case of Cambodia. IMF Working Paper (WP/02/92).

# ជំពូកទី ៣

# ជំណាំលក់យកប្រាក់៖

# ផលិតកម្ម ម៉ាឃីទីង និងពាណិជ្ជកម្ម

# *ការទាយតំលៃពីដំបូង*

## ៣.១. សេចក្តីផ្តើម

កំណើនផ្នែកសេវាកម្ម និងឧស្សាហកម្មរបស់ប្រទេសកម្ពុជាក្នុងរយៈពេលមធ្យម ប្រហែលមិនអាចលឿនទាន់គ្នានឹងកំណើនកំលាំងពលកម្មចំណូលថ្មីក្នុងកំរិត ២០០.០០០នាក់/ឆ្នាំនោះទេ ។ ហេតុនេះ ប្រជាជនកម្ពុជាភាគច្រើនបន្តរកចិញ្ចឹមជីវិតដោយពឹងលើការងារកសិកម្ម ។ ជាលទ្ធផល ការអភិវឌ្ឍន៍វិស័យកសិកម្ម គឺជាអាទិភាពចំបងគេក្នុងរបៀបវារៈរបស់រដ្ឋាភិបាល ដូចមានចែងនៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី២ (២០០១-២០០៥) និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជាតិ (២០០៣-២០០៥) ។

ក្នុងវិស័យកសិកម្ម ប្រទេសកម្ពុជាមានការរីកចំរើនគួរកត់សំគាល់ ។ ឧទាហរណ៍ ទិន្នផលស្រូវកើនពី ១,៣តោន ទៅ ២,១តោន/ហ.ត នៅចន្លោះឆ្នាំ១៩៩៤ និង២០០១ (ស្ថិតិកសិកម្មរបស់ក្រសួងកសិកម្ម, បញ្ហាផ្សេងៗ និង MAFF ២០០៣) ។ អនុវិស័យបន្លែក៏បានទទួលការយកចិត្តទុកដាក់ទាំងពីស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល (NGO) ។ ទោះយ៉ាងនេះក្តី មានការសិក្សាជាច្រើនបានកត់សំគាល់ពីផលិតភាពទាបរបស់កម្ពុជាតាមការ

ប្រៀបធៀបក្នុងតំបន់ បានបង្ហាញយ៉ាងលំអិតពីបញ្ហានានាដែលជាប់ទាក់ទង និងងបានផ្តល់អនុសាសន៍ជាច្រើនខាងគោលនយោបាយ (RGC 2002, MoC 2001; FAO, UNDP 1999; MAFF 1999; McKenney and Prum 2002) ។ អនុសាសន៍ទាំងនេះ រួមមាន ការកែលំអបច្ចេកទេសផលិតកម្ម ការជួយទ្រទ្រង់ខាងហេដ្ឋារចនាសម្ព័ន្ធ និងការធ្វើធំរុះកម្មមុខដំណាំ ។ ទោះបីមានការប្រឹងប្រែងយ៉ាងច្រើន ដើម្បីជំរុញកសិកម្មកម្ពុជា និងមានការសំរេចបាននូវសមិទ្ធិផលដ៏គួរឱ្យកោតសរសើរមួយចំនួនក្នុងទសវត្សរ៍កន្លងទៅក្តី ប៉ុន្តែប្រទេសកម្ពុជានៅមានសក្តានុពលច្រើនទៀតសំរាប់កែលំអ និងពង្រីកផលិតកម្មកសិកម្ម ។ ឧទាហរណ៍ កម្ពុជាអាចកាន់តែធូរធារថែមទៀតដោយៈ (១) ធ្វើធំរុះកម្មមុខដំណាំក្រៅពីស្រូវ ពីព្រោះសព្វថ្ងៃស្រូវបានដាំលើដីប្រហែល ៩០% នៃដីដាំដុះសរុប (២) កាត់បន្ថយអប្រសិទ្ធភាពខាងម៉ាឃីទីង (៣) ជំរុញការកែច្នៃផលកសិកម្ម និង (៤) ពង្រីកការនាំចេញផលិតផលកសិកម្ម ។ វិធានការនេះជួយបង្កើនឧត្តមភាពប្រៀបធៀប ដូច្នេះមានសារៈសំខាន់ណាស់ចំពោះប្រទេសកម្ពុជាដែលកំពុងធ្វើសេរីភាវូបនីយកម្មទីផ្សារ និងធ្វើសមាហរណកម្មទៅក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) ព្រមទាំងបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ផង ។

ដើម្បីរួមចំណែកបង្ហាញពីវិធីនានាសំរាប់ដោះស្រាយបញ្ហាប្រឈមទាំងនេះ វិបសអបានសិក្សាពីប្រសិទ្ធភាពប្រៀបធៀបនៃដំណាំមិនមែនស្រូវចំបងៗ ជាមួយគ្នានឹងបណ្តាស្ថាប័នពីខាងថៃ និងវៀតណាម ។ ការសិក្សានេះមិនពិនិត្យលើវិស័យកសិកម្មទាំងមូលទេ ប៉ុន្តែផ្តោតការយកចិត្តទុកដាក់លើបញ្ហានានាជាប់ទាក់ទិននឹង "ដំណាំលក់យកប្រាក់" ដែលមានដាំដុះកាន់តែច្រើននៅលើ "ដីថ្មី" នៅកម្ពុជា ។ ការសិក្សានេះមានបំណងបង្ហាញពីវិធីនានា ដើម្បីជំរុញដំណាំមិនមែនស្រូវ ដែលតែងបានទទួលការយកទុកដាក់តិចជាងស្រូវ ពីព្រោះស្រូវអង្ករ គឺជាស្បៀងជាមូលដ្ឋាននៅកម្ពុជា ។ ការសិក្សាបានពិនិត្យជាពិសេសលើបញ្ហាមួយចំនួនដែលទាក់ទង នឹងផលិតកម្ម ម៉ាឃីទីង ការនាំចេញ និងការកែច្នៃដំណាំលក់យកប្រាក់បួនប្រភេទសំខាន់ៗៈ សណ្តែកសៀង ពោត ដំឡូងឈើ និងស្វាយចន្ទី ។ ឯកសារនេះផ្អែកលើការវាយតំលៃជាដំបូង

មួយស្តីពីបញ្ហាសំខាន់ៗមួយចំនួនដែលនឹងត្រូវស្រាវជ្រាវថែមទៀតនៅឆ្នាំខាងមុខ ។ ទោះបីយ៉ាងនេះក្តី របាយការណ៍នេះអាចផ្តល់ពត៌មានជាទូទៅបានពីអនុវិស័យដំណាំលក់យកប្រាក់ ព្រមទាំងការកត់សំគាល់មួយចំនួនដែលផ្អែកលើគំហើញជាដំបូងៗនៃការចុះសិក្សាដល់ទីកន្លែង ។

ដើម្បីវាយតំលៃពីផលិតកម្ម ស្ថិតិកសិកម្មដែលប្រមូលនិងចងក្រងដោយ MAFF នឹងយកមកវិភាគដោយផ្ទៀងមើលជាមួយគំហើញដែលបានពីការចុះសិក្សាដល់កន្លែង ។ ទិន្នន័យក៏រិតផលិតកម្មថ្នាក់ស្រុក បានប្រមូលមកពីខេត្តបីៈ កំពង់ចាម ព្រះវិហារ និងបាត់ដំបង ។ បុគ្គលិកបច្ចេកទេសកសិកម្មនៅថ្នាក់ក្រសួង និងថ្នាក់ខេត្ត ក៏ត្រូវបានសំភាស ដើម្បីផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃទិន្នន័យ និងប្រមូលមតិរបស់ពួកគេអំពីបញ្ហាប្រឈមសព្វថ្ងៃក្នុងមុខដំណាំដែលបានសិក្សា ។ មានការប្រឹងប្រែងពិនិត្យឡើងវិញផងដែរពីការសិក្សាមានស្រាប់នានាខាងកសិកម្មដែលអាចមានចុះពត៌មានជាប់ទាក់ទងនឹងដំណាំបួនមុខដែលបានសិក្សា ។ លើសពីនេះទៀតឯកសារអន្តរជាតិនានា ជាពិសេសទាក់ទិននឹងបរិបទស្រដៀងគ្នានឹងប្រទេសកម្ពុជា ត្រូវបានពិនិត្យឡើងវិញ ដើម្បីដកស្រង់យកប្រធានបទ និងបញ្ហាសាមញ្ញៗដែលអាចជាប់ទាក់ទងនឹងស្ថានភាពប្រទេសកម្ពុជា ។

ទាក់ទិននឹងការចុះសិក្សាដល់កន្លែង មានធ្វើសំភាសន៍ពាក់កណ្តាលរៀបរយជាមួយផលិតករ ១៦នាក់ (៤នាក់ក្នុងដំណាំមួយមុខៗ), អ្នកលក់ដុំ/ពាណិជ្ជករ ១៤នាក់ (អ្នកលក់វត្ថុធាតុដើម ១២នាក់ និងអ្នកលក់ផលិតផលកែច្នៃ ២នាក់), សហគ្រាសកែច្នៃ ៤, អ្នកនាំចេញ ៣នាក់ និងមន្ត្រី ៨នាក់ (៥នាក់នៅថ្នាក់ស្រុក និង ៣នាក់នៅថ្នាក់ជាតិ) ។ ការសំភាសន៍ស៊ីជម្រៅទាំងនេះ បានធ្វើឡើងជាសំខាន់ដើម្បីប្រមូលពត៌មាន និងការយល់ដឹងផ្សេងៗដែលត្រូវមានដើម្បីដោះស្រាយចំងល់ និងមិនអាចឆ្លើយបានដោយប្រើទិន្នន័យទីពីរ (secondary data) ។

## ៣.២. ផលិតកម្មដំណាំលក់យកប្រាក់នៅកម្ពុជា

### *៣.២.១. ដំណាំលក់យកប្រាក់សំខាន់ៗនៅកម្ពុជា*

កសិកម្មកម្ពុជានៅតែជាផ្នែកមួយយ៉ាងធំនៃសេដ្ឋកិច្ចកម្ពុជា ថ្វីបើការរួមចំនែករបស់វាបានធ្លាក់ចុះជាភាគរយក្តី ។ គិតតាមក៏រិតថ្លៃឆ្នាំ១៩៩៣ តំលៃបន្ថែមបានពីកសិកម្ម កើនពី

៥៩០លានដុល្លារនៅឆ្នាំ១៩៨៥ ដល់ ១.០៣៨លានដុល្លារនៅឆ្នាំ១៩៩៥ និងដល់ ១.០៨៤លានដុល្លារនៅឆ្នាំ២០០១ (Sok and Acharya 2002) ។ គិតជាភាគរយក្នុង ផសស វិស័យកសិកម្មមានចំណែក ៥៩% នៅឆ្នាំ១៩៨៥, ៤២% នៅឆ្នាំ១៩៩៥ និង ៣៤% នៅឆ្នាំ២០០១ គឺបង្ហាញនូវកំណើនយឺតជាងវិស័យសេវាកម្ម និងឧស្សាហកម្ម ។ ក្នុងវិស័យកសិកម្ម ស្រូវជាដំណាំធំជាងគេដោយផលិតបាន ២៤០លានដុល្លារនៅឆ្នាំ១៩៨៥, ៤២៦លានដុល្លារនៅឆ្នាំ១៩៩៥ និង ៥២៨លានដុល្លារនៅឆ្នាំ២០០១ ។ ក្នុងឆ្នាំដូចគ្នា "ដំណាំផ្សេងៗ" មានតំលៃ ១១៦លានដុល្លារ, ១៥១លានដុល្លារ, និង ១៧៥លានដុល្លាររៀងគ្នា ។ ប្រភេទ "ដំណាំផ្សេងៗ" នេះ មានរាប់បញ្ចូលគ្រប់ដំណាំទាំងអស់ក្រៅពីស្រូវ ដែលប្រជាជនដាំដុះសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ។

ស្រូវគឺជាដំណាំសំខាន់ជាងគេបង្អស់នៅកម្ពុជា ហើយដាំដុះលើប្រហែល ៩០%នៃដីដាំដំណាំសរុប ។ ស្រូវអង្ករបានរួមចំណែកប្រហែល ៧០%នៃការបរិភោគប្រូតេអ៊ីន (Murshid 1998, and Chan and Acharya 2003) ។ ដូច្នេះមិនមែនជារឿងចៃដន្យទេដែល "សន្តិសុខស្បៀង" ជាប្រពៃណីតែងសំដៅដល់ "សន្តិសុខស្រូវអង្ករ" ។ នៅឆ្នាំ២០០២ តំលៃបន្ថែមក្នុងផលិតកម្មស្រូវគឺ ៤២០លានដុល្លារ ឬ ១១,៧%នៃ ផសស កម្ពុជា ។ ប៉ុន្តែការដាំដុះស្រូវភាគច្រើន គឺមានលក្ខណៈជីវព្រឹត្តិ (សំរាប់តែមួយគ្រប់ហូប) ឬក៏ពាក់កណ្តាលជីវព្រឹត្តិ ។ វិស័យនេះបានជួយឱ្យប្រជាជនរស់រានជីវិត ប៉ុន្តែវាមិនបានចូលរួមចំណែកច្រើនណាស់ណាទេដល់សេដ្ឋកិច្ចផ្តល់ចំណូលជាសាច់ប្រាក់ ។ ឧទាហរណ៍ ការិយាល័យម៉ាឃីទីងរបស់ MAFF ប៉ាន់ថា មានផលិតកម្មស្រូវតែ ១៥% ប៉ុណ្ណោះដែលត្រូវបានលក់ដូរ ។

ដំណាំនៅកម្ពុជា ចែកចេញជាស្រូវ និងដំណាំផ្សេងទៀត ឬដំណាំ "បន្ទាប់បន្សំ" ដែលឆ្លុះបញ្ចាំងម្តងទៀតពីសារៈសំខាន់ធំបំផុតដែលគេផ្តល់ឱ្យស្រូវ ។ រីឯដំណាំ "ផ្សេងទៀត" ទទួលបានការយកចិត្តទុកខាងគោលនយោបាយតិចជាងស្រូវ ហើយមានការសិក្សា និងការប្រឹងប្រែងអភិវឌ្ឍន៍តិចជាងឆ្ងាយណាស់ចំពោះមុខដំណាំមិនមែនស្រូវ ។ ប៉ុន្តែដោយសារផ្ទៃដីធំៗនៃព្រៃឈើកម្ពុជា ត្រូវបានកាប់រានប្រែក្លាយជាដីធ្វើកសិកម្ម វិស័យឯកជន រួមទាំងកសិករផង បានឆក់ឱកាសពង្រីកការដាំដុះដំណាំមិនមែនស្រូវ ។ ក្នុងតំបន់ធំៗជាច្រើននៅកម្ពុជា ដំណាំមិនមែន

ស្រូវដូចជា ពោត សណ្តែកសៀង សណ្តែកបាយ ដំឡូងឈើ ស្វាយចន្ទី ចេក និងដំណាំហូបផ្លែផ្សេងៗទៀត គឺមិនមែនជាដំណាំ "បន្ទាប់បន្សំ" ទេ ប៉ុន្តែជាដំណាំចំបងដែលប្រជាជនបានពឹងផ្អែកលើវាដើម្បីរកចិញ្ចឹមជីវិតតែម្តង ។

នៅឆ្នាំ២០០២ តួលេខកត់ត្រាជាផ្លូវការនៃតំលៃបន្ថែមផ្តល់ដោយដំណាំមិនមែនស្រូវគឺ ១៧៥លានដុល្លារ ។ តួលេខនេះទាបជាង ៦% នៃ ផសស ប៉ុន្តែនៅតែមានសារៈសំខាន់ បើពិនិត្យនៅក្នុងសេដ្ឋកិច្ចកម្ពុជាទាំងមូល ។ មានហេតុផលជាច្រើនដែលគេមិនគួរមើលរំលងសារៈសំខាន់នៃដំណាំលក់យកប្រាក់ទេ ។ ទី១ យោងតាមមន្ត្រីស្ថិតិជាន់ខ្ពស់នៃ MAFF តួលេខស្តីពីដំណាំមិនមែនស្រូវ គឺប្រមូលមិនបានល្អទេ ហើយប្រហែលទាបជាងការពិតយ៉ាងច្រើន ។ ទី២ ផលិតកម្មដំណាំមិនមែនស្រូវ កើនឡើងយ៉ាងលឿនតាមការរានយកផ្ទៃដីធំៗពីព្រៃឈើ ។ ទី៣ ភាគច្រើននៃដំណាំលក់យកប្រាក់ទាំងនេះ បានធ្វើពាណិជ្ជកម្ម និងនាំចេញទៅក្រៅ ដូច្នេះវាបានរួមចំណែកគួរឱ្យកត់សំគាល់ដល់សេដ្ឋកិច្ចលក់ដូរយកប្រាក់នៅមូលដ្ឋាន និងបានបង្កើតការងារក្នុងមូលដ្ឋានដែរ ។ ទី៤ ការសិក្សា និងអ្នកជំនាញការជាច្រើនខាងកសិកម្ម បានផ្តល់យោបល់ថា កម្ពុជាគួរធ្វើចំរុះកម្មបំបែរចេញពីការដាំស្រូវ ពីព្រោះការពឹងផ្អែកដំណាំតែមួយមុខវាមានហានិភ័យច្រើន ។ សំខាន់ជាងគេ គឺកម្ពុជាសំបូរដីមានជីជាតិល្អដែលបានពីការរានយកដីព្រៃ និងដែលផ្តល់សក្តានុពលច្រើនណាស់ក្នុងការពង្រីកការកែច្នៃ និងការនាំចេញផលិតផលដំណាំលក់យកប្រាក់ ។

តារាង ១ ប្រៀបធៀបពីផលិតកម្ម និងផលិតភាពនៃដំណាំចំបងៗនៅកម្ពុជា ដោយផ្អែកលើទិន្នន័យផលិតកម្មចងក្រងដោយ MAFF ហើយទិន្នន័យស្តីពីកំរិតថ្លៃ គណនាតាមពត៌មានបានពី MAFF និងអ្នកផ្តល់ពត៌មានសំខាន់ៗមួយចំនួន ។ ដំណាំទាំង ៨មុខដូចខាងក្រោម គឺជាដំណាំចំបងចុះក្នុង "ស្ថិតិកសិកម្ម" របស់ MAFF ។ ក្នុងព្រឹត្តប័ត្រនេះ ក៏មានចុះផងដែរនូវមុខដំណាំតូចៗមួយចំនួនដែលមិនសូវមានសារៈសំខាន់ដល់សេដ្ឋកិច្ច ។ ប៉ុន្តែ បន្លែ និងដំណាំរស់បានច្រើនឆ្នាំ ហាក់មានតំលៃគួរកត់សំគាល់ក្នុងសេដ្ឋកិច្ចកម្ពុជា ប៉ុន្តែគ្មានស្ថិតិច្បាស់លាស់ល្អទេសំរាប់ដំណាំទាំងនេះ គឺមានតែការប៉ាន់ស្មានចោលៗអំពីផ្ទៃដីធ្វើផលិតកម្ម ។

តំលៃដុលនៃផលដំណាំបង្ហាញក្នុងតារាង១ ផ្តល់នូវការប្រៀបធៀបត្រួសៗពីភាពមានចំណេញ ឬអត្រាទាញចំណូល ។ ការវាយតំលៃពីផលចំណេញអំពីដី និងពលកម្ម គួរមានផងដែរនូវការពិនិត្យពីចំណេញសុទ្ធ (ចំណេញដុលដកថ្លៃដើម) ។ ការគណនានេះមានធ្វើនៅក្នុងផ្នែកខាងក្រោមដែលជាប់ទាក់ទិននឹងការរកឃើញពីដំបូងៗ ក្នុងករណីសិក្សាពីដំណាំនានា ។

ក្រៅពីសណ្តែកសៀងដែលមានផលចំណេញខ្ពស់បំផុតដល់ ៣៣៥ដុល្លារ/ហ.ត. ផលិតកម្មស្រូវអង្ករ និងស្ករអំពៅ ក៏ផ្តល់ផលចំណេញដុលខ្ពស់ដែរក្នុងមួយហិកតាដីគឺ ២៣០ដុល្លារ និង ៣៣៣ដុល្លាររៀងៗគ្នា ។ ប៉ុន្តែក្នុងករណីភាគច្រើន ដំណាំពីរមុខនេះ ប្រមូលផលបានតែ ១ដង/ឆ្នាំ ។ គឺបានន័យថា តួលេខនេះ គឺជាផលចំណេញដុលលើដីមួយហិកតាក្នុង "អំឡុងពេលមួយឆ្នាំ" ។ ផលចំណេញពីពោត សណ្តែកសៀង សណ្តែកបាយ និងល្ង គឺសំរាប់តែរយៈពេល ៦ខែប៉ុណ្ណោះ ពីព្រោះដីដែលដាំដំណាំទាំងនេះ ជាទូទៅអាចដាំបានពីរដងក្នុងរយៈពេលមួយឆ្នាំ ដែលអាចជាមុខដំណាំដដែល ឬដំណាំមួយផ្សេងដែលផ្តល់ផលចំណេញប្រហែលៗគ្នា ។ តាមធម្មតាពោត សណ្តែកសៀង និងល្ង ត្រូវបានដាំដុះផ្លាស់វេនគ្នានៅរដូវប្រាំង និងរដូវវស្សា ។ បើគិតពីផលិតភាពដី និងចំណូលរបស់កសិករ ដំណាំមិនមែនស្រូវអាចមានសារៈសំខាន់ជាងស្រូវទៅទៀត ។ ពោតអាចដាំលើដីស្រែបាន ប៉ុន្តែសណ្តែកសៀង ដាំបានតែលើដីប្រភេទខ្លះ ដែលមានជាតិអាស៊ីតតិច ។ បច្ចុប្បន្ន ដីដាំស្រូវភាគច្រើនគ្មានដាំដំណាំអ្វីផ្សេងទេ ប្រហែលដោយសារវាមានទឹកជោកជាំ ឬស្ងួតហួតហែងពេក ធ្វើឱ្យវាអន់គុណភាព[២៧] ។

ការសិក្សានេះ ពិនិត្យលើដំណាំចំបងៗបួនក្រៅពីស្រូវ ដែលធ្លាប់មានការសិក្សាយ៉ាងទូលំទូលាយ ។ ក្នុងដំណាំសំខាន់ៗទាំង ៨មុខ នៃតារាង១ បានជ្រើសយកដំណាំ ៣មុខគឺ ពោត សណ្តែកសៀង និងដំឡូងឈើ ។ ដូចមានចុះក្នុងតារាង ដំណាំទាំងនេះមានតំលៃគួរកត់សំគាល់បន្ទាប់ពីស្រូវ បានជ្រើសយកស្វាយចន្ទី ជាដំណាំទី៤ មកសិក្សា សំរាប់តំណាងឱ្យដំណាំរស់បានច្រើនឆ្នាំដែលពុំមានរាយការណ៍ច្បាស់លាស់ល្អក្នុងស្ថិតិរដ្ឋាភិបាលទេ ។ បន្ថែមទៅលើសារៈ

[២៧] ការសិក្សាពីដីសមស្របសំរាប់ដំណាំផ្សេងៗ ឥលូវនេះបានធ្វើដោយ CARDI ដែលមានអ្នកជំនាញការបច្ចេកទេសផ្នែកតំបន់ ។

សំខាន់ចំពោះសេដ្ឋកិច្ចកម្ពុជា ដំណាំ ៤មុខនេះ បង្ហាញពីកសិដ្ឋានប្រភេទផ្សេងៗគ្នាក្នុងតំបន់ខុសៗគ្នានៃកម្ពុជា ព្រមទាំងមានសក្តានុពលសំរាប់ធ្វើការពង្រីក ។

**តារាង ១. ផលិតកម្ម និងផលិតភាពនៃដំណាំចំបងៗនៅកម្ពុជា ក្នុងឆ្នាំ២០០២**

| | តោន[ក] | តោន/ហ.ត[ក] | ដុល្លារ/តោន[ខ] | ដុល្លារ/ហ.ត (ដុល) | លានដុល្លារ (ដុល) |
|---|---|---|---|---|---|
| (1) | (2) | (3) | (4) | (5) | (6) |
| ១. ស្រូវ | 3,822,509 | 1.92 | 120 | 230 | 459 |
| ២. ពោត | 148,897 | 2.08 | 80 | 166 | 12 |
| ៣. សណ្តែកសៀង | 38,801 | 1.34 | 250 | 335 | 10 |
| ៤. សណ្តែកបាយ | 23,925 | 0.68 | 240 | 163 | 6 |
| ៥. ដំឡូងឈើ | 122,014 | 6.33 | 20 | 127 | 2 |
| ៦. ល្ង | 10,157 | 0.51 | 370 | 190 | 4 |
| ៧. អំពៅ | 208,819 | 22.23 | 15 | 333 | 3 |
| ៨. សណ្តែកដី | 9,738 | 0.85 | 200 | 169 | 2 |
| ចំណេញដុលសរុប ក្រៅពីស្រូវ | | | | | 39 |

*ប្រភព: [ក] MAFF ស្ថិតិកសិកម្ម ២០០២-០៣, [ខ] ផ្អែកលើស្ថិតិ MAFF និងកិច្ចសំភាសន៍នានា ។*

## *៣.២.២. ផលិតកម្ម សណ្តែកសៀង ពោត ដំឡូងមី និងស្វាយចន្ទី*

### *៣.២.២.១. ផលិតកម្មសណ្តែកសៀង*

សណ្តែកសៀង គឺជាធញ្ញជាតិមួយដែលមានធ្វើពាណិជ្ជកម្មជាអន្តរជាតិ និងមានជាតិប្រូតេអ៊ីនខ្ពស់ និងមានជាតិខ្លាញ់តិច ។ ដោយសារប្រជាជនទូទៅកាន់តែងាកទៅរកអាហារមានជាតិប្រូតេអ៊ីនផ្តល់សុខភាពល្អ ដូច្នេះទៅអនាគតសណ្តែកសៀងនឹងមានទីផ្សារល្អ ។ ដោយមានប្រភពដើមមកពីប្រទេសចិន សណ្តែកសៀងមានដាំ និងប្រើប្រាស់ជាប្រពៃណីនៅអាស៊ីខាងកើត និងអាស៊ីអគ្នេយ៍ជាច្រើនពាន់ឆ្នាំមកហើយ ។ សព្វថ្ងៃនៅ U.S.A ក៏មានដាំវាយ៉ាងច្រើនៗដែរ (FAO, 1994) ។ កម្ពុជាផលិតសណ្តែកសៀងបានច្រើនណាស់ ហើយភាគច្រើនសំរាប់នាំចេញ ។ សណ្តែកសៀងមិនអាចដាំបាននៅគ្រប់តំបន់នៃប្រទេសកម្ពុជាទេ ពីព្រោះវាទាមទារដីមានជីជាតិល្អ និងមានជាតិអាស៊ីតតិចជាងដំណាំផ្សេងៗទៀតនៅក្នុងតារាង១ ។ ទោះយ៉ាងនេះក្តី កម្ពុជាហាក់មានលក្ខណៈសមស្របគួរសម សំរាប់ដំណាំនេះ ដោយទទួលបានទិន្នផលជាមធ្យម

ប្រហែល ១តោន/ហ.ត ដែលជាទិន្នផលខ្ពស់ជាងគេក្នុងតំបន់អាស៊ាន (FAO, 2000) ។ យោងតាមស្ថិតិរបស់ FAO 2000 កម្ពុជាគឺជាប្រទេសនាំចេញសណ្តែកសៀងធំជាងគេនៅតំបន់អាស៊ានបន្ទាប់ពីវៀតណាម ។

ផលិតកម្មសណ្តែកសៀងប្រចាំឆ្នាំ តាមឯកសាររបស់ MAFF បានធ្លាក់ចុះពីប្រហែល ៣៥.០០០តោននៅឆ្នាំ១៩៩៩ មក ២៨.០០០តោននៅឆ្នាំ២០០០, និង ២៤.៦០០តោននៅឆ្នាំ២០០១ ។ ផលិតកម្មនៅឆ្នាំ២០០២ អាចបន្តធ្លាក់ចុះទៀត ដោយសារធាតុអាកាសមិនអំណោយផល ។ ប៉ុន្តែការធ្លាក់ចុះផលិតកម្មក្នុងពេលកន្លងមក ហាក់បណ្តាលជាសំខាន់ដោយសារការផ្លាស់ប្តូរទៅធ្វើដំណាំផ្សេងដែលផ្តល់ផលកំរៃច្រើនជាង នៅតាមខេត្តផលិតចំបងៗ ទោះបីលំនាំផលិតកម្មប្រែប្រួលខុសគ្នាពីខេត្តមួយទៅខេត្តមួយក្តី ។

កំពង់ចាម ជាខេត្តផលិតសណ្តែកសៀងច្រើនជាងគេបំផុត (តារាង ២) ថ្វីបើជួនកាលទទួលបានទិន្នផលទាបជាងមធ្យមភាគថ្នាក់ជាតិក្តី ។ រឿងនេះដោយសារកំពង់ចាមមានដីក្រហមច្រើនជាងគេ ដែលសមស្របសំរាប់សណ្តែកសៀង ។ ប៉ុន្តែផលិតកម្មសណ្តែកសៀងនៅកំពង់ចាម បានធ្លាក់ចុះជាងពាក់កណ្តាលពី ៣៣.០០០តោននៅឆ្នាំ១៩៩៩ ដល់ ១៤.៣៤៩តោននៅឆ្នាំ២០០១ តែនៅឆ្នាំ២០០២ វាស្ទុះឡើងវិញដល់ ២៧.៨៧២តោន យោងតាមស្ថិតិក្រសួងកសិកម្ម ។ ផ្អែកតាមការចុះសិក្សាដល់កន្លែង ការប្រែប្រួលនេះបណ្តាលពីការផ្លាស់ប្តូរទៅដាំដំណាំផ្សេងដែលមានផលចំណេញច្រើនជាង ជាពិសេស ចេក និងកៅស៊ូ ដែលបានរីកលូតលាស់គួរកត់សំគាល់នៅក្នុងខេត្ត ។

ខេត្តបាត់ដំបង ក៏ផលិតសណ្តែកសៀងច្រើនដែរ បន្ទាប់ពីខេត្តកំពង់ចាម ។ ខុសពីកំពង់ចាម តំបន់ផលិតកម្មនៅបាត់ដំបង បានកើន ៤ដង នៅចន្លោះឆ្នាំ១៩៩៩ និង ២០០២ ហើយទិន្នផលបានខ្ពស់ជាងមធ្យមភាគថ្នាក់ជាតិ ។ បាត់ដំបងមានអំណោយផលល្អដោយសារនៅជាប់ព្រំដែនថៃដែលជាទីផ្សារនាំចេញចំបងមួយ សំរាប់គ្រាប់ធញ្ញជាតិកម្ពុជា ។ នៅក្នុងខេត្តនេះ តាមធម្មតាគេដាំសណ្តែកសៀងក្រោយប្រមូលផលពោតរួច និងដាំលើដីថ្មីដែលរានយកពីដីព្រៃកាន់តែច្រើនឡើងៗ ។

**តារាង ២. តំបន់ប្រមូលផល ទិន្នផល និងផលិតកម្មសណ្តែកសៀង**

| ខេត្ត | តំបន់ប្រមូលផល (ហ.ត) | | | ទិន្នផល (តោន/ហ.ត) | | | ផលិតកម្ម (តោន) | | |
|---|---|---|---|---|---|---|---|---|---|
| | 1999 | 2001 | 2002 | 1999 | 2001 | 2002 | 1999 | 2001 | 2002 |
| កំពង់ចាម | 32,950 | 20,210 | 19,272 | 1.00 | 0.71 | 1.45 | 33,000 | 14,349 | 27,872 |
| បាត់ដំបង | 1,500 | 4,279 | 6,012 | 1.04 | 1.28 | 1.30 | 1,560 | 5,469 | 7,816 |
| កំពង់ធំ | 260 | 3,220 | 2,023 | 1.03 | 1.08 | 0.83 | 268 | 3,471 | 1,688 |
| ព្រះវិហារ[ក] | - | 539 | 771 | - | 1.50 | 0.54 | - | 809 | 413 |
| កណ្តាល | 215 | 30 | 175 | 1.00 | 0.80 | 0.80 | 215 | 24 | 140 |
| ខេត្តផ្សេងទៀត | 20 | 409 | 682 | .. | .. | .. | 20 | 536 | 772 |
| សរុប | 34,945 | 28,687 | 28,935 | 1.00 | 0.86 | 1.34 | 35,063 | 24,658 | 38,801 |

*[ក] មិនអាចរកទិន្នន័យសំរាប់ឆ្នាំ១៩៩៩ បានទេ ។ ប្រភព: MAFF "ស្ថិតិកសិកម្ម ១៩៩៩-២000, ២00១-0២ និង ២00២-0៣" ។*

ផលិតកម្មសណ្តែកសៀងនៅខេត្តកំពង់ធំ និងព្រះវិហារ ក៏កើនឡើងដែរ ដោយសារហេតុផលដូចគ្នានឹងខេត្តបាត់ដំបង ។ ព្រៃមួយភាគធំត្រូវបានរានយក ហើយដីថ្មីភាគច្រើនបានដាំសណ្តែកសៀង ។ ថ្វីបើខេត្តព្រះវិហារនៅដាច់ស្រយាល មិនអំណោយផលខាងការដឹកជញ្ជូនក្តី បើធៀបនឹងខេត្តកំពង់ចាម និងបាត់ដំបង គឺបានទិន្នផលមធ្យមខ្ពស់ដល់ ២តោន/ហ.ត ដែលអាចទូទាត់នឹងចំណាយដឹកជញ្ជូនដែលខ្ពស់លើសគេប្រហែល ២0ដុល្លារ/តោននោះបានហើយ ។ ទិន្នន័យថ្នាក់ស្រុកដែលទទួលបានពីខេត្តបង្ហាញថា ផលិតកម្មសណ្តែកសៀងនៅព្រះវិហារ មានទីតាំងចំបងនៅស្រុកត្បែងមានជ័យ ។ យោងតាមការចុះសិក្សាដល់កន្លែងក្នុងស្រុកនេះទិន្នផលសណ្តែកសៀងជាមធ្យមនៅឆ្នាំ២00២គឺ ២តោន/ហ.ត ប៉ុន្តែទិន្នន័យរបស់ MAFF ក្នុងតារាង២ បង្ហាញថា ទិន្នផលបានប្រហែលតែ 0,៥៤តោន/ហ.ត ។ ការចុះសិក្សាដល់កន្លែងនៅក្នុងខេត្តនេះបង្ហាញថា ផលិតកម្មមានទំហំធំជាងតួលេខកត់ត្រាជាផ្លូវការ និងបានរកឃើញថា ផលិតកម្មសណ្តែកសៀងបានពង្រីកបន្ថែមនៅលើដីថ្មីដែលរានពីព្រៃបាន ។ នៅពេលចំណាយដឹកជញ្ជូនត្រូវថយចុះតាមការកែលំអផ្លូវថ្នល់ក្នុងពេលខាងមុខ ផលិតកម្មសណ្តែកសៀងនៅក្នុងខេត្តនេះ ប្រហែលនឹងកើនឡើងថែមទៀត ។

*ការសង្កេតឃើញលើផលិតកម្មសណ្តែកសៀងនៅឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម*

នៅឃុំបុសខ្នុរ គេដាំសណ្តែកសៀងនៅខែកក្កដា និងប្រមូលផលនៅខែតុលា ឬវិច្ឆិកា ក្នុងរដូវវស្សា ដោយវាមានអាយុមធ្យម ៣ខែកន្លះ ។ ប៉ុន្តែមានពូជសណ្តែកសៀង ៣ប្រភេទ ផ្អែកតាមអាយុកាលរបស់វាដែលមានចាប់ពី ៧០ថ្ងៃ ទៅ ១០០ថ្ងៃ ។ ឃុំបុសខ្នុរផលិតបានពី ៣.០០០-៥.០០០តោន/ឆ្នាំទៅតាមលក្ខណៈអាកាសធាតុ ។ ថ្វីបើ សណ្តែកសៀងមិនត្រូវការសំណើមច្រើនក៏ដោយ តែនៅតែត្រូវពឹងលើអាកាសធាតុ ពីព្រោះគ្មានប្រព័ន្ធស្រោចស្រពនៅតំបន់នោះ ។ ឧទាហរណ៍ ដោយសារការរាំងស្ងួតនៅឆ្នាំ២០០២ ទិន្នផលសណ្តែកសៀងនៅបុសខ្នុរថយចុះពី ១,៥-២,០តោន/ហ.ត មកត្រឹម ០,៥តោន./ហ.ត ។ ក្នុងតំបន់សិក្សានេះ គេមិនឃើញមានប្រើជីគីមីទេ ដោយសារដីក្រហមសំបូរជីជាតិស្រាប់ហើយ ។ ការងារដាំដុះមានលក្ខណៈសាមញ្ញទេ រួមទាំងការរៀបចំដី ការដាំ ការជំរះស្មៅ ការប្រមូលផល និងការប្រឡេះយកគ្រាប់ ។

ទោះបីកសិដ្ឋានសឹងទាំងអស់ជា "កសិដ្ឋានប្រចាំគ្រួសារតូចៗ" មានទំហំ ២-៣ហ.ត ជាមធ្យម ប៉ុន្តែតាមធម្មតាការងារដាំដុះទាំងអស់ធ្វើដោយកំលាំងពលកម្មស៊ីឈ្នួលដែលភាគច្រើនមកពីស្រុកផ្សេងទៀត និងដោយគ្រឿងចក្រជួលគេ ។ ក្នុងការរៀបចំដី និងប្រឡេះយកគ្រាប់ គេប្រើម៉ាស៊ីន ហើយគេជួលកំលាំងពលកម្មសំរាប់ការដាំ ជំរះស្មៅ និងប្រមូលផល ។ គេជួលកម្មករពី ១០-១៥នាក់ សំរាប់ដាក់គ្រាប់ដាំ ជំរះស្មៅពីរដង និងប្រមូលផល ។ អត្រាកំរៃជាមធ្យមគឺ ៤.០០០រៀល (១ដុល្លារ)/ថ្ងៃ ដោយអាចប្រែប្រួលឡើងចុះប្រហែល ១៥% ទៅតាមតំរូវការកម្មករ ។ មានការធ្វើយន្តកម្មខ្លះៗហើយ ជាពិសេសក្នុង ២-៣ឆ្នាំកន្លងមក ។ ទោះបីការភ្ជួររាស់ដោយកំលាំងបុរស និងសត្វអូសទាញ មានតំលៃថោកត្រឹម ៤០.០០០រៀល/ហ.តក៏ដោយ ក៏ឥលូវកសិករភាគច្រើនជួលត្រាក់ទ័រដើម្បីភ្ជួររាស់ដីកសិដ្ឋានរបស់គេក្នុងតំលៃ ៦០.០០០-៧០.០០០រៀល/ហ.ត ។ ការចូលចិត្តប្រើត្រាក់ទ័រជាងសត្វអូសទាញនេះ គេប្រាប់មូលហេតុថា ការភ្ជួរដោយត្រាក់ទ័របានម៉ដ្តល្អជាង ហើយត្រាក់ទ័រអាចធ្វើការងារបានទាន់ពេលល្អដែលមានសារៈសំខាន់ជាពិសេសសំរាប់កសិដ្ឋានមានផ្ទៃដីធំៗ ។

នៅបុសខ្នុរ កសិករជាច្រើនរាយការណ៍ថា បានប្តូរពីការដាំសណ្តែកសៀង មកដាំចេក វិញកាលពី ៧ឆ្នាំមុន ពីព្រោះបានផលចំណេញច្រើនជាង ។ ផលិតកម្មចេក ១ហ.ត ផ្តល់ចំណូល ដុលប្រហែល ៥០០ដុល្លារ/ឆ្នាំ រីឯសណ្តែកសៀង ១ហ.ត ផ្តល់ចំណូលបានតែ ៣០០ដុល្លារ រួមនឹង ១០០ដុល្លារទៀតបានពីការដាំដំណាំមួយផ្សេងនៅរដូវប្រាំង ។ ជាអកុសល កសិករត្រូវ តែប្តូរទៅដាំសណ្តែកសៀងនៅរៀងរាល់ ៣ឆ្នាំម្តង ដោយសារតែមានជំងឺចម្លងដោយសត្វល្អិត ចង្រៃដែលប៉ះពាល់ដល់ដើមចេក[២៨] ។

ដូចក្នុងតំបន់ជនបទផ្សេងៗទៀតសិក្សាដោយលោក Chan និង Acharya (2003) កម្មសិទ្ធិដីនៅបុសខ្នុរ បានប្រមូលផ្តុំនៅក្នុងដៃគ្រួសារមួយចំនួនតូច ។ គេរាយការណ៍ថា គ្រួសារ ប្រហែល ២០%មានដី ២០-៣០ហ.ត/គ្រួសារ, ៥០%មានដីប្រហែល ២ហ.ត/គ្រួសារ និង ៣០%ទៀតគឺជាគ្រួសារគ្មានដី ។ គ្រួសារគ្មានដីមួយចំនួន បានជួលដីក្នុងតំលៃ ១០០ដុល្លារ/ ហ.ត/ឆ្នាំ ហើយគេអាចទទួលបានផលចំណេញសុទ្ធប្រហែល ១៩០ដុល្លារ (ពតិមានលំអិតស្តីពី ថវិកាផលិតកម្មមានបង្ហាញក្នុងតារាង ៣) ។ គួរកត់សំគាល់ថា ពលកម្មក្នុងគ្រួសារមិនបានគិត បញ្ចូលក្នុងតារាងនេះទេ ។ ដូច្នេះ ផលចំណេញសុទ្ធក្នុងតួលេខ គឺមានប្រាក់កំរៃសំរាប់កម្មករ ស៊ីឈ្នួល និងទ្រព្យសកម្មនានា ដូចជាដីជាដើម ។ MAFF (2003) បានចាត់ទុកពលកម្មក្នុង គ្រួសារថាជាចំណែកមួយនៃបន្ទុកចំណាយ ដូច្នេះបានគណនាឃើញផលចំណេញសុទ្ធទាបជាង ត្រឹម ១៣០ដុល្លារ/ហ.ត រីឯតួលេខរកឃើញក្នុងការសិក្សានេះគឺ ២៤៣ដុល្លារ ។

បុសខ្នុរ គឺជាឃុំផលិតសណ្តែកសៀងមុនគេនៅខេត្តកំពង់ចាម ។ ដូច្នេះ ផលិតភាពបាន ធ្លាក់ចុះជាបន្តបន្ទាប់ក្នុងពេលកន្លងទៅ ដោយសារការថយចុះជីជាតិដី ។ ឧទាហរណ៍ គេរាយ ការណ៍ថា ទិន្នផលជាមធ្យមគឺ ២,៥តោននៅឆ្នាំ១៩៩៥ ដោយធ្លាក់ចុះមកដល់ ២,០តោននៅឆ្នាំ ១៩៩៨ ហើយបច្ចុប្បន្នបានត្រឹម ១,៥តោនបើសិនគ្មានការរាំងស្ងួត ។ ទោះយ៉ាងនេះក្តី គេមិន គិតថា មានការចាំបាច់ត្រូវប្រើជីដើម្បីកែលំអដីទេ ។ តាមបច្ចេកទេស គេដឹងមិនច្បាស់ទេថា តើអាចគេដាំដុះបានប៉ុន្មានឆ្នាំទៀតមុននឹងដីក្លាយជាខ្សោះលែងដាំអ្វីកើត ។

[២៨] នៅពេលសិក្សា មិនទាន់មានការស្រាវជ្រាវអ្វីសំរាប់ទប់ទល់នឹងជំងឺនេះទេ ។

**តារាង ៣. ថវិកាផលិតកម្មសណ្តែកសៀងនៅខេត្តកំពង់ចាម និងព្រះវិហារ ក្នុងឆ្នាំ២០០២**

| មុខចំណាយ (ក្នុង ១ហ.ត) | កំពង់ចាម | ព្រះវិហារ |
|---|---|---|
| គ្រាប់ពូជ (២.៥០០រៀល x ៥០គ.ក) | 165,000 | 125,000 |
| ការរៀបចំដីលើកទី១ | 75,000 | 120,000 |
| ការរៀបចំដីលើកទី២ | 50,000 | - |
| ការដាំ | 50,000 | 52,000 |
| ការជំរះស្មៅលើកទី១ | 35,000 | 52,000 |
| ការជំរះស្មៅលើកទី២ | 35,000 | 52,000 |
| ការប្រមូលផល | 80,000 | 75,000 |
| ការប្រលេះយកគ្រាប់ | 40,000 | 50,000 |
| ចំណាយសរុបជារៀល | 530,000 | 526,000 |
| ចំណាយសរុបជាដុល្លារ | 133 | 132 |
| ផលចំណេញដុលមធ្យម (១,៥ត. x ២៥០ដុល្លារ) | 375 | 500 |
| ចំណូលសុទ្ធ | 243 | 368 |
| បន្ទុកចំណាយលើការជួលដី/ឱកាស | 100 | 80 |

*ប្រភព: កិច្ចសំភាសន៍ស៊ីជម្រៅជាមួយកសិករ ៥នាក់នៅកំពង់ចាម និងព្រះវិហារ មីនា ២០០៣ ។*

***នៅស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ***

ផលិតកម្មសណ្តែកសៀងនៅខេត្តព្រះវិហារ គឺស្រដៀងគ្នានឹងខេត្តកំពង់ចាមដែរ ។ គេធ្វើការដាំដុះពីខែកក្កដា ដល់តុលា ឬវិច្ឆិកា និងដាំឆ្លាស់វេនជាមួយសណ្តែកបាយ ឬល្ង ។ ដូចនៅខេត្តកំពង់ចាមដែរ គេជួលពលកម្មមកពីស្រុកផ្សេងៗ ដើម្បីជួយដាំ ជំរះស្មៅ និងប្រមូលផល ។ កំរៃប្រចាំថ្ងៃគឺ ៣.៥០០-៥.០០០រៀលដែលអាចឡើងចុះដូចនៅកំពង់ចាមដែរ ។ ប៉ុន្តែ ដីខេត្តព្រះវិហារ មានអំនោយផលជាងនៅកំពង់ចាម ពីព្រោះវាជាដីថ្មី (គឺទើបកាប់រានព្រៃបានភ្លាម) ។ កសិករជាច្រើនមិនភ្ជួរដីទេ ដើម្បីកាត់បន្ថយចំណាយ ។ បើគេភ្ជួរដី ទិន្នផលក្នុង១ហ.ត គឺ ២តោន ធៀបនឹង ១,៥តោនបើមិនភ្ជួរ ។ តាមធម្មតា តំលៃភ្ជួរខ្ពស់ដល់ ១២០.០០០រៀល/ហ.ត

ធៀបនឹងគីរិត ៧៥.000រៀលនៅខេត្តកំពង់ចាម ។ រឿងនេះដោយសារដីថ្មីក្នុងខេត្តព្រះវិហារនៅមានឫសឈើច្រើនដែលធ្វើឱ្យពិបាកភ្ជួរ ។

ដោយសារដីមានជីជាតិល្អជាង សណ្តែកសៀងនៅខេត្តព្រះវិហារផ្តល់ផលចំណេញជាមធ្យមខ្ពស់ជាងនៅខេត្តកំពង់ចាម ទោះបីខេត្តព្រះវិហារនៅដាច់ស្រយាល ហើយការដឹកជញ្ជូនផលិតផលអស់សោហ៊ុយច្រើនជាងក៏ដោយ ។ មានឱកាសល្អជាច្រើនដើម្បីពង្រីកផលិតកម្មសណ្តែកសៀងនៅខេត្តព្រះវិហារ ប៉ុន្តែរឿងនេះធ្វើឱ្យថយចុះតំបន់ព្រៃឈើ ។ មានគ្រួសារជាច្រើនបានចាប់យកឱកាសនេះ ។ ឧទាហរណ៍ ៥0% នៃគ្រួសារក្នុងភូមិមួយចំនួនទើបធ្វើចំណាកស្រុកថ្មីៗមកពីខេត្តដទៃ ។ សំណួរសំខាន់ៗជាច្រើនដែលទាក់ទងនឹងចំណុចនេះមានជាអាទិ៍៖ (១) តើមានផលចំណេញឬទេក្នុងការប្រែក្លាយដីព្រៃទៅជាកសិដ្ឋាន? (២) បើសិនព្រៃឈើគួរកាត់បន្ថយដើម្បីបង្កើនការធ្វើកសិកម្ម តើដីថ្មីគួរបែងចែកយ៉ាងណា? បច្ចុប្បន្ន ការរានព្រៃជាអំពើល្មើសច្បាប់ ទោះបីវានៅតែកើតមានឡើង ដោយផ្តល់ផលប្រយោជន៍ទៅឱ្យអ្នកដែលហ៊ានប្រថុយ ឬអ្នកមានអំណាចធ្វើដូច្នេះបាន ។

*៣.២.២.២. ផលិតកម្មពោត*

ពោត (ធញ្ញជាតិមួយទៀតដែលមានធ្វើជាពាណិជ្ជកម្មជាអន្តរជាតិ) គឺជាដំណាំពេញនិយមមួយដែលមានដាំក្នុងគ្រប់ខេត្តនៅកម្ពុជា ។ ពោតមិនទាមទារដីគុណភាពល្អដូចសណ្តែកសៀងទេ ថ្វីបើដីល្អផ្តល់ទិន្នផលខ្ពស់ជាងក្តី ។ យោងតាម FAO (FAO, 2000) កម្ពុជា វៀតណាម និងថៃ សុទ្ធតែជាប្រទេសនាំចេញពោត ។ ពោតពីរប្រភេទមានដាំនៅកម្ពុជាគឺ ពោតស សំរាប់មនុស្សបរិភោគនៅក្នុងស្រុក និងពោតក្រហមដែលភាគច្រើនសំរាប់ផលិតចំណីសត្វ និងការនាំចេញ ។ កសិករកម្ពុជាជាច្រើន ក៏មានដាំពោតជាខ្នាតតូចក្នុងលក្ខណៈដំណាំបន្ទាប់បន្សំដែរ ។

យោងតាមស្ថិតិ MAFF ផលិតកម្មពោតមានសារៈសំខាន់នៅគ្រប់ខេត្ត-ក្រុង ។ តែខេត្តបាត់ដំបងលេចធ្លោជាងគេ ដោយសារមានចំណែក ៧៤% នៃផលិតកម្មពោតសរុបនៅឆ្នាំ២00១ និង ៦២%នៅឆ្នាំ២00២ ។ ដូចមានបង្ហាញក្នុងតារាង៤ ផលិតកម្មពោតនៅបាត់ដំបង បានកើនឡើងយ៉ាងលឿនក្នុងរយៈពេលដ៏ខ្លីមួយ ។ កំណើនជាងបីដងក្នុងផលិតកម្មពីឆ្នាំ១៩៩៩ ដល់

២០០២ គឺជាលទ្ធផលនៃកំណើនទ្វេទាំងផ្ទៃដីប្រមូលផល និងទិន្នផល/ហ.ត ។ ទិន្នផលជាមធ្យម បានកើនពី ១,៧២ ដល់ ២,៨៦តោន/ហ.ត ។ ផ្អែកលើការចុះសិក្សាដល់កន្លែង ទិន្នផលពោតជាមធ្យមនៅបាត់ដំបងគឺ ៥តោន/ហ.ត ។ ទិន្នផល ១,៧២តោន/ហ.តនៅឆ្នាំ១៩៩៩ និង ២,៨៦តោន/ហ.ត នៅឆ្នាំ២០០២ បានកត់ត្រានេះ ប្រហែលអាចជាកំហុសមួយនៅក្នុងរបាយការណ៍រដ្ឋបាល ។

## តារាង ៤. តំបន់ប្រមូលផល ទិន្នផល និងផលិតកម្មពោត

| ខេត្ត | តំបន់ប្រមូលផល (ហ.ត) | | | ទិន្នផល (តោន/ហ.ត) | | | ផលិតកម្ម (តោន) | | |
|---|---|---|---|---|---|---|---|---|---|
| | 1999 | 2001 | 2002 | 1999 | 2001 | 2002 | 1999 | 2001 | 2002 |
| បាត់ដំបង | 14,025 | 29,648 | 32,409 | 1.72 | 4.63 | 2.86 | 24,077 | 137,152 | 92,778 |
| កណ្ដាល | 14,268 | 10,682 | 9,403 | 1.87 | 1.35 | 1.58 | 26,676 | 14,390 | 14,854 |
| កំពង់ចាម | 13,197 | 5,374 | 8,035 | 1.61 | 0.89 | 1.07 | 21,296 | 4,772 | 8,604 |
| បន្ទាយមានជ័យ | 4,624 | 7,598 | 8,435 | 1.13 | 1.14 | 1.11 | 5,203 | 8,698 | 9,329 |
| ព្រៃវែង | 2,246 | 2,190 | 1,684 | 1.59 | 1.51 | 1.60 | 3,582 | 3,310 | 2,690 |
| ក្រចេះ | 2,342 | 1,812 | 1,703 | 1.40 | 1.41 | 1.52 | 3,272 | 2,553 | 2,594 |
| ខេត្តផ្សេងៗ | 9,037 | 9,909 | 9,925 | .. | .. | .. | 11,168 | 14,714 | 18,048 |
| សរុប | 59,739 | 67,213 | 71,594 | 1.59 | 2.76 | 2.08 | 95,274 | 185,589 | 148,897 |

*ប្រភព: MAFF "ស្ថិតិកសិកម្ម ១៩៩៩-២០០០, ២០០១-០២ និង ២០០២-០៣" ។*

ផលិតកម្មពោតនៅបាត់ដំបងពីឆ្នាំ១៩៩៩ ដល់ ២០០០ ក៏ស្ទុះឡើងខ្លាំងដែរក្នុងស្ថិតិរបស់ MAFF ដែលមានការខុសប្លែកគ្នា ។ ផលិតកម្មពោតនៅបាត់ដំបង ដែលបានកត់ត្រាគឺ ២៤.០៧៧តោននៅឆ្នាំ១៩៩៩ ហើយស្ទុះឡើងដល់ ៩៩.៨៨៥តោននៅឆ្នាំ២០០០ ។ មូលហេតុនៃបាតុភូតនេះគឺ ៣ស្រុក (កំរៀង ភ្នំព្រឹក និងសំពៅលូន) ស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅឡើយ ដូច្នេះគ្មានបញ្ចូលក្នុងស្ថិតិខេត្តទេរហូតដល់ឆ្នាំ១៩៩៩ ។ ស្រុកទាំង៣ មានដីខ្មៅដីជាតិល្អ និងមានសំណើមគ្រប់គ្រាន់សមស្របណាស់សំរាប់ផលិតកម្មពោត ។ ម្យ៉ាងទៀតមានលទ្ធភាពទាក់ទងផ្ទាល់ទៅទីផ្សារនៅព្រំដែនថៃ ។ ស្រដៀងនឹងខេត្តព្រះវិហារដែរ ក្នុងស្រុកទាំងនេះមានការរានដីយ៉ាងលឿន ដូច្នេះមានសក្ដានុពលខ្ពស់ណាស់សំរាប់ការពង្រីកផលិតកម្ម

ពោត ។ សំរាប់ការសិក្សានេះ ការចុះសិក្សាដល់កន្លែង បានធ្វើនៅស្រុកផលិតពោតសំខាន់ៗបី នៅបាត់ដំបង ដើម្បីបានយល់ដឹងកាន់តែច្បាស់ពីផលិតកម្ម និងម៉ាឃីទីង ។

តារាង៤ បង្ហាញពីភាពខុសគ្នាខ្លះៗរវាងខេត្តកសិកម្មធំបងៗផ្សេងទៀត ។ ឧទាហរណ៍ នៅខេត្តកណ្តាល និងកំពង់ចាម មានការថយចុះច្រើនក្នុងផលិតកម្មពោត ស្របគ្នានឹងការធ្លាក់ចុះយ៉ាងខ្លាំងនៃទិន្នផល ។ នៅខេត្តកណ្តាលពីឆ្នាំ១៩៩៩-២០០១ ផ្ទៃដីប្រមូលផលថយចុះជិត ៥០% ហើយទិន្នផលថយចុះ ២៨% ។ កត្តាទាំងពីរនេះ បានបញ្ចុះផលិតកម្មពី ២៦.៦៧៦តោន ដល់ ១៤.៣៩០តោន ។ ផលិតកម្មពោតនៅកំពង់ចាមមានការថយចុះកាន់តែច្រើន ដល់ទៅ ៣ដង ។ យោងតាមការសំភាសន៍ជាមួយអ្នកលក់ដុំ មូលហេតុចំបង់គឺ កសិករប្តូរទៅដាំដំណាំផ្សេងដែលផ្តល់ផលចំណេញច្រើនជាង ពីព្រោះទីផ្សារពោតនៅវៀតណាមនៅនឹងស្ពឹកមិនរីកចំរើនទៅមុខ ។

### *ការសង្កេតលើផលិតកម្មពោតនៅបាត់ដំបង*

ផលិតកម្មពោតនៅបាត់ដំបង ប្រមូលផ្តុំក្នុង ៣ស្រុក គឺ សំពៅលូន ភ្នំព្រឹក និងកំរៀង (តារាង ៤) ។ យោងតាមស្ថិតិផ្លូវការ ១០ស្រុកផ្សេងទៀតនៅក្នុងខេត្ត មានផលិតកម្មពោតតិចតួចណាស់ ។ ស្រុកទាំង៣ នៅជាប់ព្រំដែនថៃ និងស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមរហូតដល់ឆ្នាំ១៩៩៨ ។ កសិដ្ឋានភាគច្រើន ស្ថិតនៅលើដីថ្មីទើបរានបានពីដីព្រៃ ហើយគេដាំពោតក្រហមសំរាប់នាំចេញទៅថៃ ។ ក្រុមហ៊ុនផលិតកម្មចិញ្ចឹមសត្វ C.P. ដែលមានទីតាំងនៅភ្នំពេញ បានទិញយកតែមួយភាគតូចនៃផលិតកម្មសរុបប៉ុណ្ណោះ ។

ដូចមានបង្ហាញក្នុងតារាង៥ ផ្ទៃដីផលិតកម្មពោតក្រហមសរុបនៅបាត់ដំបង កើនពី ១២.២៧៤ហ.ត នៅឆ្នាំ១៩៩៩ ដល់ ៣០.៣៨៣ហ.តនៅឆ្នាំ២០០១ ។ តួលេខនេះមិនដូចបេះបិទនឹងតួលេខកត់ត្រានៅកំរិតជាតិ ដូចមានចុះក្នុងតារាង៣ នោះទេ ប៉ុន្តែតួលេខខុសគ្នាមានទំហំតូចអាចមិនបាច់គិតគូរបាន ។ ក្នុងទិន្នផលមធ្យម ៥តោន/ហ.ត ផលិតកម្មពោតឆ្នាំ២០០២ មានប្រហែល ១៥០.០០០តោន ឬ ១២លានដុល្លារ គិតតាមតំលៃនៅកសិដ្ឋាន ៨០ដុល្លារ/តោន ។ ប៉ុន្តែតាមការសំភាសន៍ជាមួយមន្ត្រីស្រុក ផ្ទៃដីផលិតកម្មរាយការណ៍ជាផ្លូវការនៅ

ថ្នាក់ខេត្ត ដូចមានចុះក្នុង តារាង៤ គឺតិចជាងផ្ទៃដីជាក់ស្តែងឆ្ងាយណាស់ ។ ឧទាហរណ៍ ប្រធានការិយាល័យកសិកម្មស្រុកកំរៀងរាយការណ៍ថា ផ្ទៃដីដាំពោតមាន ១៩.០០០ហ.តនៅឆ្នាំ ២០០២ បើធៀបនឹង ១២.៧១៣ហ.ត ដែលបានកត់ត្រានៅមន្ទីរកសិកម្មខេត្ត ។ ដូច្នេះ ផលិតកម្មពោតជាក់ស្តែង គួរមានតួលេខខ្ពស់ជាងនេះច្រើនណាស់ ។

**តារាង ៥. ផ្ទៃដីផលិតកម្មពោតក្រហមក្នុងស្រុកនានានៅខេត្តបាត់ដំបង ១៩៩៩ - ២០០២** ( ហ.ត)

| ស្រុក | 1999 | 2000 | 2001 | 2002 |
|---|---|---|---|---|
| សំពៅលូន | 8,000 | 10,598 | 12,472 | 12,713 |
| ភ្នំព្រឹក | 585 | 3,308 | 9,500 | 8,600 |
| កំរៀង | 3,615 | 6,596 | 8,357 | 8,221 |
| ស្រុកផ្សេងទៀត | 74 | 299 | 54 | 139 |
| សរុប | 12,274 | 20,801 | 30,383 | 29,673 |

*ប្រភព: "ស្ថិតិដំណាំឧស្សាហកម្មនិងបន្ទាប់បន្សំ" ឯកសារចេញផ្សាយពីឆ្នាំ១៩៩៩-២០០២ មន្ទីរកសិកម្មខេត្តបាត់ដំបង ។*

នៅបាត់ដំបង គេច្រើនដាំពោតនៅខែមីនា-មេសា ហើយប្រមូលផលនៅខែកក្កដា-សីហា ។ ពោតអាចដាំបានដែរនៅចន្លោះខែសីហា និងធ្នូ នៅពេលសំណើមនៅមានគ្រប់គ្រាន់នាចុងរដូវវស្សា។ ដំណាំពោតត្រូវចំនាយ១២០ថ្ងៃ ទើបអាចប្រមូលផលបាន ។ នៅរដូវប្រាំង តាមធម្មតាកសិករដាំដំណាំផ្សេងដែលត្រូវការទឹកតិច ដូចជាសណ្តែកបាយ សណ្តែកដី ឬសណ្តែកសៀង ។ បន្ទាប់មក កសិករជួបបញ្ហាត្រូវជ្រើសមុខដំណាំណាដែលត្រូវដាំក្នុងចំណោមពោត ដំឡូងឈើ សណ្តែកសៀង និងសណ្តែកបាយ ។ ការស្រាវជ្រាវរកឃើញថា ក្នុងកិរិតណាមួយ កសិករមួយចំនួនបានផ្លាស់ប្តូរចុះឡើងក្នុងចំណោមដំណាំផ្សេងៗ សំដៅរកផលចំណេញឱ្យបានច្រើន ដើម្បីឆ្លើយតបនឹង "សញ្ញាទីផ្សារ" ឬការផ្លាស់ប្តូរក្នុងកំរិតថ្លៃប្រៀបធៀប ។ ឧទាហរណ៍ នៅរដូវប្រាំងឆ្នាំ២០០៣ កសិករជាច្រើនចាប់ផ្តើមដាំដំឡូងឈើជំនួសពោតវិញ ។

រហូតដល់ពេលថ្មីៗនេះ គេទិញពូជពោតមកពីថៃ ។ ប៉ុន្តែកាលពី ២ឆ្នាំមុន ក្រុមហ៊ុន C.P. ដែលមានម្ចាស់ជាថៃដែរនោះ បានផ្សព្វផ្សាយជំរុញពូជពោតរបស់ខ្លួន ហើយកសិករនៅ

បាត់ដំបងជាច្រើននាក់បានដាំវាសាកមើល ។ ពូជមួយបាវ ១៤គ.ក ថ្លៃ ១.២០០បាត ឬ ១១៤.០០០រៀល ។ យោងតាមការឆ្លើយសំភាសន៍ តំលៃនេះនៅថេរ ២-៣ឆ្នាំមកហើយ[២៩] ។

សព្វថ្ងៃ ការងារដាំដុះភាគច្រើនធ្វើដោយម៉ាស៊ីន និងកំលាំងពលកម្មស៊ីឈ្នួល ។ ការភ្ជួររាស់ដោយត្រាក់ទ័រ ចាប់ផ្តើមនៅខែមីនា ក្រោយពីសណ្តែក និងដំណាំផ្សេងទៀតប្រមូលផលរួចភ្លាម ។ តំលៃភ្ជួររាស់ដីគឺ ២៥០-២៨០បាត/រ៉ៃ[៣០] ។ តំលៃនេះគឺប្រហែល ១៥៤.០០០រៀល ឬ ៣៨ដុល្លារ/ហ.ត ។ គេត្រូវភ្ជួរដី ២លើកៈ លើកទី១ ភ្ជួរដោយត្រាក់ទ័រមាន ៧ស្លាប និងលើកទី២ ភ្ជួរដោយត្រាក់ទ័រមាន ៣ស្លាប ។ ចំពោះកសិដ្ឋានថ្មីដែលនៅមានឫសឈើច្រើន កសិករច្រើនតែមិនភ្ជួរទេ ពីព្រោះដីនៅមានជីជាតិល្អ ហើយថ្លៃភ្ជួរខ្ពស់ ២ដង ជាងកសិដ្ឋានគ្មានឫសឈើ ។

### តារាង ៦. ថវិកាផលិតកម្មពោតនៅ ៣ស្រុកក្នុងខេត្តបាត់ដំបងនាឆ្នាំ២០០២

| មុខចំណាយ | បាត/ហ.ត[ក] | រៀល/ហ.ត | ដុល្លារ/ហ.ត |
|---|---|---|---|
| ពូជ (២.៥០០រៀល x ៥០គ.ក) | 1,875 | 178,125 | 45 |
| ការរៀបចំដី | 3,125 | 296,875 | 74 |
| ការដាំ | 750 | 71,250 | 18 |
| ការជំរះស្មៅ | 1,250 | 118,750 | 30 |
| ការប្រមូលផល | 2,500 | 237,500 | 59 |
| សរុបចំណាយជាបាត | 9,500 | 902,500 | 226 |
| ផលចំណេញដុលជាមធ្យម | 15,000 | 1,425,000 | 356 |
| ផលចំណេញសុទ្ធ | 5,500 | 522,500 | 131 |
| បន្ទុកចំណាយលើការជួល/ឱកាសប្រើដី | 1,500 | 148,438 | 37 |

*[ក] ក្នុងតំបន់ដែលសិក្សា ថ្លៃគ្រប់ប្រភេទគេកំណត់ជាបាត ។ ប្រភពៈ សំភាសន៍ជាមួយកសិករ ៤នាក់នៅបាត់ដំបង ខែមីនា ២០០៣ ។*

[២៩] នៅតំបន់ភាគច្រើននៃខេត្តបាត់ដំបង គេប្រើប្រាក់បាតជាទូទៅជាងប្រាក់រៀល ។ ថ្លៃគ្រប់ប្រភេទត្រូវបានកំណត់ និងរាយការណ៍ជាប្រាក់បាតថៃ ។

[៣០] "រ៉ៃ" ជារង្វាស់ផ្ទៃក្រឡាមួយប្រើនៅថៃ ។ ១រ៉ៃ ស្មើនឹង ៤០ម. x ៤០ម. ឬ ១.៦០០ម$^{២}$ ។ ដូច្នេះ ១ហ.ត ស្មើនឹង ៦,២៥រ៉ៃ ។

បច្ចុប្បន្ន កសិករមួយចំនួនតូចប្រើថ្នាំគីមីជំនួសកំលាំងពលកម្មជំរះស្មៅ ។ ប៉ុន្តែកសិករភាគច្រើនបានដឹងពីគ្រោះថ្នាក់នៃថ្នាំគីមី ហើយបន្តជួលកំលាំងពលកម្មឱ្យជំរះស្មៅ ។ អត្រាកំរៃកំលាំងពលកម្មប្រចាំថ្ងៃ គឺប្រហែល ៥០បាត ឬ ៤.៥០០រៀល/ថ្ងៃ ។ កម្មករភាគច្រើនជាជនចំណាកមកពីតំបន់ផ្សេងទៀតនៃកម្ពុជា ។ ពួកគេធ្វើការទាំងនៅកម្ពុជា និងថៃ និងភាគច្រើនជាការងារកសិដ្ឋាន ។ ពតិមានលំអិតស្ដីពីថវិកាផលិតកម្មពោតមានចុះក្នុងតារាង៦ ។

សរុបមក ៣ស្រុកដែលផលិតពោតក្នុងខេត្តបាត់ដំបង មានជីវភាពធូរធារ ។ មូលហេតុសំខាន់ គឺដីសំបូរ និងមានជីជាតិល្អណាស់ ។ គ្រួសារជាមធ្យម មានដីប្រហែល ៦ហ.ត ដែលផ្ដល់ផលចំណេញសុទ្ធប្រហែល ១.០០០ដុល្លារ/ឆ្នាំ (Chan and Charya, 2003) ។ ប៉ុន្តែ សព្វថ្ងៃគំលាតចំណូលបានផុសឡើង បន្ទាប់ពីការិតចំណូលទាបនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅមុនឆ្នាំ១៩៩៨ ។ អ្នកមានអំណាចខ្លាំង ទទួលបានដីច្រើនជាង និងបានក្លាយជាអ្នកមានដោយមានដី ២០-៣០ហ.ត/គ្រួសារ ។ ភូមិខ្លះ។ដូចជា ស្រឡៅជ្រំ ជាដើម គឺមានត្រាក់ទ័រប្រហែល ១០-៥០គ្រឿង ដែលមានតំលៃ ៥.០០០-៦.០០០ដុល្លារ/គ្រឿង ដូច្នេះប្រសើរច្រើនណាស់ជាងភូមិឯទៀត។នៅកម្ពុជា ។ តាមការប្រមើល តំបន់ទាំងនេះមានអនាគតល្អ ទោះបីអាចបាត់បង់ព្រៃអស់ក៏ដោយ ។

### *៣.២.២.៣ ផលិតកម្មដំឡូងមី/ឈើ*

គេផលិតដំឡូងឈើភាគច្រើនសំរាប់ការប្រើប្រាស់ក្នុងស្រុក ជានំចំណី ឬអាហារបំពេញបន្ថែមលើបាយនៅទូទាំងកម្ពុជា ។ ដំឡូងឈើងាយដាំដុះណាស់ ហើយគ្រួសារជាច្រើនបានដាំវាក្នុងច្បារតាមផ្ទះ ។ "ដំឡូងមី" ជាដំណាំក្នុងអំបូរដូចគ្នា ប៉ុន្តែគេកែច្នៃវាទៅជាម្សៅសំរាប់ធ្វើអាហារមនុស្ស និងចំណីសត្វ ។ ក្នុងប្រទេសមួយចំនួន គេប្រើពាក្យ "ដំឡូងឈើ" និង "ដំឡូងមី" ជំនួសគ្នាចុះឡើង ។ ក្នុងស្ថិតិរដ្ឋាភិបាល គេប្រើពាក្យដំឡូងឈើ សំរាប់ទាំងដំឡូងឈើ និងដំឡូងមី ។ ដើម្បីសំរួលការងារ ឯកសារនេះបានប្រើពាក្យដំឡូងឈើសំរាប់ទិន្នន័យផលិតកម្មក្នុងតារាង៧ ។ ប៉ុន្តែការសិក្សារបស់យើងផ្ដោតលើដំឡូងមី ហើយនឹងប្រើពាក្យនេះក្នុងការពិភាក្សាលំអិតពីដំណាំនេះ ។

ដំឡូងមីមានតំលៃទាបប្រហែល ២០ដុល្លារ/តោន ។ ប៉ុន្តែដីល្អមួយហិកតាផ្តល់ផល ដំឡូង ៣០តោន ឬផលចំណេញដុល ៦០០ដុល្លារ ។ តួលេខនេះខ្ពស់ជាខ្លាំងជាងស្រូវដែលផ្តល់ជាមធ្យម ២២០ដុល្លារ/តោន ។ នៅឆ្នាំ២០០២ ផលិតកម្មសរុបដំឡូងឈើ/មី មានប្រហែល ១២២.០១៤តោន ។ ក្នុងតំលៃ ២០ដុល្លារ/តោន, ចំណូលដុលដល់សេដ្ឋកិច្ចកម្ពុជា មាន ២,៤លានដុល្លារ ដែលអាចជាតួលេខតូចបន្តិចក្នុងបរិបទសេដ្ឋកិច្ចកម្ពុជាទាំងមូល ។ ប៉ុន្តែស្ថិតិនានាហាក់ដូចទាបជាងការពិតច្រើនណាស់ យោងតាមការស៊ើបសួរដល់កន្លែងរបស់យើង ។ ឧទាហរណ៍ ក្នុងតំបន់ខ្លះ នៅកំពង់ចាម និងបាត់ដំបង ផលិតកម្មដំឡូងឈើដែលគេរាយការណ៍វាធំពីរដងជាងចំនួនចុះក្នុងស្ថិតិផ្លូវការនានា ។

ដោយសារសមត្ថភាពកែច្នៃមានកំរិតនៅកម្ពុជា ដំឡូងមីនៅភាគច្រើន បាននាំចេញទៅវៀតណាម និងថៃ ដើម្បីកែច្នៃ ។ យោងតាមស្ថិតិ MAFF បង្ហាញក្នុងតារាង៧, ខេត្តផលិតដំឡូងមីចំបង៧គឺ កំពង់ចាម កំពង់ធំ និងសៀមរាប ។ ផលិតកម្មដំឡូងឈើសរុប ថយចុះពី ២២៨.៦២២តោននៅឆ្នាំ១៩៩៩ មកត្រឹម ១៤២.២៦២តោននៅឆ្នាំ២០០១ និងចុះដល់ ១២២.០១៤តោននៅឆ្នាំ២០០២ ។ ការធ្លាក់ធ្ងន់ធ្ងរបែបនេះ គឺដោយសារការថយចុះទិន្នផលយ៉ាងខ្លាំងពី ១៦តោន/ហ.តនៅឆ្នាំ១៩៩៩ មក ១០តោន/ហ.ត នៅឆ្នាំ២០០១ និង ៤,៧តោន/ហ.តនៅឆ្នាំ២០០២ ។ ការធ្លាក់ចុះមានមូលហេតុមិនច្បាស់លាស់សោះ ហើយមន្ត្រី MAFF មិនអាចបកស្រាយបានទេ ។ វាអាចគ្រាន់តែជាកំហុសក្នុងស្ថិតិ ឬការរាយរបាយការណ៍ក្នុងបែបបទរដ្ឋបាលខុស ។ ឧទាហរណ៍ ការចុះសិក្សាដល់កន្លែងនៅកំពង់ចាមរកឃើញថា ទិន្នផលដំឡូងមីជាមធ្យមគឺ ២០តោន/ហ.ត ដូចមុននៅឆ្នាំ២០០២ និង ២០០៣ ។ គេក៏សង្កេតឃើញកំហុសស្រដៀង៧គ្នា ក្នុងទិន្នន័យរបស់ខេត្តបាត់ដំបង និងក្រចេះ ។ ការធ្លាក់ចុះនៅឆ្នាំ២០០១ ប្រហែលដោយសារ "រឿងស្ថិតិ" ជាជាងការពិតជាក់ស្តែង ។

ដោយសារមានដីសំបូរនៅកំពង់ចាម បាត់ដំបង រតនគិរី និងមណ្ឌលគិរី សក្តានុពលសំរាប់ពង្រីកផលិតកម្មដំឡូងឈើមានច្រើនណាស់ ។ នៅស្រុកខ្លះក្នុងបាត់ដំបង ទិន្នផលដំឡូងមី គឺ ៥០តោន/ហ.តនៅឆ្នាំ២០០២

យោងតាមការចុះសិក្សាដល់កន្លែងរបស់យើង ។ ប៉ុន្តែទិន្នផលមធ្យមកត់ត្រាជាផ្លូវការសំរាប់ខេត្តបាត់ដំបង បានតែ ៦,១៨ តោន/ហ.ត ដែលខុសឆ្ងាយពីគ្នាគួរកត់សំគាល់ ។ ការធ្លាក់ចុះទិន្នផលយ៉ាងខ្លាំងក្នុងខេត្តផ្សេងទៀត ដូចជា កំពត ស្ទឹងត្រែង និងក្រចេះ គួរឱ្យសង្ស័យខ្លាំងណាស់ និងគួរពិនិត្យមើលដោយប្រុងប្រយ័ត្ន ។

**តារាង ៧. ផ្ទៃដីប្រមូលផល ទិន្នផល និងផលិតកម្មដំឡូងឈើ[ក]**

| ខេត្ត | ផ្ទៃប្រមូលផល (ហ.ត) | | | ទិន្នផល (តោន/ហ.ត) | | | ផលិតកម្ម (តោន) | | |
|---|---|---|---|---|---|---|---|---|---|
| | 1999 | 2001 | 2002 | 1999 | 2001 | 2002 | 1999 | 2001 | 2002 |
| កំពង់ចាម | 4,855 | 4,740 | 8,532 | 21.36 | 14.15 | 4.74 | 103,700 | 67,051 | 40,421 |
| កំពង់ធំ | 940 | 1,880 | 1,321 | 11.83 | 10.46 | 7.66 | 11,120 | 19,660 | 10,125 |
| សៀមរាប | 845 | 865 | 1,060 | 14.64 | 11.84 | 15.62 | 12,375 | 10,243 | 16,555 |
| បាត់ដំបង | 619 | 146 | 949 | 19.04 | 6.18 | 11.43 | 11,785 | 903 | 10,847 |
| កំពត | 1,059 | 770 | 800 | 16.53 | 5.18 | 7.71 | 17,510 | 3,990 | 6,169 |
| ស្ទឹងត្រែង | 943 | 150 | 223 | 11.86 | 4.00 | 4.34 | 11,180 | 600 | 968 |
| ក្រចេះ | 607 | 334 | 120 | 16.84 | 9.03 | 15.13 | 10,220 | 3,016 | 1,816 |
| ខេត្តផ្សេងៗ | 4,135 | 4,705 | 6,279 | .. | .. | .. | 50,622 | 36,799 | 33,113 |
| សរុប | 14,003 | 13,590 | 19,284 | 16.32 | 10.47 | 6.33 | 228,512 | 142,262 | 122,014 |

*[ក] យោងតាមប្រធានការិយាល័យស្ថិតិនៃក្រសួងកសិកម្ម, ដំឡូងមីបានបូកបញ្ចូលក្នុងទិន្នន័យដំឡូងឈើ ។*
*ប្រភព: MAFF "ស្ថិតិកសិកម្ម ១៩៩៩-២០០០, ២០០១-០២ និង ២០០២-០៣" ។*

មានសញ្ញាខ្លះបង្ហាញថា ផលិតកម្មដំឡូងឈើនៅកំពង់ចាមកំពុងកើនឡើង ព្រោះឥលូវនេះមានរោងចក្រកែច្នៃដំឡូងឆៅនៅក្នុងខេត្តផ្ទាល់ ។ រោងចក្រស្រូបយកប្រហែល ១ភាគ៣នៃផលិតកម្មក្នុងខេត្ត ចំណែកឯ ២ភាគ៣ ទៀត ត្រូវរកទីផ្សារនៅវៀតណាមជាទូទៅតាមច្រក មិនផ្លូវការ ។ ដោយសារដំឡូងឈើឆៅវាធ្ងន់ និងមានតំលៃទាបដូច្នេះការពឹងផ្អែកលើការ នាំចេញដំឡូងមិនកែច្នៃទៅវៀតណាមប្រហែលមិនអាចរស់រានបានទេ ។ ការបង្កើតរោងចក្រ កែច្នៃនិងកែលំអហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន អាចផ្តល់គ្រឿងលើកទឹកចិត្តចំទិសដៅមួយសំរាប់ការពង្រីកផលិតកម្មដំឡូងឈើ ។ ដោយសារជាតំបន់ផលិតដំឡូងឈើធំជាងគេ ដូច្នេះបាន

ជ្រើសយកខេត្តកំពង់ចាមធ្វើជាកន្លែងចុះសិក្សា ដើម្បីបានយល់ដឹងកាន់ស៊ីជម្រៅពីផលិតកម្ម ម៉ាឃីទីង ការនាំចេញ និងការកែច្នៃដំឡូងមី ។

### *ការសង្កេតលើផលិតកម្មដំឡូងមីនៅមេមត់ ខេត្តកំពង់ចាម*

ដីក្រហមនៅខេត្តកំពង់ចាម សមស្របល្អណាស់សំរាប់ផលិតកម្មដំឡូងមី ។ កសិករភាគច្រើនមានដីកសិកម្ម ២-៣ហ.ត[៣១] ។ នៅតំបន់ខ្លះ ទិន្នផលខ្ពស់ដល់ ៣៥តោន/ហ.ត បើសិនមានដីល្អ និងការគ្រប់គ្រងល្អលើការដាំដុះ ។ ប៉ុន្តែទិន្នផលមធ្យមនៅកំពង់ចាម បានប្រហែល ២០តោន/ហ.ត បើគ្មានប្រើជី ។ ដោយម្ចាស់កសិដ្ឋានជាច្រើនពុំមានលទ្ធភាពភ្ជួរ ទិន្នផលមធ្យមក៏ត្រូវថយចុះ ពីព្រោះទិន្នផលនៅកសិដ្ឋានទាំងនេះ បានប្រហែល ១៥តោន/ហ.ត ។ ទោះយ៉ាងនេះក្តី ទិន្នផលនៅតែខ្ពស់ច្រើនជាងនៅតំបន់ឯទៀត លើកលែងតែនៅបាត់ដំបងដែលដីមានគុណភាពល្អជាង ។ ឧទាហរណ៍ នៅក្រុងព្រះសីហនុ និងកំពង់ស្ពឺ រោងចក្រកែច្នៃរបស់ក្រុមហ៊ុន ម៉ុង រិទ្ធី ដែលនៅទីនោះបានបិទទ្វារ ដោយសារការផ្គត់ផ្គង់ដំឡូងមីមានចំនួនមិនគ្រប់គ្រាន់ ដោយទិន្នផលនៅទីនោះបានប្រហែលតែ ៨តោន/ហ.ត ។

គេដាំដំឡូងឈើនៅខែមេសា-ឧសភា ហើយប្រមូលផលនៅខែធ្នូ-មីនា ។ ទោះជាការប្រមូលផលអាចពន្យាពេលបានក្តី ប៉ុន្តែរយៈពេលដាំដុះប្រសើរបំផុតដើម្បីកិនយកម្សៅបានច្រើនជាអតិបរមាគឺ ១០ខែ ។ ជាលទ្ធផល គេអាចដាំបានតែម្តងទេក្នុងមួយឆ្នាំ ។ គេយកដើមដំឡូងមកពីវៀតណាមក្នុងតំលៃ ១៥០រៀល/២ម៉ែត្រដើមដំឡូង ។ ពូជដើមដំឡូងនេះ គេអាចយកវាទៅដាំបានដើមដំឡូងជាច្រើនថែមទៀត ។

ការដាំដំឡូងមីមានលក្ខណៈសាមញ្ញបំផុត ។ ការងារមានជាអាទិ៍ ការរៀបចំដី ការដាំ ការជំរះស្មៅ និងការប្រមូលផល ។ ក្នុង៥ឆ្នាំកន្លងមក នៅកសិដ្ឋានជាច្រើនគេប្រើត្រាក់ទ័រជំនួសសត្វអូសទាញ ដើម្បីរៀបចំដី ។ ហើយការជំរះស្មៅធ្វើ ២ដងក្នុងរយៈពេលដាំដុះ និងត្រូវជួលកំលាំងពលកម្មក្នុងតំលៃប្រហែល ៣.៥០០រៀល/ថ្ងៃ/ម្នាក់ៗ ។ ការប្រមូលផលក៏ធ្វើ

[៣១] កសិករជាច្រើន (ភាគច្រើនជាអ្នកតាំងទីលំនៅថ្មីនៅក្នុងតំបន់សិក្សា) ជាអ្នកគ្មានដីទេ ។

ដោយកម្មករដែរ ។ ចំណាយសរុប គឺប្រហែល ១៧០ដុល្លារ/ហ.ត ឬ ៣០% នៃចំណូលដុល ចំពោះកសិដ្ឋានដែលបានភ្ជួររាស់ ។ ពតិមានលំអិតនៃថវិកាដាំដំណាំមានបង្ហាញក្នុងតារាង៨ ។

**តារាង ៨. ថវិកាផលិតកម្មដំឡូងឈើនៅខេត្តកំពង់ចាមក្នុងឆ្នាំ២០០២**

| មុខចំណាយ | រៀល/ហ.ត | ដុល្លារ/ហ.ត |
|---|---|---|
| ពូជ | 40,000 | 10 |
| ការរៀបចំដីលើកទី១ | 70,000 | 18 |
| ការរៀបចំដីលើកទី២ | 70,000 | 18 |
| ការដាំ | 50,000 | 13 |
| ការជំរះស្មៅលើកទី១ | 105,000 | 26 |
| ការជំរះស្មៅលើកទី២ | 105,000 | 26 |
| ការប្រមូលផល | 200,000 | 50 |
| សរុបចំណាយ | 640,000 | 160 |
| សរុបចំណាយរួមទាំងការជួលដី | 940,000 | 235 |
| ចំណូលដុលមធ្យម | 2,250,000 | 563 |
| ចំណូលសុទ្ធ ដកថ្លៃជួលដី | 1,610,000 | 403 |
| តំលៃ ជួលដី/ឱកាសប្រើដី | 300,000 | 75 |

*ប្រភព: កិច្ចសំភាសន៍ស៊ីជំរៅជាមួយកសិករបីនាក់នៅមេមត់ ខេត្តកំពង់ចាម មីនា ២០០៣ ។*

*សំគាល់: តួលេខខាងលើគឺជាការចំណាយជាសាច់ប្រាក់សុទ្ធ គ្មានគិតចូលការប្រើពលកម្មគ្រួសារទេ ។*

ក្នុងការទទួលផលចំណេញ អ្នកក្រត្រូវចាញ់ប្រៀបគេ ដោយសារគ្មានប្រាក់គ្រប់គ្រាន់សំរាប់ជួលត្រាក់ទ័រភ្ជួរដីកសិដ្ឋានដែលត្រូវចំណាយប្រហែល ៤០ដុល្លារ/ហ.ត សំរាប់ការភ្ជួរពីរដង ។ ឥណទានក្រៅផ្លូវការ ដែលអាចរកខ្ចីបានក្នុងអត្រាការប្រាក់ ១២០%/ឆ្នាំ វាថ្លៃហួសពេកសំរាប់ពួកគេ ។ ដីអ្នកក្រ ១ហ.ត ផ្តល់ផលប្រហែល ១៥តោន ធៀបនឹង ២៣តោន/ហ.ត សំរាប់អ្នកមានលទ្ធភាពភ្ជួរដីកសិដ្ឋានរបស់គេ ។ ដីបានភ្ជួរ និងមិនបានភ្ជួរ ផ្តល់ទិន្នផលខុសគ្នាប្រហែល ៨តោន ឬ ១៦០ដុល្លារ ។ ផ្អែកលើការចុះសិក្សាដល់កន្លែងពីដំបូងៗ កសិករក្រីក្រអាចរកប្រាក់បានប្រហែល ១០០ដុល្លារ/ហ.ត បើសិនគេអាចរកឥណទានបាន ។

### *៣.២.២.៤. ផលិតកម្មស្វាយចន្ទី*

ស្វាយចន្ទី ជាដំណាំរស់បានច្រើនឆ្នាំ គឺខុសប្លែកពីដំណាំបីប្រភេទខាងលើ ។ គ្រាប់ស្វាយចន្ទី ស្ថិតក្នុងចំណោមអាហារផ្តល់សុខភាពល្អដែលកាន់តែមានប្រជាប្រិយភាពក្នុងពិភពលោក ។ ឧទាហរណ៍ ឥណ្ឌា មានប្រវត្តិក្នុងការដាំ កែច្នៃ និងនាំចេញគ្រាប់ស្វាយចន្ទីដ៏យូរលង់មកហើយ ។ ដំណាំនេះ បង្កើតការងារបានច្រើនណាស់ ទាំងក្នុងផ្នែកផលិតកម្ម និងការកែច្នៃ (Kannan, 1983) ។ ជាទូទៅ គេដាំកូនស្វាយចន្ទីនៅរដូវវស្សា ហើយវាអាចរស់បានដល់ ៣០ឆ្នាំ ។ គេត្រូវចំណាយប្រាក់ ១០០ដុល្លារ ដើម្បីដាំស្វាយចន្ទីលើដីកសិដ្ឋានពាណិជ្ជកម្ម ១ហ.ត ។ ដើមស្វាយចន្ទី ចាប់មានផ្លែនៅ ៣ឆ្នាំក្រោយមក ហើយចំនួនផ្លែនឹងកើនឡើងជាបណ្តើរៗទៅតាមទំហំដើម ។ ស្វាយចន្ទី ១ហ.ត អាចផលិតគ្រាប់ជាប់សំបកបានពី ៥០០គ.ក ទៅ ២.០០០គ.ក ដែលសព្វថ្ងៃលក់បាន ៥៣០ដុល្លារ/តោន ។ ដូច្នេះ ដីមួយហិកតា អាចផ្តល់ចំណូលដុលជាមធ្យមប្រហែល ៣០០ដុល្លារ ។

ស្វាយចន្ទីមានដាំនៅកម្ពុជាជាយូរមកហើយ ប៉ុន្តែផលិតកម្មនេះទើបធ្វើពាណិជ្ជកម្មក្នុងប៉ុន្មានឆ្នាំថ្មីៗនេះទេ ។ ក្នុងទសវត្សរ៍កន្លងទៅ គេបានពង្រីកផលិតកម្មគួរកត់សំគាល់សំរាប់ការនាំចេញ ហើយទទួលបានច្រើនលានដុល្លារ សំរាប់សេដ្ឋកិច្ចកម្ពុជា ។ កសិដ្ឋានថ្មីៗជាច្រើនបានដាំស្វាយចន្ទី ហើយរឿងនេះទំនងកើនឡើងទៀតក្នុងអនាគត ។ ដោយស្វាយចន្ទីមានថ្លៃខ្ពស់នៅទីផ្សារអន្តរជាតិ កម្ពុជាមានសក្តានុពលពង្រីកដំណាំនេះថែមទៀតសំរាប់នាំចេញ ។ ក្នុង៣ឆ្នាំកន្លងមក ផលិតកម្មប្រចាំឆ្នាំសរុបនៅកម្ពុជាតាមការប៉ាន់ស្មានរបស់ពាណិជ្ជករ និងអ្នកលក់ដុំគឺពី ១០.០០០ ទៅ ១៥.០០០តោនគ្រាប់ស្វាយចន្ទីជាប់សំបក ដែលភាគច្រើននាំចេញទៅវៀតណាម ។

ស្ថិតិផ្លូវការស្ទើរតែគ្មានសោះទេសំរាប់ផលិតកម្មស្វាយចន្ទី ។ MAFF មានតែទិន្នន័យស្តីពីផ្ទៃដីដាំដុះប៉ុណ្ណោះដែលជាតួលេខប៉ាន់ស្មានច្បោលៗ ប្រហែលទាបហួសពេកហើយ ។ រឿងនេះដោយសារស្វាយចន្ទីជាច្រើនគេដាំវាក្នុងដីឡូត៍ផ្ទះ ឬក្នុងចំការដំណាំដែលពិបាកវាស់ផ្ទៃដីឱ្យបានជាក់លាក់ ។ ទោះយ៉ាងនេះក្តី ទិន្នន័យរបស់ MAFF ដូចមានចុះក្នុងតារាង៩ អាចជួយផ្តល់រូបភាពជារួមមួយនៃទំហំមុខដំណាំរស់បានយូរឆ្នាំនេះ ។

ស្វាយចន្ទីអាចដាំក្នុងលក្ខខណ្ឌច្រើនបែបយ៉ាង និងមានដីដាំស្វាយចន្ទីនៅគ្រប់ខេត្ត យោងតាមស្ថិតិ MAFF ។ ប៉ុន្តែក្នុងផ្ទៃដីដាំស្វាយចន្ទីសរុប ៣៦.២៨៥ហ.ត, ភាគច្រើនស្ថិតនៅខេត្តរតនគីរី កំពង់ចាម និងកំពង់ធំ ។ ថ្វីបើមានស្វាយចន្ទីជាច្រើនបានដាំនៅក្នុងចំការ ឬកសិដ្ឋានគ្រួសារ ប៉ុន្តែក្នុងចំការក្រុមហ៊ុនក៏មានដាំវាច្រើនដែរ ។ នៅកំពង់ចាម ចំការធំជាងគេមានទំហំប្រហែល ២.០០០ហ.ត ជារបស់ក្រុមហ៊ុនឯកជនឈ្មោះ Agrostar ។ ចំការនេះមានម្ចាស់ ១០នាក់ចូលហ៊ុនគ្នា និងតំណាងឱ្យជិត ២០%នៃផ្ទៃដីដាំស្វាយចន្ទីសរុបនៅកំពង់ចាម ។ រតនគីរីមានសក្តានុពលធំណាស់សំរាប់ពង្រីកផលិតកម្មស្វាយចន្ទី ពីព្រោះដីមានជីជាតិល្អ ។ នៅខេត្តនេះ ដើមស្វាយចន្ទីភាគច្រើនជារបស់ចំការក្រុមហ៊ុននានា ។ ប៉ុន្តែបញ្ហាទាក់ទិននឹងការកាន់កាប់ដី ក៏ត្រូវដោះស្រាយផងដែរ ។

**តារាង ៩. តំបន់ដាំស្វាយចន្ទីនៅកម្ពុជាពីឆ្នាំ២០០០ ដល់ ២០០២**

| ខេត្ត | ផ្ទៃដីបានដាំដុះ ( ហ.ត) | | |
|---|---|---|---|
| | 2000 | 2001 | 2002 |
| រតនគីរី | 917 | 15,848 | 16,485 |
| កំពង់ចាម | 10,872 | 10,872 | 10,758 |
| កំពង់ធំ | 4 | 1,016 | 2,744 |
| កោះកុង | 840 | 873 | 894 |
| កំពង់ស្ពឺ | 162 | 236 | 1,086 |
| ក្រចេះ | 228 | 228 | 1,295 |
| តាកែវ | 207 | 207 | 970 |
| បន្ទាយមានជ័យ | 427 | 427 | 1 |
| សៀមរាប | 416 | 416 | 390 |
| មណ្ឌលគីរី | 380 | 380 | 380 |
| កំពង់ឆ្នាំង | 376 | 379 | 226 |
| ពោធិសាត់ | 0 | 326 | 334 |
| កំពត | 319 | 5,796 | 305 |
| ស្វាយរៀង | 248 | 312 | 136 |
| ខេត្តផ្សេងទៀត | 257 | 357 | 281 |
| សរុប | 15,653 | 37,673 | 36,285 |

*សំគាល់: គ្មានទិន្នន័យស្តីពីស្វាយចន្ទីទេសំរាប់ឆ្នាំ១៩៩៩ ទោះបីនៅពេលនោះមានដាំវាហើយក៏ដោយ ។*
*ប្រភព: ក្រសួងកសិកម្ម "ស្ថិតិកសិកម្មឆ្នាំ១៩៩៩-២០០០, ២០០១-០២ និង ២០០២-០៣ ។*

ផ្ទៃដីដាំដុះសរុបក្នុងតារាង៩ មិនទាន់ផ្តល់ផលទាំងអស់ទេ ពីព្រោះដើមស្វាយចន្ទីដាំថ្មីត្រូវមានអាយុ ៣-៤ឆ្នាំ ទើបមានផ្លែ[៣២] ។ យោងតាមការចុះសិក្សាដល់កន្លែង ដី១ហ.ត ផ្តល់ផលជាគ្រាប់ជាប់សំបក ០,៥-២តោន ទៅតាមគុណភាពដី និងដំណាក់កាលលូតលាស់ ។ បើទិន្នផលមធ្យមបាន ១តោន/ហ.ត ដូច្នេះដើមពេញវ័យ ៣៦.២៨៥ហ.ត អាចផ្តល់គ្រាប់ស្វាយចន្ទីជាប់សំបកប្រហែល ៣៦.២៨៥តោន ។ ដោយថ្លៃមធ្យម (ក្នុង៣ឆ្នាំកន្លងមក) គឺ ៥០០ដុល្លារ/តោន ដូច្នេះកម្ពុជាអាចរកចំណូលបាន ១៨លានដុល្លារ/ឆ្នាំពីដំណាំនេះ ។ ក្នុងពេលនេះ តំលៃប៉ាន់ស្មាននៃការនាំចេញស្វាយចន្ទីគឺពី ៥-៧,៥លានដុល្លារ ពីព្រោះគេប៉ាន់ស្មានថាផលិតកម្មប្រចាំឆ្នាំមានទំហំពី ១០.០០០តោនទៅ ១៥.០០០តោនក្នុង ៤ឆ្នាំកន្លងមក ។

### *៣.២.៣. បញ្ហាចំបងៗក្នុងផលិតកម្ម*

ផលិតកម្មជាលក្ខណៈពាណិជ្ជកម្មនៃដំណាំមិនមែនស្រូវ គឺជារឿងថ្មី ។ ការចុះសិក្សាដល់ទីកន្លែងបានរកឃើញបញ្ហាចំបងៗខ្លះ ព្រមទាំងបញ្ហាទូទៅមួយចំនួន ដូចជា ការកែលំអទិន្នផល ភាពអាចរកបានធាតុចូល និងចលនាថ្លៃ ។ បញ្ហាចំបងៗដែលគួរបង្ហាញគឺ :

#### *៣.២.៣.១. ឥណទាន*

កង្វះឥណទាន ហាក់ដូចជាឧបសគ្គមួយចំពោះការពង្រីកផលិតកម្មពោត សណ្តែកសៀង និងដំឡូងឈើ ។ កង្វះឥណទានបានពង្រីកគំលាតរវាងកសិករធូរធារ និងកសិករក្រីក្រ ។ នៅកម្ពុជាគ្មានគំរោងឥណទានពិសេសអ្វីសំរាប់ជំរុញផលិតកម្មដំណាំលក់យកប្រាក់ទេ ។ អ្នកផ្តល់ឥណទានដែលមានតិចនាក់ អាចសំលឹងឃើញថា តំបន់ផលិតកម្មនៅដាច់ស្រយាលទើបកើតថ្មី ដូចជា ខេត្តព្រះវិហារ និងស្រុកនានាក្នុងអតីតតំបន់ខ្មែរក្រហមនៅបាត់ដំបង វាមានហានិភ័យខ្ពស់ពេក ។

[៣២] ដើមស្វាយចន្ទីអាចរស់បាន ៤០ឆ្នាំ ប៉ុន្តែវាមានផលិតភាពខ្ពស់បំផុតពីឆ្នាំទី១០ ទៅឆ្នាំទី២០ ។

### *៣.២.៣.២. ការពង្រីកកសិដ្ឋាន និងការបំផ្លិចបំផ្លាញព្រៃឈើ*

ការបន្តពង្រីកដំណាំទាំងបួនដែលបានសិក្សា បានកើតមានឡើងតាមរយៈការកាប់បំផ្លាញព្រៃឈើ ។ រឿងនេះបានបំផុសសំណួរសំខាន់មួយៈ "តើការបង្វែរព្រៃឈើទៅជាដីកសិដ្ឋានអាចជួយឱ្យរស់រានបានទេ?" ពិតហើយ កំនើនប្រជាជនខ្ពស់ បានដាក់សំពាធប្រជាសាស្ត្រលើការប្រើប្រាស់ដី ក្នុងពេលមិនទាន់បង្កើតការងារបានច្រើនគ្រប់គ្រាន់នៅខាងក្រៅវិស័យកសិកម្ម ។ បច្ចុប្បន្ននេះ ការរានដីកំពុងកើតយ៉ាងអនាធិបតេយ្យ និងបានចំណេញច្រើនដល់អ្នកមានអំណាចដែលអាចទទួលបានសិទ្ធិកាន់កាប់ដីក្នុងរូបភាពណាមួយ ហើយធ្វើឱ្យខូចប្រយោជន៍ដល់អ្នកក្រ ។

### *៣.២.៣.៣. អវត្តមាននៃការជួយទ្រទ្រង់ផ្នែកបច្ចេកទេស*

កន្លងមក មានការជួយទ្រទ្រង់តិចតួចពីវិស័យសាធារណៈចំពោះដំណាំមិនមែនស្រូវក្រៅពីបន្លែ ដោយសារគេបានប្រឹងប្រែងខ្លាំងណាស់ដើម្បីបង្កើនផលិតផលស្រូវដែលមាន ដូចជាការផ្តោតលើពូជស្រូវមានទិន្នផលខ្ពស់ និងការប្រើប្រាស់ជីឱ្យបានសមស្របជាដើម ។ ប៉ុន្តែក្នុងចំណោមអ្នកបច្ចេកទេស និងបុគ្គលិកផ្សព្វផ្សាយរបស់រដ្ឋាភិបាល ហាក់ដូចខ្វះខាតក៏រិតជំនាញក្នុងបញ្ហាផលិតកម្មជាប់ទាក់ទិននឹងដំណាំមិនមែនស្រូវ ។

## ៣.៣. ម៉ាឃីទីង និងការនាំចេញ

### *៣.៣.១. ម៉ាឃីទីង និងការនាំចេញសណ្តែកសៀង*

ម៉ាឃីទីងដើរតួនាទីជាគន្លឹះក្នុងការកំណត់ថ្លៃ និងអនាគតនៃផលិតកម្មមុខទំនិញនានា ។ បើគ្មានម៉ាឃីទីងទេ ផលិតផលនឹងមានតំរូវការតិចតួច ហើយគ្មានអ្វីជួយលើកទឹកចិត្តឱ្យផលិតទេ ។ "ម៉ាឃីទីងធ្វើឱ្យប្រែប្រួលផលិតផលទៅតាមពេលវេលា ទីកន្លែង និងទ្រង់ទ្រាយ តាមរយៈការស្តុក ការដឹកជញ្ជូន និងការកែច្នៃ ។ តាមរយៈម៉ាឃីទីង ទំនិញត្រូវបានដោះដូរ និងកំណត់ថ្លៃ ។ ទីផ្សារផ្តល់ជាសញ្ញាទៅឱ្យអ្នកផលិត អ្នកកែច្នៃ អ្នកផ្គត់ផ្គង់ធាតុចូល និងអ្នកប្រើប្រាស់អំពីតំលៃទិញ តំលៃលក់ ការស្តុក ការកែច្នៃ និងការដឹកជញ្ជូន" (Norton and Alwang 1993:251) ។ ដូចក្នុងប្រទេសអភិវឌ្ឍន៍តិចជាងគេជាច្រើនទៀតដែរ កម្ពុជាមានចំណុច

ខ្សោយធ្ងន់ធ្ងរខាងម៉ាឃីទីង ដោយសារកង្វះខាតខាងហេដ្ឋារចនាសម្ព័ន្ធ កង្វះពតិមានក្នុងចំណោមផលិតករ និងការប្រែប្រួលខុសលំនាំដើមបង្កដោយរដ្ឋាភិបាល ។ ប៉ុន្តែមានការប្រឹងប្រែងច្រើនណាស់ហើយដើម្បីអភិវឌ្ឍប្រព័ន្ធម៉ាឃីទីងនៅកម្ពុជា ហើយវាបានកាត់បន្ថយកំសោយផ្នែកម៉ាឃីទីង និងជួយឱ្យរចនាសម្ព័ន្ធទីផ្សារប្រកួតប្រជែងផុសចេញមក (MAFF 1997 and PRASAC II 2003) ។

ភាគច្រើននៃសណ្តែកសៀងផលិតនៅកម្ពុជា បាននាំចេញទៅវៀតណាម និងថៃ (ភាគច្រើននាំចេញក្រៅផ្លូវការ) ។ ពាណិជ្ជករថៃ និងវៀតណាម ដែលតាមដានថ្លៃនៅទីផ្សារអន្តរជាតិជាអ្នកកំណត់ថ្លៃសណ្តែកឱ្យកម្ពុជា ។ ទីផ្សារសណ្តែកសៀងនៅកម្ពុជា មានការប្រែប្រួលថ្លៃយ៉ាងខ្លាំងក្នុងឆ្នាំនិមួយៗ ដូចបង្ហាញក្នុងក្រាហ្វិក ១៣ ។ ឧទាហរណ៍ យោងតាមការសំភាសន៍នៅកន្លែងសិក្សា សណ្តែកសៀងគុណភាពលេខ១ លក់បាន ១.២០០រៀល/គ.ក នៅខែវិច្ឆិកា ឆ្នាំ២០០២ ក្រោយពេលប្រមូលផលភ្លាម តែថ្លៃធ្លាក់ចុះយ៉ាងរហ័សដល់ ៩០០រៀល/គ.ក នៅខែធ្នូ រួចឡើងថ្លៃវិញដល់ ១.៣០០រៀល/គ.ក នៅខែមីនា ឆ្នាំ២០០៣ ។ ប៉ុន្តែ គួរកត់សំគាល់ជាសំខាន់ថា ក្នុងអំឡុងខែវិច្ឆិកា-មករា ដែលជាពេលទើបប្រមូលផលភ្លាមៗ ថ្លៃមិនប្រែប្រួលខ្លាំងទេ បើធៀបនឹងរយៈពេលមុនប្រមូលផល ។ ក្នុង ៥ឆ្នាំកន្លងមកដែលមានស្ថិតិថ្លៃចងក្រងដោយ MAFF ចលនាថ្លៃពុំមានលំនាំអ្វីច្បាស់លាស់ទេ ។ នៅឆ្នាំ១៩៩៩ និង ២០០១ ថ្លៃឡើងខ្ពស់នៅខែធ្នូ និងមករា ធ្វើឱ្យអ្នកលក់ដុំដែលមានស្តុកសណ្តែកសៀងត្រូវខាតអស់ ។ ប៉ុន្តែបទពិសោធន៍នៅឆ្នាំ១៩៩៨, ២០០០ និង ២០០២ គឺផ្ទុយគ្នាស្រឡះវិញ ។ តាមការពន្យល់របស់អ្នកលក់ដុំដែលឆ្លើយសំភាសន៍ ចលនាថ្លៃដ៏គំហុកបែបនេះ មានមូលហេតុទាក់ទងនឹងទីផ្សារវៀតណាម ជាជាងកំលាំងទីផ្សារនៅកម្ពុជា ។

ការចុះសិក្សាដល់ទីកន្លែងរកឃើញថា រចនាសម្ព័ន្ធទីផ្សារសណ្តែកសៀងក្នុងស្រុកមានលក្ខណៈប្រកួតប្រជែង ដោយសារមានការប្រកួតប្រជែងយ៉ាងតឹងតែងរវាងឈ្មួញកណ្តាលធ្វើឱ្យកសិករអាចទទួលបានថ្លៃប្រកួតប្រជែងនៅឯកសិដ្ឋានដែរ ។ លើកលែងតែនៅតំបន់ឆ្ងាយៗចេញ ជាទូទៅកសិករមានឈ្មួញច្រើននាក់អាចជ្រើសរើសបាន ។ ឧទាហណ៍ នៅឃុំបុសខ្នុរ

មានអ្នកលក់ដុំ៧នាក់ និងឈ្មួញកណ្តាល ៣នាក់ទៀតមកពីទីផ្សារស្រុកនានាដែលមកទិញសណ្តែកសៀងផ្ទាល់ពីកសិករ ។ ប៉ុន្តែ កសិករក្រីក្រមួយចំនួនត្រូវតែលក់ទៅឱ្យពាណិជ្ជករខ្លះដែលជាម្ចាស់បំណុលរបស់ខ្លួន ។ ម្យ៉ាងទៀត មានឈ្មួញកណ្តាលច្រើនស្រទាប់ពេក ធ្វើឱ្យថយចុះតំលៃបន្ថែមដែលត្រូវបានដល់កសិករ ។

### ក្រាហ្វិក ១៣. ថ្លៃលក់ដុំសណ្តែកសៀងនៅខេត្តកំពង់ចាមឆ្នាំ១៩៩៨-២០០៣




*ប្រភព: ព្រឹត្តិប័ត្រថ្លៃលក់ដុំ ការិយាល័យម៉ាឃីទីង ក្រសួងកសិកម្ម សំរាប់ឆ្នាំ១៩៩៨-២០០២ ។*

នៅកំរិតភូមិ ពាណិជ្ជករមានពីរកំរិត ។ ពាណិជ្ជករកំរិតទី១ ប្រមូលផលិតផលផ្ទាល់ពីកសិករសំរាប់លក់ទៅឱ្យពាណិជ្ជករកំរិតទី២ ដែលស្តុកផលិតផលសំរាប់លក់ដុំទៅឱ្យពាណិជ្ជករមកពីក្រៅ ។ ក្នុងករណីភូមិបុសខ្នុរ មានពាណិជ្ជករកំរិតទី៣ មកពីទីរួមស្រុកព្រៃទទឹងដែលមានទីផ្សារធំនៅតាមផ្លូវជាតិលេខ ៦ ។ ពាណិជ្ជករកំរិតទី៣ អាចទិញសណ្តែកសៀងស្តុកទុក ឬលក់ចេញឱ្យអ្នកលក់ដុំនៅភ្នំពេញ ឬអ្នកលឿង ។ បន្ទាប់មក អ្នកលក់ដុំ ឬឈ្មួញ នៅអ្នក

លឿងលក់ផលិតផលទៅឱ្យពាណិជ្ជកររៀតណាមដែលដឹកវ៉ារហូតទៅដល់វៀតណាម ។ បើសិនសណ្តែកសៀងនោះសំរាប់នាំចេញបន្ត ត្រូវបូកពាណិជ្ជករ២-៣កំរិតថែមទៀតនៅវៀតណាម ។

ផលចំណេញរបស់ពាណិជ្ជករម្នាក់ៗពិបាកប៉ាន់ស្មានណាស់ ។ ពួកគេអាចបានចំណេញច្រើន ឬត្រូវខាត ទៅតាមកំលាំងទីផ្សារដែលមិនអាចគ្រប់គ្រងបាន ។ តួលេខប៉ាន់ស្មានក្នុងតារាង១០ ផ្អែកលើពាណិជ្ជករច្រើននាក់ដែលបានរាយការណ៍ថា ពួកគេពេញចិត្តនឹងផលចំណេញ៥ដុល្លារ ចំពោះការទិញ និងលក់ផលិតផល ១តោន ដែលជាផលចំណេញជាតួយ៉ាងមួយបានពីការលក់ផលិតផលកសិកម្មភ្លាមៗក្រោយពេលទិញបាន ។ ក្នុង ៥ដុល្លារនេះ ត្រូវចំណាយ១ដុល្លារលើពលកម្មលើកដាក់ទំនិញ ។ ផ្អែកលើការប៉ាន់ស្មាននេះ និងចំណាយលើការដឹកជញ្ជូនបន្ទុកចំណាយក្នុងខ្សែរយៈទីផ្សារសំរាប់សណ្តែកសៀងដឹកពីបុសខ្នុរទៅវៀតណាម អាចបំបែកលំអិតដូចបង្ហាញក្នុងតារាង១០ ។

**តារាង១០. ថ្លៃសណ្តែកសៀងនៅក្នុងខ្សែរយៈទីផ្សារ (ដុល្លារ/តោន) នៅតាមផ្លូវពាណិជ្ជកម្មពីឃុំបុសខ្នុរ ខេត្តកំពង់ចាម ទៅតាំងចូវ ប្រទេសវៀតណាម**

| ផ្លូវពាណិជ្ជកម្ម | ដុល្លារ/តោន | | | | |
|---|---|---|---|---|---|
| | ចំនេញជាមធ្យម | ដឹកជញ្ជូន | លើក និងដាក់ | សរុប | ថ្លៃលក់ |
| | (1) | (2) | (3) | (1+2+3) | |
| កសិករ | | | | | 230 |
| ឈ្មួញកណ្តាលកំរិតទី១ (ក្នុងភូមិ) | 5 | 2 | 0 | 7 | 237 |
| ឈ្មួញកណ្តាលកំរិតទី២ (ក្នុងភូមិ និងទីផ្សារ) | 5 | 0 | 2 | 7 | 244 |
| ឈ្មួញកណ្តាលកំរិតទី៣ (ក្រៅភូមិៈ ព្រៃទទឹង) | 5 | 2.5 | 2 | 9.5 | 253.5 |
| កំរិតទី៤ (អ្នកលឿង) | 5 | 7 | 2.5 | 14.5 | 268 |
| កំរិតទី៥ (វៀតណាម-តាំងចូវ) | 5 | 15 | 3 | 23 | 291 |
| សរុប | 25 | 26.5 | 9.5 | 61 | |

*ប្រភពៈ កិច្ចសំភាសន៍ជាមួយអ្នកលក់ដុំ និងអ្នកដឹកជញ្ជូន នៅខេត្តកំពង់ចាម និងអ្នកលឿង មីនា ២០០៣ ។*

នៅខែមីនា ២០០៣ កសិករលក់សណ្តែកសៀង ១តោនបាន ២៣០ដុល្លារ ។ គិតទាំងផលចំណេញម៉ាឃីទីងតូចៗ និងចំនាយដឹកជញ្ជូនទាំងអស់ផង សណ្តែកសៀង១តោន ដឹកដល់តាំងចូវនៅវៀតណាមមានតំលៃ ២៩១ដុល្លារ ។ ដូច្នេះបន្ទុកចំណាយលើម៉ាឃីទីងគឺ ៦១ដុល្លារ/តោន ឬ ២៧%នៃថ្លៃនៅកសិដ្ឋាន ។ ក្នុងចំណាយនេះ គ្មានគិតចូលទេនូវប្រាក់កំរៃក្រៅផ្លូវការដែលគេរាយការណ៍ថាមិនធំដុំទេនៅតាមផ្លូវនេះ ។

កម្ពុជាជាប្រទេសមួយតូច និងជាអ្នកទទួលយកថ្លៃ ជាជាងអ្នកកំណត់ថ្លៃ ។ ដើម្បីបង្កើនថ្លៃនៅកសិដ្ឋាន ត្រូវតែកាត់បន្ថយចំណាយដឹកជញ្ជូន និងចំនួនស្រទាប់ឈ្មួញកណ្តាល ។ គេទទួលស្គាល់ជាទូទៅថា ចំណាយដឹកជញ្ជូននៅកម្ពុជា អាចកាត់បន្ថយបានច្រើនណាស់ តាមរយៈការកែលំអ និងការកសាងផ្លូវគមនាគមន៍ និងការបញ្ចុះពន្ធលើប្រេងឥន្ធនៈ ។ ដោយកសិដ្ឋានកម្ពុជាភាគច្រើនគឺតូចៗ ដូច្នេះ ការបង្កើតសហករណ៍កសិករអាចជួយកាត់បន្ថយចំនួនស្រទាប់ឈ្មួញកណ្តាល ។

*៣.៣.១.១. អត្រាបញ្ចុះតំលៃខ្ពស់សំរាប់អ្នកក្រ*

បញ្ហាសំខាន់មួយគឺ កសិករប្រហែលពី ៤០-៥០% ដែលសឹងតែជាអ្នកក្រទាំងអស់គ្នារាយការណ៍ថា បានលក់សណ្តែកសៀងរបស់ខ្លួនមុនពេលប្រមូលផល ។ ជាលទ្ធផល គេទទួលបានតែ ៤០០-៦០០រៀល/គ.កប៉ុណ្ណោះ ទៅតាមប្រវែងរយៈពេលមុនការប្រមូលផល ។ ថ្លៃដែលពួកគេទទួលបានគឺ ៤០-៦០%នៃថ្លៃក្រោយពេលប្រមូលផល ដែលតាមធម្មតាគឺប្រហែល ១.០០០រៀល ។ នេះជាបញ្ហាមួយធ្ងន់ធ្ងរដែលធ្វើឱ្យអ្នកក្រនៅតែក្រ ហើយវាកើតមានឡើងជាសំខាន់ដោយសារកង្វះឥណទានមានតំលៃសមរម្យសំរាប់អ្នកក្រ ។

មានឈ្មួញកណ្តាលជាច្រើនដែលជាប់ពាក់ព័ន្ធនឹងទីផ្សារ "អនាគត" បែបនេះ ។ ពាណិជ្ជករ តូចៗយកប្រាក់ពីអ្នកលក់ដុំ ហើយឱ្យកសិករខ្ចីបន្ត ដូច្នេះគេបានកាត់យកផលចំណេញជា សក្តានុពលមួយចំនួនពីកសិករ ។ ជាមធ្យម គ្រួសារនៅបុសខ្នុរលក់សណ្តែកសៀងប្រហែល ៤០០គ.ក ឬ ២០% នៃផលសណ្តែកទាំងអស់របស់គេនៅមុនពេលប្រមូលផល ។ ក្នុងចំណោម តំរូវការផ្សេងៗ

កសិករត្រូវការប្រាក់ជាពិសេសសំរាប់ចំណាយប្រើប្រាស់ និងការចូលបច្ច័យនៅវត្តក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ។

នៅក្នុងភូមិគ្មានគំរោងឥណទានផ្លូវការទេ ប្រហែលដោយសារភូមិនៅឆ្ងាយដាច់ស្រយាលពេក ។ ជាលទ្ធផល អ្នកចងការប្រាក់ក្រៅផ្លូវការដើរតួនាទីចំបងក្នុងការផ្តល់ឥណទាន ។ គ្រួសារមានដីច្រើនជាង ៣ហ.ត អាចទទួលបានកំចីថោកបន្តិចពីអ្នកចងការប្រាក់ក្នុងអត្រាថេរ ៥%/ខែ ។ ប៉ុន្តែ គ្រួសារមានដីតិចតួច ឬគ្មានដីសោះ ត្រូវបង់អត្រាការប្រាក់ដល់ ១០%/ខែ ឬខ្ពស់ជាងនេះទៀត ។ ករណីបែបនេះ ឃើញមាននៅគ្រប់កន្លែងបានចុះសិក្សានៅខេត្តកំពង់ចាម ព្រះវិហារ និងបាត់ដំបង ។

គេឱ្យថ្លៃទាបខ្លាំងបែបនេះដល់កសិករដែលលក់សណ្តែកមុនពេលប្រមូលផល គឺដោយសារ "បន្ទុកចំណាយលើជំនួញ" មានកំរិតខ្ពស់ ។ កសិករក្រីក្រអាចមិនគោរពតាមកិច្ចសន្យា ដោយលក់ផលិតផលទៅឱ្យពាណិជ្ជករផ្សេង ហើយនៅជំពាក់បំណុលម្ចាស់កំចីដដែលនោះតទៅទៀត ។ ដើម្បីអនុវត្តឱ្យបានតាមកិច្ចព្រមព្រៀង ម្ចាស់កំចីត្រូវត្រួតពិនិត្យកូនបំណុលរបស់ខ្លួនឱ្យបានជិតដល់ និងយកសំណងសណ្តែកភ្លាម នៅពេលប្រមូលផលបានហើយ ។ មធ្យោបាយនេះពុំមានប្រសិទ្ធភាពល្អទេ ដោយសារគ្មានពេលហាលគ្រាប់សណ្តែក ។ នៅពេលម្ចាស់កំចីយកសណ្តែកសៀងនេះទៅហាល វាត្រូវស្រកទំងន់អស់ប្រហែល ១០% ។

នៅបុសខ្នុរ កសិករចង់បានការធានាថ្លៃពីអ្នកចង់ទិញផលិតផល ដើម្បីពួកគេបង្កើនផលិតកម្មសណ្តែកសៀង ។ បច្ចុប្បន្ននេះ ការដាំចេកហាក់ដូចបានចំណេញច្រើនជាង ពីព្រោះវាផ្តល់ចំនូលប្រចាំឆ្នាំប្រហែល ៦០០ដុល្លារ/ហ.ត សំរាប់ទីផ្សារក្នុងស្រុក ។ កសិករប្រាប់ថា បើសណ្តែកសៀងមួយហិកតាផ្តល់ចំណូលដុលបាន ៤០០-៥០០ដុល្លារ ពួកគេនឹងប្តូរពីការដាំចេកទៅដាំសណ្តែកសៀងវិញ ។ នៅពេលនេះ កសិករជាច្រើននាក់ជ្រើសយកការដាំចេក ទោះបីដើមចេកត្រូវអន់ក្រោយពេលដាំបាន៣ឆ្នាំដោយសារជម្ងឺ និងត្រូវប្តូរបង្វិលមុខដំណាំទៅដាំអ្វីផ្សេងសិនក្តី ។

### *៣.៣.១.២. ការបន្លំថ្លៃកជញ្ជីង*

បញ្ហាសំខាន់មួយទៀតគឺ ការបន្លំថ្លៃកជញ្ជីងពីឈ្មួញកណ្តាល ។ កសិករ និងពាណិជ្ជករអ្នកឆ្លើយសំភាសន៍មានជំនឿជាទូទៅថា មានការបន្លំនៅពេលថ្លឹង ។ អតីតពាណិជ្ជករម្នាក់សារភាពថា នៅឆ្នាំ១៩៩៦ ឈ្មួញកណ្តាល រួមទាំងខ្លួនគាត់ផង បានចំណេញ ៧០គ.ក ពីការបន្លំថ្លៃកជញ្ជីងលើការថ្លឹងសណ្តែក ៥០០គ.ក ។ ប៉ុន្តែជាបណ្តើរៗ កសិករចេះយកបាន់ផលិតផលរបស់ខ្លួនទៅឱ្យអ្នកលក់ដុំក្នុងភូមិ ហើយលក់ឱ្យពួកនេះដោយផ្ទាល់តែម្តង ។ ការលក់បែបនេះជួយបញ្ចៀសការបន្លំពីពាណិជ្ជករនៅក៏រិតទី១ ។ កសិករមួយចំនួនក៏មានជញ្ជីងខ្លួនឯងដែរ ប៉ុន្តែនៅតែត្រូវបាត់អស់ប្រហែល ៥គ.ក ដោយសារឈ្មួញកណ្តាលនៅតែបន្លំបានដដែល ដោយគេផ្តល់ឱកាសឱ្យកសិករប្រៀបធៀបជញ្ជីងរបស់គេ ជាមួយនឹងជញ្ជីងរបស់កសិករផ្ទាល់ ។ ក្រោយពីសាកបាវទី១ កសិករជឿថា ជញ្ជីងរបស់ពាណិជ្ជករ អំណោយផលដល់គាត់ជាង ហើយក៏សំរេចចិត្តប្រើជញ្ជីងនោះដើម្បីថ្លឹងបាវនានាដែលនៅសល់ ។ នៅពេលថ្លឹងបាវទី១ ពាណិជ្ជករ "ចេះកែកុន" ជញ្ជីងខ្លួនធ្វើឱ្យកសិករពេញចិត្តនឹងវា ហើយក៏អាចបន្លំបានពី ៣-៥គ.ក/បាវ ដោយកែជញ្ជីងឱ្យស៊ីទំងន់ ពេលថ្លឹងបាវឯទៀតៗដែលនៅសល់ ។ ពតិមាននេះយោងតាមរបាយការណ៍ពីឈ្មួញកណ្តាលក៏រិតទី១ដែលសារភាពថាបានធ្វើដូច្នេះ ។

ពាណិជ្ជករតូចៗក្នុងភូមិ ព្យាយាមរៀបចំការទិញលក់ដែលគេអាចយកចំណេញបាន ទោះបីកសិករជាច្រើនចេះរំលងពួកគេចោល ហើយលក់ផលិតផលផ្ទាល់ទៅឱ្យអ្នកលក់ដុំនៅក្នុងភូមិតែម្តងក្តី ។ ប៉ុន្តែ ពាណិជ្ជករតូចៗហ៊ានឱ្យថ្លៃខ្ពស់ជាងអ្នកលក់ដុំ ដោយគេរំពឹងបានចំណេញខ្លះពីការបន្លំថ្លៃកជញ្ជីង ដើម្បីទូទាត់នឹងការហ៊ានឱ្យថ្លៃខ្ពស់ដល់កសិករ ។ ឧទាហរណ៍ពាណិជ្ជករមួយចំនួនតូចបានបញ្ជាក់និងរាយការណ៍ថា ពាណិជ្ជករក៏រិតទី១ ឱ្យថ្លៃ ៩២០រៀល/គ.ក ទៅកសិករនៅខែមករា ២០០៣ ។ ប៉ុន្តែ គេលក់សណ្តែកសៀងក្នុងតំលៃ ៩០០រៀល/គ.ក ទៅឱ្យអ្នកលក់ដុំក្នុងភូមិ ។ ក្នុងនេះពាណិជ្ជករហាក់ដូចជាត្រូវខាត តែតាមពិតពួកគេនៅតែបានចំណេញខ្លះដែរ ។ មធ្យោបាយតែមួយ ដើម្បីអាចបានចំណេញ (ដូចដែលពាណិជ្ជករអ្នកឆ្លើយសំភាសន៍បានសារភាពប្រាប់) គឺការបន្លំថ្លៃកជញ្ជីង ។ ផលចំណេញដែលពាណិជ្ជករតូចៗ

ទទួលបាន វាមិនច្រើនណាស់ណាទេ ប៉ុន្តែពួកគេនៅតែអាចស្រូបយកចំណូលបានពីពួកកសិករដែលមិនចង់ទាំងលក់ផលិតផលឱ្យពួកគេផង ។

### ៣.៣.១.៣. បន្ទុកចំណាយការដឹកជញ្ជូន

នៅពេលចុះសិក្សា ផ្លូវទៅកាន់ភូមិនៅតែយ៉ាប់យ៉ឺននៅឡើយ ទោះបីអ្នកភូមិមានចិត្តត្រេកអរនឹងការជួសជុលខ្លះៗក្នុងពេលកន្លងមកក្តី ។ គេត្រូវចំណាយ ១០.០០០រៀល ដើម្បីដឹកសណ្តែកសៀង ១តោន ពីភូមិបុសខ្នុរទៅផ្សារព្រៃទទឹងដែលនៅចំងាយ ២៦គ.ម ។ ចំណាយដឹកជញ្ជូនបានថយចុះជាបន្តបន្ទាប់ ដោយសារកំណើនការប្រជែងគ្នាក្នុងចំណោមអ្នកដឹកជញ្ជូន និងវត្តមានឡានប្រើហើយតំលៃថោកៗផលិតនៅកូរ៉េដែលគេលក់មានច្រើននៅកម្ពុជា ។ ស្ថានភាពផ្លូវក៏ជាកត្តាជួយកាត់បន្ថយបន្ទុកចំណាយលើការដឹកជញ្ជូនដែរ ។ ផ្លូវល្អសំរួលឱ្យមានឈ្មួញកណ្តាលច្រើននាក់ទៀតធ្វើដំណើរមកភូមិ និងបង្កើនការប្រជែងគ្នាទិញផលិតផលរបស់កសិករ ដែលអាចជួយបង្កើនកំរិតថ្លៃនៅកសិដ្ឋាន ។ នៅក្នុងភូមិ គេប្រើរទេះសេះ ដើម្បីដឹកសណ្តែកសៀងទៅទីតាំងអ្នកលក់ដុំ ។ ចំណាយដឹកជញ្ជូនតាមបែបបុរាណនេះគឺ ២.៥០០រៀល/បាវនៅរដូវវស្សា ឬ ៥០០រៀល/បាវនៅរដូវប្រាំង ។

### ៣.៣.១.៤. កំរៃនៅតាមផ្លូវដឹកជញ្ជូន

គេរាយការណ៍ថា បច្ចុប្បន្ននេះកំរៃនៅតាមផ្លូវមិនចោទបញ្ហាទេ ។ ប៉ុន្តែនៅមុនឆ្នាំ១៩៩៧ គេត្រូវចំណាយ ២២ដុល្លារ/តោន ពីបុសខ្នុរទៅអ្នកលឿង ធៀបនឹងតំលៃគេលក់ត្រឹម ៨ដុល្លារ/តោន ។ ការធ្លាក់ចុះយ៉ាងខ្លាំងនៃចំណាយដឹកជញ្ជូន បានជួយដល់ទីផ្សារសណ្តែកសៀងយ៉ាងពិតប្រាកដ ។ មូលហេតុមួយដែលធ្វើឱ្យចំណាយដឹកជញ្ជូនខ្ពស់ខ្លាំងណាស់កាលពីមុន គឺដោយសារវត្តមានកំលាំងប្រដាប់អាវុធអនាធិបតេយ្យនៅតាមផ្លូវដែលទាមទារប្រាក់ពីអ្នកដឹកជញ្ជូន ។ ម្យ៉ាងទៀត រថយន្តដឹកទំនិញប្រជែងគ្នាក៏មានតិចដែរ ។

**ប្រអប់ទី ១. លោក អ៊ី សុផល អ្នកលក់ដុំ/ពាណិជ្ជករ នៅបុសខ្នុរ ខេត្តកំពង់ចាម**

លោក អ៊ី សុផល ជាអ្នកលក់ដុំនៅឃុំបុសខ្នុរ ហើយគេគិតថា គាត់ជាអ្នករកស៊ីធំជាងគេក្នុងចំនោមអ្នកលក់ដុំទាំង ៧នាក់ក្នុងឃុំនេះ ។ សណ្ដែកសៀងប្រហែល ១.០០០ត.ក បានលក់ដូរតាមរយៈគាត់ ។ ក្នុងចំនួននេះប្រហែល ៣០% បញ្ជូនទៅទីផ្សារស្រុកនៅព្រៃទទឹងដែលនៅជិត, ៥០%បញ្ជូនទៅអ្នកលឿង និង ២០% ទៅភ្នំពេញ ។

សុផល រកស៊ីតាមម្ដាយគាត់ដែលប្រកបរបរនេះជាង ២០ឆ្នាំមកហើយ ។ គាត់ស្គាល់ពាណិជ្ជករជាច្រើនទាំងនៅកម្ពុជា និងវៀតណាម ។ គាត់អះអាងថា មានស្គាល់ពាណិជ្ជករវៀតណាមប្រហែល ១០នាក់ តាមរយៈម៉ូយគាត់នៅអ្នកលឿងដែលទិញទំនិញពីគាត់ទៅលក់ឱ្យពាណិជ្ជករវៀតណាម ។ ពាណិជ្ជករវៀតណាមជាកត្តាចំបងក្នុងការសំរេចចិត្តថា តើគាត់គួរ ឬមិនគួរស្តុកទុកផលិតផលថែមទៀត ។ គាត់និយាយថា គាត់ជឿតាមភាគច្រើននៃឈ្មួញកណ្ដាលទាំង ១០នាក់នោះ ហើយឈ្មួញវៀតណាមមិនដែលបោកប្រាសគាត់ទេ ។ គេបានសង្កេតឃើញថា ចំពោះអ្នកលក់ដុំថ្មី វាមិនមែនជាការងាយស្រួលទេក្នុងការកសាងទំនាក់ទំនងជាលក្ខណៈបុគ្គលឱ្យបានរឹងមាំល្អជាមួយពាណិជ្ជករវៀតណាមឱ្យបានយូរឆ្នាំ ។ ទំនាក់ទំនងបែបនេះបានជួយសំរួលពាណិជ្ជកម្មក៏ពិតមែន ប៉ុន្តែវាក៏ដើរតួជារបាំងមួយដែលរារាំងអ្នកចូលរកស៊ីថ្មីដែរ ។

លោក អ៊ី សុផល ពេញចិត្តហើយនឹងកំរិតចំណេញ ៥ដុល្លារ/តោន ។ ក្នុងនេះ ១ដុល្លារគឺសំរាប់ជួលកម្មករ លើកដាក់ផលិតផល និង ១ដុល្លារទៀតសំរាប់ចំណាយលើបាវ ។ ក្រោយពេលប្រមូលផលភ្លាម គាត់ទិញផលិតផលផ្ទាល់ពីកសិករ ។ ក្រោយមកទៀតគាត់ទិញពីពាណិជ្ជករតូចៗដែលដើរប្រមូលទិញពីកសិករអ្នកមានលទ្ធភាពស្តុកសណ្ដែកទុក រង់ចាំឱ្យវាឡើងថ្លៃ ។ គាត់ជឿថា ថ្លៃសណ្ដែកសៀង និងសណ្ដែកបាយដែលគេឱ្យថ្លៃគាត់ ត្រូវបានកំនត់ជាប្រយោលដោយពាណិជ្ជករវៀតណាម និងមិនជាប់ទាក់ទងជាមួយការផ្គត់ផ្គង់ និងតំរូវការនៅកម្ពុជាទេ ។ គេប្រាប់គាត់ថា សណ្ដែកសៀងគាត់ គេបញ្ជូនវាហួតទៅដល់ប្រទេសចិន ។

ក្នុង ១០ឆ្នាំកន្លងមកដែលគាត់រកស៊ីដោយឯករាជ្យនេះ លោក សុផល មិនដែលខាតបង់ក្នុងការជួញសណ្ដែកសៀងទេ ។ ទោះយ៉ាងនេះក្តីនៅឆ្នាំ២០០២-០៣ គាត់ត្រូវខាតអស់

ប្រហែល ១០.០០០ដុល្លារ ដោយសារសណ្ដែកបាយធ្លាក់ថ្លៃខ្លាំងពេក ។ គាត់ទិញសណ្ដែកបាយថ្លៃ ៣២០ដុល្លារ/តោនមកស្ដុកទុក តែក្រោយមកវាបានធ្លាក់ថ្លៃដល់ ១២០ដុល្លារ/តោន ។ នៅខែមីនា សណ្ដែកឡើងថ្លៃវិញដល់ ២១០ដុល្លារ/តោន ហើយគាត់ក៏បានពិចារណាលក់ចេញខ្លះនូវស្ដុកសណ្ដែកគាត់ដែលមានប្រហែល ១០០តោន ។

ដោយគាត់ជាអ្នកមានដើមទុនច្រើនណាស់នៅក្នុងឃុំ ដូច្នេះ មានគេត្រូវការខ្ចីឥណទានពីគាត់ ។ គាត់បានចូលរួមជាមួយអ្នកផ្សេងៗទៀត ដើម្បីធ្វើសកម្មភាពក្នុងទីផ្សារ "អនាគត" (ពាក្យប្រើក្នុងមូលដ្ឋានគឺ បណ្ដាក់) ។ ជារៀងរាល់ឆ្នាំ គាត់ឱ្យប្រាក់គេខ្ចីប្រហាក់ប្រហែលនឹងតំលៃសណ្ដែក ២០តោន ។ ប្រតិបត្តិការនេះជាច្រើន ធ្វើតាមរយៈពាណិជ្ជករតូចៗដែលយកកំរៃ ៥០-១០០រៀល/គ.ក ពីកសិករអ្នកខ្ចីប្រាក់ ។ គាត់គិតថា មានតំរូវការឥណទានសំរាប់សណ្ដែកដល់ទៅ ១០០តោន បើសិនគាត់ចង់ពង្រីកវាឱ្យធំ ។ មុនពេលភ្ជុំបិណ្ឌ ឬពីរខែមុនការប្រមូលផល គេលក់សណ្ដែកសៀងឱ្យគាត់ថ្លៃ ៤០០រៀល/គ.ក ។ នៅពេលភ្ជុំបិណ្ឌ ឬមួយខែមុនការប្រមូលផល ថ្លៃឡើងដល់ ៥០០រៀល/គ.ក ។ ក្រោយប្រមូលផលរួចថ្លៃឡើងដល់ ៩០០-១.០០០រៀល/គ.ក ។ ប៉ុន្តែគាត់និយាយថា ជារៀងរាល់ឆ្នាំ អតិថិជនរបស់គាត់ប្រហែល ២០% មិនអាចផ្ដល់សណ្ដែកតាមចំនួនក្នុងកិច្ចសន្យាទេ ដូច្នេះគេត្រូវរង់ចាំរហូតដល់ឆ្នាំបន្ទាប់ ដោយមិនអនុវត្តតាមលក្ខខណ្ឌដដែលទេ ។ គាត់គិតថា វាមានការពិបាកសំរាប់កសិករក្រីក្រនៅក្នុងឃុំនេះ ហើយគាត់និយាយថា "កសិករក្រីក្រកាន់តែក្រថែមទៀត ។ បញ្ហានេះបង្កឱ្យមានចោរកម្មច្រើនជាងមុន" ។

### *៣.៣.១.៥. នៅត្បែងមានជ័យ ខេត្តព្រះវិហារ*

នៅតំបន់ដាច់ស្រយាលនេះ មានពាណិជ្ជករ ៧នាក់ប្រជែងគ្នាទិញសណ្ដែកសៀងប្រហែល ២.០០០តោន[៣៣] ។ ពួកគេមិនស្ដុកផលិតផលយូរទេ ព្រោះគេមិនហ៊ានប្រថុយនឹងការ

[៣៣] ពាណិជ្ជករប៉ាន់ស្មានថា ផលិតកម្មសណ្ដែកសៀងក្នុងស្រុកគាត់មានប្រហែល ២.០០០តោននៅឆ្នាំ ២០០២ ប៉ុន្តែស្ថិតិផ្លូវការបង្ហាញថា មានត្រឹម ៤១៣តោននៅឆ្នាំ២០០២នេះ ។

ធ្លាក់ថ្លៃ ។ ជាធម្មតា ពួកគេដឹកសណ្តែកសៀងទៅកំពង់ធំ ក្នុងតំលៃ ១០ដុល្លារ/តោន ដើម្បីលក់ទៅឱ្យអ្នកលក់ដុំនៅទីនោះ និងនៅកំពង់ចាម ។

ដូចនៅកំពង់ចាមដែរ ពាណិជ្ជករតែងពេញចិត្តនឹងផលចំណេញប្រហែល ១៥-២០រៀល/គ.ក ឬ ៤-៥ដុល្លារ/តោន ។ នៅកំពង់ចាមមានឈ្មួញកណ្តាល ៥នាក់ដែលទិញសណ្តែកសៀងពីព្រះវិហារ ។ ពាណិជ្ជករទាំងនេះ ផ្តល់ប្រាក់ឱ្យឈ្មួញកណ្តាលនៅព្រះវិហារខ្ចី ដោយសារឈ្មួញនៅព្រះវិហារច្រើនខ្វះសាច់ប្រាក់ ។ ជាលទ្ធផល ពាណិជ្ជករនៅព្រះវិហារ ត្រូវចងភ្ជាប់នឹងពាណិជ្ជករនៅកំពង់ធំក្នុងកំរិតណាមួយ ។ តាមមតិរបស់ពាណិជ្ជករអ្នកឆ្លើយសំភាសន៍នៅកំពង់ធំ គឺមានការប្រជែងគ្នាខ្លាំងណាស់ក្នុងចំណោមពាណិជ្ជករនៅទីនោះ ។ ពាណិជ្ជករដែលយកសណ្តែកសៀងមកពីព្រះវិហារ គេមានជំរើសអាចលក់ផលិតផលទៅអ្នកលក់ដុំនៅភ្នំពេញ នៅអ្នកលឿង ឬនៅកំពង់ធំ ។ គេតែងទូរស័ព្ទទៅគ្រប់ពាណិជ្ជករ មុននឹងធ្វើការសំរេចចិត្ត ។ ប៉ុន្តែពាណិជ្ជករនៅព្រះវិហារជាច្រើនបានទទួលកំចីពីអ្នកលក់ដុំនៅកំពង់ធំ ដូច្នេះច្រើនតែត្រូវលក់សណ្តែករបស់ខ្លួនទៅឱ្យពួកនេះ ។

ការប្រជែងគ្នាក្នុងចំណោមឈ្មួញកណ្តាលនៅត្បែងមានជ័យ មិនតឹងតែងខ្លាំងទេ ។ ពាណិជ្ជករហាក់ទទួលបានផលកំរៃច្រើនពីសកម្មភាពផ្តល់កំចី និងពាណិជ្ជកម្មរបស់ខ្លួន ។ ពាណិជ្ជករអ្នកឆ្លើយសំភាសន៍ម្នាក់ប្រាប់ថា គាត់បានចាប់ធ្វើរបរនេះកាលពី ៤ឆ្នាំមុនដោយពេលនោះមានប្រាក់តែ ៣.០០០ដុល្លារក្នុងដៃ ។ ក្នុងទឹកប្រាក់នេះ គាត់បានខ្ចី ១.០០០ដុល្លារពីសាច់ញាតិ ។ បច្ចុប្បន្នគាត់ប្រើទុនផ្ទាល់ខ្លួន ២០.០០០ដុល្លារធ្វើជាទុនបង្វិល ។ សកម្មភាពផ្តល់កំចីរបស់គាត់ ប្រហែលផ្តល់ផលចំណេញបានច្រើនជាងសកម្មភាពធ្វើពាណិជ្ជកម្មជាក់ស្តែងទៅទៀត ។

តាមគេរាយការណ៍ប្រាប់ កសិករភាគច្រើននៅព្រះវិហារបានខ្ចីប្រាក់ក្នុងអត្រាការប្រាក់ ៥-៦%/ខែ ដែលភាគច្រើនខ្ចីពីពាណិជ្ជករ ។ គេត្រូវការសាច់ប្រាក់ដើម្បីបង់ថ្លៃជួលកំលាំងពលកម្មមកដាំ ជំរះស្មៅ និងប្រមូលផល ។ ដូច្នេះគេត្រូវបង្ខំលក់ផលិតផលរបស់ខ្លួនទៅឱ្យម្ចាស់បំណុលតាមថ្លៃនៅទីផ្សារទូទៅ ។ ក្នុងការអនុវត្តជាក់ស្តែងគឺ មានបង្កប់ការគំរាមថា បើកសិករមិនស្មោះត្រង់លក់ផលិតផលរបស់ខ្លួនទៅឱ្យពាណិជ្ជករផ្សេងដើម្បីបានថ្លៃខ្ពស់ជាង នឹងមានការ

ពិន័យដោយមិនឱ្យខ្ចីប្រាក់ទៀតនៅពេលក្រោយ ។ របៀបអនុវត្តន៍នេះ ខុសប្លែកគ្នាពីខេត្តកំពង់ចាម ដែលតាមរបាយការណ៍មានកសិករ ២០%បានលក់ផលិតផលមុនរដូវប្រមូលផលដូចនៅព្រះវិហារដែរ ។ កសិករទទួលបានថ្លៃតែ ៤០០-៥០០រៀល/គ.ក នៅពេលយកប្រាក់គេមុនដូច្នេះ ធៀបនឹង ៩០០រៀល/គ.ក បើលក់ក្រោយពេលប្រមូលផលរួច ហើយរឿងនេះបង្ហាញពីការបញ្ចុះថ្លៃយ៉ាងច្រើនសំរាប់រយៈពេលប្រហែលតែ ២ខែ ។ អត្រាមិនសងបំណុលរបស់ពាណិជ្ជករម្នាក់ដែលមានអ្នកសុំខ្ចីប្រាក់ប្រហែល ២០០នាក់ គឺប្រហែល ២០% ។

### *៣.៣.២. ម៉ាឃីទីង និងការនាំចេញពោតនៅខេត្តបាត់ដំបង*

ផលិតផលពោតនៅបាត់ដំបង ពឹងផ្អែកសឹងតែទាំងស្រុងលើទីផ្សារថៃ ដោយសារទីផ្សារក្នុងស្រុកស្រូបយកតែសមាមាត្រមួយតូចប៉ុណ្ណោះ (តិចជាង ១០%) នៃផលិតកម្មពោតសរុបនៅបាត់ដំបង ។ ឧទាហរណ៍ ការសំភាសន៍បានឱ្យដឹងថា កសិករដាំពោតភាគច្រើនមានការព្រួយបារម្ភជាខ្លាំងនៅពេលព្រំដែនខ្មែរ-ថៃ ត្រូវបិទ ក្រោយពីមានកុប្បកម្មប្រឆាំងថៃនៅភ្នំពេញកាលពីថ្ងៃទី២៩ មករា ២០០៣ ។

ថ្វីបើហាក់ដូចពុំមានរបាំងអ្វីធំដុំចំពោះការចូលប្រកបរបរនេះ ប៉ុន្តែឃើញមានឈ្មួញតែ ២-៣នាក់ប៉ុណ្ណោះ ។ រឿងនេះអាចបង្កឱ្យមានទីផ្សារផ្តាច់មុខដោយជនមួយក្រុម (oligopolistic market) ។ នៅស្រុកកំពង់រៀង ខ្មែរមួយចំនួនធ្វើការប្រមូលពោតឱ្យពាណិជ្ជករថៃ ដោយ ទទួលបានកំរៃ ២បាត/បាវទំងន់១២០គ.ក ។ អ្នកប្រមូលទិញនៅមូលដ្ឋានទាំងនេះ ប្រមូលពោតពីកសិដ្ឋានក្រោយពេលប្រមូលផល រួចច្រកដាក់បាវ ហើយស្តុកវាទុកក្នុងឃ្លាំងនៅកសិដ្ឋាន ។ ពាណិជ្ជករថៃ រកស៊ីតែជាមួយអ្នកណាដែលគេស្គាល់ និងជឿទុកចិត្ត ។ មានខ្មែរតែម្នាក់គត់ដែលបានក្លាយជាពាណិជ្ជករខ្លួនឯង ក្រោយពីធ្វើការឱ្យពាណិជ្ជករថៃអស់រយៈពេល ៤ឆ្នាំ ។

ប៉ុន្តែនៅស្រុកសំពៅលូនដែលជាកន្លែងផលិតពោតធំជាងគេនៅកម្ពុជា ឃើញមានពាណិជ្ជករ-អ្នកនាំចេញពោតច្រើននាក់ ។ មួយចំនួនមកពីក្រុងបាត់ដំបង ដោយសារតាម

ពតិមានទទួលបាន គឺអ្នកនៅក្នុងមូលដ្ឋានមិនសូវហ៊ានប្រកបរបរនេះ ។ ជាលទ្ធផល នៅសំពៅលូនហាក់ដូចមានការប្រកួតប្រជែងខ្លាំងជាង ទោះបីថ្លៃនៅកសិដ្ឋាន មិនខុសគ្នាច្រើនក្ដី ។

ជាទូទៅ កសិករនៅស្រុកទាំងនេះ ហាក់ដូចមានការប្រុងប្រយ័ត្នច្រើនចំពោះបញ្ហាបន្លំភ្នែកជញ្ជីង គឺដូចកសិករដាំសណ្ដែកសៀងនៅកំពង់ចាមដែរ ។ អ្នកឆ្លើយសំភាសន៍ម្នាក់ដែលបានចាប់អារម្មណ៍ភ្លាម១លើបញ្ហានេះបានប្រាប់ថា មានលទ្ធភាពជាច្រើនដែលការបន្លំអាចកើតមានឡើង ។ ប៉ុន្តែដោយសារពោតមានតំលៃថោក និងមានទិន្នផលខ្ពស់ ដូច្នេះបញ្ហាបន្លំភ្នែកជញ្ជីងប្រហែលមិនសូវសំខាន់ប៉ុន្មានទេចំពោះកសិករឯទៀត១ ។

លទ្ធភាពធ្វើកម្ពុជាភាវូបនីយកម្មលើពាណិជ្ជកម្មពោត គឺពិតជាមាន ទោះជាឥលូវនេះពាណិជ្ជករថៃក្នុងឋានៈជាអ្នកទិញពោតមានតែម្នាក់ឯងក្នុងតំបន់ គេមានអំណាចតថ្លៃកាន់តែច្រើនក្ដី ។ នៅខាងកម្ពុជា មានកិច្ចប្រឹងប្រែងមួយចំនួន ដើម្បីបង្កើតទីផ្សារពោត ឬបង្កើតសមាគម ដើម្បីបង្កើនកំលាំងរបស់កសិករខ្មែរក្នុងការចរចាថ្លៃ ។ ប៉ុន្តែ មកទល់សព្វថ្ងៃ រឿងនេះមិនទាន់បានជោគជ័យទេ ដោយសារមូលហេតុផ្សេង១ ។

នៅឆ្នាំ២០០២ មានគំនិតផ្ដួចផ្ដើមមួយដើម្បីបង្កើតសមាគមកសិករ និងទីផ្សារ សំដៅពង្រឹងកំលាំងកសិករក្នុងការចរចា ។ ប៉ុន្តែយោងតាមមន្ត្រីស្រុក "ពាណិជ្ជករថៃមិនយល់ព្រមនឹង គំនិតនេះទេ" ហើយគំរាមបិទព្រំដែន បើខាងកម្ពុជាធ្វើតាមគំនិតនេះ ។ នៅខាងកម្ពុជា មាន ការបារម្ភពីល្បឿននៃការលក់ដូរ បើពោតត្រូវឆ្លងកាត់សមាគមសិន មុននឹងទៅដល់អ្នកទិញ នៅថៃ ។ លំហូរសាច់ប្រាក់លឿន គឺចំណុចបារម្ភដ៏ធំរបស់កសិករ ពីព្រោះឥណទានមានការ ប្រាក់ខ្ពស់ណាស់សំរាប់ពួកគេ ។

កាលពី ៧ឆ្នាំមុន ថ្លៃពោតនៅកសិដ្ឋាន មានសភាពនឹងនរ ដោយប្រែប្រួលតែ ២,៨-៣,២បាត/គ.ក ឬប្រហែល ៧០ដុល្លារ/តោន ។ អ្នកលក់ដុំថៃដែលមានចំងាយតែ ១ម៉ោងក្នុងការធ្វើដំណើរពីព្រំដែន គេហ៊ានឱ្យថ្លៃដល់ ៣,៨-៣,៩បាត/គ.ក ។ បន្ទុកចំណាយដឹកជញ្ជូនគឺ ១៥០បាត/តោន ឬ ០,១៥បាត/គ.ក ។ កសិករថៃរាយការណ៍ថាទទួលបាន

៣.៦បាត/គ.ក ទោះជាពោតរបស់គេអន់ជាងក៏ដោយ ។ កសិករថៃ ប្រើជីគីមីសំរាប់ផលិតកម្មពោត ឯកសិករកម្ពុជាមិនប្រើទេដោយសារដីថ្មីមានជីជាតិល្អស្រាប់ហើយ ។

អាជ្ញាធរព្រំដែន និងស្រុក ក៏ទាមទារប្រាក់កំរៃខ្ពស់ដែរ ដែលគាបសង្កត់ដល់កំរិតថ្លៃនៅកសិដ្ឋាន ។ សេចក្តីលំអិតពីបន្ទុកចំណាយ និងអត្រាចំណេញក្នុងពាណិជ្ជកម្មពោត មានបង្ហាញក្នុងតារាង១១ ។

**តារាង ១១. ផលចំណេញនៅតាមខ្សែរយៈទីផ្សារពោតនៅឆ្នាំ២០០៣**

| | បាត/តោន | រៀល/តោន | ដុល្លារ/តោន |
|---|---|---|---|
| ថ្លៃនៅកសិដ្ឋាន | 2,900 | 275,500 | 69.05 |
| ប្រាក់កំរៃតាមផ្លូវ (៣០-៤០បាត/កន្លែង) | 10 | 950 | 0.24 |
| ប្រាប់កំរៃត្រូវបង់ចំពោះរថយន្ត | 20 | 1,900 | 0.48 |
| "ភាស៊ី" ត្រូវបង់នៅកម្ពុជា | 100 | 9,500 | 2.38 |
| "ភាស៊ី" ត្រូវបង់នៅថៃ | 183 | 17,417 | 4.37 |
| ប្រាក់កំរៃសំរាប់នគរបាលព្រំដែន | 10 | 950 | 0.24 |
| វិភាគទានផ្លូវបង់ឱ្យអាជ្ញាធរខាងដឹកជញ្ជូន | 15 | 1,425 | 0.36 |
| ប្រាក់កំរៃសរុប | 338 | 32,142 | 8.06 |
| ការប្រលេះយកគ្រាប់ | 167 | 15,833 | 3.97 |
| ការលើក-ដាក់នៅកម្ពុជា | 125 | 11,875 | 2.98 |
| ចំណាយដឹកជញ្ជូនពីកសិដ្ឋានទៅផ្លូវធំ | 167 | 15,833 | 3.97 |
| ចំណាយដឹកជញ្ជូននៅថៃ | 150 | 14,250 | 3.57 |
| បន្ទុកចំណាយម៉ាឃីទឹងសរុប | 947 | 89,933 | 22.54 |
| ផលចំណេញសុទ្ធសំរាប់ពាណិជ្ជករ | 100 | 9,500 | 2.38 |
| ថ្លៃដែលផ្តល់ឱ្យនៅថៃ | 3,947 | 374,933 | 93.97 |
| ថ្លៃនៅកសិដ្ឋានជា %នៃថ្លៃដែលផ្តល់នៅថៃ | | | 73.5% |
| ប្រាក់កំរៃសរុបជា %នៃថ្លៃនៅកសិដ្ឋាន | | | 11.7% |
| ប្រាក់កំរៃសរុបជា %នៃចំណេញសុទ្ធសំរាប់កសិករ | | | 31.4% |
| ប្រាក់កំរៃសរុបជា% នៃចំនេញសុទ្ធសំរាប់ពាណិជ្ជករ | | | 336% |
| ចំនេញសុទ្ធសំរាប់ពាណិជ្ជករជា %ថ្លៃនៅកសិដ្ឋាន | | | 3.4% |

*ប្រភព: ផ្អែកលើបទសំភាសន៍ស៊ីជំរៅជាមួយពាណិជ្ជករ ២នាក់ និងមន្ត្រីស្រុកនៅបាត់ដំបង ២នាក់ នៅខែមីនា ២០០៣*
*សំគាល់: គោលបំណងនៃការបង្ហាញជា ៣រូបិយវត្ថុគឺដើម្បីសំរួលការគណនារបស់មជ្ឈដ្ឋានខុសៗគ្នា ។*

### ៣.៣.៣. ម៉ាឃីទីង និងការនាំចេញដំឡូងឈើនៅខេត្តកំពង់ចាម

បើគិតតាមទំងន់ ដំឡូងមីមានតំលៃថោកជាងគេក្នុងចំនោមដំណាំបានសិក្សាទាំងបួន ។ នៅឆ្នាំ២០០៣ វាថ្លៃ ៨០-៩០រៀល/គ.ក ឬ ២០-២២ដុល្លារ/តោន ។ ដំឡូងមីភាគច្រើន ទោះនៅទាំងមើម ឬបកសំបក ហាន់ និងហាល ស្ងួត ត្រូវបាននាំចេញទៅវៀតណាម ដូច្នេះមាន ការពឹងផ្អែកក៏រិតខ្ពស់លើទីផ្សារនៅវៀតណាម ។ ពាណិជ្ជកម្មនេះមានលក្ខណៈក្រៅផ្លូវការ ដែលធ្វើឱ្យពាណិជ្ជករនិងកសិករកម្ពុជាចាញ់ប្រៀបគេ ។ ឧទាហរណ៍ មានសេចក្តីរាយការណ៍ ថា នៅខែមីនា ឆ្នាំ២០០៣ អាជ្ញាធរវៀតណាមបានសំរេចចិត្តឈប់ទិញមើមដំឡូងមីពីកម្ពុជា ភ្លាមៗ ដោយសារមានផលិតផលគ្រប់គ្រាន់ហើយនៅវៀតណាម ។ រឿងនេះធ្វើឱ្យកសិករ កម្ពុជាមានបញ្ហាខ្លាំង ដោយមិនអាចលក់ផលិតផលរបស់ខ្លួនក្នុងចំនួនច្រើនៗទៅកន្លែងណា ផ្សេង ។ ម្យ៉ាងទៀត កសិករនិងពាណិជ្ជករអ្នកឆ្លើយសំភាសន៍ប្រាប់ថា ពួកគេមិនដឹងពីការ សំរេចចិត្តនេះជាមុន ដូច្នេះហើយបានខាតបង់ធ្ងន់ធ្ងរណាស់នៅពេលដឹកជញ្ជូនផលិតផលរហូត ទៅដល់ព្រំដែន ។ ជាភ័ព្វល្អ ខាងវៀតណាមនៅអនុញ្ញាតប្រភេទដំឡូងបកសំបក-ហាន់ និងហាល ស្ងួតឱ្យចូលទៅទីផ្សាររបស់គេ ។ ដូច្នេះហើយប្រជាជនត្រូវធ្វើការកែច្នៃនេះដោយខ្លួនឯង ។ ប៉ុន្តែទោះបីគេទទួលបានតំលៃបន្ថែមខ្លះពីការកែច្នៃនេះក្តី ក៏ចំណូលសរុបបានពីផលិតផលគឺមាន កំរិតតិចជាងមុន ។

នៅក្នុងស្រុកមានសមត្ថភាពកែច្នៃមិនគ្រប់គ្រាន់ទេ ដើម្បីស្រូបយកដំឡូងមីដែលផលិត រួចនៅកំពង់ចាម ។ ក្នុងរោងចក្រទើបតំលើងថ្មីនៅក្នុងខេត្ត អាចកែច្នៃបានប្រហែល ១/៣ នៃ ផលិតផលសរុបប៉ុណ្ណោះ ។ កសិករប្រជែងគ្នាលក់ទៅឱ្យរោងចក្រ ហើយមានកសិករមួយចំនួន មិនសប្បាយចិត្តនៅពេលគេមិនទិញផលិតផលខ្លួន ។ ពួកគេជឿថាមានការរើសអើង ដោយ សារពុំមានទំនាក់ទំនងស្គាល់អ្នកណានៅក្នុងរោងចក្រ ។ ប៉ុន្តែកសិករត្រូវចុះឈ្មោះសិន ទើប រោងចក្រអាចទិញផលិតផលរបស់ពួកគេ ។ ដូច្នេះប្រហែលត្រូវចំណាយពេលខ្លះ ទើបគ្រប់ៗគ្នា បានយល់ច្បាស់ពីបទបញ្ជា និងនីតិវិធីបែបនេះ ។

មានពាណិជ្ជករមួយចំនួនទិញដំឡូងជាមើមពីកសិករហើយនាំចេញទៅវៀតណាម ។ តាមធម្មតា កសិករលក់ផលដំឡូងរបស់ខ្លួនក្នុងចំនួនច្រើន៧ ដោយផ្អែកលើការប៉ាន់ស្មានច្បោល១ពីបរិមាណសរុប ។ ប៉ុន្តែធ្វើបែបនេះកសិករ ប្រហែលត្រូវចាញ់ប្រៀប ពីព្រោះពាណិជ្ជករមានបទពិសោធន៍ច្រើនជាងក្នុងការប៉ាន់ស្មានចំនួនផលិតផល ។

ទោះបីគ្មានការប្រមូលប្រាក់កំរៃផ្លូវការលើពាណិជ្ជកម្មដំឡូងមីក្តី ប៉ុន្តែពាណិជ្ជករនៅតែត្រូវចំនាយប្រាក់ និងពេលវេលាច្រើន ដើម្បីដោះស្រាយការទារប្រាក់កំរៃក្រៅផ្លូវការនៅតាមផ្លូវ ។ ពាណិជ្ជករអ្នកឆ្លើយសំភាសន៍ម្នាក់រាយការណ៍ថា គាត់ត្រូវបង់កំរៃនៅ ៩កន្លែងក្នុងចំងាយផ្លូវតែ ១២គ.ម នៅពេលបញ្ជូនទំនិញទៅវៀតណាម ។ ចំណុចត្រួតពិនិត្យភាគច្រើនសុទ្ធតែខុសច្បាប់ និងចល័ត ។ គេទារប្រាក់មិនច្រើនទេត្រឹម ៥០០រៀល ឬ ១.០០០រៀល/រថយន្តដឹកដំឡូង៧តោន ប៉ុន្តែវាធ្វើឱ្យយឺតដំណើរ និងបង្កការរំខាន ។ នៅបាត់ដំបង ដំឡូងជាមើមក៏មាននាំចេញទៅថៃដែរ ។ សំរាប់ដំណាំប្រភេទនេះគ្មានការតំរូវឱ្យបង់ប្រាក់កំរៃលើការនាំចេញទេ ប៉ុន្តែអាជ្ញាធរកម្ពុជានៅព្រំដែន បានទារយក ២០០បាតចំពោះការដឹកដំឡូងមួយរថយន្ត១ ។

### ៣.៣.៤. ម៉ាឃីទីង និងការនាំចេញស្វាយចន្ទី

ថ្លៃគ្រាប់ស្វាយចន្ទី អាចប្រែប្រួលខ្លាំងណាស់ ។ ឧទាហរណ៍ ថ្លៃគ្រាប់ស្វាយចន្ទីជាប់សំបក បានប្រែប្រួលពីជាង ១.០០០ដុល្លារ/តោននៅឆ្នាំ១៩៩៩ មកត្រឹម ៤០០ដុល្លារនៅឆ្នាំ២០០១ ហើយ ៤៥០ដុល្លារនៅឆ្នាំ២០០២ និង ៥៣០ដុល្លារនៅឆ្នាំ២០០៣ ។ ការធ្លាក់ថ្លៃយ៉ាងខ្លាំងពីឆ្នាំ១៩៩៩-២០០១ អាចបណ្តាលពីការធ្លាក់ថ្លៃក្នុងទីផ្សារអន្តរជាតិ និងបញ្ហាទាក់ទិននឹងរចនាសម្ព័ន្ធទីផ្សារក្នុងស្រុក ។ ដោយសារផលិតកម្មទំហំតូច ប្រហែល ១% នៃផលិតកម្មពិភពលោក (ប្រហែល ១លានតោន) ប្រទេសកម្ពុជាគឺជាអ្នកទទួលថ្លៃ និងសឹងតែគ្មានឥទ្ធិពលទៅលើថ្លៃទីផ្សារអន្តរជាតិ (តារាង ១០) ។ ប៉ុន្តែ ការធ្លាក់ថ្លៃពីឆ្នាំ១៩៩៩-២០០០ ប្រហែលមិនមែនជាលទ្ធផលនៃការធ្លាក់ថ្លៃនៅទីផ្សារអន្តរជាតិទេ ប៉ុន្តែជាលទ្ធផលនៃតំរូវការខ្ពស់ជាង

ធម្មតាក្នុងឆ្នាំ១៩៩៩ ពីអ្នកកែច្នៃនៅវៀតណាមដែលកាលនោះហ៊ានអោយថ្លៃខ្ពស់ខ្លាំងណាស់ ។

ក្នុងចំណោមឈ្មួញកណ្តាល មានការប្រជែងគ្នាកំរិតខ្ពស់ ។ ឧទាហរណ៍ នៅខេត្តកំពង់ធំ កសិករនិងពាណិជ្ជករ អាចជ្រើសរើសអ្នកលក់ដុំបាន ពីព្រោះពួកនេះមានដល់ទៅ ៧នាក់នៅឯផ្សារកំពង់ធំ ។ អ្នកលក់ដុំនៅកំពង់ធំ ក៏មានជំរើសអាចលក់ទៅឱ្យពាណិជ្ជករនៅអ្នកលឿង ភ្នំពេញ ឬនៅកំពង់ចាមដែរ ។ មុននឹងមានការលក់ដូរ គេចរចាថ្លៃគ្នាតាមទូរស័ព្ទចល័ត ។

ប៉ុន្តែនៅក្នុងភូមិ កសិករ ជាពិសេសអ្នកមានដើមស្វាយចន្ទីតិច និងនៅឆ្ងាយពីទីផ្សារ មិនសូវមានពាណិជ្ជករ ច្រើនមករកទិញផលិតផលរបស់គេទេ ។ លើសពីនេះទៀត ជារឿយៗ កសិករមិនបានដឹងពីកំរិតថ្លៃនៅទីផ្សារទេ ។

កសិករជាច្រើនខ្ចីប្រាក់ពីពាណិជ្ជករមុនពេលប្រមូលផល ។ ទោះបីជាគោលការណ៍ គេត្រូវលក់ផលិតផលតាមថ្លៃទីផ្សារក៏ដោយ ប៉ុន្តែកំលាំងតថ្លៃរបស់គេបានថយចុះ ។ ក្នុងករណីនេះ ឈ្មួញកណ្តាលអាចកំណត់ថ្លៃឱ្យអតិថិជនដែលជាប់ខសន្យាជាមួយខ្លួន ។

មានឈ្មួញកណ្តាលជាច្រើនស្រទាប់នៅក្នុងខ្សែរយៈទីផ្សារគ្រាប់ស្វាយចន្ទី ។ តាមផ្លូវពាណិជ្ជកម្មចេញពីកំពង់ចាម គឺកសិករលក់ផលិតផលទៅឱ្យឈ្មួញកណ្តាលកំរិតទី១ (កូនដៃតាមពាក្យអ្នកមូលដ្ឋាន) នៅក្នុងភូមិ រួចលក់បន្តទៅឈ្មួញកណ្តាលកំរិតទី២នៅឯផ្សារក្នុងស្រុក ក្រោយមកលក់បន្តឱ្យឈ្មួញនៅភ្នំពេញ ឬអ្នកលឿង មុននឹងបញ្ជូនទៅវៀតណាម ។ ផ្លូវពាណិជ្ជកម្មមួយទៀតគឺ ពីកំពង់ចាមទៅសួង (ស្រុកមួយក្នុងខេត្តកំពង់ចាម) ដែលនៅជិតវៀតណាម ហើយបន្ទាប់មកបញ្ជូនទៅវៀតណាមតែម្តង ។

ដោយសារផលិតកម្មកសិកម្ម និងថ្លៃកសិកម្ម វាប្រែប្រួលតាមអាកាសធាតុ ដូច្នេះថ្លៃដែលប្រជាជនកម្ពុជាទទួលបាន ក៏ប្រែប្រួលដែរ ។ ម្យ៉ាងទៀតកម្ពុជាហាក់ដូចជាទីផ្សារទ្រទាប់សំរាប់វៀតណាមដែលទទួលកិច្ចសន្យាផ្ទាល់ពីប្រទេសអ្នកប្រើប្រាស់ ហើយមកប្រមូលទិញគ្រាប់ស្វាយចន្ទីពីកម្ពុជា បើសិនការផ្គត់ផ្គង់ក្នុងស្រុករបស់ខ្លួន មិនបានគ្រប់តាមចំនួនក្នុងកិច្ច

សន្យា ។ កម្ពុជាមិនទាន់នាំចេញគ្រាប់ស្វាយចន្ទីបកសំបកហើយឱ្យបានច្រើនគួរសមទៅកាន់ប្រទេសអ្នកប្រើប្រាស់ចុងក្រោយទេ ។ មានរោងចក្រកែច្នៃមួយទើបបានបង្កើតនៅពេលថ្មីៗ ដែលទទួលកែច្នៃបានប្រហែល ៥% នៃផលិតផលស្វាយចន្ទីសរុបនៅកម្ពុជា (ពតិមានលំអិតមានចុះក្នុងផ្នែកកែច្នៃ) ។ ជាលទ្ធផល ថ្លៃទីផ្សារសំរាប់ស្វាយចន្ទីកម្ពុជា អាចត្រូវវៀតណាមកំណត់ឱ្យជាបន្តទៀត លើកលែងតែមានការប្រជែងគ្នាក្នុងចំណោមអ្នកទិញនៅវៀតណាម ។ ម្យ៉ាងទៀត ទីផ្សារស្វាយចន្ទីនៅកម្ពុជាមានលក្ខណៈក្រៅផ្លូវការ និងមានការប្រែប្រួលខុសលំនាំដើមជាច្រើនដែលអាចប៉ះពាល់គួរកត់សំគាល់ដល់ការិតថ្លៃនៅកសិដ្ឋាន ។ ទន្ទឹមនឹងនេះ វៀតណាមដែលនាំចេញគ្រាប់ស្វាយចន្ទីប្រហែល ១00.000តោន/ឆ្នាំ នៅតែជាទីផ្សារដ៏សំខាន់សំរាប់កម្ពុជា ។ ការចុះសាកសួរដល់កន្លែងបានឱ្យដឹងថា នៅឆ្នាំ២00១ គ្រាប់ស្វាយចន្ទីភាគច្រើនបានទៅវៀតណាមតាមច្រកស្នាច់ ដែលជាតំបន់ព្រំដែននៅខេត្តកំពង់ចាម ។ ការនាំចេញបែបនោះមានលក្ខណៈក្រៅផ្លូវការ និងគ្មានការកត់ត្រាទេ ។

**តារាង ១២. ការនាំចេញគ្រាប់ស្វាយចន្ទីជាប់សំបក ប៉ាន់ស្មានដោយអ្នកលក់ដុំ**

| | 1999 | 2000 | 2001 | 2002 | 2003 |
|---|---|---|---|---|---|
| គ្រាប់ស្វាយចន្ទីជាប់សំបក នាំចេញ(ត.) | 11,000 | 12,000 | 10,000 | 12,000 | 15,000 |
| ថ្លៃមធ្យមដែលកសិករទទួលបាន (ដុល្លារ/តោន) | $1,000 | $600 | $400 | $450 | $530 |
| តំលៃនាំចេញដែលបានដល់កសិករ (លានដុល្លារ) | $11m | $7.2m | $4.0m | $5.4m | $7.9 |

*ប្រភព: យោងតាមការសំភាសន៍ជាមួយកសិករនៅខេត្តកំពង់ចាម និងកំពង់ធំ និងអ្នកលក់ដុំនិងពាណិជ្ជករនៅកំពង់ចាម កំពង់ធំ និងអ្នកលឿងនៅខែមីនា ២00៣ ។*

សក្តានុពលសំរាប់ពង្រីកផលិតកម្មស្វាយចន្ទីហាក់ដូចមានច្រើនសំបើមណាស់ ។ ស្វាយចន្ទីអាចដាំដុះលើដីច្រើនប្រភេទ ហើយនៅមានដីជាច្រើនទៀតសំរាប់បង្កើនផលិតកម្ម ។ តំរូវការគ្រាប់ស្វាយចន្ទីក្នុងទីផ្សារពិភពលោក ហាក់ដូចមានអនាគតល្អ ពីព្រោះវាមានជីវជាតិល្អច្រើន ។ ចំពោះរឿងដីធ្លីវិញ ផលិតកម្មស្វាយចន្ទីហាក់ដូចអាចពង្រីកបានច្រើនក្នុងខេត្តរតនគិរី មណ្ឌលគិរី និងស្ទឹងត្រែង (ដែលគេអាចនាំចេញផលិតផលទៅទីផ្សារវៀតណាមនៅជិតនោះ)

និងនៅខេត្តកំពង់ធំ សៀមរាប និងខេត្តផ្សេងៗជាច្រើនទៀត ។ ដោយសារការរាំងស្ទះខាងម៉ាឃីទីង ថ្លៃស្វាយចន្ទីនៅកសិដ្ឋានកន្លងមកមានកំរិតទាប ដែលបានកាត់បន្ថយការលើកទឹកចិត្តចំពោះកសិករដើម្បីធ្វើវិនិយោគ ឬពង្រីកការវិនិយោគទុន ។ ផលិតកម្មប្រហែលអាចកើនច្រើនថែមទៀត បើសិនគេអាចកាត់បន្ថយបន្ទុកចំណាយផ្នែកម៉ាឃីទីង ។

កត្តាមួយទៀតជាប់ទាក់ទិននឹងសក្តានុពលផលិតកម្មគឺ ថ្លៃកសិដ្ឋានអាចកើនឡើងនៅពេលកម្ពុជាមានកន្លែងបកសំបកគ្រាប់ស្វាយចន្ទី ។ បន្ទាប់មកកម្ពុជាអាចលក់វាដោយផ្ទាល់នៅបណ្តាប្រទេសអ្នកប្រើប្រាស់ធំៗ ដូចជា ជប៉ុន និងសហរដ្ឋអាមេរិក ។ ក្នុងសេណារីយ៉ូបែបនេះត្រូវមានវិនិយោគទុនថែមទៀតលើការដាំ ហើយអាចបង្កើតតំលៃបន្ថែមមួយកំរិតទៀតនៅកម្ពុជា ។ បច្ចុប្បន្ន នៅខេត្តកំពង់ចាម មានកសាងសហគ្រាសមួយសំរាប់បកសំបកគ្រាប់ស្វាយចន្ទី ។ គេរង់ចាំមើលថាតើរោងចក្រនោះមានប្រសិទ្ធភាព និងអាចរស់រានបានឬទេ ពីព្រោះរោងចក្រនេះ ប្រហែលពុំមានកំរិតសេដ្ឋកិច្ចវិមាត្រ (ទំហំផលិតកម្ម) និងបន្ទុកចំណាយទាបលើប្រេងឥន្ធនៈ ដូចរោងចក្រនៅវៀតណាមទេ ។

**តារាង ១៣. ផលិតកម្មគ្រាប់ស្វាយចន្ទីជាប់សំបកក្នុងពិភពលោកពីឆ្នាំ១៩៩៧-២០០១ (ពាន់តោន)**

| | 1997-98 | 1998-99 | 1999-00 | 2000-01 |
|---|---|---|---|---|
| ឥណ្ឌា | 430 | 360 | 300 | 325 |
| ប្រេស៊ីល | 185 | 175 | 115 | 180 |
| វៀតណាម | 140 | 110 | 70 | 100 |
| តង់ហ្សានី | 80 | 110 | 80 | 100 |
| ម៉ូហ្សំប៊ិក | 30 | 40 | 40 | 40 |
| ឥណ្ឌូនេស៊ី | 20 | 40 | 20 | 30 |
| កម្ពុជា | 11 | 12 | 10 | 12 |
| ប្រទេសផ្សេងៗ | 104 | 58 | 60 | 138 |
| សរុប | 1,000 | 905 | 695 | 925 |

*ប្រភព: ក្រុមប្រឹក្សាគ្រាប់ឈើអន្តរជាតិ ព្រឹត្តប័ត្រស្ថិតិពិភពលោក មេសា ២០០១ អេឡិចត្រូនិច ចុះផ្សាយក្នុង http://inc.treenuts.org/stats_cashew_apr01.html " ព៌ាទ័ស្មានដោយផ្នែកលើការចុះសិក្សាដល់កន្លែង*

### ៣.៣.៥. ការប៉ាន់ស្មាននៃការនាំចេញផលិតផលកសិកម្មបច្ចុប្បន្ន

មានការយល់ស្របជាទូទៅថា ប្រទេសកម្ពុជាមានធនធានធម្មជាតិសំបូរ និងធាតុអាកាសអំណោយផល ដូច្នេះហើយមានឧត្តមភាពប្រៀបធៀបជាសក្តានុពលខាងកសិកម្ម ។ ប៉ុន្តែឧត្តមភាពប្រៀបធៀបពិតជាក់ស្តែងខាងកសិកម្ម មិនទាន់លេចជារូបរាងនៅឡើយទេ (Kato, *et al,* 1998 and Chan, 2000) ។ ការសិក្សាមួយចំនួនបានបង្ហាញពីឧបសគ្គក្នុងការពង្រីកការនាំចេញខាងកសិកម្ម ។ ឧបសគ្គគេតែងលើកឡើងជាទូទៅគឺមានអប្រសិទ្ធិភាពក្នុងការងារក្រោយពេលប្រមូលផល លំហូរពត៌មានមិនគ្រប់គ្រាន់ បន្ទុកចំណាយដឹកជញ្ជូនខ្ពស់ កន្លែងត្រួតពិនិត្យមិនស្របច្បាប់ និងកង្វះទីផ្សារខាងក្រៅ[៣៤] ។ ការសិក្សានេះព្យាយាមវាយតំលៃថា តើសក្តានុពលនាំចេញខាងកសិកម្មរបស់កម្ពុជាអាចពង្រីកបានឬទេ ដោយមិនចាំបាច់ធ្វើការងារជាន់គ្នានឹងការសិក្សាផ្សេងៗទៀតដែលបានធ្វើហើយ ក្នុងពេលថ្មីៗ ដូចជា ការសិក្សាដ៏ទូលំទូលាយឈ្មោះថា "ការសិក្សាពីសមាហរណកម្ម និងភាពប្រកួតប្រជែង" ដែលក្រសួងពាណិជ្ជកម្មបានបញ្ចប់ហើយជាដើម ។ គំហើញថ្មីៗបានពីការវិភាគលើទិន្នន័យមានស្រាប់ និងការចុះសាកសួរដល់ទីកន្លែង គឺជាចំណុចផ្តោតចំបងនៃការពិភាក្សា ប៉ុន្តែនៅមានបញ្ហាដ៏សំខាន់ៗមួយចំនួនទៀតដែលគួរបញ្ជាក់ឡើងវិញ ។

**តារាង ១៤. ការនាំចេញផលិតផលក្នុងវិស័យកសិកម្មដែលផ្អែកលើទិន្នន័យផ្លូវ**

| HS | មុខទំនិញ | តំលៃនាំចេញ (លានដុល្លារ) | |
|---|---|---|---|
| | | 2000 | 2001 |
| 01 | សត្វរស់ | 0.05 | 1.07 |
| 03 | ត្រី ក្តាម ខ្យង បង្គា, និងសត្វគ្មានឆ្អឹងខ្នងផ្សេងទៀត | 5.90 | 6.07 |
| 10 | ធញ្ញជាតិ | 0.96 | 2.39 |
| 40 | កៅស៊ូ និងសំភារៈធ្វើពីកៅស៊ូ | 31.99 | 25.83 |

[៣៤] ឧទាហរណ៍ សូមអាន MoC, 2001 ការសិក្សាពីសមាហរណកម្ម និងភាពប្រកួរប្រជែង និងឯកសារ MAFF (1999) "កម្ពុជាៈ យុទ្ធសាស្ត្រកសិកម្ម និងក្របខណ្ឌគោលនយោបាយសំរាប់សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រមានចីរភាព", MAFF, FAO, UNDP (Phnom Penh: January 1999) ។

| | | | |
|---|---|---|---|
| 44 | ឈើ និងសំភារៈធ្វើពីឈើ, ធ្យូង | 34.07 | 23.10 |
| | សរុប (ដកឈើចេញ...) | 38.90 | 35.36 |
| | សរុប (រាប់ទាំងឈើ...) | 72.97 | 58.46 |
| | សំលៀកបំពាក់ | 985.00 | 1112.00 |
| | សរុបការនាំចេញ | 1408.00 | 1438.00 |
| | នាំចេញកសិកម្ម ដកឈើ ធៀបនឹងសំលៀកបំពាក់ | 3.9% | 3.2% |
| | នាំចូលកសិកម្ម ដកឈើ ធៀបនឹងសំលៀកបំពាក់ | 7.4% | 5.3% |
| | នាំចេញកសិកម្ម ដកឈើ ធៀបនឹងនាំចេញសរុប | 2.8% | 2.5% |
| | នាំចូលកសិកម្ម ដកឈើ ធៀបនឹងនាំចេញសរុប | 5.2% | 4.1% |

*ប្រភព: ក្រសួងពាណិជ្ជកម្ម ការនាំចេញឆ្នាំ២០០០ និង ២០០១ ។*

ដូចមានចុះក្នុងតារាង១៤ តាមតួលេខផ្លូវការចងក្រងដោយរដ្ឋាភិបាល ការនាំចេញផលិតផលសរុបក្នុងវិស័យកសិកម្មរួមទាំងឈើ មាន ៥៨,៥លានដុល្លារនៅឆ្នាំ២០០១ ។ តួលេខនេះតិចណាស់ ធៀបនឹងការនាំចេញសំលៀកបំពាក់សរុបដែលមានដល់ទៅ ១.១១២លានដុល្លារក្នុងឆ្នាំដូចគ្នា ។ គឺបានន័យថា ការនាំចេញកសិកម្មក្រៅពីឈើ បានត្រឹមតែ ៣,២% នៃការនាំចេញសំលៀកបំពាក់ ឬ ២,៥%នៃការនាំចេញសរុបនៅឆ្នាំ២០០១ ។

## តារាង ១៥. តំលៃនាំចេញនៃផលិតផលកសិកម្មសំខាន់ៗផ្អែកតាមការប៉ាន់ស្មានរបស់អ្នកលក់ដុំ និងពាណិជ្ជករ និងផ្អែកលើតួលេខផ្លូវការ

| ផលិតផល | តំលៃនាំចេញប៉ាន់ស្មាន សំរាប់ឆ្នាំ២០០២ (លានដុល្លារ) | សក្តានុពលពង្រីកការនាំចេញ [ក] |
|---|---|---|
| គ្រាប់ធញ្ញជាតិ | | |
| ស្រូវ | 7.0 | ខ្ពស់ |
| សណ្តែកសៀង | 8.0 | ខ្ពស់ណាស់ |
| ស្វាយចន្ទី | 5.4 | ខ្ពស់ណាស់ |
| សណ្តែកបាយ | 1.5 | ខ្ពស់ណាស់ |
| ពោត | 12.0 | ខ្ពស់ណាស់ |
| ល្ង | 3.5 | ខ្ពស់ |
| ដំឡូងឈើ | 2.0 | ខ្ពស់ណាស់ |
| អំពៅ | 0.5 | ខ្ពស់ |
| សរុបរងគ្រាប់ធញ្ញជាតិ | 39.9 | |

| | | |
|---|---|---|
| ត្រី | 6.0 | ខ្ពស់ណាស់ |
| គោនិងក្របីរស់ | 2.0 | ខ្ពស់ណាស់ |
| កៅស៊ូ | 25.8 | ខ្ពស់ណាស់ |
| សរុបរង | 33.8 | |
| សរុប | 73.7 | |

*[ក] ការវិនិច្ឆ័យនេះផ្អែកតាមពត៌មានប្រមូលបានក្នុងការសិក្សានេះ ។ ប្រភព: ផ្អែកលើការសំភាសន៍ជាមួយកសិករនៅកំពង់ចាម កំពង់ធំ និងអ្នកលក់ដុំ/ពាណិជ្ជករនៅកំពង់ចាម កំពង់ធំ អ្នកលឿង ក្រុងព្រះសីហនុ ខែមីនា ឆ្នាំ២០០៣ ។*

ប៉ុន្តែបើវិនិច្ឆ័យតាមពត៌មានប្រមូលបានក្នុងពេលចុះសាកសួរដល់កន្លែង ការនាំចេញកសិកម្មពិត គួរតែខ្ពស់ជាងនេះច្រើន ។ មន្ត្រីជាន់ខ្ពស់ខាងស្ថិតិនៅក្រសួងកសិកម្ម ក៏ទទួលស្គាល់ដែរថា តួលេខរបស់ខ្លួនប៉ាន់ស្មានទាបជាងចំនួនពិត ។ ផ្អែកលើបទសំភាសន៍ជាមួយនឹងអ្នកលក់ដុំ និងពាណិជ្ជករ ផលិតផលកសិកម្មមិនមែនឈើបាននាំចេញសរុបនៅឆ្នាំ២០០១ គួរបានប្រហែល ៧០លានដុល្លារ មិនមែន ៣៥លានដុល្លារដូចក្នុងស្ថិតិរដ្ឋាភិបាលទេ ហើយពត៌មាននេះជាដំណឹងល្អមួយ ។ តួលេខខុសគ្នាខ្លាំងទាក់ទិននឹងធញ្ញជាតិ ដែលរដ្ឋាភិបាលរាយការណ៍ថាមាន ២,៣៩លានដុល្លារ តែការប៉ាន់ស្មានរបស់យើងគឺប្រហែល ៤០លានដុល្លារ ។ ទោះយ៉ាងនេះក្តី សូម្បីតួលេខសុទិដ្ឋិនិយមក្នុងតារាង ១៥ ក៏បង្ហាញថា ការនាំចេញកសិកម្មនៅទាបខ្លាំងណាស់ បើធៀបនឹងការនាំចេញសំលៀកបំពាក់ ។ តារាង ១៥ ក៏បានប៉ាន់ស្មានពីកំរិតសក្តានុពលដើម្បីពង្រីកផលិតកម្ម និងការនាំចេញផលដំណាំ ហើយនិងអនុវិស័យខ្លះៗខាងកសិកម្ម ។

**ប្រអប់ ២. បន្ទុកចំណាយដឹកជញ្ជូន តាមផ្លូវពាណិជ្ជកម្មមួយចំនួន**

ស្រូវ សណ្តែកសៀង ស្វាយចន្ទី សណ្តែកបាយ ពោត អំពៅ ល្ងរ គ្រាប់ឈូក ដំឡូងឈើ និងសូម្បីតែ គោនិងក្របី ក៏បច្ចុប្បន្នបាននាំចេញជាវត្ថុធាតុដើមសុទ្ធសាធ ។ ធៀបនឹងប្រទេសដទៃទៀតដែលមានផ្លូវថ្នល់ល្អច្រើនជាង និងពន្ធលើប្រេងឥន្ទនៈទាបជាងច្រើន, បន្ទុកចំណាយលើការលក់ដូរគួរមានកំរិតខ្ពស់ណាស់នៅកម្ពុជា ដែលមានហេដ្ឋារចនាសម្ព័ន្ធទន់ខ្សោយ និងការធ្វើកសិកម្មជាទ្រង់ទ្រាយតូច ។ បន្ទុកចំណាយដឹកជញ្ជូនប្រៀបធៀប មានបង្ហាញក្នុងដំណាក់កាលទី២ នៃការសិក្សា ។ កម្ពុជាជាប្រទេសមួយតូច ហេតុនេះគឺជាអ្នក

ទទួលយកថ្លៃសំរាប់គ្រប់ផលិតផល ។ ជាលទ្ធផល បន្ទុកចំណាយលក់ដូរនិងដឹកជញ្ជូនខ្ពស់ បានគាបសង្កត់ថ្លៃនៅកសិដ្ឋាន ។ ចំពោះផលិតផលធ្ងន់ៗមានតំលៃទាប ដូចជា អំពៅ និង ដំឡូងឈើជាដើម, បន្ទុកចំណាយដឹកជញ្ជូនស្ទើរតែបានរាំង ទាំងស្រុងដល់តំបន់មួយចំនួន ក្នុងការទទួលបានថ្លៃនៅកសិដ្ឋានដែលអាចមានចំណេញ ។ តទៅនេះគឺជាបន្ទុកចំណាយដឹក ជញ្ជូននៅតាមផ្លូវជាក់ស្តែងមួយចំនួន ដែលបានរកឃើញក្នុងការចុះអង្កេតដល់កន្លែង ។

ពីឃុំបុសខ្នុរ (ខេត្តកំពង់ចាម) ទៅអ្នកលឿង ដោយកាត់តាមទីរួមខេត្តព្រៃវែង បន្ទុកចំណាយដឹកជញ្ជូន ផលិតផលកសិកម្មគឺ ៨ដុល្លារ/តោន និងត្រូវចំណាយពេល ៦ម៉ោង ចំពោះរថយន្តដឹកទំនិញ ១៨តោន ដែលប្រើម៉ាស៊ូតអស់ប្រហែល ១០០លីត្រ (៤០ដុល្លារ) ដើម្បីធ្វើដំណើរចំងាយផ្លូវ ១២០គ.ម រវាងចំណុចទាំងពីរ ។ អត្រា ៨ដុល្លារ/តោន គឺរួម បញ្ចូលទាំងកំរៃនានានៅតាមផ្លូវដែលមានប្រហែល ១ដុល្លារនាពេលបច្ចុប្បន្ន ប៉ុន្តែគ្មានបូក ថ្លៃលើក-ដាក់ទេ ដែលអស់ប្រហែល ១ដុល្លារថែមទៀត ។ ក្នុងពេលមានអសន្តិសុខនៅមុន ឆ្នាំ១៩៩៨ បន្ទុកចំណាយនេះគឺ ២២ដុល្លារ/តោន ។

ផ្លូវមួយទៀតគឺពីបុសខ្នុរទៅអ្នកលឿង ដោយកាត់តាមភ្នំពេញ ។ ចំងាយផ្លូវមាន ១៨០គ.ម ត្រូវចំណាយពេលប្រហែល ៨ម៉ោង និងប្រើម៉ាស៊ូតអស់ ១២០លីត្រ ។ ប្រាក់កំរៃ ក្រៅផ្លូវការសរុបនៅតាមផ្លូវ គឺប្រហែល ៨០.០០០រៀល ឬ ២០ដុល្លារ ។ យោងតាមអ្នក ដឹកជញ្ជូនម្នាក់ ប្រាក់កំរៃនេះមានបូកទាំងការបង់ដើម្បីជៀសផុតពីការថ្លឹងផង ។

គេចំណាយ ១០ដុល្លារ/តោន ដើម្បីដឹកជញ្ជូនសណ្តែកសៀងតាមរថយន្តពីស្រុកត្បែង មានជ័យ ព្រះវិហារ ទៅទីរួមខេត្តកំពង់ធំ ។ បន្ទាប់មកពីខេត្តកំពង់ធំទៅអ្នកលឿងត្រូវចំនាយ ដឹកជញ្ជូនអស់ ១០ដុល្លារ/តោន បើដឹកតាមរថយន្តដឹកទំនិញតូចៗ ឬ ៨ដុល្លារ/តោន បើដឹកតាម រថយន្តធំៗ ។ ការបង់កំរៃតាមផ្លូវពីខេត្តព្រះវិហារទៅកំពង់ធំ គឺអស់ប្រហែល ៥.០០០រៀល/

រថយន្ត/កន្លែង ។ អាចមាន ២ ឬ ៣កន្លែងបែបនេះ ដែលសុទ្ធតែមិនស្របច្បាប់ទាំងអស់ ។

### ៣.៣.៦. ចំណុចខ្សោយចំបងៗក្នុងប្រព័ន្ធម៉ាឃីទីង និងការនាំចេញ

#### ៣.៣.៦.១. លំហូរពតិមាននៅខ្សោយ

មានការនិយាយច្រើនគ្រប់គ្រាន់ហើយ ពីលំហូរពតិមានអន់ខ្សោយក្នុងទីផ្សារកសិកម្ម ហើយក្រសួងពាណិជ្ជកម្ម ក៏បានប្រឹងប្រែង និងធ្វើផែនការធ្វើរួចហើយ ដើម្បីកែលំអលំហូរពតិមាន ជាពិសេសទៅដល់កសិករ ។ ការងារនេះច្បាស់ជាជួយកាត់បន្ថយការកេញប្រវ័ញ្ចលើពីកសិករដែលមានពតិមានមិនគ្រប់គ្រាន់អំពីផលិតផលរបស់ខ្លួន ។ ប៉ុន្តែចំពោះលំហូរពតិមាននៅកំរិតអន្តរជាតិ គឺមានការយកចិត្តទុកដាក់តិចជាង ។ ការចុះសាកសួរដល់កន្លែងបានរកឃើញថា អ្នកលក់ដុំធំៗជាងគេនៅកម្ពុជា ភាគច្រើនមិនទាន់មានប្រភពពតិមានដ៏គួរទុកចិត្តទេ ដើម្បីធ្វើការទស្សន៍ទាយពីការប្រែប្រួលក្នុងផលិតកម្ម និងកំរិតថ្លៃ ។ ជារឿយៗមានការសំរេចចិត្តខុសអំពីចំនួនផលិតផលត្រូវស្តុកទុក ដោយសារទទួលបានពតិមានមិនពិតពីគូរប្រជែង ។ ភាពមិនច្បាស់លាស់របស់អ្នកលក់ដុំដែលផុសចេញពីពតិមានមិនពិត វាមានផលប៉ះពាល់ដោយផ្ទាល់ចំពោះផលិតករ រួមទាំងកសិករក្រីក្រផងដែរ ។ នៅកម្ពុជា អ្នកទិញនៅតំបន់ដាច់ស្រយាលគឺជាអ្នកផ្តាច់មុខ ហើយអាចកំណត់កំរិតថ្លៃសំរាប់ទីផ្សារក្នុងតំបន់បាន ។ អ្នកលក់ដុំ ឬពាណិជ្ជករភាគច្រើន គ្មានប្រើទេនូវអ៊ិនធឺណែតដែលអាចផ្តល់ពតិមានជួយដល់មុខរបររបស់ខ្លួនបាន ។

#### ៣.៣.៦.២. បន្ទុកចំណាយខ្ពស់លើការលក់ដូរ

គេទទួលស្គាល់ជាទូទៅថា បន្ទុកចំណាយលក់ដូរខ្ពស់ វារារាំងដល់ពាណិជ្ជកម្ម និងបន្ទុចបង្អាក់ផលិតកម្ម ។ គេឃើញច្បាស់ហើយថា បន្ទុកចំណាយនៅកម្ពុជាលើការលក់ដូរ វាខ្ពស់ជាងនៅប្រទេសជិតខាង ដោយសារប្រព័ន្ធស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធទីផ្សាររូបវ័ន្តនៅអន់ខ្សោយជាងគេ ។ ដូច្នេះគួរលើកឡើងពីកត្តាធំៗមួយចំនួន ដែលបានបង្កើនបន្ទុកចំណាយលើការលក់ដូរនេះ ។

- **ផ្លូវអន់:** បញ្ហានេះបានលើករួចហើយ ប៉ុន្តែគួរបញ្ជាក់ឱ្យច្បាស់ម្តងទៀត ។ ទោះបីក្នុងពីរទសវត្សរ៍កន្លងទៅ កម្ពុជាបានប្រឹងប្រែងស្តារឡើងវិញទាំងបរិមាណ និងគុណភាពផ្លូវ និងក្នុងករណីខ្លះមានទាំងស្ពានផង ប៉ុន្តែនៅមិនទាន់បានគ្រប់គ្រាន់ទេ ។ ស្ថានភាពផ្លូវគឺអន់ខ្លាំងណាស់ ធ្វើឱ្យអស់សោហ៊ុយច្រើនក្នុងការដឹកជញ្ជូនផលិតផល

និងមនុស្ស ។ នេះជាឧបសគ្គជាមូលដ្ឋានមួយដែលរារាំងវិស័យកសិកម្មក្នុងការរីកលូតលាស់ចេញពីកិរិតជីវព្រឹត្តិ ។ ផ្លូវអន់ បង្កការចាញ់ប្រៀបគេនៃផលិតផលធ្ងន់មានតំលៃទាប ដូចជា ដំឡូងឈើ និងអំពៅ ។ ដូច្នេះត្រូវពន្លឿនសកម្មភាពកសាងផ្លូវគមនាគន៍ និងស្ពាន បើសិនចង់ពង្រីកផលិតកម្ម និងពាណិជ្ជកម្មខាងកសិកម្ម ។

- **បន្ទុកចំណាយដឹកជញ្ជូនខ្ពស់:** បន្ថែមទៅលើផ្លូវគមនាគមន៍អន់ មានកត្តាមួយចំនួនទៀតដែលបង្កើនបន្ទុកចំណាយដឹកជញ្ជូន ។ ទី១ ពន្ធខ្ពស់លើប្រេងឥន្ទនៈគឺជាមុខចំណាយខ្ពស់បំផុតនៃការដឹកជញ្ជូន ។ "ការសិក្សាពីសមាហរណកម្ម និងភាពប្រកួតប្រជែង" របស់ក្រសួងពាណិជ្ជកម្ម បានបង្ហាញច្បាស់ថា ពន្ធលើប្រេងឥន្ទនៈនៅកម្ពុជា មានកិរិតខ្ពស់ជាងគេនៅក្នុងតំបន់[៣៥] ។ រឿងនេះបានកាត់បន្ថយយ៉ាងធ្ងន់ធ្ងរដល់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់ ។ ដូចកត្តាផ្លូវអន់ដែរ ពន្ធខ្ពស់លើប្រេង បានបង្កើនបន្ទុកចំនាយដឹកជញ្ជូនទំនិញ និងមនុស្ស, រាំងស្ទះពាណិជ្ជកម្ម, សង្កត់ចុះកិរិតថ្លៃនៅកសិដ្ឋាន, ហើយជាលទ្ធផលបានធ្វើឱ្យបាក់ទឹកចិត្តក្នុងការផលិត ។ ទី២. យានយន្តដឹកជញ្ជូននៅកម្ពុជា ពុំមានប្រសិទ្ធភាពទេបើធៀបនឹងប្រទេសនៅជិតខាង ហើយមួយភាគធំគឺដោយសារផ្លូវ ស្ពាន គុណភាពអន់ ។ កត្តានេះបានបង្កើនបន្ទុកចំណាយឯកតាសំរាប់ការដឹកជញ្ជូនផលិតផលកសិកម្មមួយកិរិតទៀត ដោយវាបង្កើនបន្ទុកចំណាយលើការថែទាំ និងជួសជុល ។
- **បន្ទុកចំណាយលើការិយាធិបតេយ្យខ្ពស់:** អ្នកនាំចេញជាផ្លូវការនៃផលិតផលកសិកម្ម បានត្អូញត្អែរពីចំណាយខ្ពស់ក្នុងការបញ្ជូនផលិតផល ឆ្លងកាត់អាជ្ញាធរផ្សេងៗ ដូចជា ការិយាល័យគយ និងនគរបាល ។ ពួកគេអះអាងថា "បន្ទុកចំណាយលើការិយាធិបតេយ្យ" គឺជាឧបសគ្គចំបងមួយចំពោះការធ្វើជំនួញឱ្យមានភាពប្រកួតប្រជែងល្អ ហើយបន្ទុកចំណាយទាំងនេះត្រូវបានផ្ទេរទៅលើផលិតករ ។

---

[៣៥] MOC (2001)c, "ការសិក្សាពីសមាហរណកម្ម និងភាពប្រកួតប្រជែង- ផ្នែក គ." ភ្នំពេញ

ប៉ុន្តែ អ្នកនាំចេញក្រៅផ្លូវការមិនបានត្អូញត្អែរច្រើនពីបន្ទុកចំណាយទាំងនេះទេ ។ ពួកគេមិនទាមទារក្រដាសស្នាមអ្វីពីអាជ្ញាធរជាប់ទាក់ទិនទេ ទោះបីពួកគេបានបង់ប្រាក់កំរៃក្រៅផ្លូវការទៅឱ្យមន្ត្រីនានានៅតាមផ្លូវ និងនៅតាមចំណុចត្រួតពិនិត្យក៏ដោយ ។

- **បន្ទុកចំណាយខ្ពស់លើការប្រមូលទិញ:** កសិកម្មកម្ពុជា មានលក្ខណៈសំខាន់ជាកសិដ្ឋានខ្នាតតូច ។ ដោយសារមានកសិដ្ឋានតូចៗច្រើន ការប្រមូលផលិតផល និងទិញដុំ ត្រូវចំណាយអស់ច្រើន ។ម្យ៉ាងទៀត មានឈ្មួញកណ្តាលច្រើនស្រទាប់ពេកក្នុងខ្សែរយៈទីផ្សារ ។ ឧទាហរណ៍ សំរាប់ទីផ្សារគ្រាប់ធញ្ញជាតិខ្លះ គឺមានអ្នកប្រមូល (អ្នកមូលដ្ឋានហៅថា កូនកំព្រូង) ទិញផលិតផលផ្ទាល់ពីកសិករ ។ បន្ទាប់មក អ្នកប្រមូលទាំងនេះលក់ផលិតផលទៅឱ្យពាណិជ្ជករនៅទីផ្សារស្រុក (ហៅថា មេកំព្រូង) ។ ពាណិជ្ជករទាំងនេះមិនស្តុកទំនិញយូរទេ ហើយលក់វាចេញវិញទៅឱ្យពាណិជ្ជករធំៗនៅខេត្តដែលមានលទ្ធភាពស្តុកទុកបានយូរជាង បើសិនគេចង់ ។ពាណិជ្ជករថ្នាក់ខេត្តទាំងនេះ លក់ទំនិញទៅឱ្យអ្នកលក់ដុំធំៗ ដែលធ្វើការលក់ដូរផ្ទាល់ជាមួយអ្នកទិញបរទេស ។ រចនាសម្ព័ន្ធបែបនេះដែលឃើញមានជាទូទៅក្នុងទីផ្សារគ្រាប់ធញ្ញជាតិ មានឈ្មួញកណ្តាលបួនស្រទាប់ ហើយវាបានបង្កើនបន្ទុកចំណាយច្រើនណាស់លើការលក់ដូរផលិផលកសិដ្ឋាន មុននឹងបានទៅដល់អ្នកប្រើប្រាស់ចុងក្រោយ ជាពិសេសនៅឯប្រទេសផ្សេងទៀត ។ នៅពេលប្រទេសមួយដែលមានកសិដ្ឋានតូចៗច្រើនបែបនេះ ត្រូវប្រកួតប្រជែង នឹងប្រទេសមួយទៀតដែលមានកសិដ្ឋានតូចៗតិចជាងនិងកសិដ្ឋានធំៗច្រើនជាង ក្នុងការនាំចេញផលិតផលជាក់លាក់ណាមួយ ប្រទេសដែលមានកសិដ្ឋានតូចៗច្រើននឹងមានកំលាំងប្រកួតប្រជែងតិចជាង (បើសិនកត្តាផ្សេងទៀតមានដូចគ្នា) ។ រឿងនេះគឺដោយសារមានបន្ទុកចំណាយខ្ពស់លើការប្រមូលទិញ ដែលគាបសង្កត់ចុះកំរិតថ្លៃនៅកសិដ្ឋាន ។

### ៣.៣.៦.៣. កង្វះស្តង់ដាគុណភាព ឬការគិតគូររយៈពេលវែង

អ្នកលក់ដុំមួយចំនួនបានឆ្លើយសំភាសន៍ប្រាប់ពីការអនុវត្តន៍ "មិនល្អ" ខ្លះក្នុងពាណិជ្ជកម្ម ផលិតផលកសិកម្មជាច្រើន ដែលធ្វើឱ្យបរាជ័យដល់ការព្យាយាមចាប់យកទីផ្សារខ្លះ ។ បញ្ហាទូទៅមួយគឺ ផលិតផលដូចជា សណ្តែកសៀង និងគ្រាប់ឈូក បានយកទៅត្រាំទឹកដើម្បីបង្កើនទំងន់ ។ ក្នុងរយៈពេល២-៣សប្តាហ៍ គ្រាប់ធញ្ញជាតិឃើញនៅល្អទេ តែក្រោយមកវានឹងខូចអស់ ។ ថ្វីបើគំនិតខ្លីបែបនេះមិនទាន់ច្រើនណាស់ណាក៏ដោយ ប៉ុន្តែវាបានកំចាត់អ្នកលក់ដុំអស់មួយចំនួនដែលបានបាត់បង់ទីផ្សារខ្លះ ។ ឧទាហរណ៍ គេរាយការណ៍ថា នៅមុនទសវត្សរ៍១៩៩០ ថៃជាទីផ្សារសណ្តែកសៀងមួយធំរបស់កម្ពុជា ។ ប៉ុន្តែដោយសារបញ្ហាខាងលើ កម្ពុជាបានបាត់បង់ទីផ្សារនេះទៅ ។ ដូចគ្នាដែរ នៅចុងទសវត្សរ៍១៩៨០ គ្រាប់ឈូកលែងរកទីផ្សារបាននៅសិង្ហបុរី ឬកន្លែងផ្សេងទៀត ដោយសារតែទង្វើបែបនេះ ។ គេដឹងមិនច្បាស់ទេថា ទង្វើបែបនេះបានចាប់ផ្តើមឡើងដោយហេតុអ្វី ប៉ុន្តែគំនិតខ្លីកើតចេញពីភាពក្រីក្រអាចជាមូលហេតុមួយ ហើយមនុស្សដែលចង់បានចំណេញទទេៗក៏អាចជាមូលហេតុមួយទៀត ។ ទោះយ៉ាងនេះក្តី ការបន្លំបែបនេះគេជឿថានៅមាននៅឡើយ ក្នុងទីផ្សារកសិកម្មខ្លះៗ ។ ឧទាហរណ៍នៃការអនុវត្តន៍មិនល្អផ្សេងទៀតមានដូចជា ការយកគ្រាប់ស្វាយចន្ទីទុំទៅលាយជាមួយគ្រាប់ស្វាយចន្ទីមិនទាន់ទុំនៅពេលបានថ្លៃខ្ពស់, យកល្ងទៅលាយជាមួយខ្សាច់, យកទឹកចាក់បញ្ចូលក្នុងសាច់មាន់កាប់លក់, យកដែកគោលនិងលោហធាតុផ្សេងទៀតទៅញាត់ក្នុងបង្កង... ។ ការអនុវត្តន៍ទាំងអស់នេះ មានគោលដៅបង្កើនទំងន់ផលិតផល ។ ការអនុវត្តន៍បែបនេះអាចបាត់ទៅវិញអស់ក្នុងរយៈពេលវែងនៅពេលទីផ្សារមានស្ថិរភាព ប៉ុន្តែការអប់រំសាធារណៈមានសារៈសំខាន់បំផុតដើម្បីបន្ទឿនការបញ្ឈប់ទង្វើនេះ ។ បន្ទុកចំណាយក៏ខ្ពស់ពេកដែរ បើសិនគេពិចារណាពីសក្តានុពលដើម្បីនាំចេញ ។ នៅក្នុងគំនិតនេះដែរ អនាម័យហ្វីតូ មានសារៈសំខាន់បំផុត បើសិនកម្ពុជាមានបំណងចូលទៅទីផ្សារអឺរ៉ុប និងប្រទេសអភិវឌ្ឍន៍ផ្សេងៗទៀត ។

### ៣.៣.៦.៤. "ទីផ្សារស្តើង (thin markets) "

គួរឱ្យយកចិត្តទុកដាក់ដែរដែលអ្នកលក់ដុំបានប្រាប់ថា នៅពេលមានតំរូវការច្រើនពីក្រៅប្រទេសនូវផលិតផលណាមួយ, កសិករនិងអ្នកលក់រាយដែលបានដឹងពីរឿងនេះ គេទាមទារថ្លៃខ្ពស់ខ្លាំងណាស់ ។ ថ្លៃថ្មីដែលគេទាមទារវាខ្ពស់ជាងថ្លៃទីផ្សារយ៉ាងច្រើន ធ្វើឱ្យអ្នកលក់ដុំមិនអាចប្រមូលទិញផលិតផលបានគ្រប់គ្រាន់ ដើម្បីបំពេញតាមកិច្ចសន្យានាំចេញ ។ ជាទូទៅវាត្រឹមត្រូវហើយដែលតំរូវការខ្ពស់ធ្វើឱ្យថ្លៃឡើងខ្ពស់ (បើកត្តាផ្សេងៗទៀតនៅដដែល) ហើយវាគ្មានអ្វីខុសទេដែលកសិករឬអ្នកលក់រាយទាមទារថ្លៃខ្ពស់ ។ ប៉ុន្តែគឺការកេងយកចំណេញច្រើនហួសហេតុពីសំណាក់អ្នកទាមទារថ្លៃខ្ពស់បែបនេះ ដែលធ្វើឱ្យការលក់ដូរបរាជ័យ ។ ដំណើរការក្នុងរឿងនេះ មានជាសង្ខេបដូចតទៅ ។ តំរូវការពីក្រៅប្រទេស ផ្អែកលើថ្លៃជាទូទៅនៅទីផ្សារកម្ពុជា ។ នៅពេលថ្លៃកើនឡើង ការលក់ដូរមិនធ្វើបានចប់សព្វគ្រប់ទេ ។ ពិតណាស់ថ្លៃនឹងត្រូវធ្លាក់ចុះវិញ តែបើសិនជាវាយឺតពេលពេក វាបង្កើតបន្ទុកចំណាយថែមទៀតចំពោះអ្នកលក់ដុំ ។ នេះជាបញ្ហាចំបងមួយ ក្នុងការចុះកិច្ចសន្យាធំៗជាមួយបរទេស ។ បច្ចុប្បន្ននេះ អ្នកលក់ដុំគ្រាន់តែទិញផលិតផលតាមថ្លៃនៅទីផ្សារដោយមិនបង្កការប៉ះទង្គិចដល់តំរូវការ ហើយស្តុកវា រង់ចាំលក់ឱ្យពាណិជ្ជករថៃ ឬវៀតណាម ដែលមករកទិញនៅកម្ពុជាដើម្បីនាំចេញបន្ត ។ នេះជាឧទាហរណ៍ទីផ្សារ "ស្តើង" ឬ ទំហំតូចនៃផលដំណាំខ្លះៗក្រៅពីស្រូវ ។

### ៣.៣.៦.៥. កិច្ចសន្យាធ្វើកសិកម្មពិបាកបង្កើត

វិធីមួយដើម្បីដោះស្រាយរឿង "ទីផ្សារស្តើង" គឺការធ្វើ "កិច្ចសន្យាធ្វើកសិកម្ម" ។ អ្នកលក់ដុំរាយការណ៍ថា ពួកគេបានអនុវត្តរួចហើយ តែមិនបានសំរេចទេ ។ ពួកគេថែមទាំងបានផ្តល់សាច់ប្រាក់ និងមធ្យោបាយផ្សេងទៀត ដល់កសិករដើម្បីឱ្យផលិតមុខដំណាំដែលគេត្រូវការ ។ ពួកគេក៏បានយល់ព្រមទិញផលិតផលក្នុងថ្លៃមួយជាក់លាក់ដែរ ដែលត្រូវតែទាបជាងថ្លៃនៅទីផ្សារ ។ ប៉ុន្តែនៅពេលព្រមព្រៀងគ្នាសព្វគ្រប់ហើយ ជារឿយៗកសិករមិនគោរពតាមកិច្ចសន្យាទេ ។ ពួកគេអាចលក់ផលិតផលរបស់ខ្លួនមួយភាគទៅឱ្យអ្នកចុះកិច្ចសន្យា ហើយលក់ចំនួននៅសល់ដោយស្ងាត់ៗទៅទីផ្សារដែលបានថ្លៃខ្ពស់ជាង ។ ដូច្នោះ ទីផ្សារអនាគត (ឬការបណ្តាក់)

ហាក់ដូចមិនដំនើរការទេ ក្នុងបរិបទកម្ពុជាបច្ចុប្បន្ន ដែលមានអ្នកក្រីក្រខ្លាំង និងខ្វះមធ្យោបាយសក្តិសិទ្ធិសំរាប់បង្ខំឱ្យអនុវត្តកិច្ចសន្យា ។ ទោះយ៉ាងនេះក្តី ទីផ្សារបែបនេះគួរតែបង្កើតឡើង បើសិនអ្នកលក់ដុំត្រូវនាំចេញផលិតផលក្នុងចំនួនច្រើនៗ និងដោយផ្ទាល់ទៅប្រទេសឯទៀត ក្រៅពីវៀតណាម និងថៃ ដែលគ្រាន់តែកាត់យកតំលៃបន្ថែមមួយកំរិតអំពីកសិករកម្ពុជា ។

## ៣.៤. ការកែច្នៃកសិផល

ការជំរុញផលិតកម្មដំណាំលក់យកប្រាក់ វាដើរស្របគ្នានឹងការជំរុញសហគ្រាសកែច្នៃកសិផល ។ ផលិតផលកសិកម្មរបស់កម្ពុជាភាគច្រើន បច្ចុប្បន្នត្រូវបាននាំចេញទៅធ្វើការកែច្នៃ និងនាំចេញបន្តនៅកន្លែងផ្សេងទៀត ។ មួយភាគធំនៃស្រូវ សណ្តែកសៀង គ្រាប់ស្វាយចន្ទី សណ្តែកបាយ ពោត អំពៅ ល្ង គ្រាប់ឈូក ដំឡូងមី គោ ក្របី ត្រី និងជ័រទឹក ត្រូវបាននាំចេញទាំងដុលទៅវៀតណាម ថៃ និងម៉ាឡេស៊ី ។ រឿងនេះបានជួយបង្កើនតំរូវការផលិតផលកម្ពុជា ប៉ុន្តែ វាបានកាត់បន្ថយតំលៃបន្ថែមជាសក្តានុពលដែលអាចទទួលបានតាមការបង្កើតរោងចក្រកែច្នៃនៅកម្ពុជា ។ ដូចជាគ្មានមូលហេតុអ្វីទេដែលធ្វើឱ្យកម្ពុជាមិនអាចអភិវឌ្ឍន៍បាននូវឧស្សាហកម្មកែច្នៃកសិផល (ដែលមិនចាំបាច់តែមានបច្ចេកវិទ្យាខ្ពស់នោះទេ) ។ ជាលទ្ធផលគឺមានសក្តានុពលធំណាស់ក្នុងការអភិវឌ្ឍន៍វិស័យនេះ ។

តាមពិត សកម្មភាពកែច្នៃកសិផលទំនើប ទើបកើតមានក្នុងពេលថ្មីៗនៅកម្ពុជា ។ រោងចក្រកែច្នៃមួយចំនួនតូចបានបង្កើតឡើង និងធ្វើប្រតិបត្តិការក្នុង២-៣ឆ្នាំចុងក្រោយ ។ បើសិនឧស្សាហកម្មថ្មីរីកធំធាត់ ផលចំណេញផ្ទាល់ គឺការបង្កើតការងារ និងតំលៃបន្ថែមច្រើនទៀតក្នុងផ្នែកនេះ ។ វានឹងជួយស្រូបយកយ៉ាងហោចណាស់ក៏មួយភាគនៃកម្មករថ្មីប្រមាណ ២០០.០០០នាក់ដែលចូលទៅក្នុងកំលាំងពលកម្មក្នុងមួយឆ្នាំៗ ។ ផលចំណេញប្រយោល អាចជាការបង្កើនផលិតកម្មផលដំណាំ ដើម្បីបំរើតំរូវការធាតុចូលតាមសហគ្រាសនានា ។ លើសពីនេះទៀត ផលិតផលកែច្នៃនៅក្នុងស្រុក អាចចូលមកជំនួសផលិតផលនាំចូលដែលមានលក់ជាច្រើនក្នុងទីផ្សារកម្ពុជា គឺវាអាចជួយសន្សំសំចៃបានច្រើនណាស់នូវរូបិយប័ណ្ណដែលត្រូវចំណាយលើការនាំចូលម្ហូបអាហារកែច្នៃ ។

ការបង្កើតឡើងរោងចក្រកែច្នៃនៅជិតតំបន់កសិកម្ម (មិនមែននៅប្រទេសដទៃ) យ៉ាងហោចណាស់បានជួយសន្សំសំចៃបន្ទុកចំណាយលើការដឹកជញ្ជូន និងអាចជួយបង្កើនកំរិតថ្លៃនៅកសិដ្ឋាន ។ គ្រឿងលើកទឹកចិត្តបែបនេះកសិករត្រូវការខ្លាំងណាស់ដើម្បីពង្រីកផលិតកម្មកសិកម្ម និងកាត់បន្ថយភាពក្រីក្រ ។ យោងតាមសមត្ថភាពកែច្នៃមានកំរិតនាពេលបច្ចុប្បន្នផលិតផលដើមរបស់កម្ពុជាភាគច្រើន ត្រូវដឹករហូតទៅដល់វៀតណាម និងថៃ ។ បន្ទុកចំណាយពាណិជ្ជកម្មដែលកើតមាននៅតាមផ្លូវ បានកាត់បន្ថយកំរិតថ្លៃនៅកសិដ្ឋានយ៉ាងជាក់ស្តែង ពីព្រោះថ្លៃ នៅរោងចក្រនៅថៃ និងវៀតណាម ប្រហែលមិនត្រូវបានបង្កើនទេសំរាប់ផលិតផលរបស់កម្ពុជាដែលតំណាងឱ្យតែមួយភាគតូចនៃធាតុចូលសរុប ។

ដូច្នេះ សំខាន់ត្រូវធ្វើការវាយតំលៃពីការអភិវឌ្ឍន៍រោងចក្រកែច្នៃកសិផលដំក្មេងខ្ចីនៅកម្ពុជា ។ សំរាប់គោលដៅនេះ បានធ្វើសំភាសន៍សហគ្រាសចំនួនបួន ពីព្រោះពុំមានសហគ្រាសកែច្នៃកសិផលច្រើនទេនៅកម្ពុជា ។ តាមពិតទៅ សហគ្រាសកែច្នៃកសិផលដែលមានទំហំគួរកត់សំគាល់ហាក់ដូចជាគ្មានក្រៅពីនេះទេ ។ គោលដៅមួយនៃការចុះសាកសួរ គឺដើម្បីវាយតំលៃពីសក្តានុពលនៃការពង្រីកវិស័យនេះដោយមានផលចំណេញ ។

ទាក់ទងនឹងបញ្ហានេះ មានកិច្ចប្រឹងប្រែងមួយចំនួនរួចហើយ ដោយបានលទ្ធផលចំរុះ ។ សរុបមកគេអាចនិយាយបានថា វិស័យឯកជនបានផ្តួចផ្តើមធ្វើខ្លះហើយក្នុងផ្នែកកែច្នៃនេះ ។ ប៉ុន្តែគេមិនទាន់អាចមើលឃើញនៅឡើយថា តើអាជីវកម្មទាំងអស់នេះនឹងទទួលបានជោគជ័យឬយ៉ាងណា ។ លក្ខណៈអំណោយផលនៃការមានទីតាំងនៅជិតកសិដ្ឋាន គឺជាកត្តាមួយក្នុងចំណោមកត្តាជាច្រើន ដែលកំណត់ពីផលចំណេញនៃរបរជំនួញក្នុងផ្នែកនេះ ។

### *៣.៤.១. ក្រុមហ៊ុនវិនិយោគទុនម្សៅដំឡូងមី ម៉ុង រិទ្ធី (ក្រុងព្រះសីហនុ)*

ក្រុមហ៊ុន ម៉ុង រិទ្ធី បានដាក់ទុន ២,៨លានដុល្លារ ដើម្បីតំលើងរោងចក្រកែច្នៃដំឡូងមីមួយនៅក្រុងព្រះសីហនុ នាឆ្នាំ១៩៩៩ ។ រោងចក្រនេះនាំចូលពីថៃ និងមានសមត្ថភាពកែច្នៃមើមដំឡូងមីឆៅ ២០០តោន/ថ្ងៃ ដើម្បីផលិតម្សៅដំឡូង ៥០តោន ។ វាជារោងចក្រប្រភេទនេះទី១ក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ ដើម្បីដំណើរការពេញកំលាំង រោងចក្រត្រូវការបុគ្គលិក

៥២នាក់ គិតទាំងអ្នកយាម និងកម្មករប្រចាំថ្ងៃ ។ ប្រាក់កំរៃប្រចាំថ្ងៃសំរាប់កម្មករ ម្នាក់គឺ ៧.០០០រៀល (១,៧៥ដុល្លារ) ហើយនៅពេលរោងចក្រដំណើរការ មានកម្មករ ២៨នាក់ ត្រូវធ្វើការជាច្រើនថ្ងៃក្នុងមួយខែ។ ។ បុគ្គលិកមានប្រាក់ខែទទួលបាន ៥០-៨០ដុល្លារ /ខែ ។ និយោជិត និងកម្មករភាគច្រើន ជ្រើសរើសយកមកពីភូមិកំណើតរបស់លោក ម៉ុង រិទ្ធី ។

ក្រុមហ៊ុន ម៉ុង រិទ្ធី បានប្រើដី ១.៨០០ហ.ត ក្នុងដីសម្បទានសរុប ១១.០០០ហ.ត ដែលទទួលបានពីរដ្ឋាភិបាល ដើម្បីដាំដំឡូងមី ។ ប៉ុន្តែមានតែ ៣៨៧ហ.តប៉ុណ្ណោះ ដែលសមស្រប សំរាប់ដំណាំនេះ ដោយបានទិន្នផលមើមដំឡូងមីឆៅ ១២តោន/ហ.ត ។ ផលដំឡូងនេះមិនគ្រប់គ្រាន់ទេ ហើយក្រុមហ៊ុនត្រូវពឹងផ្អែកលើកសិករនៅជិត។ ក្នុងការផ្គត់ផ្គង់មើមដំឡូងមីឱ្យរោងចក្រ ។

មើមដំឡូងមីដែលក្រុមហ៊ុនផលិត រួមទាំងមើមដំឡូងដែលទិញពីក្រៅ នៅតែតិចខ្លាំងណាស់សំរាប់ដំណើរការពេញកំលាំងរបស់រោងចក្រ ។ ចំណុចល្អបំផុត គឺរោងចក្របានផ្តល់ទីផ្សារមួយដែលលើកទឹកចិត្តកសិករឱ្យផលិតដំឡូងមីច្រើនថែមទៀត និងបានប្រាក់ចំណូលច្រើនដែរ ។ ដីសំរាប់ដាំដំឡូងមីហាក់ដូចឃើញមានច្រើនណាស់ ហើយដើម្បីលើកទឹកចិត្តឱ្យមានការដាំដំឡូងមីច្រើន ក្រុមហ៊ុនបានផ្តល់ពូជ (ពូជពីដំបូងគេនាំចូលពីថៃ និងវៀតណាម) ដោយមិនគិតថ្លៃទៅកសិករ ឬវិនិយោគិនផ្សេងទៀត ដែលចង់ដាំវា ។ ក្រុមហ៊ុនអាចជួយក្នុងការងាររៀបចំដីផងដែរ ដោយទារប្រមូលប្រាក់កំរៃនៅក្រោយពេលប្រមូលផលរួច ដែលជាក់ស្តែង គឺជាការផ្តល់កំចីគ្មានយកការប្រាក់ក្នុងកំរិត ៩០ដុល្លារ/ហ.ត ។ ក្រុមហ៊ុនក៏ធានាទិញដំឡូងមីពីផលិតករក្នុងកំរិតថ្លៃនៅរោងចក្រ ២០ដុល្លារ/តោន ។ ប៉ុន្តែ ការលើកទឹកចិត្តរបស់ក្រុមហ៊ុន ហាក់ដូចតិចតួចពេកដើម្បីបំផុសឱ្យមានការឆ្លើយតបច្រើន។ពីសំណាក់ពួកម្ចាស់ដី ។

នៅខេត្តកំពង់ស្ពឺ ថ្លៃកសិដ្ឋានគឺ ១៧-១៨ដុល្លារ/តោន ។ គិតតាមទិន្នផលមធ្យម ១២តោន/ហ.ត, ចំណូលដុលអាចបានប្រហែល ១៥០ដុល្លារ/ហ.ត ប៉ុន្តែបន្ទុកចំនាយលើការរៀបចំដី និងពលកម្ម អស់ជាង ១០០ដុល្លារ/ហ.ត ។ គេមើលឃើញច្បាស់ថា ចំណូលនេះមិនទាន់គ្រប់គ្រាន់ទេសំរាប់ផលិតករក្នុងបណ្តាខេត្តដូចជា កំពង់ស្ពឺ និងកំពត ដែលមានដីគុណភាព

អន់ ។ ដូច្នេះ ឬមួយកំរិតថ្លៃ ឬមួយទិន្នផល ត្រូវកើនឡើងដើម្បីឱ្យកសិករបានផលចំណេញពីការដាំដំឡូងមី ។ ចំពោះកំរិតថ្លៃ ក្រុមហ៊ុនប្រាប់ថាមិនអាចតំលើងខ្ពស់ថែមទៀតទេ ពីព្រោះថ្លៃអន្តរជាតិបន្តនៅទាប ។ ក្រុមហ៊ុនលក់ផលិតផលខ្លួនប្រហែល ៤០%នៅក្នុងស្រុកក្នុងតំលៃ ១៧០ដុល្លារ/តោនម្សៅដំឡូងមី ហើយ ៦០%ទៀតនាំចេញទៅកូរ៉េ ។

ដោយសារពុំមានដំឡូងមីគ្រប់គ្រាន់នៅជិតៗ ក្រុមហ៊ុនបានទៅប្រមូលទិញមើមដំឡូងមីពីតំបន់ឆ្ងាយនៅខេត្តកំពង់ចាមដែលមានដីមានជីជាតិល្អ ។ កសិករមួយចំនួនបានលក់ដំឡូងមីរបស់ខ្លួនទៅឱ្យក្រុមហ៊ុន នៅមុនពេលមានបង្កើតរោងចក្រប្រភេទដូចគ្នាមួយផ្សេងទៀតឈ្មោះថា T.T.Y. នៅក្នុងខេត្ត ។ លោក ម៉ុង រិទ្ធី ហ៊ានទិញពីឈ្មួញកណ្តាលក្នុងតំលៃ ១៥ដុល្លារ/តោន ហើយក្រុមហ៊ុនត្រូវដឹកផលិតផលទៅរោងចក្រដោយអស់សោហ៊ុយលើសពី ៥ដុល្លារ/តោន ។ ប្រេងឥន្ធនៈជាធាតុចូលដែលថ្លៃជាងគេសំរាប់ការងារដឹកជញ្ជូន ហើយម្តងម្កាលរថយន្តដឹក ត្រូវគេឃាត់ដំណើរនៅចំណុចត្រួតពិនិត្យ ។ នៅតំបន់ដីក្រហមខេត្តកំពង់ចាម ទិន្នផលបានខ្ពស់ដល់ ២៥តោន/ហ.ត ។ ដោយថ្លៃនៅកសិដ្ឋានគឺប្រហែល ១៤ដុល្លារ/តោន ចំណូលដុលសំរាប់ផលិតករអាចបានដល់ ៣៥០ដុល្លារ/ហ.ត ធៀបនឹង ១៥០ដុល្លារនៅខេត្តកំពង់ស្ពឺ ។ ជាការប្រសើរ រោងចក្រគួរផ្លាស់ទីតាំងទៅទីនោះវិញ ពីព្រោះមើមដំឡូងមីភាគច្រើនផលិតនៅខេត្តកំពង់ចាម ហើយនាំចេញទៅវៀតណាម ។

នៅឆ្នាំ២០០៣ រោងចក្របានផ្អាកដំណើរការដោយសារខ្វះមើមដំឡូងមី ។ តាមពិតផលិតកម្មដំឡូងមីអាចពង្រីកទៅបានលុះត្រាតែបានថ្លៃខ្ពស់គ្រប់គ្រាន់ ។ ក្រុមហ៊ុនបានអះអាងថា មិនអាចតំឡើងថ្លៃបានទេ ពីព្រោះមិនអាចតំឡើងថ្លៃផលិតផលកែច្នៃបាន ។ ប៉ុន្តែ ថ្លៃមើមដំឡូងមីអាចតំឡើងបាន បើសិនបន្ទុកចំណាយលើផលិតកម្ម ជាពិសេសប្រេងឥន្ធនៈ ត្រូវបានកាត់បន្ថយ ។ ពន្ធលើប្រេងឥន្ធនៈនៅកម្ពុជា វាខ្ពស់ជាងគេឆ្ងាយណាស់ក្នុងតំបន់នេះ ។ លោក ម៉ុង រិទ្ធី បានកត់សំគាល់ថា សហគ្រាសកែច្នៃកសិផលនៅថៃ អាចស្នើសុំការបង្វិលសងប្រាក់ពន្ធលើប្រេងឥន្ធនៈ ហើយនេះជាគ្រឿងលើកទឹកចិត្តដ៏សំខាន់មួយដែលគេត្រូវការ ដើម្បីជំរុញវិស័យកែច្នៃកសិផល ។

### *៣.៤.២. ក្រុមហ៊ុនអភិវឌ្ឍន៍ដំណាំកសិកម្មផ្កាច់មុខ T.T.Y. និង IMEX. (ស្រុកមេមត់ ខេត្តកំពង់ចាម)*

អាជីវករកម្ពុជាម្នាក់បានវិនិយោគទុន ៦លានដុល្លារ កសាង T.T.Y. នេះ ដែលបានចាប់ធ្វើប្រតិបត្តិការនៅខែធ្នូ ២០០១ ។ សហគ្រាសនេះមានរោងចក្រមួយសំរាប់កែច្នៃមើមដំឡូងឈើ ២០០តោន ដើម្បីទទួលបានម្សៅដំឡូង ៥០តោន ក្នុងមួយថ្ងៃៗ ។ នៅពេលដំណើរការរោងចក្រប្រើកម្មករសរុប ១០៨នាក់ ធ្វើការជា ៣វេន ចំនួន ៨ម៉ោងក្នុងមួយវេន ។ កម្មករមានប្រាក់កំរៃជាមធ្យម ៨.០០០រៀល/នាក់/ថ្ងៃ (២ដុល្លារ) ។ T.T.Y. មានបុគ្គលិក ៣១នាក់ថែមដែលបំរើការងារមិនមែនផលិតកម្ម ។ កម្មករភាគច្រើនមកពីតំបន់ជិតខាង ។

គេទិញរោងចក្រមកពីថៃ ហើយដាក់តំលើងវានៅស្រុកមេមត់ ខេត្តកំពង់ចាម ។ វាជារោងចក្រប្រភេទនេះទី២ ដែលដាក់តំលើងនៅកម្ពុជា គឺបន្ទាប់ពីការតំលើងរោងចក្រមួយរបស់ក្រុមហ៊ុន ម៉ុង រិទ្ធី នៅក្រុងព្រះសីហនុ ក្នុងឆ្នាំ១៩៩៩ ។ រោងចក្រ T.T.Y. មានទីតាំងនៅតំបន់យុទ្ធសាស្ត្រ ហើយមិនប្រឈមនឹងកង្វះការផ្គត់ផ្គង់មើមដំឡូងមីដូចរោងចក្រ ម៉ុង រិទ្ធីទេ ។

ពីខែធ្នូ ២០០១ ដល់ មីនា ២០០២ រោងចក្រមិនអាចរកមើមដំឡូងមីបានគ្រប់ ពីព្រោះវាថ្លៃហួសពេក ។ ពាណិជ្ជករវៀតណាមម្នាក់បានទិញមើមដំឡូងមីក្នុងថ្លៃ ១០៥រៀល/គ.ក ពីកសិករ ឬ ២៧ដុល្លារ/តោន។ ក្រុមហ៊ុនគិតថា មិនអាចមានចំណេញទេនៅក៏រិតថ្លៃនេះ ហេតុនេះរោងចក្រដំណើរការតែមួយខែ ដោយកែច្នៃដំឡូងមីបាន ៦.០០០តោន និងផលិតម្សៅដំឡូងបាន ១.៥០០តោន ។ នៅឆ្នាំ២០០២-០៣ រោងចក្រអាចដំណើរការពេញសមត្ថភាពបាន ៩ខែ ពីខែធ្នូ ២០០២ ដល់ឧសភា ២០០៣ ដោយទិញបានមើមដំឡូងមី ៣០.០០០តោន និងផលិតម្សៅដំឡូងបាន ៧.៥០០តោន ។ ថ្លៃមើមដំឡូងមីគឺប្រហែល ៨៧រៀល/គ.ក ឬ ២២ ដុល្លារ/តោន ។

នៅឆ្នាំ២០០២-០៣ ក្នុងស្រុកមេមត់តែមួយ ផលិតកម្មមើមដំឡូងមីមានប្រហែល ៩០.០០០តោន យោងតាមការសិក្សាមួយរបស់ក្រុមហ៊ុន ។ ដូច្នេះការទិញចូលរបស់ T.T.Y. គឺបានត្រឹមតែមួយភាគបីនៃផលិតកម្មសរុបនៅស្រុកមេមត់ប៉ុណ្ណោះ គឺមិនទាន់គិតដល់ខេត្តទាំង

មូលទេ ។ ហេតុនេះក្រុមហ៊ុនមិនប្រឈមនឹងកង្វះការផ្គត់ផ្គង់មើមដំឡូងមីទេ លើកលែងតែវៀតណាមហ៊ានឱ្យថ្លៃខ្ពស់ដែលក្រុមហ៊ុនមិនហ៊ានឱ្យ ។ នៅខែមីនា ២០០៣ វៀតណាមបានបិទការនាំចូលមើមដំឡូងមីពីកម្ពុជា ដែលប្រហែលដោយសារការផ្គត់ផ្គង់ក្នុងស្រុកមានចំនួនគ្រប់គ្រាន់ ។ រឿងនេះបានជួយឱ្យ T.T.Y. មានអំណាចទិញមើមដំឡូងមីផ្តាច់មុខ ។ ចំពោះដំឡូងនៅសល់ គេបក ចិត និងហាលវា ហើយលក់ទៅឱ្យវៀតណាមក្នុងតំលៃមួយដែលថោកជាង ។

វៀតណាមបានទិញដំឡូងឈើពីខេត្តកំពង់ចាម ដើម្បីផ្គត់ផ្គង់ទៅឱ្យរោងចក្រកែច្នៃសំរាប់នាំចេញ ។ មន្ត្រីក្រុមហ៊ុនម្នាក់ដែលបានទៅធ្វើទស្សនកិច្ចនៅខេត្តតៃនិញរបស់វៀតណាមដែលនៅជាប់ព្រំដែនបានរាយការណ៍ថា ក្នុងតំបន់ជិតខេត្តកំពង់ចាម វៀតណាមមាន ៧ រោងចក្រខ្នាតមធ្យមដែលនីមួយៗមានសមត្ថភាពកែច្នៃមើមដំឡូងមី ១០០-២០០តោន/ថ្ងៃ ហើយមានជាង ១០០រោងចក្រដែលនីមួយៗអាចកែច្នៃបាន ៥តោន ។ ផលិតផលកែច្នៃរួចសំរាប់បំរើការនាំចេញជាសំខាន់ ។ តាមសេចក្តីរាយការណ៍ វៀតណាមផលិតដំឡូងមីបានច្រើនណាស់សំរាប់ផ្គត់ផ្គង់រោងចក្រនានា ។ ដូច្នេះខេត្តកំពង់ចាម ហាក់ដូចជាតំបន់ទ្រទាប់មួយសំរាប់វៀតណាម ។ នៅពេលមានកង្វះខាតនៅវៀតណាម ពាណិជ្ជករវៀតណាមទិញមើមដំឡូងឈើពីខេត្តកំពង់ចាម ហើយនៅពេលមានច្រើនគ្រប់គ្រាន់ ពាណិជ្ជករវៀតណាមមិនទិញដំឡូងមីកំពង់ចាមទេ ។ បំរាមនៅខែមីនា ២០០៣ គឺជាឧទាហរណ៍ដ៏ជាក់ស្តែងមួយ ។ ប៉ុន្តែក្នុងពេលកន្លងមក ផលិតផលភាគច្រើនអាចរកទីផ្សារបាន ទោះបីបានថ្លៃទាបបន្តិចក្តី ។

T.T.Y. គឺជារោងចក្រតែមួយគត់នៅខេត្តកំពង់ចាម ជារោងចក្រមួយក្នុងចំណោមរោងចក្រពីរនៅកម្ពុជាដែលកែច្នៃដំឡូងមី ។ សំនួរសំខាន់នៅទីនេះគឺថា នៅពេលរោងចក្រនៅវៀតណាមអាចទិញមើមដំឡូងពីកម្ពុជា ដើម្បីកែច្នៃនិងនាំចេញទៅម៉ាឡេស៊ី និងកូរ៉េ តើហេតុអ្វីរោងចក្រនៅកម្ពុជាមិនអាចធ្វើដូច្នេះបាន? យ៉ាងហោចណាស់ក៏រោងចក្រកម្ពុជាមានទីតាំងអំណោយផលជាងរោងចក្រនៅវៀតណាមដែលត្រូវចំណាយច្រើនជាងលើការដឹកជញ្ជូន និងបង់ប្រាក់កំរៃនៅតាមផ្លូវ ។

T.T.Y. រាយការណ៍ថា ខ្លួនពុំមានសមត្ថភាពប្រកួតប្រជែងដូចរោងចក្រនៅវៀតណាមទេ ទោះបីកិរិតបច្ចេកវិទ្យា និងប្រសិទ្ធភាពផលិតកម្ម អាចប្រៀបធៀបគ្នាបានក្តី ។ ការបញ្ជាទិញពីម៉ាឡេស៊ី បានផ្តល់ថ្លៃ (f.o.b) ដូចគ្នា សំរាប់កំពង់ផែក្រុងព្រះសីហនុ នឹងកំពង់ផែក្រុងហូជីមិញ ។ ប៉ុន្តែចំណាយដឹកជញ្ជូនពីរោងចក្រនៅខេត្តកំពង់ចាម ទៅដល់កំពង់ផែក្រុងព្រះសីហនុ វារុញបញ្ចុះថ្លៃនៅរោងចក្រដល់កំរិតមួយដែល T.T.Y. មិនអាចរកចំណេញបាន ។ បន្ទុកចំណាយដឹកជញ្ជូនពីទីតាំងរោងចក្រនៅមេម៉ត់ ទៅក្រុងព្រះសីហនុគឺ ២០-២៥ដុល្លារ/តោន ។ លើសពីនេះទៀត ក្រុមហ៊ុនត្រូវចំណាយអស់ច្រើនគួរសមទាក់ទិននឹងការបង់កំរៃផ្លូវការ និងក្រៅផ្លូវការនៅឯកំពង់ផែ ។ គេមិនបានប្រាប់ពីចំនួនពិតប្រាកដទេ ប៉ុន្តែចំណុចសំខាន់គឺការគណនាឃើញថា បន្ទុកចំណាយសរុប ត្រូវអស់ច្រើនជាងក្នុងការបញ្ជូនផលិតផលតាមកំពង់ផែក្រុងហូជីមិញ ដោយឆ្លងកាត់ចំណុចត្រួតពិនិត្យនានានៅព្រំដែន និងឈ្មួញកណ្តាលច្រើននាក់នៅវៀតណាម ។ មូលហេតុលើកឡើងមួយទៀតគឺ បន្ទុកចំណាយខ្ពស់នៃការដឹកជញ្ជូនតាមកប៉ាល់ពីក្រុងព្រះសីហនុ ទៅផែណាមួយក្នុងតំបន់ ពីព្រោះកំពង់ផែក្រុងព្រះសីហនុ យកថ្លៃខ្ពស់ជាងគេបំផុតនៅក្នុងតំបន់ ។

នៅឆ្នាំ២០០២ ក្រុមហ៊ុនបាននាំចេញម្សៅដំឡូងមី ៥០០តោន ទៅម៉ាឡេស៊ី ។ ក្នុងការបញ្ជូនផលិតផលពីរោងចក្រទៅចំណុចត្រួតពិនិត្យស្ទាច់ ត្រូវចំណាយ ៨ដុល្លារ/តោន គឺមាន ៥ដុល្លារសំរាប់ការដឹកជញ្ជូន និង ៣ដុល្លារ ជាប្រាក់កំរៃក្រៅផ្លូវការ ហើយពីស្ទាច់ទៅកំពង់ផែក្រុងហូជីមិញត្រូវចំណាយអស់ ៣៧ដុល្លារ/តោន ។ ដូច្នេះបន្ទុកចំណាយដឹកជញ្ជូនសរុបគឺ ៤៥ដុល្លារ/តោន ។ ក្រុមហ៊ុនអះអាងថា មិនបានចំណេញអ្វីទេ ប៉ុន្តែចង់ផ្សព្វផ្សាយផលិតផលរបស់ខ្លួននៅទីផ្សារអន្តរជាតិ ។ យោងតាមមន្ត្រីអ្នកឆ្លើយសំភាសន៍ មានអតិថិជនមកពីវៀតណាម ថៃ ម៉ាឡេស៊ី បារាំង និងអង់គ្លេស បានមកស្រាវជ្រាវចង់ទាក់ទងទិញដូរជាមួយក្រុមហ៊ុន ពីព្រោះគេគិតថា ម្សៅដំឡូងមីរបស់រោងចក្រ T.T.Y. ល្អជាងគេ ដោយសារដី និងទឹកនៅក្នុងតំបន់នេះមានគុណភាពល្អ ។

ប៉ុន្តែ T.T.Y. មិនចាំបាច់បារម្ភអ្វីច្រើនពេកពីការនាំចេញទេ ពីព្រោះម្សៅដំឡូងមីមានតំរូវការក្នុងស្រុកច្រើនណាស់ ។ គេប៉ាន់ស្មានថា ការប្រើប្រាស់ក្នុងស្រុកមានទំហំ ៧០០តោន/ខែ គឺខ្ពស់ជាងផលិតកម្មបច្ចុប្បន្នរបស់ រោងចក្រ ។ T.T.Y. បានលក់ម្សៅដំឡូង ១.០០០តោន តាមថ្លៃនៅរោងចក្រ ១៥០ដុល្លារ/តោន ។ តាមពិត ក៏មានការនាំចូលម្សៅដំឡូងមកជួយបំពេញតំរូវការក្នុងស្រុកដែរ យោងតាមការប៉ាន់ស្មានរបស់ T.T.Y.។ ដូច្នេះអនាគតសំរាប់ T.T.Y. មើលឃើញថាល្អ ដូច្នេះហើយក្រុមហ៊ុនមានបំណងបង្កើនសមត្ថភាពកែច្នៃរបស់ខ្លួនឱ្យបានទ្វេដង ។ ប៉ុន្តែក្រុមហ៊ុនត្អូញត្អែរពីចំណាយច្រើនលើប្រេងឥន្ធនៈ ដែលភាគច្រើនមកពីការយកពន្ធដ៏ខ្ពស់ ។ ដោយសារបន្ទុកចំណាយម៉ាឃីទីងខ្ពស់ ក្រុមហ៊ុនមិនរំពឹងថា អាចប្រកួតប្រជែងបានល្អជាមួយសហគ្រាសវៀតណាមទេ ក្នុងការពង្រីកទីផ្សារនាំចេញរបស់ខ្លួន ។

### *៣.៤.៣. ក្រុមហ៊ុនផលិតកម្មសត្វចិញ្ចឹម និងចំណីសត្វ (AAFP)*

AAFP គឺជាសហគ្រាសរបស់អាជីវករថៃខាងកែច្នៃកសិផលដែលមានជួលប្រើបុគ្គលិក-កម្មករ ២៣០នាក់ ។ AAFP កសាងឡើងនៅខែធ្នូ ១៩៩៧ នៅខេត្តកណ្តាល ចំងាយ ២៥គ.ម ពីខាងលិចក្រុងភ្នំពេញ ។ AAFP ផលិតចំណីសត្វ សំរាប់ផលិតកម្មជ្រូកជាសំខាន់ទី១ និងសំរាប់បសុសត្វជាសំខាន់ទី២ ។ ជាមួយគ្នានឹងសកម្មភាពកែច្នៃនេះ AAFP មានកម្មវិធីមួយដើម្បីជំរុញផលិតកម្មពោតក្រហមក្នុងវិស័យខាងក្រោម (downstream sectors) និងផលិតកម្មជ្រូកនិងបសុបក្សីក្នុងវិស័យខាងលើ (upstream sectors) ។

AAFP ស្រូបយកជាធាតុចូលរបស់ខ្លួន នូវសមាមាត្រមួយគួរកត់សំគាល់នៃផលិតកម្មកសិកម្មកម្ពុជា ។ ធាតុចូលក្នុងស្រុកសំរាប់សហគ្រាស រួមមាន ពោត សណ្តែកសៀង ស្រូវចុងអង្ករ កន្ទក់អង្ករ កន្ទក់ស្រូវសាលី ត្រីងៀត សំបកងាវ និងថ្មកំបោរ។ នៅឆ្នាំ២០០២ ក្រុមហ៊ុនទិញពោតក្រហម ៨.០០០តោន, សណ្តែកសៀង ១.០០០តោន, ស្រូវ ចុងអង្ករ និងកន្ទក់ ៣.០០០តោន, និងត្រីងៀតប្រហែល ១.០០០តោន ។ ទោះបីផលិតផលអន្តរការីទិញចូលទាំងនេះមានចំនួនច្រើនគួរកត់សំគាល់ ប៉ុន្តែវាតំណាងឱ្យតែមួយភាគតូចនៃផលិតកម្ម

សរុបនៅកម្ពុជា ។ ផ្អែកលើទិន្នន័យផលិតកម្មផ្លូវការឆ្នាំ២០០២ មានចុះនៅក្នុងតារាង១ ដែលទំនងជាទាបជាងផលិតកម្មជាក់ស្តែងដូចបានពិភាក្សាខាងលើ, AAFP បានទិញយកតែ ៥% នៃផលិតកម្មពោតសរុប, ៣% នៃផលិតកម្មសណ្តែកសៀងសរុប, និង ៣% នៃផលិតកម្មដំឡូងមីសរុប ។

បន្ថែមទៅលើធាតុចូលក្នុងស្រុក, AAFP ត្រូវនាំចូលផលិតផលអន្តរការីមួយចំនួនដូចជាម្សៅសណ្តែកសៀង ជាតិប្រូតេអ៊ីននិងវីតាមីន និងបរិក្ខារសំរាប់ផលិតកម្មជ្រូកនិងបសុសត្វ ។ បទសំភាសន៍បានបង្ហាញថា ទំនិញអន្តរការីនាំចូល និងបរិក្ខារទាំងនេះត្រូវជាប់ពន្ធនាំចូលពី ៧-៣៥% ។ តាំងពីឆ្នាំ១៩៩៩ មក AAFP បាននាំចូលម្សៅសណ្តែកសៀង ៥.០០០តោនពីឥណ្ឌាកាត់តាមវៀតណាម ។ ម្សៅសណ្តែកសៀងមានតំលៃប្រហែល ២១០ដុល្លារ/តោន (c.i.f. នៅភ្នំពេញ) ដូច្នេះតំលៃសរុបនៃការនាំចូលគឺ ១,០៥លានដុល្លារ ។ មានការបង់ពន្ធនាំចូល ៣៥% ត្រូវជាទឹកប្រាក់ពន្ធសរុប ៣៦៧.៥០០ដុល្លារ ។ នេះជាបន្ទុកចំណាយមួយយ៉ាងខ្ពស់ដែលបានផ្ទេរទៅឱ្យកសិករអ្នកមកទិញចំណីសត្វពីសហគ្រាស ហើយរឿងនេះបានធ្វើឱ្យខូចខាតដល់ភាពប្រកួតប្រជែងនៃផលិតផលរបស់ AAFP ។ ឯធាតុចូលអន្តរការីផ្សេងៗទៀតក៏ត្រូវជាប់ពន្ធនាំចូលពី ៧-១៥% ដែរ ។

AAFP ជាសហគ្រាសផលិតកម្មចំណីសត្វតែមួយគត់នៅកម្ពុជា ហើយគេអាចគិតថាសហគ្រាសបានចំណេញពីការរកស៊ីផ្តាច់មុខនៅកម្ពុជា ។ ប៉ុន្តែក្រុមហ៊ុនបានប្រាប់ថា ផលិតផលចំណីសត្វរបស់ខ្លួនតាមពិតត្រូវប្រកួតប្រជែងជាមួយផលិតផលរបស់វៀតណាម និងថៃ ដែលភាគច្រើនចូលមកទីផ្សារកម្ពុជាជាលក្ខណៈក្រៅផ្លូវការ ឬតាមការរត់ពន្ធ និងដែលលក់បានថោកជាងផលិតផលរបស់ AAFP ។ រឿងនេះហាក់ដូចជាករណីជាទូទៅមួយដែល សហគ្រាសក្នុងស្រុកនានាតែងរាយការណ៍ប្រាប់ ហើយវាបំផុសចំងល់ដ៏ធំមួយគឺ ហេតុអ្វីបានជាយ៉ាងដូច្នេះពីព្រោះសហគ្រាសក្នុងស្រុកយ៉ាងហោចណាស់ក៏មានប្រៀបលើគេខាងទីតាំងដែរ រីឯកត្តាផ្សេងៗទៀតក៏អាចអាចប្រៀបធៀបគ្នាបានដែរ ។

មូលហេតុចំបងដែលគេបានលើកឡើង ជាប់ទាក់ទិននឹងកត្តាមួយចំនួនដែលរួមឱ្យផ្សំគ្នាធ្វើឱ្យបន្ទុកចំណាយផលិតកម្មកើនខ្ពស់ជាងនៅ ថៃ និងវៀតណាម ។ ទី១ ធាតុចូលខ្លះដូចជាម្សៅសណ្តែកសៀង និងជាតិវីតាមីន និងប្រូតេអីន មិនទាន់មានផលិតនៅកម្ពុជាទេ ដោយសារកង្វះសមត្ថភាពកែច្នៃ ដូច្នេះត្រូវតែនាំចូល និងត្រូវបង់ពន្ធនាំចូលយ៉ាងខ្ពស់ ។ ទី២ ប្រេងឥន្ធនៈដែលជាធាតុចូលដ៏ចំបងសំរាប់ដំណើរការរោងចក្រ វាមានថ្លៃខ្ពស់ជាងនៅប្រទេសជិតយ៉ាងច្រើន ដោយសាររដ្ឋាភិបាលកម្ពុជាយកពន្ធខ្ពស់ជាងគេ ។ ទី៣ តាមធម្មតា សហគ្រាសនានានៅកម្ពុជា ត្រូវបង់ចំណាយបង្កប់ខ្ពស់ ដោយសារការកែលំអយឺតខាងអភិបាលកិច្ច ។ ទី៤ ទំហំសេដ្ឋកិច្ច កត្តាសេដ្ឋកិច្ចវិមាត្រ (economies of scale) ហាក់ដូចមិនអាចជួយអ្វីទេដល់ AAFP នៅក្នុងការប្រកួតប្រជែងជាមួយ ថៃ និងវៀតណាម ពីព្រោះប្រទេសទាំងពីរនេះមានសេដ្ឋកិច្ចធំជាងកម្ពុជាឆ្ងាយណាស់ ។ កត្តាអស់ទាំងនេះបានគួបផ្សំគ្នា ធ្វើឱ្យខូចខាតដល់ភាពប្រកួតប្រជែងជាសក្តានុពលរបស់ AAFP និងបង្កឧបសគ្គដល់ការរីកចំរើនរបស់គេ ។

ក្នុងការប្រមើលពីអនាគត គេអាចអះអាងបានថា តំរូវការចំណីអាហារសត្វអាចរីកធំច្រើនថែមទៀត បើសិនមានគំរោងឥណទានសំរាប់ជួយកសិករដែលចង់ផលិតបសុសត្វ និងជ្រូកឱ្យបានច្រើន ។ បច្ចុប្បន្ននេះ បើសិនជាមានមីក្រូឥណទាន ក៏វាមានថ្លៃខ្ពស់ពេកមិនអាចធ្វើគំរោងកសិកម្មបានចំណេញទេ ។ សព្វថ្ងៃ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និង NGOs គិតអត្រាការប្រាក់ ៤០-៦០%/ឆ្នាំ ដែលខ្ពស់ហួសពេកចំពោះកសិករអ្នកចង់ចិញ្ចឹមជ្រូក ឬបសុសត្វ ។ តាមរបាយការណ៍ កសិករនៅវៀតណាម និងថៃ អាចទទួលបានឥណទានថោកជាងតាមរយៈកម្មវិធីជួយទ្រទ្រង់ ពិសេសនៃរដ្ឋាភិបាលរបស់ពួកគេ ។

ទោះយ៉ាងនេះក្តី AAFP នៅតែរីកលូតលាស់បានថ្វីបើមានជួបបញ្ហានានាដូចបង្ហាញខាងលើក្តី ។ នៅពេលចាប់ផ្តើមនៅឆ្នាំ១៩៩៧ ផលិតកម្មអាហារសត្វមានកំរិតទាបជាងសព្វថ្ងៃឆ្ងាយណាស់ បានប្រហែល ២.០០០តោន/ឆ្នាំប៉ុណ្ណោះ។ នៅឆ្នាំ២០០៣ ទំហំផលិតកម្មគឺ ៣០០តោន/ថ្ងៃ គឺវាអាចឡើងដល់ជាង ១០.០០០តោន/ឆ្នាំ ។ ប៉ុន្តែគេអាចជជែកវែកញែកបានថា សហគ្រាសមានសក្តានុពលធំជាងនេះច្រើនទៀតដើម្បីរីកលូតលាស់ ។ ទី១ វាហាក់

ដូចជាមិនមានឧសគ្គអ្វីចំបងទេ ទាក់ទិននឹងការផ្គត់ផ្គង់ទំនិញអន្តរការីទៅឱ្យ AAFP ពីព្រោះសព្វថ្ងៃវាស្រូបយកប្រហែលតែ ៥% នៃគ្រាប់ធញ្ញជាតិសំខាន់ៗប៉ុណ្ណោះសំរាប់ប្រើជាធាតុចូល ។ ទី២ តំរូវការផលិតកម្មបសុសត្វ និងជ្រូក នឹងអាចកើនឡើង បើសិនគេអាចបញ្ចុះថ្លៃចំណីសត្វបាន ។ ការវិភាគលើផលិតកម្មជ្រូកបង្ហាញថា ផលចំណេញគឺបានទាប ដោយសារឥណទាន និងចំណីសត្វ មានថ្លៃខ្ពស់ ។

### *៣.៤.៤. ផលិតផលកសិកម្មខ្មែរ ( ស្រុកជើងព្រៃ ខេត្តកំពង់ចាម)*

បង្កើតឡើងនៅឆ្នាំ២០០១ ផលិតផលកសិកម្មខ្មែរ (KAP) គឺជាក្រុមហ៊ុនមួយដែលកែច្នៃគ្រាប់ស្វាយចន្ទី ភាគច្រើនសំរាប់នាំចេញ ។ ក្រុមហ៊ុនមានរោងចក្រមួយមានទីតាំងនៅតាមផ្លូវជាតិលេខ៧ ក្នុងខេត្តកំពង់ចាម ។ វាជាសហគ្រាសតែមួយគត់ដែលធ្វើជំនួញនេះក្នុងប្រវត្តិសាស្ត្រកម្ពុជា ថ្វីបើកម្ពុជាមានដាំស្វាយចន្ទីជាច្រើនទសវត្សរ៍មកហើយក្តី ។ គេជំរះសំបកចេញពីគ្រាប់ស្វាយចន្ទី ហើយវេចខ្ចប់វាសំរាប់នាំចេញ ដោយប្រើបច្ចេកវិទ្យាដែលប្រើកំលាំងពលកម្មច្រើន ។ ក្រុមហ៊ុនប្រើកម្មករប្រហែល ២៨០នាក់ ដែលភាគច្រើនជាស្ត្រីវ័យក្មេងមកពីតំបន់ជិតៗ ។ កម្មករម្នាក់ទទួលបានជាមធ្យម ៣០ដុល្លារ/ខែ ដោយផ្អែកទៅលើទិន្នផល ។ សំភារៈ និងឧបករណ៍ សំរាប់ជំរះសំបកគ្រាប់ស្វាយចន្ទី គឺសាមញ្ញទេ ហើយអាចធ្វើចម្លងតាមនៅកម្ពុជា បន្ទាប់ពីបាននាំវាចូលពីដំបូងពីប្រទេសក្រៅ ។

ក្នុងសមត្ថភាពបច្ចុប្បន្នមានកំលាំងកម្មករ ២៨០នាក់ រោងចក្រអាចកែច្នៃគ្រាប់ស្វាយចន្ទីបានប្រហែល ១.០០០តោន/ឆ្នាំ ។ ចំនួននេះគឺមិនដល់ ១០%នៃផលិតកម្មគ្រាប់ស្វាយចន្ទីសរុបនៅកម្ពុជាផងដែលគេប៉ាន់ថាមាន ១២.០០០តោន/ឆ្នាំ ។ គ្រាប់ស្វាយចន្ទីដែលនៅសល់គេបញ្ជូនទៅវៀតណាមដើម្បីកែច្នៃយ៉ាងសាមញ្ញដូចគ្នា ហើយនាំចេញបន្តទៅប្រទេសទី៣ ។ ក្រុមហ៊ុនមានសក្តានុពលអាចពង្រីក និងជួលកម្មករដល់ទៅ ៣.០០០នាក់ ដើម្បីកែច្នៃបាន ៤០តោន/ថ្ងៃ ឬ ១២.០០០តោន/ឆ្នាំ ដែលជាផលិតកម្មសរុបប៉ាន់ស្មានបច្ចុប្បន្នរបស់កម្ពុជា ។ ក្នុងនេះសំនួរមានតែមួយទេ គឺទីផ្សារនាំចេញ ។

កន្លងមក KAP ដណ្តើមបានទីផ្សារមួយនៅកាណាដា ។ ម្ចាស់ក្រុមហ៊ុនមានសាច់ញាតិរស់នៅកាណាដា ដែលចាត់ចែងការងារទីផ្សាររបស់ក្រុមហ៊ុននៅទីនោះ ។ គាត់រាយការណ៍ថាផលិតផលគាត់លក់ដាច់ល្អនៅកាណាដា ដោយសារមានការផ្សព្វផ្សាយពិសេសថា ជាស្វាយចន្ទីដាំមិនប្រើជាតិគីមីមកពីប្រទេសកម្ពុជា ឃីហោ KAP ហើយក្រុមហ៊ុនមានបំណងពង្រីកទីផ្សារទៅចិន និងសហរដ្ឋអាមេរិកទៀត ។ ប៉ុន្តែ KAP ត្រូវប្រជែងជាមួយវៀតណាម សំរាប់ទីផ្សារនាំចេញ ហើយវាជាការលំបាកមួយសំរាប់ក្រុមហ៊ុន ។

យោងតាមម្ចាស់ក្រុមហ៊ុន បញ្ហាសំខាន់គឺ គូប្រជែងវៀតណាម ដែលទិញគ្រាប់ស្វាយចន្ទីឆៅពីកម្ពុជា ដើម្បីបង្គ្រប់កិច្ចសន្យានាំចេញ គេអាចលក់គ្រាប់ស្វាយចន្ទីកែច្នៃរួចក្នុងតំលៃមួយដែលទាបជាងតំលៃរួចដើមរបស់ KAP ។ ថ្លៃដែលបង់ដោយអតិថិជនជាសក្តានុពលគឺ ៣.០០០-៣.៣០០ដុល្លារ/តោនគ្រប់ស្វាយចន្ទីបករួច ។ អ្នកកែច្នៃនៅវៀតណាមគេពេញចិត្តនឹងថ្លៃនេះហើយ ប៉ុន្តែសំរាប់ KAP វាមិនទាន់ខ្ពស់គ្រប់គ្រាន់ទេដើម្បីបានផលចំណេញខាងសេដ្ឋកិច្ច ។ មូលហេតុចំបងដែលលើកឡើង វាជាប់ទាក់ទងនឹងបន្ទុកចំណាយដែលចោទដូចគ្នានឹងសហគ្រាសផ្សេងៗទៀតដែរ ។

យោងតាមម្ចាស់ក្រុមហ៊ុន បន្ទុកចំណាយសរុបលើការកែច្នៃនិងម៉ាឃីទីងគឺប្រហែល ១.០០០ដុល្លារ/តោនគ្រាប់ស្វាយចន្ទីបករួច ។ ក្នុងនេះមួយចំនួនធំគឺជាការបង់កំរៃក្រៅផ្លូវការមុនពេលដឹកចេញពីក្រុងព្រះសីហនុទៅទីផ្សារបរទេស ។ បន្ទុកចំណាយលើពលកម្ម ដែលមានប្រហែល ៣០ដុល្លារ/ខែ/កម្មករម្នាក់ ឬប្រហែល ៣៥០ដុល្លារ/តោនគ្រាប់ស្វាយចន្ទីបករួចគឺទាប និងប្រកួតប្រជែងបានជាមួយវៀតណាម ។ ប៉ុន្តែប្រេងឥន្ទនៈនៅកម្ពុជាវាថ្លៃជាងនៅវៀតណាមច្រើនណាស់ ។

ទោះយ៉ាងនេះក្តី KAP ហាក់ដូចមានអនាគតល្អ ពីព្រោះមានស្វាយចន្ទីឆៅច្រើនណាស់សំរាប់ឱ្យក្រុមហ៊ុនធ្វើការកែច្នៃ ឱ្យតែមានតំរូវការគ្រប់គ្រាន់នូវគ្រាប់ស្វាយចន្ទីបករួចរបស់ KAP ។ ដូចបានពិភាក្សានៅខាងលើ សក្តានុពលសំរាប់ពង្រីកផលិតកម្មស្វាយចន្ទីមានធំធេងណាស់ បើសិនមានការលើកទឹកចិត្តគ្រប់គ្រាន់សំរាប់កសិករ ។ ក្រៅពីការប្រមើលឃើញលើការផ្គត់ផ្គង់

គ្រាប់ស្វាយចន្ទីនៅ ម្ចាស់ក្រុមហ៊ុនមានសុទិដ្ឋិនិយមពីការរកបានទីផ្សារនានាដែលផ្តល់ថ្លៃកំរិតអន្តរជាតិ ដល់គ្រាប់ស្វាយចន្ទីបកររួចរបស់គាត់ ។ បញ្ហាប្រឈមចំបងបំផុតក្នុងការពង្រីកអាជីវកម្ម គឺការកាត់បន្ថយបន្ទុកចំណាយម៉ាឃីទីងពីរោងចក្រទៅដល់នាវានៅក្រុងព្រះសីហនុ ។ ការកាត់បន្ថយបន្ទុកចំណាយក្នុងខ្សែរយៈទីផ្សារ អាចបង្កើនផលចំណេញជាសក្តានុពលទាំងសំរាប់អ្នកកែច្នៃ និងកសិករ ហើយទាំងអស់នេះនឹងជួយជំរុញកំណើនផលិតកម្ម និងការនាំចេញ ។

## ៣.៥. សន្និដ្ឋាន

ផលិតកម្មដំណាំមិនមែនស្រូវនៅកម្ពុជា មានសក្តានុពលខ្ពស់ដើម្បីពង្រីក សំខាន់ដោយសារសំបូរដីមានជីជាតិល្អ ដែលទើបរានយកថ្មីៗពីដីព្រៃ ។ សក្តានុពលនេះកំពុងសំរេចបាននៅកន្លែងជាច្រើន ថ្វីបើស្ថិតិផ្លូវការហាក់មិនបានបង្ហាញទាន់ពេលពីកំណើនក្នុងវិស័យដំណាំលក់យកប្រាក់ ។ ការចុះសាកសួរដល់កន្លែងអំពី សណ្តែកសៀង ពោត ដំឡូងមី និងស្វាយចន្ទី បានឱ្យដឹងថា ផលិតកម្មនៅក្នុងតំបន់សិក្សាត្រូវបានប៉ាន់ស្មានទាបជាខ្លាំងនៅក្នុងស្ថិតិផ្លូវការ ។ ប្រហែលដល់ពេលវេលាដែលកម្ពុជាត្រូវធ្វើជំរឿនកសិកម្មហើយ ដើម្បីមានទិន្នន័យត្រឹមត្រូវសំរាប់ធ្វើវិភាគលើវិស័យកសិកម្ម ។

សំនួរចំបងទាក់ទងនឹងការពង្រីកដំណាំលក់យកប្រាក់ គឺការដោះដូរគ្នា (trade-off) រវាងការអភិរក្សព្រៃ និងការពង្រីកកសិដ្ឋាន ។ ថ្មីៗនេះ នៅកម្ពុជាមានការកាប់បំផ្លាញព្រៃឈើច្រើនណាស់ ទាំងដើម្បីយកឈើហ៊ុប និងការពង្រីកកសិដ្ឋាន ។ សំពាធប្រជាសាស្ត្រទៅលើដីធ្លីកំពុងកើនឡើង ដោយសារប្រជាជនបានកើនឡើងពី ៦លាននាក់នៅទសវត្សរ៍១៩៦០ ដល់ ៩លាននាក់នៅចុងទសវត្សរ៍១៩៨០ និង ១៣លាននាក់នៅឆ្នាំ២០០៣ ។ លើកលែងតែប្រពលវប្បកម្មកសិកម្មអាចធ្វើបានសំរេចដោយមានចីរភាព ការពង្រីកកសិដ្ឋានទៅក្នុងតំបន់ព្រៃទំនងជានៅតែបន្តទៀត បើសិនគេសន្មតថា វិស័យមិនមែនកសិកម្មមានអត្រាកំណើនដូចគ្នានឹងកាលពី ៥ឆ្នាំកន្លងទៅ ។

តាមធម្មតាគេផលិតដំណាំលក់យកប្រាក់សំរាប់លក់ដូរ ។ ដូច្នេះម៉ាឃីទីងមានសារៈសំខាន់បំផុតចំពោះផលិតកម្ម ។ នៅកម្ពុជា រចនាសម្ព័ន្ធទីផ្សារហាក់ដូចមានការប្រកួតប្រជែង

គួរសម ពីព្រោះមានអ្នកទិញ និងអ្នកលក់ផលដំណាំចំបងៗជាច្រើននាក់ ប៉ុន្តែរចនាសម្ព័ន្ធទីផ្សារ (មានទាំងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងស្ថាប័ន) នៅទន់ខ្សោយខ្លាំងណាស់ ទោះបីរាជរដ្ឋាភិបាលកម្ពុជាបានញុំាងឱ្យមានការរីកចំរើនមួយចំនួនហើយក្តី ។ កម្ពុជាត្រូវប្រឈមនឹងឧបសគ្គជាច្រើនមានជាអាទិ៍ កង្វះធូទ់ធូរនូវផ្លូវថ្នល់ និងស្ថាប័នទ្រទ្រង់ផ្សេងៗដូចជា សហករណ៍ និងទីផ្សារ, លំហូរពត៌មានអន់ដែលកាន់តែយ៉ាប់យ៉ឺនដោយសារអត្រាអក្ខរកម្មទាបក្នុងចំណោមកសិករ, ហើយនិងការប្រែប្រួលខុសលំនាំដើម (distortions) បង្កដោយរដ្ឋាភិបាលក្នុងរូបភាពជាការយកប្រាក់កំរៃក្រៅផ្លូវការលើការដឹកជញ្ជូន និងពាណិជ្ជកម្ម ។

ការនាំចេញខាងកសិកម្ម ហាក់ដូចខ្ពស់ជាងតួលេខក្នុងឯកសារផ្លូវការរបស់គយ ។ ការនាំចេញភាគច្រើន មានលក្ខណៈក្រៅផ្លូវការ ហើយត្រូវបង់ប្រាក់កំរៃក្រៅផ្លូវការខ្ពស់នៅច្រកព្រំដែន ។ ប្រាក់កំរៃក្រៅផ្លូវការទាំងនេះ វាដើរតួដូចជាពន្ធដាក់ស្ពែងមួយយកលើពាណិជ្ជករដែលមិនអាចតំលើងថ្លៃអន្តរជាតិបានទេ ហើយក៏ផ្ទេរបន្ទុកចំណាយនេះទៅលើកសិករ ។ ការកាត់បន្ថយប្រាក់កំរៃបែបនេះ ប្រហែលអាចបង្កើនកំរិតថ្លៃនៅកសិដ្ឋាន ហើយជាលទ្ធផលចំណូលរបស់កសិករនឹងកើនឡើង ។

ការនាំចេញខាងកសិកម្មភាគច្រើន គឺជាផលិតផលដើម ដោយសារកម្ពុជាមានសមត្ថភាពកែច្នៃកសិផលបានតិចតួចណាស់ ។ មានសហគ្រាសកែច្នៃកសិកម្មទំនើបមួយចំនួនបានកសាងរួចហើយ ដូចជា សហគ្រាសចំបងៗទាំងបួននៅក្នុងការសិក្សានេះ ។ តាមការប្រមើលមើលសហគ្រាសទាំងនេះហាក់ដូចមានអនាគតល្អ ពីព្រោះមានផលិតផលវត្ថុធាតុដើមផ្គត់ផ្គង់យ៉ាងសំបូរដូចជា ពោត សណ្តែកសៀង ដំឡូងមី និងស្វាយចន្ទី, ព្រមទាំងមានទីផ្សារល្អសំរាប់ផលិតផលសំរេច ។ ប៉ុន្តែបើធៀបនឹងគូប្រជែងនៅក្នុងប្រទេសជិតខាងសហគ្រាសកម្ពុជាសព្វថ្ងៃត្រូវចាញ់ប្រៀបដោយសារមានបន្ទុកចំណាយខ្ពស់លើ ប្រេងឥន្ធនៈ ពន្ធលើធាតុចូល និងការយកកំរៃក្រៅផ្លូវការនៅឯព្រំដែន ។ វិធានការខាងគោលនយោបាយដើម្បីជួយពង្រឹងភាពប្រកួតប្រជែង នឹងអាចជួយបង្កើនផលិតកម្មដំណាំ ដែលនឹងផ្តល់ផលចំណេញដល់ទាំងកសិករ និងពាណិជ្ជករ ។

